ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ចក្ខុវិស័យនិងយុទ្ធសាស្ត្រ
# ស្ដីពី
# សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះ
# នៃរាជរដ្ឋាភិបាល

២០២៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ចក្ខុវិស័យនិងយុទ្ធសាស្ត្រ

# ស្តីពី

# សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះ

# នៃរាជរដ្ឋាភិបាល

២០២៥

©រក្សាសិទ្ធិអ្នកនិពន្ធ

រាល់ការផលិត ឬចម្លងឡើងវិញ នូវស្នាដៃនេះ ទោះទាំងស្រុងក្ដី ទោះដោយភាគក្ដី និងទោះប្រើមធ្យោបាយអ្វីក៏ដោយ ត្រូវហាមឃាត់ កាលបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ។

ការបំពានលើសិទ្ធិអ្នកនិពន្ធ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារ ដោយអនុលោមតាមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ និងត្រូវផ្ដន្ទាឱ្យទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចំពោះព្យសនកម្មដែលបានបង្កឡើង។

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

“**ការកែទម្រង់និងការពង្រឹងអភិបាលកិច្ច**” គឺជាស្នូលនៃ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០** របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលនេះជាសក្ខីកម្មបញ្ជាក់អំពីអាទិភាពគន្លឹះនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលផ្តោតការយកចិត្តទុកដាក់លើការងារកែទម្រង់ផង និងការជំរុញល្បឿននៃការពង្រឹងអភិបាលកិច្ចនៅទូទាំងស្ថាប័នសាធារណៈផង។

រដ្ឋាភិបាលនៃប្រទេសនីមួយៗ បានចាប់យកការកែទម្រង់លើវិស័យអាទិភាពរបស់ខ្លួនទៅតាមវិធីសាស្ត្រដោយឡែកៗពីគ្នា អាស្រ័យលើបរិបទសង្គម ប្រពៃណីស្ថាប័ន និងបែបបទរដ្ឋបាលរៀងៗខ្លួន។ សម្រាប់កម្ពុជា យើងបានរៀបចំការងារកែទម្រង់ជាកម្មវិធីរយៈពេលវែងដោយមានការកំណត់ចក្ខុវិស័យវែងឆ្ងាយនិងប្រាកដនិយម បែងចែកជាដំណាក់កាលប្រកបដោយតថភាពនិយមនិងគោលដៅជាក់លាក់ មានរចនាសម្ព័ន្ធដឹកនាំនិងយន្តការអនុវត្តច្បាស់លាស់។ វិធីសាស្ត្រកែទម្រង់នេះបានបង្ហាញអំពីសេចក្តីក្លាហាន មហិច្ឆតានិងឆន្ទៈមោះមុតរបស់យើងលើការកែទម្រង់ ដោយអាចអនុវត្តទៅបានតាមបរិបទកម្ពុជានិងឆ្លើយតបបានចំពោះសេចក្តីត្រូវការរបស់កម្ពុជាប្រកបដោយមោទនភាព ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។ ផ្អែកលើទស្សនវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកម្មវិធីកែទម្រង់រយៈពេលវែងជាច្រើនលើគ្រប់វិស័យ ជាពិសេស កម្មវិធីកែទម្រង់ពាក់ព័ន្ធនឹងការបង្កើនគុណភាពអភិបាលកិច្ច ការកែទម្រង់លើរចនាសម្ព័ន្ធ និងការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធដែលអាចចាត់ទុកជាកិច្ចការកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាល គឺ **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់**

**ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់។**

ការកែទម្រង់អភិបាលកិច្ចមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសមត្ថភាព ភាពរឹងមាំ និងភាពធន់របស់ស្ថាប័នសាធារណៈ ក្នុងការឆ្លើយតបបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ចំពោះបញ្ហាប្រឈមនានាដែលកើតចេញពីសភាពការណ៍វិវត្តយ៉ាងឆាប់រហ័ស ពោរពេញដោយភាពមិនប្រាកដប្រជាខ្ពស់ និងភាគច្រើនមិនចំណុះក្រោមការគ្រប់គ្រងរបស់កម្ពុជាទាំងស្រុង។ ជាក់ស្តែង សកលលោកកំពុងស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ ជាពិសេស ការកើនឡើងកាន់តែខ្លាំងនូវគោលនយោបាយគាំពារនិយមនិងសង្គ្រាមពាណិជ្ជកម្ម, ភាពតានតឹងនៃការប្រកួតប្រជែងភូមិសាស្ត្រសេដ្ឋកិច្ចនិងនយោបាយ និងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិ។ ស្ថិតក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការដឹកនាំកិច្ចការកែទម្រង់គន្លឹះរបស់ខ្លួន បានបោះជំហានជាប្រវត្តិសាស្ត្រមួយក្នុងនីតិកាលទី៦ នៃរដ្ឋសភា កន្លងទៅ នោះគឺការធានាសុខដុមនីយកម្មនៃការកែទម្រង់គន្លឹះទាំងនេះឱ្យមានសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព តាមរយៈការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមគ្នា ហើយដែលការងារនេះត្រូវបានអនុវត្តនិងធ្វើបច្ចុប្បន្នកម្ម ដើម្បីបន្តអនុវត្តក្នុងរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភានេះ។

**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ឆ្លុះបញ្ចាំងអំពីនិរន្តរភាពជាគោលនយោបាយនៃការកែទម្រង់ និងសុខដុមភាពជាយុទ្ធសាស្ត្រនៃកិច្ចការកែទម្រង់ ដោយផ្អែកលើសមិទ្ធផលនិងបទពិសោធន៍កន្លងទៅ ធ្វើជាមូលដ្ឋានឈានឆ្ពោះទៅសម្រេចបាននូវគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ស្របតាមទស្សនវិស័យ “**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**” ចក្ខុវិស័យនិងយុទ្ធសាស្ត្រសុខដុមនីយកម្មកិច្ចការកែទម្រង់នេះនៅបន្តរក្សានិងប្រតិបត្តិតាមអភិក្រមគន្លឹះចំនួន ៤ ប្រការ គឺ ៖

**ទី១) អភិក្រមរក្សាគំហើញទាំងមូល** សំដៅដល់ប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន ជាប្រព័ន្ធនៃការកែទម្រង់

**ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី** សំដៅដល់កម្មវិធីកែទម្រង់នីមួយៗបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួន ដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន

**ទី៣) អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ** សំដៅដល់ការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផង និងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈកែទម្រង់ជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតផង និង

**ទី៤) អភិក្រមបុរេសកម្ម** សំដៅដល់ការប្រមើល និងត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នា តាមរយៈយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.ក.**) ដោយមិនរង់ចាំបញ្ហាកើតឡើងទើបគិតគូរដាក់ចេញនូវសកម្មភាពនោះឡើយ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានត្រួសត្រាយមាគ៌ានៃសុខដុមនីយកម្មកិច្ចការកែទម្រង់ ៣ បូក ១ ក្នុងនីតិកាលទី៦នៃរដ្ឋសភាកន្លងទៅ ដែលប្រការនេះបានធ្វើឱ្យរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា មានមូលដ្ឋានគ្រឹះដ៏រឹងមាំដើម្បីធ្វើបច្ចុប្បន្នកម្ម រក្សាជីវភាពនៃការកែទម្រង់ និងពង្រឹងអភិបាលកិច្ច បានកាន់តែប្រសើរឡើង។

ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការ

ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ឯកឧត្តម **កើត រិទ្ធ** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាសហប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌, ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលបានសហការគ្នា ដឹកនាំ ណែនាំ និងតម្រង់ទិសជាប់ជាប្រចាំដល់យន្តការ **យ.ស.ក.** រហូតសម្រេចបាននូវបច្ចុប្បន្នកម្មនៃ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** នេះឡើង។

ខ្ញុំក៏សូមកោតសរសើរចំពោះក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន និងអង្គភាពនានា ជាពិសេសថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ដែលបានសហការនិងគាំទ្រគ្នា ប្រកបដោយសាមគ្គីភាព ស្មារតីទទួលខុសត្រូវ ឆន្ទៈកែទម្រង់ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ក្នុងនាមជាសេនាធិការដ៏ចំណានរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់រៀងៗខ្លួន។

ខ្ញុំរំពឹងថា **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ក្លាយជាមគ្គុទេសក៍ដ៏រស់រវើក សម្រាប់អនុវត្តយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.ក.**)។ ទន្ទឹមនេះ ខ្ញុំសូមលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន និងអង្គភាពដែលជាតួអង្គពាក់ព័ន្ធទាំងអស់ បន្តចូលរួមអនុវត្តនិងដកស្រង់បទពិសោធន៍ មេរៀនល្អៗ នៅក្នុងកិច្ចដំណើរការនៃការអនុវត្តចក្ខុវិស័យ និងយុទ្ធសាស្ត្រសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនេះ យកធ្វើជាមូលដ្ឋានកាន់តែ

ប្រសើរឡើងថែមទៀត ដើម្បីពង្រឹងគុណភាពអភិបាលកិច្ច រួមចំណែកបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ឱ្យបានកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ១១ កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកានុក្រម


**បុព្វកថា** ........ I

**បញ្ជីពាក្យកាត់** ........ XI

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១. ក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ន នៃកម្មវិធីកែទម្រង់គន្លឹះ** ........ ៩

**១.១. ក្របខ័ណ្ឌស្ថាប័ន** ........ ៩

១.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៩

១.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ........ ១៥

១.១.៣. វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ........ ២៥

១.១.៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ........ ៤៥

១.១.៥. កម្មវិធីកែទម្រង់ច្បាប់ ........ ៥០

**១.២. សមិទ្ធផល** ........ ៥៧

១.២.១. សមិទ្ធផលនិងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់នីមួយៗ ........ ៥៧

១.២.២. សមិទ្ធផលនិងបញ្ហាប្រឈមនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ... ១០១

**១.៣. ស្ថានភាពបច្ចុប្បន្ន** ........ ១០៤

១.៣.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ១០៤

១.៣.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ....១០៦

១.៣.៣. វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ........ ១១៨

១.៣.៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ........ ១១៨

១.៣.៥. កម្មវិធីកែទម្រង់ច្បាប់ ........ ១២០

**ជំពូកទី២. ចក្ខុវិស័យស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ........ ១២៥

**២.១. ចក្ខុវិស័យនិងបេសកកម្ម** ........ ១២៥

២.១.១. ចក្ខុវិស័យ ........ ១២៥

២.១.២. បេសកកម្ម ........ ១២៧

**២.២. ក្របខ័ណ្ឌផែនការសកម្មភាពរួមនិងប្រភពធនធានថវិកា** ........ ១២៨

២.២.១. ក្របខ័ណ្ឌផែនការសកម្មភាពរួម ........ ១២៨

២.២.២. ប្រភពធនធានថវិកាគាំទ្រ ........ ១៤២

**២.៣. យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ........ ១៤៤

២.៣.១. មុខងារនិងភារកិច្ច ........ ១៤៤

២.៣.២. ការរៀបចំផែនការសកម្មភាពនិងរបបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ........ ១៤៦

២.៣.៣. កិច្ចប្រជុំប្រចាំត្រីមាស ........ ១៤៧

២.៣.៤. យន្តការសម្របសម្រួលកម្រិតមន្ត្រីបង្គោលបច្ចេកទេស ........ ១៤៧

**សន្និដ្ឋាន** ........ ១៤៩

**បញ្ជីឧបសម្ព័ន្ធ** ........ ១៥៣

ឧបសម្ព័ន្ធទី១. អនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ........ ១៥៧

ឧបសម្ព័ន្ធទី២. អនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ (និរាករណ៍) ........ ១៦៥

ឧបសម្ព័ន្ធទី៣. ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ លើលិខិតលេខ ៥៥៩១ សហវ.លស.អគហ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ........ ១៧១

ឧបសម្ព័ន្ធទី៤. ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លើលិខិតលេខ ៥០៩៤ សហវ.លស.អគហ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ ................................ ១៧៥

ឧបសម្ព័ន្ធទី៥. របាយការណ៍ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥................ ១៧៩

ឧបសម្ព័ន្ធទី៦. របាយការណ៍ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥..................... ១៨៥

ឧបសម្ព័ន្ធទី៧. របាយការណ៍ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥.................... ១៩៧

ឧបសម្ព័ន្ធទី៨. របាយការណ៍ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ ................... ២០៥

ឧបសម្ព័ន្ធទី៩. របាយការណ៍ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤..................... ២១១

ឧបសម្ព័ន្ធទី១០. របាយការណ៍ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤............. ២១៧

ឧបសម្ព័ន្ធទី១១. របាយការណ៍ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤................. ២២៥

ឧបសម្ព័ន្ធទី១២. របាយការណ៍ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤................ ២៣៥

ឧបសម្ព័ន្ធទី១៣. របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ................. ២៤១

ឧបសម្ព័ន្ធទី១៤. របាយការណ៍ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣.............. ២៤៧

ឧបសម្ព័ន្ធទី១៥. របាយការណ៍ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ................. ២៥៩

ឧបសម្ព័ន្ធទី១៦. របាយការណ៍ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ............... ២៦៩

ឧបសម្ព័ន្ធទី១៧. របាយការណ៍ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២............... ២៧៥

ឧបសម្ព័ន្ធទី១៨. របាយការណ៍ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២............... ២៨១

ឧបសម្ព័ន្ធទី១៩. របាយការណ៍ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ................ ២៨៧

ឧបសម្ព័ន្ធទី២០. របាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ............ ២៩៣

ឧបសម្ព័ន្ធទី២១. របាយការណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ............... ៣០១

ឧបសម្ព័ន្ធទី២២. របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ .................. ៣០៧

ឧបសម្ព័ន្ធទី២៣. របាយការណ៍ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១................. ៣១៣

ឧបសម្ព័ន្ធទី២៤. របាយការណ៍ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១..................៣១៩
ឧបសម្ព័ន្ធទី២៥. របាយការណ៍ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០................ ៣២៥
ឧបសម្ព័ន្ធទី២៦. របាយការណ៍ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ...................៣២៩
ឧបសម្ព័ន្ធទី២៧. របាយការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ...................៣៣៥
ឧបសម្ព័ន្ធទី២៨. របាយការណ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨..............៣៣៩
ឧបសម្ព័ន្ធទី២៩. របាយការណ៍ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ .............. ៣៤៥
ឧបសម្ព័ន្ធទី៣០. សេចក្តីសម្រេចរួមលេខ០០៦ សហវ ចុះថ្ងៃទី១៩
ខែឧសភា ឆ្នាំ២០១៥ (និរាករណ៍)..............................៣៥៣
ឧបសម្ព័ន្ធទី៣១. ផែនការសកម្មភាពឆ្នាំ២០២៥ នៃយន្តការ
សម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល......៣៥៧

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| កសហវ. | : | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ហ.ស. | : | ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| គ.ក.ច. | : | គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ |
| គ.ក.ប.យ. | : | គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| គ.ក.ស. | : | គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| គ.ក.ហ. | : | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| គ.ជ.អ.ប. | : | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.វ.រ. | : | គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា |
| គ.ហ.ស. | : | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ផ.ស.ស. | : | ផលិតផលក្នុងស្រុកសរុប |
| យ.ស.ក. | : | យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល |
| អ.គ.រ. | : | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| អ.គ.ហ. | : | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| អ.ដ.ក. | : | អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ |
| អ.ព.ដ. | : | អគ្គនាយកដ្ឋានពន្ធដារ |

| | | |
|---|---|---|
| BSP | : | Budget Strategic Plan<br>ផែនការយុទ្ធសាស្រ្តថវិកា |
| CAP | : | Consolidated Action Plan<br>ផែនការសកម្មភាពរួម |
| FMIS | : | Financial Management Information System<br>ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| MTBF | : | Medium Term Budget Framework<br>ក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| MTFF | : | Medium Term Fiscal Framework<br>ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម |
| NRMIS | : | Non-tax Revenue Management Information System<br>ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| IPSAS Cash Basis | : | International Public Sector Accounting Standards Cash Basis<br>ស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ ផ្អែកលើមូលដ្ឋានសាច់ប្រាក់ |
| SARMIS | : | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យ-សម្បត្តិរដ្ឋ<br>State Assets Register Management Information System |
| TSA | : | Treasury Single Account<br>គណនីទោលរតនាគារ |

# សេចក្តីផ្តើម

កិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល សំដៅដល់ការកែទម្រង់ដែលមានចរិតលក្ខណៈជាប្រព័ន្ធនិងប្រទាក់ក្រឡាបស់រាជរដ្ឋាភិបាល ដែលរួមមានការកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់ច្បាប់។

ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ២០០៤ មកដែលដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន។ ការកែទម្រង់នេះត្រូវបានបែងចែកជា ៤ ដំណាក់កាល តាំងពីការចាប់ផ្តើមដំបូង ពោលគឺត្រូវអនុវត្តរហូតដល់ឆ្នាំ២០២៧ ដើម្បីសម្រេចចក្ខុវិស័យ **"ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលផ្តោតលើធាតុចូល ឬមជ្ឈការ ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ"**។

ការកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានចាប់ផ្តើមដំបូងនៅឆ្នាំ២០០២ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់។ ផ្អែកលើវឌ្ឍនភាពនៃការកែទម្រង់រដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានពង្រីកកិច្ចការកែទម្រង់នេះទៅកាន់គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០០៨ តាមរយៈការបោះ-ឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស។ នៅក្នុងដំណាក់កាលនេះ ដំណើរការអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានជួបប្រទះបញ្ហាប្រឈមស្មុគស្មាញ ស៊ីជម្រៅ ទូលំទូលាយ និងប្រទាក់ក្រឡាគ្នាជាអន្តរវិស័យ។ ស្ថានភាពនេះ បានតម្រូវឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ ដំណាក់កាលទី១ ពីឆ្នាំ២០១០

ដល់ឆ្នាំ២០២០ និងកម្មវិធីជាតិដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។ កិច្ចការកែទម្រង់នេះ ដឹកនាំដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន។

ការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានចាប់ផ្តើមអនុវត្តជាផ្លូវការ ចាប់ពីឆ្នាំ២០១៥ តាមរយៈការដាក់ចេញនូវកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដំណាក់កាលទី១ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ បច្ចុប្បន្ន ការកែទម្រង់រដ្ឋបាលសាធារណៈបាននិងកំពុងធ្វើបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០៣៥។ កិច្ចការកែទម្រង់នេះ ដឹកនាំដោយគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធាន។

ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានចាប់ផ្តើមដំបូងនៅឆ្នាំ២០០០ ក្រោមទម្រង់ជា "ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌" ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ចាប់ពីឆ្នាំ២០១៣ ការកែទម្រង់យុត្តិធម៌ ត្រូវបានផ្ទេរពីទីស្តីការគណៈរដ្ឋមន្ត្រី មកស្ថិតក្រោមការគ្រប់គ្រងនិងដឹកនាំរបស់ក្រសួងយុត្តិធម៌។ ជាមួយនឹងបច្ចុប្បន្នកម្មលើផែនការយុទ្ធសាស្ត្រនិងយន្តការស្ថាប័ន គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ដែលមានសហប្រធាន ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល។

ការកែទម្រង់ច្បាប់ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០២៤ ដោយផ្តាច់ចេញពីអតីត "ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌" និងត្រូវបានដាក់ឱ្យស្ថិតនៅក្រោមទីស្តីការគណៈ-រដ្ឋមន្ត្រី។ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ នៅឆ្នាំ២០២៥ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបានអនុម័តនិងកំពុងដំណើរការប្រកាសដាក់ឱ្យ

អនុវត្តដោយ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងក្របខ័ណ្ឌដែលកម្មវិធីកែទម្រង់នីមួយៗ ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងនីមួយៗដាច់ដោយឡែកពីគ្នា ដំណើរការអនុវត្តជាក់ស្ដែងនៃការកែទម្រង់ទាំងនេះ តែងទាមទារឱ្យមានកិច្ចសហការ និងការគាំទ្រពីគ្នាទៅវិញទៅមក ជាលក្ខណៈប្រទាក់ក្រឡានិងជាប្រព័ន្ធនៃការកែទម្រង់។

ក្នុងន័យនេះ បន្ទាប់ពីការអនុវត្តការកែទម្រង់នីមួយៗនៅតាមការដ្ឋាននីមួយៗដាច់ដោយឡែកពីគ្នាអស់រយៈពេលប៉ុន្មានឆ្នាំកន្លងមក នៅឆ្នាំ២០១៥ តាមរយៈសេចក្ដីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ទាំង៣ បានបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្មនៃទំនាក់ទំនងការងារកែទម្រង់ទាំងបីនេះរបស់រាជរដ្ឋាភិបាល។ យន្តការសម្របសម្រួលនេះ ធ្វើឡើងក្រោមទម្រង់ជារបបប្រជុំប្ដូរវេនប្រចាំត្រីមាស រវាងអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់នីមួយៗ។ ស្ថិតក្រោមវិធាននៃសេចក្ដីសម្រេចរួមនេះ កិច្ចប្រជុំប្ដូរវេនត្រូវបានរៀបចំនិងបានសម្រេចសកម្មភាពជាបន្តបន្ទាប់ដោយបានពិភាក្សាលើការងារសំខាន់ៗ ដោះស្រាយបញ្ហាប្រឈមគន្លឹះរួមគ្នា បានឈានទៅដល់ការរៀបចំផែនការសកម្មភាពរួមគ្នានិងបានរៀបចំសិក្ខាសាលារួមគ្នាផងដែរ។

នាឱកាសបិទបញ្ចប់សិក្ខាសាលាស្ដីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ **សម្ដេចក្រឡាហោម ស ខេង** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្ដល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ឱ្យពិនិត្យលទ្ធភាពបញ្ចូលលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំ

ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ទៅក្នុងយន្តការសម្របសម្រួលនៃលេខាធិការដ្ឋានកែទម្រង់ជាប្រព័ន្ធទាំង ៣ ខាងលើ។ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់នេះ អគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ទាំង៤ បានពិនិត្យ ពិភាក្សា និងរកឃើញថា ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានលក្ខណៈពិសេស ដោយឡែក ខុសប្លែក ពីការកែទម្រង់ ៣ ផ្សេងទៀត ទាំងរចនាសម្ព័ន្ធស្ថាប័ន ទាំងវិស័យការងារ។ ផ្អែកតាមរបកគំហើញនេះ យន្តការសម្របសម្រួលការងារកែទម្រង់ ៣ បូក ១ ត្រូវបានបង្កើតឡើង តាមការឯកភាពគាំទ្រដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨។ ចាប់ពីពេលនោះមក កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងយន្តការសម្របសម្រួលការកែទម្រង់ទាំង៣ និងបានប្រែក្លាយប្រព័ន្ធសម្របសម្រួលនេះ ទៅជាយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល ដោយរក្សាបាននូវលក្ខណៈពិសេសនៃការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌នៅក្នុងយន្តការថ្មីនេះ ដែលត្រូវបានកំណត់ថាជាយន្តការសម្របសម្រួលការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល ឬហៅកាត់ថា "**យ.ស.ក.**"។

ផ្អែកលើមូលដ្ឋាននេះ ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការងារកែទម្រង់ ៣ បូក ១ ក៏ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២២ ក្រោមអធិបតីភាពបើកដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអធិបតីភាពបិទដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ដែលកាលពីពេលនោះជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធាន **គ.ជ.អ.ប.**។

ក្រោយមកទៀត នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានសម្រេចបង្កើត

និងដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ច្បាប់និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់នៅក្នុងឆ្នាំ២០២៤ ដែលទទួលបន្ទុកដឹកនាំនិងសម្របសម្រួលដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ដូចនេះ កម្មវិធីកែទម្រង់ច្បាប់ត្រូវបានបញ្ចូលបន្ថែមទៅក្នុងយន្តការសុខដុមនីយកម្មដែលមានស្រាប់ ធ្វើឱ្យមានការកែសម្រួលពីការកែទម្រង់ ៣ បូក ១ ទៅជាកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាលទ្ធផល អនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើងដើម្បីជានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

ជាចុងក្រោយ នៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៥នេះ តាមរយៈវិបស្សនាប្រចាំឆ្នាំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ទាំង ៥ បានសម្រេចជាឯកច្ឆ័ន្ទធ្វើបច្ចុប្បន្នកម្ម "ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១" ឬ "៣ បូក ២" ទៅជា "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**"។

ទំនាក់ទំនងប្រទាក់ក្រឡានិងជាប្រព័ន្ធនៃកិច្ចការកែទម្រង់ទាំងនេះ មានវិសាលភាពគ្របដណ្តប់លើ៖

១. ស្ថាប័នដឹកនាំការងារកែទម្រង់ ឬតួអង្គនិម្មាបនករកែទម្រង់

២. ក្រសួង ស្ថាប័នអនុវត្តការកែទម្រង់ ឬតួអង្គប្រតិបត្តិករកែទម្រង់

៣. ទំនាក់ទំនងខាងមុខងារនិងការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ទំនាក់ទំនងរវាងកម្មវិធីកែទម្រង់មួយទៅកាន់កម្មវិធីកែទម្រង់មួយទៀត

៥. ទំនាក់ទំនងរវាងការកែទម្រង់គន្លឹះទៅកាន់ការកែទម្រង់តាមវិស័យ។ល។

ឈរលើមូលដ្ឋានេះ កិច្ចការកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាលមានទំនាក់ទំនងនិងភាពប្រទាក់ក្រឡាគ្នាលើកម្មវត្ថុចំនួន ៥ ដូចខាងក្រោម៖

**ទី១) មុខងារ** ៖ មុខងារនៅទីនេះ សំដៅទាំងមុខងាររបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន ការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នគឺជាកិច្ចការកែទម្រង់គន្លឹះស្ថិតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈនៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារទាមទារឱ្យមានការគិតគូរជាកញ្ចប់ជាមួយនឹងការផ្ទេរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ដើម្បីគាំទ្រការអនុវត្តមុខងារដែលត្រូវបានផ្ទេរប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

**ទី២) ហិរញ្ញវត្ថុ** ៖ ការអនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួង ស្ថាប័ន ត្រូវមានថវិកាគាំទ្រ។ នៅក្នុងបរិបទដែលសមិទ្ធកម្មក្លាយជាគោលដៅនៃការគ្រប់គ្រងក្នុងរដ្ឋបាលសាធារណៈកម្ពុជាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ថវិកាមិនត្រឹមតែជាការគាំទ្រដល់ការបំពេញមុខងារនិងភារកិច្ចតែប៉ុណ្ណោះទេ តែថវិកាគឺជាឧបករណ៍នៃគោលនយោបាយ ឬថវិកាត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយ។ ជារួម ថវិកាត្រូវប្រើប្រាស់ដើម្បីសម្រេចលទ្ធផលដែលបានគ្រោងទុក។ នេះគឺជាគោលនយោបាយនៃថវិកាសមិទ្ធកម្មនៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយឡែក នៅក្នុងក្របខ័ណ្ឌនៃកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ហិរញ្ញវត្ថុឬថវិកាត្រូវគាំទ្រនិងមានសង្គតិភាពទៅនឹងគោលនយោបាយកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គោលនយោបាយកែទម្រង់មុខងារសាធារណៈ គោលនយោបាយកែទម្រង់ច្បាប់ និងគោលនយោបាយកែទម្រង់ប្រព័ន្ធយុត្តិធម៌។

**ទី៣) ធនធានមនុស្ស ៖** ការអភិវឌ្ឍធនធានមនុស្សនៅក្នុងមុខងារសាធារណៈគឺជាកិច្ចការចម្បងមួយនៅក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេស គឺជាអាទិភាពមុនគេនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញនូវអាទិភាពគន្លឹះចំនួន ៣ នៅក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលរួមមាន ៖ ***១) ពង្រឹងប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ, ២) ពង្រឹងសមត្ថភាពមន្ត្រីនិងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារនិង ៣) ដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។*** អាទិភាពគន្លឹះទាំង ៣ នេះផ្តោតទៅលើការពង្រឹងធនធានមនុស្សក្នុងមុខងារសាធារណៈ ពោលគឺមន្ត្រីរាជការនៅគ្រប់ជាន់ថ្នាក់។

**ទី៤) ប្រព័ន្ធយុត្តិធម៌ ៖** ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ អាចមានចរិតលក្ខណៈពិសេសពីកម្មវត្ថុទាំង ៣ ខាងលើ នៅត្រង់ថាការងារនេះផ្តោតទៅលើវិស័យយុត្តិធម៌ ឬនិយាយម្យ៉ាងទៀត ការកែទម្រង់គឺជាសកម្មភាពការងារនៅក្នុងអំណាចមួយដោយឡែកផ្សេងពីអំណាចនីតិប្រតិបត្តិ ឬរាជរដ្ឋាភិបាល នោះគឺអំណាចតុលាការ។ ទោះយ៉ាងណាក៏ដោយ កាលណានិយាយពីមុខងារ ហិរញ្ញវត្ថុឬថវិកា និងធនធានមនុស្សឬមន្ត្រីរាជការ ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅតែមានទំនាក់ទំនងជាប្រយោលផងនិងដោយផ្ទាល់ផងជាមួយនឹងការកែទម្រង់ ៤ ផ្សេងទៀត ដោយខានមិនបាន។

**ទី៥) ច្បាប់ ៖** ការកែទម្រង់ច្បាប់ផ្តោតទៅលើវដ្តនៃច្បាប់ ទាំងក្នុងដំណាក់កាលរៀបចំ ដំណាក់កាលអនុវត្ត និងដំណាក់កាលត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្ត ក្នុងគោលបំណងពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ឧត្តមានុភាពគតិយុត្ត ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់។

**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** នេះ ត្រូវបានសម្រេចឡើងបន្ទាប់ពីបានពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាច្រើនលើក រួមមាន៖

- កិច្ចប្រជុំផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ

- កិច្ចប្រជុំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
- វិបស្សនាប្រចាំឆ្នាំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
- ការពិនិត្យនិងឯកភាពដោយប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ
- ការពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** នេះ អាចទុកជាមគ្គុទេសក៍បង្ហាញផ្លូវ ក្នុងគោលបំណង ៣ ដូចខាងក្រោម៖

ទី១. បង្ហាញអំពីក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ននៃកម្មវិធីកែទម្រង់នីមួយៗ។

ទី២. បង្ហាញអំពីចក្ខុវិស័យបេសកកម្មយុទ្ធសាស្ត្រកម្មវិធីការងារនិងយន្តការដឹកនាំសម្របសម្រួល និងដោះស្រាយកិច្ចប្រឈមជាលក្ខណៈអន្តរកែទម្រង់ ស្របតាមចក្ខុវិស័យសុខដុមនីយកម្ម។

ទី៣. បង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តធៀបជាមួយនឹងផែនការសកម្មភាពដែលត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ប្រកបដោយទស្សនវិស័យនៃការកែទម្រង់ និងភាពប្រាកដនិយមនៃបរិការណ៍ជាក់ស្តែង។

# ជំពូកទី១.
# ក្របខ័ណ្ឌស្ថាប័ន សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ន
# នៃកម្មវិធីកែទម្រង់គន្លឹះ

## ១.១. ក្របខ័ណ្ឌស្ថាប័ន

### ១.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានដាក់ចេញនិងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤។ ការកែទម្រង់នេះមានគោលដៅកសាងប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដាអន្តរជាតិ ដែលនឹងផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញឬលទ្ធផល និងវិមជ្ឈការ។ ក្នុងបេសកកម្មនេះ ក្រុមការងារ ៣ កម្រិតផ្សេងគ្នាត្រូវបានបង្កើត រួមមាន៖ ១). គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលហៅកាត់ថា **គ.ហ.ស.**) ២). គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ដែលហៅកាត់ថា **គ.ក.ហ.**) និង៣). ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន, នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងនៅតាមរដ្ឋបាលរាជធានី ខេត្ត (ដែលហៅកាត់ថា **ក.ហ.ស.**)។

#### ១.១.១.១. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញភារកិច្ចដឹកនាំ រៀបចំសម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង

ជំពូកទី១

ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។ **គ.ហ.ស.** នេះគឺជាវេទិកាកម្រិតបច្ចេកទេសខ្ពស់មួយ ដើម្បីតាមដាននិងសម្របសម្រួលក្នុងចំណោមអង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាលទាំងអស់។ **គ.ហ.ស.** មានសមាសភាព ដូចតទៅ៖

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប | អនុប្រធានប្រចាំការ |
| ៣. ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | មួយរូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំ ប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | | អនុប្រធាន |
| ៥. អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ៦. អង្គភាពប្រតិបត្តិនៃគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត | | សមាជិក |
| ៧. អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ៨. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | សមាជិកអចិន្ត្រៃយ៍។ |

#### ១.១.១.២. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ក.ហ.**) ជាគណៈកម្មការផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) ដែលដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។ សមាសភាពនៃ **គ.ក.ហ.** គឺជាថ្នាក់ដឹកនាំនៃ **កសហវ.** ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នៅតាមអគ្គនាយកដ្ឋាន និងប្រធានអង្គភាពនានាក្រោមឱវាទ **កសហវ**. ដែលចូលរួមអនុវត្តការងារកែទម្រង់។ **គ.ក.ហ.** រៀបចំកិច្ចប្រជុំត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស និងឆ្នាំ មុនកិច្ចប្រជុំនៃ **គ.ហ.ស.**។

### ១.១.១.៣. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**កសហវ**. ក្នុងនាមជាតួអង្គនិម្មាបនករ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( **ក.ហ.ស.** ) ត្រូវបានបង្កើតឡើងនៅតាមអង្គភាពក្រោមឱវាទរបស់ខ្លួន២កម្រិត រួមមាន ទី១ ) អង្គភាពនៅថ្នាក់កណ្តាល ដែលមាន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន និងទី២ ) អង្គភាពនៅថ្នាក់មូលដ្ឋាន ដែលជាមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំរាជធានី ខេត្តទាំង ២៥។ **ក.ហ.ស.** នៅក្នុង **កសហវ**. មានភារកិច្ចដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់សាមីអង្គភាពនីមួយៗ ដែលមានមាសភាពដូចតទៅ៖

**ក.ហ.ស. នៃ កសហវ. សម្រាប់អង្គភាពថ្នាក់កណ្តាល**

| | | |
|---|---|---|
| ១. អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ | | ប្រធាន |
| ២. អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង | ១ រូប | អនុប្រធានប្រចាំការ |
| ៣. អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង | ១ ឬ ច្រើន | រូបអនុប្រធាន |
| ៤. ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ | ១ ឬ ច្រើនរូប | សមាជិក |
| ៥. មន្ត្រីជំនាញពាក់ព័ន្ធក្រោមឱវាទ | ១ ឬ ច្រើនរូប | សមាជិក |

ជំពូកទី១

| | | |
|---|---|---|
| ៦. មន្ត្រីបង្គោល ដែលជាអ្នកទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន | ១ ឬ ច្រើនរូប | លេខាធិការ។ |

**គ.ហ.ស. នៃ គសហទ. សម្រាប់អង្គភាពថ្នាក់មូលដ្ឋាន**

| | | |
|---|---|---|
| ១. ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២. អនុប្រធានមន្ទីរ សហវ. ទទួលបន្ទុកហិរញ្ញវត្ថុ | | អនុប្រធានប្រចាំការ |
| ៣. អនុប្រធានមន្ទីរ សហវ. ដទៃទៀត | ១ ឬច្រើនរូប | សមាជិក |
| ៤. មន្ត្រីជំនាញពាក់ព័ន្ធ | ១ ឬច្រើនរូប | សមាជិក |
| ៥. មន្ត្រីបង្គោល | ១ រូប | លេខាធិការ។ |

អគ្គនាយកដ្ឋាន ដែលមានមន្ត្រីបង្គោលច្រើនរូប អាចរៀបចំបង្កើតជាក្រុមមន្ត្រីបង្គោលបាន តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ដើម្បីសម្របសម្រួលការងារផ្ទៃក្នុង និងជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**អ.គ.ហ.**"។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទនីមួយៗ នៃ **គសហទ.** ត្រូវតែងតាំងដោយរដ្ឋមន្ត្រី **គសហទ.**។ កិច្ចដំណើរការនៃ **គ.ហ.ស.** នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ **គសហទ.** ត្រូវកំណត់ដោយប្រធាន **គ.ហ.ស.** នីមួយៗ។

### ១.១.១.៤. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន (**គ.ហ.ស.**) ដែលត្រូវបានដឹកនាំដោយថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នសាមីនោះ ដែលជាសមាជិកនៃ **គ.ហ.ស.**។ កិច្ចដំណើរការនៃ **គ.ហ.ស.** នៅតាមក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន។ សមាសភាពនៃ **គ.ហ.ស.** នេះគួរតែយ៉ាង-

ហោចណាស់ជាអនុប្រធានផ្នែកហិរញ្ញវត្ថុឬគណនេយ្យ។ សមាសភាពនៃ **ក.ហ.ស**. នៅតាមក្រសួង ស្ថាប័ន រួមមាន៖

១. ប្រធាន **ក.ហ.ស**. ១ រូប ត្រូវជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំមួយរូប ទទួលបន្ទុកផ្ទាល់ជួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន

២. អនុប្រធាន **ក.ហ.ស**. ១ រូប អាចជាអនុរដ្ឋលេខាធិការ ឬអគ្គលេខាធិការ ឬអគ្គនាយក ទទួលបន្ទុកហិរញ្ញវត្ថុ ឬថ្នាក់ដឹកនាំបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស**.

៣. សមាជិក **ក.ហ.ស**. មួយចំនួន ដែលត្រូវមាន៖

- តំណាង ១ រូប ពីគ្រប់អគ្គនាយកដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង ស្ថាប័នផ្ទាល់ និង
- តំណាង ១ រូប ពីគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង ស្ថាប័នសាមី នីមួយៗ

លេខាធិការ **ក.ហ.ស**. ១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោលតែងតាំងដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ស្របតាមសំណើនិងលក្ខខណ្ឌយោងការងារដែលកំណត់ដោយប្រធាន **គ.ហ.ស**.។

សមាសភាពជាក់ស្ដែង នៃ **ក.ហ.ស**. នៅតាមក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ដោយមានការឯកភាពពីប្រធាន **គ.ហ.ស**.។

### ១.១.១.៥. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមរដ្ឋបាលរាជធានី ខេត្ត

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមរដ្ឋបាលរាជធានី ខេត្ត (**ក.ហ.ស**.) ដែលត្រូវបានដឹកនាំដោយផ្ទាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ដែលជាសមាជិក **គ.ហ.ស.**។ ការរៀបចំនិងការប្រព្រឹត្តទៅ នៃ **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុលោមតាមសារាចររាជរដ្ឋាភិបាល លេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សមាសភាព **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចនៃអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលត្រូវអនុលោមដូចតទៅ៖

១. ប្រធាន **ក.ហ.ស.** ១ រូប ត្រូវជាអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

២. អនុប្រធានប្រចាំការ **ក.ហ.ស.** ១ រូប ត្រូវជា អភិបាលរងនៃគណៈអភិបាលរដ្ឋបាលរាជធានី ខេត្ត ដែលទទួលបន្ទុកហិរញ្ញវត្ថុ ឬដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.**

៣. អនុប្រធាន **ក.ហ.ស.** មួយចំនួន ត្រូវជា អភិបាលរងនៃគណៈអភិបាលរដ្ឋបាលរាជធានី ខេត្ត ក្រៅពីអភិបាលរងដែលត្រូវបានចាត់តាំងជាអនុប្រធានប្រចាំការ

៤. សមាជិក មួយចំនួន ត្រូវជា នាយករដ្ឋបាល និង នាយកទីចាត់ការ និងមន្ត្រីជំនាញពាក់ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត

៥. លេខាធិការ **ក.ហ.ស.** ១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោល។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

#### ១.១.១.៦. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាសេនាធិការរបស់ **គ.ហ.ស.** ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ **គ.ហ.ស.** និងសម្របសម្រួលការងារជាមួយ **ក.ហ.ស.** នៃក្រសួង ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទ **កសហវ.** ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងសម្របសម្រួលការងារជាមួយការកែទម្រង់ផ្សេងទៀត

របស់រាជរដ្ឋាភិបាល។

**អ.គ.ហ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ និងមានតួនាទីផ្តល់ការគាំទ្រជូនក្រសួង ស្ថាប័ន និងអង្គភាពនានាក្រោមឱវាទ **គសហវ.** ទាំងក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ក្របខ័ណ្ឌស្ថាប័ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**




### ១.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាការកែទម្រង់ផ្នែកអភិបាលកិច្ច ដែលផ្តោតលើការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានភាពធន់មាំ មានសមត្ថភាព មានលទ្ធភាព និងភាពស្អាតស្អំក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារ ធនធាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព

ជំពូកទី១

តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ កម្មវិធីកែទម្រង់នេះ បានចាប់ផ្តើមក្នុងដំណាក់កាលដំបូងជាប្រវត្តិសាស្ត្រតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ផ្អែកតាមបទពិសោធន៍ និងភាពជោគជ័យនៃការអនុវត្តការកែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃការកែទម្រង់នេះទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនាឆ្នាំ២០០៩ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំបង្កើតនូវគណៈកម្មាធិការអន្តរក្រសួងមួយសម្រាប់ការដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការងារកែទម្រង់នេះ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការរៀបចំបង្កើត "គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ" ដែលហៅកាត់ថា "**គ.ជ.អ.ប**." សម្រាប់ដឹកនាំ សម្របសម្រួល និងគ្រប់គ្រងកិច្ចដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ផ្អែកតាមការវិវឌ្ឍនៃការកែទម្រង់នេះកាន់តែស៊ីជម្រៅពីមួយដំណាក់កាលទៅមួយដំណាក់កាលបានតម្រូវឱ្យមានការកែសម្រួលជាបន្តបន្ទាប់នូវសមាសភាពនៃ **គ.ជ.អ.ប**. ដែលបច្ចុប្បន្ននេះ យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ សមាសភាពនៃ **គ.ជ.អ.ប**. រួមមានចំនួន២៦រូប ក្នុងនោះ៖

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៤. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ជាអនុប្រធាន |
| ៥. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៦. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៧. ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ០១រូប | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៨. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៩. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ១០. រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ១១. រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ជាសមាជិក |
| ១២. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១៣. រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១៤. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាសមាជិក |
| ១៥. រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | ជាសមាជិក |
| ១៦. រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ជាសមាជិក |
| ១៧. រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១៨. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| ១៩. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ជាសមាជិក |

| | |
|---|---|
| ២០. រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០២រូប | ជាសមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | ជាសមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ០១រូប | ជាសមាជិក |
| ២៤. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប | ជាសមាជិក |
| ២៥. ប្រធានលេខាធិការដ្ឋាន **គ.ជ.អ.ប**. | ជាសមាជិក។ |

**គ.ជ.អ.ប**. មានបេសកកម្មសំខាន់ពាក់ព័ន្ធនឹង ១). ការរៀបចំតាក់តែង និងអនុវត្តកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ២). ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការពិនិត្យមើលឡើងវិញ និងកំណត់នូវមុខងារ ធនធាន (ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) សិទ្ធិអំណាច និងការទទួលខុសត្រូវដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ, ៣). ការលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំតាក់តែង ឬការធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ, ៤). ការធានាឱ្យមានការសម្របសម្រួល និងពិគ្រោះយោបល់អំពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានាដែលរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធានាឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ៥). ការធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការ

អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ដើម្បីជានាដល់ការសម្រេចបេសកកម្មរបស់ខ្លួន **គ.ជ.អ.ប**. ចាំបាច់ត្រូវរៀបចំបង្កើតអនុគណៈកម្មាធិការនានាដែលបច្ចុប្បន្ន **គ.ជ.អ.ប**. មានអនុគណៈកម្មាធិការក្រោមចំណុះចំនួន ៣ គឺ៖

**១.អនុគណៈកម្មាធិការមុខងារ និងធនធាន** ដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប**. លើកិច្ចការនានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការលើកកម្ពស់សមភាពយេនឌ័រ និងការបន្សាំការប្រែប្រួលអាកាសធាតុ
- ពិនិត្យ និងផ្តល់យោបល់លើជម្រើសនានាសម្រាប់ការរៀបចំ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីកំណត់មុខងារ និងធនធាន បែបបទ និងនីតិវិធីសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើវិធានការ ឬវិធីសាស្ត្រពង្រឹង និងពង្រីកការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់នូវជម្រើសសមស្របសម្រាប់ដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ពិនិត្យ និងផ្ដល់យោបល់លើការរៀបចំ និងការពង្រឹងយន្តការ និងនីតិវិធីសម្រាប់អនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- ពិនិត្យ និងផ្ដល់យោបល់លើការរៀបចំ ការពង្រឹង និងការកែលម្អយន្តការ នីតិវិធី និងដំណើរការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្ដល់យោបល់លើការរៀបចំយន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ **គ.ជ.អ.ប**.។

**២. អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ** ដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានតួនាទីផ្ដល់យោបល់ជូន **គ.ជ.អ.ប**. លើកិច្ចការនានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្ដល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រថវិកា និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់នូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បែបបទ និងនីតិវិធីសម្រាប់ផ្ទេរ

ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌ ចំណូលចែករំលែក និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធ នីតិវិធី និងដំណើរការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងជម្រើសនានាសម្រាប់ការបង្កើតប្រភពចំណូលផ្ទាល់នៅមូលដ្ឋាន និងការរៀបចំប្រព័ន្ធបែងចែកធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមធម៌
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាននានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំបន្សុីគ្នារវាងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគជាមួយនឹងដំណើរការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំស្តង់ដា និងបែបបទសម្រាប់ការធ្វើសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំយន្តការគាំទ្រ អភិវឌ្ឍសមត្ថភាព តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ **គ.ជ.អ.ប**.។

៣. **អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានតួនាទីផ្តល់យោបល់ជូន **គ.ជ.អ.ប**. លើកិច្ចការនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

ជំពូកទី១

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បី កំណត់អំពីប្រភេទ ចំនួនបុគ្គលិក បែបបទ និងនីតិវិធីសម្រាប់ផ្ទេរបុគ្គលិកទៅ ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិក ព្រមទាំងការរៀបចំការពិពណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការពង្រឹងយន្តការអភិវឌ្ឍសមត្ថភាព ព្រមទាំងវិធីសាស្ត្រ និងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលដល់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធវាយតម្លៃ ការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការពង្រឹងយន្តការអភិវឌ្ឍសមត្ថភាព ព្រមទាំងវិធីសាស្ត្រ និងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលដល់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធវាយតម្លៃ ការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ **គ.ជ.អ.ប**.។

ជាមួយគ្នានេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏បាន តម្រូវឱ្យរៀបចំបង្កើតនូវលេខាធិការដ្ឋាន **គ.ជ.អ.ប**. មួយ ដើម្បីធ្វើជាសេនាធិការឱ្យ **គ.ជ.អ.ប**. និងអនុគណៈកម្មាធិការនានារបស់ **គ.ជ.អ.ប**. ក្នុងការបំពេញមុខងាររបស់ ខ្លួនឱ្យមានប្រសិទ្ធភាព។ បច្ចុប្បន្ននេះ លេខាធិការដ្ឋាន **គ.ជ.អ.ប**. រួមមានអង្គភាព

ក្រោមចំណុះចំនួន៥ គឺ៖

១. **អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ៖** មានតួនាទីសិក្សាស្រាវជ្រាវ វិភាគ រៀបចំ និងតម្រឹមក្របខ័ណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ រួមមានដូចជា ការផ្ទេរមុខងារនិងធនធាន វិមជ្ឈការហិរញ្ញវត្ថុ ការកសាងផែនការ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងធនធានធម្មជាតិ ការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២. **អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី៖** មានតួនាទីសំខាន់ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់-ក្រោមជាតិ ការកៀរគរធនធានសម្រាប់ការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.អ.ប.** និងការសម្របសម្រួល និងតម្រឹមគម្រោងកម្មវិធីដោយឡែកនានាជាមួយកម្មវិធីជាតិ។

៣. **អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ៖** មានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងការចាត់ចែង និងការផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធីជាតិ ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ **គ.ជ.អ.ប.**។

៤. **អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន៖** មានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យ វាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការប្រមូល ចងក្រង និងផ្សព្វផ្សាយព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

៥. **ក្រុមសវនកម្មផ្ទៃក្នុង៖** មានតួនាទីពាក់ព័ន្ធនឹងការធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តរបស់អង្គភាពទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលអនុវត្តកម្មវិធី ឬគម្រោងស្ថិតនៅក្រោមក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ **គ.ជ.អ.ប.**។

ជំពូក ១

# រចនាសម្ព័ន្ធដឹកនាំ នៃ គ.ជ.អ.ប.



ក្រៅពីយន្តការដែលមានលក្ខណៈជាអន្តរស្ថាប័នខាងលើ ដើម្បីធានាដល់ការលើកកម្ពស់ការទទួលខុសត្រូវលើការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅតាមក្រសួងពាក់ព័ន្ធ ក៏ត្រូវបានណែនាំដោយរាជរដ្ឋាភិបាលឱ្យរៀបចំបង្កើតនូវគណៈកម្មាធិការដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងក្រសួងសាមីនីមួយៗផងដែរ ហើយយន្តការនេះត្រូវស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវដោយផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងសាមី ដោយត្រូវមានរដ្ឋលេខាធិការ០១រូបជាអនុប្រធានប្រចាំការដើម្បីសម្របសម្រួលការងារប្រចាំថ្ងៃ និងត្រូវមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាចំណុះក្រសួងសាមីនីមួយៗជាសមាជិក។

នៅតាមរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកនីមួយៗមានការរៀបចំបង្កើតនូវ "គណៈកម្មការដឹកនាំការងារកែទម្រង់" មួយ ដើម្បីដឹកនាំកិច្ចដំណើរការជាទូទៅនៃកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គណៈកម្មការនេះមានអភិបាលខេត្តជាប្រធាន អភិបាលរងខេត្ត ០១រូបជាអនុប្រធាន និងប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធនានាជាសមាជិក។

### ១.១.៣. វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ

#### ១.១.៣.១. ក្របខ័ណ្ឌគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្ត

វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែល **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន និងមាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាអនុប្រធានប្រចាំការ រដ្ឋមន្ត្រីក្រសួង ស្ថាប័ន ចំនួន ៧ រូបទៀត ជាអនុប្រធាន រួមមាន ១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ២. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៣. រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៤. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៥. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ៦. រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ៧. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអនុប្រធាន ព្រមទាំង រដ្ឋមន្ត្រីក្រសួង ស្ថាប័នដទៃទៀត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាសមាជិក ដោយមានក្រសួងមុខងារសាធារណៈ ជាលេខាធិការដ្ឋាន ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ៣០៩ អនក្រ/បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្ដីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈ ក្នុងក្របខ័ណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (**គ.ជ.វ.**) ជាយន្តការរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈការអនុវត្តវិធានការគន្លឹះចំនួន៣ រួមមាន ១). ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ២). ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្ដិសិទ្ធិភាព និង៣). ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ដូចបានកំណត់ក្នុង **"ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល**

**នីតិកាលទី៧នៃរដ្ឋសភា**"។

**គ.ជ.រ.** មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
- ដាក់ចេញនូវវិធានការចាំបាច់ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សូចនាករសមិទ្ធកម្មសម្រាប់ការអនុវត្តវិធានការគន្លឹះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាសក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធលើការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីជំរុញនិងគាំទ្រការអនុវត្តវិធានការគន្លឹះ
- ធានាសង្គតិភាពនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈជាមួយការងារកែទម្រង់ ក្នុងវិស័យផ្សេងៗរបស់រាជរដ្ឋាភិបាល។

ដើម្បីធានាការដឹកនាំ ការសម្របសម្រួល និងការតម្រង់ទិសការងារបច្ចេកទេសក្នុងការរៀបចំ និងអនុវត្តវិធានការគន្លឹះចំនួន៣ របស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងចីរភាព រាជរដ្ឋាភិបាល បានបង្កើតអនុគណៈ-កម្មាធិការប្រតិបត្តិនៃ **គ.ជ.រ.** តាមរយៈសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតអនុគណៈកម្មាធិការប្រតិបត្តិនិងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

**គ.ជ.រ.** មានសមាសភាព ដូចខាងក្រោម៖

១. រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ ប្រធាន

២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប អនុប្រធាន

៣. តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
៤. តំណាងក្រសួងមហាផ្ទៃ សមាជិក
៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៦. តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៧. តំណាងក្រសួងសុខាភិបាល សមាជិក
៨. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
៩. ប្រធានក្រុមការងារបច្ចេកទេសទាំង៣
នៃអនុគណៈកម្មាធិការប្រតិបត្តិ សមាជិក
១០. រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួង
មុខងារសាធារណៈមួយចំនួន សមាជិក
១១. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន
នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ សមាជិកអចិន្ត្រៃយ៍
១២. អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួង
មុខងារសាធារណៈ សមាជិក
១៣. អគ្គនាយក នៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារ
សាធារណៈនៃក្រសួងមុខងារសាធារណៈ សមាជិក
១៤. អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រី
តាមឌីជីថលនៃក្រសួងមុខងារសាធារណៈ សមាជិក
១៥. អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ
មុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ សមាជិក
១៦. អគ្គាធិការ នៃអគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ សមាជិក

អនុគណៈកម្មាធិការប្រតិបត្តិនៃ **គ.ក.រ.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងតម្រង់ទិសការងារបច្ចេកទេសក្នុងការរៀបចំ និង

អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ រួមមានការរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងការកំណត់នូវក្របខ័ណ្ឌសមិទ្ធកម្មដែលរួមមានសូចនាករ គោលដៅ និងវិធីសាស្ត្រវាស់វែង ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន តាមរយៈ (១) កែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២) លើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង (៣) រៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

- លើកសំណើអំពីយុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងក្របខ័ណ្ឌសមិទ្ធកម្មសម្រាប់ការដាក់ឱ្យអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ជូន **គ.ទ.រ.** ពិនិត្យ និងសម្រេចតាមរយៈលេខាធិការដ្ឋាននៃ **គ.ទ.រ.**
- សម្របសម្រួលនិងផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ដើម្បីបំពេញតួនាទី និងភារកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់
- តាមដាន ត្រួតពិនិត្យ វាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការរៀបចំនិងការដាក់អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងឆ្នាំជូនលេខាធិការដ្ឋាននៃ **គ.ទ.រ.**។

អនុគណៈកម្មាធិការប្រតិបត្តិនៃ **គ.ទ.រ.** មានក្រុមការងារបច្ចេកទេសចំនួន៣(បី) ដើម្បីជួយបំពេញការងារ រួមមាន៖

- ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី
- ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ

- ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម។

ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ **គ.ជ.វ.** មានតួនាទី និងភារកិច្ចក្នុងការអនុវត្តការងារ ក្នុងនោះ៖

**១. ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី** មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងសិក្សាស្រាវជ្រាវស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការជ្រើសរើស និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលាអនុវត្ត ក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ ដើម្បីដាក់អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីឱ្យមានប្រសិទ្ធភាពខ្ពស់ ឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព។

**២. ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ** មានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងសិក្សាស្រាវជ្រាវស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការរៀបចំ រចនាសម្ព័ន្ធស្ថាប័ន មុខងារ របៀបរបបការងារនិងដំណើរការរដ្ឋបាល ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលាអនុវត្ត ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ ក្នុងការដាក់អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

៣. **ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម** មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងសិក្សាស្រាវជ្រាវស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការរៀបចំប្រព័ន្ធលើកទឹកចិត្តក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលាអនុវត្ត ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ ដើម្បីដាក់អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធ នឹងការកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ ឈរលើគោលការណ៍ សង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

**រចនាសម្ព័ន្ធនៃ គ.ជ.រ.**




### ១.១.៣.២. ក្របខ័ណ្ឌគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.ស.**) ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យ នស/រកត/១០២៣/

២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ដើម្បីដឹកនាំ គាំទ្រ និងសម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

**គ.ក.ស**. ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានសមាសភាពអនុប្រធាន និងសមាជិក ជារដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ក្នុងនោះរួមមាន៖

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | | ប្រធាន |
| ២. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | អនុប្រធាន |
| ៦. រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ | | អនុប្រធានប្រចាំការ |
| ៧. រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១រូប | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | ១រូប | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច | | |

| | | |
|---|---|---|
| អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងបរិស្ថាន | ១រូប | សមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ១រូប | សមាជិក |
| ១៩. រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| ២០. រដ្ឋលេខាធិការក្រសួងអធិការកិច្ច | ១រូប | សមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | សមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប | សមាជិក |
| ២៤. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| ២៥. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ២៦. រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | ១រូប | សមាជិក |
| ២៧. រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | សមាជិក |
| ២៨. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | សមាជិក |
| ២៩. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | ១រូប | សមាជិក |
| ៣០. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន កិច្ចការព្រំដែន | ១រូប | សមាជិក |

៣១. ប្រធានអនុគណៈកម្មាធិការទាំង៤ នៃ **គ.ក.ស.** សមាជិក

៣២. រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ
នៃក្រសួងមុខងារសាធារណៈមួយចំនួន សមាជិក

៣៣. តំណាងគណៈអភិបាលរាជធានី ខេត្ត សមាជិក

៣៤. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ស.** សមាជិកអចិន្ត្រៃយ៍។

**គ.ក.ស.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំនិងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព
- ពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្ត គាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព
- សិក្សានិងរៀបចំក្របខ័ណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់គុណភាពនៃសេវាសាធារណៈ និងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- លើកសំណើជូនរាជរដ្ឋាភិបាលសម្រេចលើក្របខ័ណ្ឌគតិយុត្ត យុទ្ធសាស្ត្រ ផែនការសកម្មភាពកម្មវិធី សម្រាប់គាំទ្រនិងបម្រើឱ្យការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល គាំទ្រ និងជំរុញការធ្វើបរិវត្តកម្មសេវាសាធារណៈ នវានុវត្តន៍ និងការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ
- ជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃភាពជាអ្នកដឹកនាំអង្គភាព

សាធារណៈ និងដំណើរការនៃអង្គភាពសាធារណៈឱ្យកាន់តែប្រសើរ
- រៀបចំនិងដាក់ឱ្យអនុវត្តឯកសារក្របខ័ណ្ឌសមត្ថភាពជាអ្នកដឹកនាំ និងវាយតម្លៃ និងទទួលស្គាល់ភាពជាអ្នកដឹកនាំគំរូក្នុងរដ្ឋបាលសាធារណៈ
- សិក្សាប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលជាលក្ខណៈកញ្ចប់ ដោយគ្របដណ្តប់ទាំងមន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ យោធិន មន្ត្រីនគរបាលជាតិ មន្ត្រីផ្សេងទៀត និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងលើកសំណើអំពីការកែទម្រង់ប្រព័ន្ធបៀវត្សជាលក្ខណៈកញ្ចប់
- សិក្សានិងរៀបចំការធ្វើវិចារណកម្មមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន
- គាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលនិងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួម អនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យនិងសម្រេចលើសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាល និងជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈ។

**អនុគណៈកម្មាធិការនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

អនុលោមតាមព្រះរាជក្រឹត្យ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា

ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អនុគណៈកម្មាធិការនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈចំនួន៤ ត្រូវបានបង្កើតឡើង ដែលរួមមានដូចខាងក្រោម៖

១. អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍

២. អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ

៣. អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស

៤. អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រី

**ក. អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍** មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធនឹងការលើកកម្ពស់បរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍ រួមទាំងការធ្វើឌីជីថលូបនីយកម្មសេវា
- ដឹកនាំសម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធនឹងការលើកកម្ពស់បរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍
- សិក្សាស្រាវជ្រាវអំពីទស្សនាទាន និងការវិវត្តថ្មីៗនៃការផ្តល់សេវាសាធារណៈ ជាពិសេសការវិវត្តនៃឌីជីថលូបនីយកម្មសេវា
- វិភាគលើឯកសារ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងពិនិត្យអំពីលទ្ធភាពធ្វើបរិវត្តកម្មសេវាសាធារណៈមួយចំនួនទៅកម្រិតឌីជីថល
- សិក្សា និងរៀបចំដំណើរការការងារក្នុងការបង្កើតមជ្ឈមណ្ឌលសេវាក្រោមដំបូលតែមួយ
- ប្រមូលនិងចងក្រងទិន្នន័យដែលពាក់ព័ន្ធនឹងលទ្ធផលនៃការអនុវត្តស្តង់ដា

សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- វិភាគ វាយតម្លៃ ផ្តល់អនុសាសន៍ និងតាមដានការអនុវត្តស្តង់ដាសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- កសាងលិខិតបទដ្ឋានគតិយុត្តនិងជំរុញការអនុវត្តមូលនិធិនវានុវត្តន៍ ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំនិងនវានុវត្តន៍នៅក្នុងការផ្តល់សេវាសាធារណៈនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ. អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ** មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការជំរុញ ឧត្តមភាពសេវាសាធារណៈ
- កសាងកម្មវិធី និងផែនការសកម្មភាពសម្រាប់កែលម្អនិងជំរុញឧត្តមភាពសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំយន្តការនានា ដើម្បីគាំទ្រដល់ដំណើរការនៃការកែលម្អនិងការវាយតម្លៃសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលជំរុញ និងផ្តល់យោបល់ក្នុងការកែលម្អគុណភាពសេវាសាធារណៈដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាននិងត្រួតពិនិត្យការកែលម្អគុណភាពសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃ និងការទទួលស្គាល់ក្រសួង ស្ថាប័ន និងអង្គភាពផ្តល់សេវាសាធារណៈដែលមានស្នាដៃ
- រៀបចំប្រព័ន្ធវាយតម្លៃស្នាដៃផ្អែកលើសមិទ្ធកម្មរបស់មន្ត្រីម្នាក់ៗ ដែលបម្រើការងារក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- វាយតម្លៃនិងផ្តល់វិញ្ញាបនបត្រនិងពានរង្វាន់ជូនអង្គភាពផ្តល់សេវាសាធារណៈនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្នាដៃឆ្នើមក្នុងការ

កែលម្អគុណភាពសេវាសាធារណៈ

- រៀបចំ និងលើកសំណើបង្កើតយន្តការទទួលព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ
- ផ្ដល់យោបល់ផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពីការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ
- សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំកម្មវិធី និងលើកសំណើបណ្ដុះបណ្ដាលស្ដីពីសេវាសាធារណៈ
- រៀបចំបោះពុម្ពលិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងសេវាសាធារណៈ។

**គ. អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស** មានភារកិច្ចដូចខាងក្រោម៖

- សិក្សា និងជំរុញការរៀបចំក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងផែនការអភិវឌ្ឍន៍ស្ថាប័ន
- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការជ្រើសរើស និងការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងជំរុញការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ព្រមទាំងធ្វើការវាយតម្លៃនិងជំរុញការកែលម្អគុណភាពធនធានមនុស្ស
- រៀបចំកសាងកម្រងនីតិវិធី លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំស្ដីពីការគ្រប់គ្រងធនធានមនុស្សដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំផែនការមេស្ដីពីការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងរដ្ឋបាល

សាធារណៈ

- សិក្សាលទ្ធភាពនិងជំរុញការអនុវត្តការពង្រាយមន្ត្រីរាជការឱ្យស្របតាមតម្រូវការការងារ
- សិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយអំពីបទពិសោធន៍ និងការអនុវត្តល្អនៃការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន
- រៀបចំគោលនយោបាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរចនាសម្ព័ន្ធប្រព័ន្ធបៀវត្ស និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នក្នុងវិស័យសាធារណៈ
- ផ្តួចផ្តើមរៀបចំលើកសំណើ ដើម្បីដាក់ចេញគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អនុវត្តប្រព័ន្ធលាភការនិងសមិទ្ធកម្ម
- សិក្សា និងវិភាគរចនាសម្ព័ន្ធ ទំហំការងារ ចំនួនមន្ត្រីរាជការ និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ក្នុងវិស័យសាធារណៈនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កសាងឯកសារមូលដ្ឋានសម្រាប់ការវិភាគមុខងារ ការពិពណ៌នាមុខតំណែងមន្ត្រីរាជការ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដឹកនាំការពិភាក្សា និងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ពីគោលការណ៍និងវិធីសាស្ត្រ សម្រាប់ការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀតសម្រាប់កែទម្រង់ពាក់ព័ន្ធនឹងការចំណាយបន្ទុកបុគ្គលិកក្នុងវិស័យសាធារណៈ
- រៀបចំនិងកសាងឯកសារមូលដ្ឋានសម្រាប់ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រង

ផ្អែកលើសមិទ្ធកម្ម

- រៀបចំនិងដាក់ឱ្យអនុវត្តក្រមសីលធម៌របស់មន្ត្រីរាជការសាធារណៈ។

**ឃ. អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រី** មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាល ការកសាងសមត្ថភាពធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- កសាងយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីសម្រាប់ការបណ្ដុះបណ្ដាលអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការសាធារណៈក្នុងរយៈពេលមធ្យម និងរយៈពេលវែង
- សហការជាមួយស្ថាប័ន គ្រឹះស្ថានបណ្ដុះបណ្ដាលតាមបណ្ដាក្រសួង ស្ថាប័ននានា ដើម្បីរៀបចំផែនការ កម្មវិធី វគ្គសិក្សាជាប្រព័ន្ធរួមមួយដែលអាចឆ្លើយតបនឹងសំណូមពរ តម្រូវការក្នុងការលើកកម្ពស់សមត្ថភាពជំនាញ និងសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សិក្សា និងវិភាគពីតម្រូវការនៃការបណ្ដុះបណ្ដាលជំនាញដែលត្រូវការតាមក្រសួង ស្ថាប័នដើម្បីរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ដាក់ឱ្យអនុវត្ត
- សហការជាមួយស្ថាប័នគ្រឹះស្ថានបណ្ដុះបណ្ដាលតាមបណ្ដាក្រសួងស្ថាប័ននិងវិស័យឯកជន រួមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកអាហារូបករណ៍សម្រាប់ការបណ្ដុះបណ្ដាលរយៈពេលខ្លី មធ្យម និងវែង តាមមុខជំនាញជូនមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រវត្តិសមត្ថភាពការងារ សម្រាប់រៀបចំផែនការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការស៊ីវិលក្នុងមុខងារសាធារណៈ
- រៀបចំចងក្រងនិងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មាននៃការបណ្ដុះបណ្ដាលនិងរៀបចំយន្តការ សម្រាប់ការវាយតម្លៃប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល។

### ១.១.៣.៣. ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ

អនុលោមតាមព្រះរាជក្រឹត្យ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសា-ធារណៈតម្រូវឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីគាំទ្រ និងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ហើយសមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ស.**។

#### ក. ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន

អនុលោមតាមសេចក្តីសម្រេចលេខ ៦១៣៣/២៣ មស.សសរ ស្តីពីការកំណត់សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងក្របខ័ណ្ឌ ក្រសួង ស្ថាប័ន
- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះផ្តោតទៅលើ៖ (១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២) ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង (៣) ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- អនុវត្តការត្រួតពិនិត្យឡើងវិញ និងវិភាគមុខងាររបស់ក្រសួង ស្ថាប័ន
- រៀបចំ និងអភិវឌ្ឍកម្មវិធីពង្រាយមន្ត្រីរាជការ
- រៀបចំ និងអភិវឌ្ឍកម្មវិធីដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី និងស្ថាប័ន
- រៀបចំផែនការសកម្មភាពការងារកែទម្រង់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយបន្សុី

ទៅនឹងវិធានការគន្លឹះទាំងបីរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

- ចូលរួមកិច្ចប្រជុំទៀងទាត់ប្រចាំត្រីមាស និងផ្អែកតាមការចាំបាច់ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងវិធានការនានា បញ្ហាប្រឈម ដំណោះស្រាយ
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងស្ថាប័នស្តីពីវឌ្ឍនភាពការងារជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវផ្តល់របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តតួនាទី និងភារកិច្ចប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (នៅសប្តាហ៍ទី៣ នៃខែចុងក្រោយ) មកនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈមុនពេលដាក់ជូនប្រមុខរាជរដ្ឋាភិបាល។

### ខ. ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលរាជធានី ខេត្ត

អនុលោមតាមសេចក្តីសម្រេចលេខ ៦១៣៤/២៣ មស.សសរ ស្តីពីការកំណត់សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលរាជធានី ខេត្ត ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលរាជធានី ខេត្ត មានតួនាទី និងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ
- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះផ្តោតទៅលើ៖ (១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២) ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង(៣) ការរៀបចំប្រព័ន្ធ

លើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា
- អនុវត្តការត្រួតពិនិត្យឡើងវិញ និងវិភាគមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងអភិវឌ្ឍកម្មវិធីពង្រាយមន្ត្រីរាជការ
- រៀបចំ និងអភិវឌ្ឍកម្មវិធីដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី
- រៀបចំផែនការសកម្មភាពការងារកែទម្រង់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយបន្ស៊ីទៅនឹងវិធានការគន្លឹះទាំងបីរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ចូលរួមកិច្ចប្រជុំទៀងទាត់ប្រចាំត្រីមាសនិងផ្អែកតាមការចាំបាច់ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យវឌ្ឍនភាពការងារបញ្ហាប្រឈម ដំណោះស្រាយ និងវិធានការនានា។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ដល់របាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តតួនាទី និងភារកិច្ចប្រចាំត្រីមាស ឆមាស និងឆ្នាំ (នៅសប្ដាហ៍ទី៣នៃខែចុងក្រោយ) មកនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មុនពេលដាក់ជូនប្រមុខរាជរដ្ឋាភិបាល។

### ១.១.៣.៤. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**គ.ក.ស**. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីសម្របសម្រួលនិងគាំទ្រការងារប្រចាំថ្ងៃរបស់ គណៈកម្មាធិការ និងអនុគណៈកម្មាធិការនានា។

ផ្អែកតាមអនុក្រឹត្យលេខ ៣២៥ អនក្រ.បក ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋាន

**គ.ក.ស**. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គាំទ្រដល់ការអនុវត្តមុខងាររបស់អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍ អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស និងអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរបស់ **គ.ក.ស**.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំឯកសារ របាយការណ៍កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលការងារប្រចាំថ្ងៃនិងបំពេញការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងផ្នែកភ័ស្តុភារ ក្រោមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំគម្រោងសម្រាប់អនុវត្តការអប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន **គ.ក.ស**.
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ក.ស**. លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេសដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- សហការនិងសម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈតាមការចង្អុលបង្ហាញរបស់ **គ.ក.ស**.
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធ នៃកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

- ផ្សព្វផ្សាយអំពីគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព កម្មវិធី ព្រមទាំងសមិទ្ធផលនានា នៃការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជូន **គ.ក.ស.**។

**រចនាសម្ព័ន្ធនៃ គ.ក.ស.**




## **១.១.៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌**

កម្មវិធីកែទម្រង់ច្បាប់ និងតុលាការនៅកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ២០០៣ ដែលរាជរដ្ឋាភិបាលបានអនុម័តជាឯកសារផ្លូវការ "ការកែទម្រង់ច្បាប់ និងតុលាការ"។ រាជរដ្ឋាភិបាលបានអនុម័តនូវ "កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ច្បាប់ និងតុលាការ" នាឆ្នាំ២០០៥ ដែលបានកំណត់លម្អិតពីសកម្មភាពអាទិភាព ក្នុងការអនុវត្ត

ជំពូកទី១

ទាំងសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ ត្រូវបានបន្តចាត់ទុកជាមុំដ៏សំខាន់មួយនៃយុទ្ធសាស្ត្រជាតិ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ។

នៅឆ្នាំ២០១៣ ក្រសួងយុត្តិធម៌ទទួលខុសត្រូវដោយផ្ទាល់លើការងារកែទម្រង់ច្បាប់ និងតុលាការ និងបានកែសម្រួលជាគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានសម្រេចកែសម្រួលគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ត្រូវបានក្លាយជាស្ថាប័នពីរដាច់ដោយឡែក ដែលក្រសួងយុត្តិធម៌ផ្តោតសំខាន់តែលើការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងលើកកម្ពស់គោលការណ៍នីតិរដ្ឋ ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ សម្រាប់ប្រព័ន្ធតុលាការ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានសម្រេចធ្វើវិចារណកម្មរបស់គណៈ-កម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយបង្កើតជាស្ថាប័នពីរផ្សេងគ្នារួមមាន ១). គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធច្បាប់ ស្ថិតក្រោមការដឹកនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង ២).គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្ថិតក្រោមការដឹកនាំរបស់ក្រសួងយុត្តិធម៌។ យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលហៅកាត់ថា "**គ.ក.ប.យ.**" ជាយន្តការដឹកនាំ សម្រប-សម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងលើកកម្ពស់គោលការណ៍នីតិរដ្ឋ ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និងដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សហប្រធាន |
| ២. ប្រធានតុលាការកំពូល | សហប្រធាន |
| ៣. អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | អនុប្រធានទី១ |

| | | |
|---|---|---|
| ៤. តំណាងអង្គភាពប្រឆាំងអំពើពុករលួយ | ១រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | អនុប្រធានប្រចាំការ |
| ៦. អនុប្រធានតុលាការកំពូល | ១រូប | អនុប្រធាន |
| ៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ៩. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ១រូប | សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| ១៥. ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ | | សមាជិក |
| ១៦. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ | | សមាជិក |
| ១៧. តំណាងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | ១រូប | សមាជិក |
| ១៨. ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា | | សមាជិក |
| ១៩. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | | សមាជិក |
| ២០. ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា | | សមាជិក |
| ២១. អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ | | សមាជិក |

២២. តំណាងក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌
នៃក្រសួងយុត្តិធម៌ ១រូប សមាជិក
២៣. ប្រធានសាលាដំបូងរាជធានីភ្នំពេញ សមាជិក
២៤. ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ សមាជិក
២៥. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** សមាជិក

**គ.ក.ប.យ.** មានបេសកកម្មដូចតទៅៈ

- ផ្តួចផ្តើម និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច លើផែនការយុទ្ធសាស្រ្ត កែទម្រង់ប្រព័ន្ធយុត្តិធម៌ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិធានការចាំបាច់នានាសំដៅជានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- ដាក់ចេញនូវសេចក្តីណែនាំនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យយុត្តិធម៌
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីជំរុញនិងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- លើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចលើប្រព័ន្ធលើកទឹកចិត្តសម្រាប់គាំទ្រដល់ការអនុវត្តការងារ កែទម្រង់ប្រព័ន្ធយុត្តិធម៌ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងលើកសំណើវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌

- អនុវត្តការងារផ្សេងទៀតពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌។

ផ្អែកតាមអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ មានតួនាទីជាសេនាធិការឱ្យ **គ.ក.ប.យ.** និងមានតួនាទី និងភារកិច្ច ដូចតទៅៈ

- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ប.យ.** ពិនិត្យ និងសម្រេច
- សហការ សម្របសម្រួល និងផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសតាមការចាំបាច់ ដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌តាមការចង្អុលបង្ហាញរបស់ **គ.ក.ប.យ.**
- រៀបចំសេចក្តីព្រាងសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ប.យ.** ពិនិត្យ និងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន **គ.ក.ប.យ.** លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានា ដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាលជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិលើការងារពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធយុត្តិធម៌

- រៀបចំចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសមិទ្ធផលនានានៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំផែនការយុទ្ធសាស្រ្តថវិកា និងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដំណើរការការងាររបស់ **គ.ក.ប.យ.** និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំសេចក្តីព្រាងប្រព័ន្ធលើកទឹកចិត្ត ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាពក្នុងការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌។

អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** មាននាយកដ្ឋានចំណុះចំនួនបី រួមមាន៖

១. នាយកដ្ឋានកិច្ចការទូទៅ

២. នាយកដ្ឋានកិច្ចការកែទម្រង់

៣. នាយកដ្ឋានកិច្ចសហប្រតិបត្តិការ

**អង្គការលេខនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌**




## ១.១.៥. កម្មវិធីកែទម្រង់ច្បាប់

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ( **គ.ក.ច.** ) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធី

នយោបាយរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងដើម្បីពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃច្បាប់។ ក្នុងន័យនេះ **គ.ក.ច.** មានបេសកកម្មសំខាន់ពាក់ព័ន្ធនឹង, ១). ការដឹកនាំ គាំទ្រ សម្របសម្រួល និងជំរុញការអនុវត្តការកែទម្រង់ច្បាប់, ២). ការផ្តួចផ្តើមនិងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចលើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពកែទម្រង់ច្បាប់ ផ្អែកលើគោល-នយោបាយរបស់រាជរដ្ឋាភិបាល, ៣). ការលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចលើប្រព័ន្ធលើកទឹកចិត្តសម្រាប់ការគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់ ប្រកបដោយគុណភាព សង្គតិភាព និងប្រសិទ្ធភាព, ៤). ការរៀបចំគោលការណ៍ណែនាំដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាព ក្នុងការតាក់តែងនិងផ្តល់យោបល់លើការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតសំដៅធានាបាននូវប្រសិទ្ធភាព សក្តិសិទ្ធិភាព សង្គតិភាព និងភាពសមស្របតាមការវិវត្តនៃសេដ្ឋកិច្ច សង្គម និងដាក់ចេញសេចក្តីណែនាំនិងវិធានការចាំបាច់នានា សំដៅធានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃការងារកែទម្រង់ច្បាប់, ៥). ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ច្បាប់, ៦). ការសម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិនានាដើម្បីជំរុញនិងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់, ៧). ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និង ៨).ការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមគ្រប់មធ្យោបាយ ការផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពនិងសមិទ្ធផលនានានៃការកែទម្រង់ច្បាប់ និងការធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់ច្បាប់ និងលើកសំណើវិធានការចាំបាច់នានាដើម្បីដោះស្រាយបញ្ហាប្រឈមជូនប្រមុខរាជរដ្ឋាភិបាល។ សមាសភាពនៃ **គ.ក.ច.** រួមមាន៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២. ឥស្សរជនជាន់ខ្ពស់ | ជាអនុប្រធាន |

៣. រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ជាអនុប្រធានប្រចាំការ
៤. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាអនុប្រធាន
៥. អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាអនុប្រធាន
៦. រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន២៨ ជាសមាជិក
៧. អគ្គលេខាធិការ **គ.ក.ច.** ជាសមាជិក។

ដើម្បីជានាគាំទ្រដល់កិច្ចដំណើរការការងាររបស់ខ្លួន **គ.ក.ច.** មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ ដែលហៅកាត់ថា អគ្គលេខាធិការដ្ឋាន **គ.ក.ច.**។ លើសពីនេះដើម្បីជួយដល់ការងាររបស់ខ្លួន **គ.ក.ច.** មានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់ និងអាចបង្កើតគណៈកម្មការនិងក្រុមការងារជំនាញមួយចំនួនសម្រាប់ជួយដល់ការងាររបស់ខ្លួន។ ក្នុងនោះផងដែរ តាមរយៈព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួនដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការងារកែទម្រង់ច្បាប់។

### ១.១.៥.១. គណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ

អនុលោមតាមមាត្រា៨នៃព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ **គ.ក.ច.** អាចបង្កើតគណៈកម្មការជំនាញតាមវិស័យ ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ក.ច.** ដែលក្នុងនោះគណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ ចំនួន ៤ ត្រូវរៀបចំបង្កើតឡើងដូចខាងក្រោម៖

១. **គណៈកម្មការទទួលបន្ទុកវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា៖** សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងរ៉ែនិងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម

វប្បធម៌ ប្រមាញ់ និងនេសាទ, ក្រសួងទេសចរណ៍, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងផែនការ, ក្រសួងអភិវឌ្ឍជនបទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

២. **គណៈកម្មការទទួលបន្ទុកវិស័យរដ្ឋបាលសាធារណៈ និងនីតិអន្តរជាតិ៖** សម្រប-សម្រួលជាមួយក្រសួងមុខងារសាធារណៈ, ក្រសួងអធិការកិច្ច, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋលេខាធិការដ្ឋានទទួលបន្ទុកកិច្ចការព្រំដែន។

៣. **គណៈកម្មការទទួលបន្ទុកវិស័យសង្គមកិច្ច វប្បធម៌ និងបរិស្ថាន៖** សម្របសម្រួលជាមួយក្រសួងអប់រំយុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងធម្មការនិងសាសនា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងព័ត៌មាន, ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។

៤. **គណៈកម្មការទទួលបន្ទុកវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការពារជាតិ៖** ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។

### ១.១.៥.២. ក្រុមការងារកែទម្រង់ច្បាប់តាមក្រសួង ស្ថាប័ន

អនុលោមតាមមាត្រា៩នៃព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួនដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការងារកែទម្រង់ច្បាប់ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

### ១.១.៥.៣. យន្តការស្ថាប័នអន្តរវិស័យ

យន្តការស្ថាប័នអន្តរវិស័យមួយចំនួនទៀត អាចត្រូវបានរៀបចំបង្កើតឡើងសម្រាប់គាំទ្រការអនុវត្តវិធានការយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖

១. គណៈកម្មការជាតិការពារនីត្យានុកូលភាព

២. គណៈកម្មការជាតិភាសាច្បាប់។

### ១.១.៥.៤. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ដែលមានតួនាទីជាសេនាធិការឱ្យ **គ.ក.ច**. និងមានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព សម្រាប់ការងារកែទម្រង់ច្បាប់ កម្មវិធីសកម្មភាពសម្រាប់អនុវត្តបញ្ជីបច្ចុប្បន្នកម្មនៃកម្មវិធីកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពកែទម្រង់ច្បាប់ ដើម្បីដាក់ជូន **គ.ក.ច**. ពិនិត្យនិងសម្រេច
- កំណត់អាទិភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលលែងឆ្លើយតបនឹងវឌ្ឍនភាព សេដ្ឋកិច្ច សង្គម ដើម្បីធ្វើវិសោធនកម្ម ឬកែសម្រួល ឬរៀបចំថ្មី
- រៀបចំយន្តការជូន **គ.ក.ច**. ក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សានិងប្រឹក្សាលើតម្រូវការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បគាំទ្រដល់គោលនយោបាយនិងច្បាប់នានា
- ផ្ដល់ការប្រឹក្សាលើអនុលោមភាព សន្តិសុខគតិយុត្ត សង្គតិភាព ចីរភាព និងសាមញ្ញភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- ផ្ដល់យោបល់និងលើកសំណើដំណោះស្រាយជូន **គ.ក.ច**. លើបញ្ហាប្រឈមនិងបញ្ហាបច្ចេកទេសនានាដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់ច្បាប់
- លើកសំណើអំពីដំណោះស្រាយដើម្បីកែលម្អច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ផ្សេងទៀតដែលអាចនិរាករណ៍ ឬធ្វើវិសោធនកម្ម និងដំណោះស្រាយវិវាទនៃការបកស្រាយច្បាប់ ដើម្បីជានាសន្តិសុខគតិយុត្ត និងសុខដុមនីយកម្មគតិយុត្ត

- សហការ សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍និងអង្គការជាតិ និងអន្តរជាតិ និងផ្តល់ការគាំទ្រនិងជំនួយបច្ចេកទេសតាមការចាំបាច់ដល់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការនានាពាក់ព័ន្ធនឹងការរៀបចំនិងការអនុវត្តផែនការសកម្មភាពកែទម្រង់ច្បាប់ តាមការសម្រេចរបស់ **គ.ក.ច.**
- សម្របសម្រួលការងារជាមួយអង្គភាពដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រៀបចំបទដ្ឋានឬស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ក្រសួង ស្ថាប័ន ក្នុងការតាមដានត្រួតពិនិត្យ វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដាក់ជូន **គ.ក.ច.** ពិនិត្យនិងសម្រេច
- រៀបចំប្រព័ន្ធឌីជីថលូបនីយកម្ម និងរៀបចំ ចងក្រង បោះពុម្ពផ្សាយ និងផ្សព្វផ្សាយកម្រង ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានិងព័ត៌មាន សកម្មភាព និងសមិទ្ធផលនៃការងារកែទម្រង់ច្បាប់
- សម្របសម្រួលនិងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **គ.ក.ច.**
- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ និងការងារបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.**
- រៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់គាំទ្រដំណើរការងាររបស់ **គ.ក.ច.** និងរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់
- រៀបចំសេចក្តីព្រាងប្រព័ន្ធលើកទឹកចិត្តប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព

និងចីរភាព ក្នុងការអនុវត្តការកែទម្រង់ច្បាប់
- លើកគម្រោងការងារបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្ស
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ច្បាប់ និងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **គ.ក.ច.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **គ.ក.ច.**។

អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មាននាយកដ្ឋានចំនួន ៤ ត្រូវបានបង្កើតរួមមាន៖

១. នាយកដ្ឋានគោលនយោបាយនិងផែនការ

២. នាយកដ្ឋានប្រឹក្សាច្បាប់និងតាមដានការអនុវត្តច្បាប់

៣. នាយកដ្ឋានផ្សព្វផ្សាយទំនាក់ទំនងសាធារណៈនិងកិច្ចសហប្រតិបត្តិការ

៤. នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច។

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**



## ១.២. សមិទ្ធផល

### ១.២.១. សមិទ្ធផលនិងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់នីមួយៗ

#### ១.២.១.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

#### ក. សមិទ្ធផលតាមដំណាក់កាល

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងស្មារតីប្រកាន់ខ្ជាប់ទៅតាមអភិក្រមជាខឿន (Platform Approach) ដោយបែងចែកជាបួនខឿនឬដំណាក់កាលតាមក្របខ័ណ្ឌពេលវេលាជាក់លាក់ ដូចខាងក្រោម៖

- ដំណាក់កាលទី១ "**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**" ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ និងបានផ្តល់អាទិភាពបន្ទាន់លើវិន័យថវិកា ដែលផ្តោតលើការពង្រឹងការប្រមូលនិងគ្រប់គ្រងចំណូល, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានកំណត់និងដាក់ចេញវិធានការជាច្រើន ដែលនាំឱ្យរាជរដ្ឋាភិបាលសម្រេចដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ កង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការលទ្ធកម្មសាធារណៈ។
- ដំណាក់កាលទី២ "**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**" ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដែលមានគោលដៅចម្បងលើការរៀបចំការកែលម្អការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដាអន្តរជាតិ។ ជាលទ្ធផល គណនីទោលរតនាគារ (TSA) ត្រូវបានរៀបចំនិងអនុវត្ត, មូលដ្ឋានគ្រឹះនៃគណនេយ្យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានរៀបចំនិងកសាងឡើងតាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ស្តង់ដាគណ-

ជំពូកទី១

នេយ្យនិងប្លង់គណនីថ្មី អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមនឹងការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលជា **"ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល"** ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និងពិនិត្យតាមដាន, កែលម្អចំណាត់ថ្នាក់ថវិកា វាយតម្លៃ ប្រមូលផ្ដុំ និងផ្ទៀងផ្ទាត់ និងវិភាគសម្រាប់ការរៀបចំផែនការ ការរៀបចំថវិកា ការធ្វើសេចក្ដីសម្រេចចិត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។

- ដំណាក់កាលទី៣ **"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដែលចាប់ផ្ដើមកែទម្រង់លើប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមធ្យោបាយ ឆ្ពោះទៅកាន់ប្រព័ន្ធដែលផ្ដោតលើលទ្ធផលសមិទ្ធកម្ម និងវិមធ្យោបាយ។ ដំណាក់កាលនេះ ផ្ដោតអាទិភាពយ៉ាងសំខាន់លើការអនុវត្តប្រព័ន្ធថវិកាកម្មវិធី ការបង្កើតអង្គភាពថវិកា និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលជាគន្លឹះក្នុងការផ្សារភ្ជាប់រវាងគោលនយោបាយវិស័យ និងអនុវិស័យរបស់ក្រសួង ស្ថាប័នទៅនឹងគោលនយោបាយនៃរាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលនេះផងដែរ ឯកសារយុទ្ធសាស្ត្រគន្លឹះមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តក្នុងគោលបំណងកំណត់អាទិភាពកែទម្រង់ជាយុទ្ធសាស្ត្រទៅតាមការដ្ឋានកែទម្រង់សំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន៖ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, និងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥។
- ដំណាក់កាលទី៤ **"គណនេយ្យភាពសមិទ្ធកម្ម"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០២៣

មក និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៧ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានគោលដៅសំខាន់មួយគឺ **"ការកសាងប្រព័ន្ធគណនេយ្យភាពសមិទ្ធកម្ម"** ដែលមានឧបករណ៍គាំទ្រដ៏សំខាន់នោះគឺ **"ថវិកាព័ត៌មានសមិទ្ធកម្ម"**។ ជាវឌ្ឍនភាពគន្លឹះ, បទដ្ឋានគតិយុត្តសំខាន់ៗ និងយន្តការកសាងប្រព័ន្ធគណនេយ្យភាពផ្សារភ្ជាប់នឹងសមិទ្ធកម្ម ត្រូវបានកសាងរួមមាន ការដាក់ឱ្យអនុវត្តនូវច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ និងការអនុវត្តយន្តការកិច្ច-ព្រមព្រៀងសមិទ្ធកម្ម និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម នៅតាមក្រសួង ស្ថាប័ន។

## ខ. សមិទ្ធផលគន្លឹះលម្អិត

**ទី១).** ការអនុវត្តចំណូលៈ នៅក្នុងឆ្នាំ២០២៤ ចំណូលថវិការដ្ឋសរុប (ចំណូលចរន្ត និង ចំណូលផ្សេងៗ) ប្រមូលបានប្រមាណ ២៨ ៣៥៨ ប៊ីលានរៀល សមមូលនឹងប្រមាណ ៧ ០០២ លានដុល្លារអាមេរិក (៨៩,៤០% ធៀបនឹងច្បាប់ថវិកា)។ ចំណូលថវិការដ្ឋសរុបនេះផ្សំឡើងពីចំណូលពន្ធគយ និងរដ្ឋាករ មានប្រមាណ ៣៦,៨៤%, ចំណូលពន្ធដារមានប្រមាណ ៤២,៥៩%, ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិមានប្រមាណ ១១,២៦%, ចំណូលផ្សេងៗ (ថ្នាក់ជាតិ) មានប្រមាណ ១,៣៩% និងចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិប្រមាណ ៧,៩២%។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ប្រមូលបានប្រមាណ ១០ ៤៤៨ ប៊ីលានរៀល សមមូលនឹងប្រមាណ ២ ៥៨០ លានដុល្លារអាមេរិក (៩៣,៩៧% ធៀបនឹងច្បាប់ថវិកា)។ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលបានប្រមាណ ១២ ០៧៧ ប៊ីលានរៀល ឬសមមូលនឹង ២ ៩៨២ លានដុល្លារអាមេរិក (៨២,៤៨% ធៀបនឹងច្បាប់ថវិកា)។ ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ ប្រមូលបានប្រមាណ ៣ ១៩២ ប៊ីលានរៀល សមមូលនឹងប្រមាណ ៧៨៨ លានដុល្លារអាមេរិក (១០៣,៧៤% ធៀបនឹងច្បាប់ថវិកា)។ ចំណូលផ្សេងៗ ប្រមូលបាន ៣៩៥ ប៊ីលានរៀល សមមូលនឹងប្រមាណ ៩៧ លានដុល្លារអាមេរិក

(៩១,៦៤% ធៀបនឹងច្បាប់ ថវិកា)។ ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត) ប្រមូលបាន ២ ២៤៧ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥៥៥ លានដុល្លារអាមេរិក (៩១,៥៨% ធៀបនឹងច្បាប់)។

**ទី២)**. ការអនុវត្តចំណាយ៖ ចំណាយថវិការដ្ឋក្នុងឆ្នាំ២០២៤ សម្រេចបាន ២៧ ៤៥៤ ប៊ីលានរៀល សមមូលនឹងប្រមាណ ៦ ៧៧៩ លានដុល្លារអាមេរិក (៨៨,៣៨% ធៀបនឹងច្បាប់ ឬ ៩៥,៤៦ ធៀបនឹងឥណទានក្រោយវិចារណកម្ម) ដែលរួមផ្សំដោយចំណាយបៀវត្សរ៍ ៣៩,៩៥%, ចំណាយទំនិញ-សេវា ១៩,៣០%, ចំណាយមូលធន១៦,៣៦%, និង ចំណាយផ្សេងៗ ២៤,៣៩%។ ចំណាយបៀវត្សរ៍សម្រេចបាន ១០ ៩៦៨ ប៊ីលានរៀល សមមូលនឹងប្រមាណ ២ ៧០៨ លានដុល្លារអាមេរិក (៩៧,៨២% ធៀបនឹងច្បាប់), ចំណាយទំនិញ-សេវា សម្រេចបានប្រមាណ ៥ ២៩៧ ប៊ីលានរៀល សមមូលនឹង ១ ៣០៨ លានដុល្លារអាមេរិក (៩៩,៦៣% ធៀបនឹងច្បាប់ ឬ១០២,៤៧% ធៀបឥណទានក្រោយវិចារណកម្ម), និងចំណាយមូលធនសម្រេចបាន ៤ ៤៩២ ប៊ីលានរៀល សមមូលនឹងប្រមាណ ១ ១០៩ លានដុល្លារអាមេរិក (៨១,១១% ធៀបនឹងច្បាប់ ឬ ១០១,៧០% ធៀបឥណទានក្រោយវិចារណកម្ម)។

**ទី៣)**. ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ៖ គណនីទោលរតនាគារជាតិ (Treasury Single Account-TSA) ត្រូវបានដាក់ឱ្យអនុវត្តនិងធ្វើឱ្យរាជរដ្ឋាភិបាលអាចតាមដានសមតុល្យសាច់ប្រាក់បានជាប្រចាំថ្ងៃ។ ចំណាត់ថ្នាក់ថវិកា និងប្លង់គណនី ត្រូវបានធ្វើបច្ចុប្បន្នភាព និងជំរុញដាក់ឱ្យអនុវត្តពេញលេញ។ បំណុលកកស្ទះគិតត្រឹម ៦០ថ្ងៃ ត្រូវបានដោះស្រាយទាំងស្រុង រីឯរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំនិងមានអនុលោមភាពទៅតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ ផ្អែកលើមូលដ្ឋានសាច់ប្រាក់ (IPSAS Cash Basis)។ បន្ថែមពីនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្តដល់គ្រប់ក្រសួង ស្ថាប័ន លើមុខងារស្នូលចំនួន ៦ រួមមាន (១) ម៉ូឌុលវិភាជន៍ថវិកា (២) ម៉ូឌុលគណនីត្រូវសង (៣) ម៉ូឌុលគណនីត្រូវទារ (៤) ម៉ូឌុល

គ្រប់គ្រងសាច់ប្រាក់ (៥) ម៉ូឌុលការទិញ និង (៦) ម៉ូឌុលសៀវភៅធំ។ មុខងារពីរបន្ថែម គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម ដាក់ឱ្យសាកល្បងជាបន្តបន្ទាប់នៅតាមក្រសួង ស្ថាប័ន។ ជាមួយគ្នានេះ នីតិវិធីចំណាយថវិកាចរន្ត និងនីតិវិធីចលនាឥណទានថវិកា ត្រូវបានអនុវត្តជាជំហានៗដោយក្រសួង ស្ថាប័ន (ដែលគិតត្រឹមឆ្នាំ២០២៤ មាន ១៨ ក្រសួង ស្ថាប័ន បានអនុវត្តពេញលេញ)។

FMIS ក៏ត្រូវបានរៀបចំដាក់ឱ្យអនុវត្តនូវរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ FMIS Portal V1 ត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ រីឯមុខងារស្នូលនៃ FMIS ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តជាបណ្ដើរនៅកម្រិតរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ទី៤)**. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ៖ ក្របខ័ណ្ឌគតិយុត្តដ៏សំខាន់ចំនួន ២ ត្រូវបានរៀបចំឡើងជាលើកដំបូង គឺ១). ច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានដាក់ឱ្យអនុវត្តតាមរយៈព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ និង២). ច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានដាក់ឱ្យអនុវត្តតាមរយៈព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។ បន្ថែមពីនេះ គោលនយោបាយកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនិងទ្រព្យសម្បត្តិត្រូវបានសិក្សានិងគិតគូរជាក្របខ័ណ្ឌរយៈពេលវែង ដែលនឹងត្រូវកំណត់ក្នុង ឯកសារគោលស្ដីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនិងឯកសារគោលស្ដីពីការកែទម្រង់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលនឹងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២៥ តទៅ។

ក្នុងទិដ្ឋភាពទំនើបកម្មការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនិងទ្រព្យសម្បត្តិរដ្ឋ, ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងមុខងារ e-Payment ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នប្រមូលចំណូល និងរដ្ឋបាលរាជធានី ខេត្ត ក៏ដូចជាត្រៀមគិតគូរបន្តការអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ត្រឹមឆ្នាំ២០២៧ ខាងមុខ។ រីឯប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក៏ត្រូវ

បានដាក់ឱ្យអនុវត្តនៅតាមគ្រប់អង្គភាពកាន់កាប់ទ្រព្យសម្បត្តិនៅកម្រិតក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត និងឈានដល់ការអនុវត្តនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នៅឆ្នាំ២០២៦ តទៅផងដែរ។

**ទី៥)**. ការកែលម្អប្រព័ន្ធថវិកា៖ ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តនៅតាមគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ គិតត្រឹមឆ្នាំ២០២៤ អង្គភាពថវិកាមានចំនួនសរុប ៩៣៩ ដែលក្នុងនោះរដ្ឋបាលកណ្តាលមានចំនួន ៣៣៦ និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញ រាជធានី ខេត្ត) ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាល អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ មានចំនួន១២០និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាសុទ្ធតែជាអាណាប័កផ្ទេរសិទ្ធិ។ ក្នុងការឈានទៅកាន់ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម (MTFF), ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) និងផែនការយុទ្ធសាស្ត្រ ថវិការបស់ក្រសួង ស្ថាប័ន (BSP) ត្រូវបានរៀបចំ ដាក់ឱ្យអនុវត្តនិងបានផ្សារភ្ជាប់ជាបណ្តើរៗ ជាមួយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ បច្ចុប្បន្ន ក្របខ័ណ្ឌថវិការយៈពេលមធ្យមដែលកំណត់ ពិដានថវិកាតាមវិស័យ និងក្រសួង ស្ថាប័ន ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី និងបាន ក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំថវិការបស់ក្រសួង ស្ថាប័ន។ លើសពីនេះ គោលការណ៍ ណែនាំស្តីពីការតាមដាននិងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត តាមរយៈប្រកាសលេខ ១១៣ សហវ.ប្រក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២។ គិតត្រឹម ឆ្នាំ២០២៤ គ្រប់ក្រសួង ស្ថាប័នត្រូវបានអនុវត្តសាកល្បងនូវថវិកាសមិទ្ធកម្ម ដែលបាន រៀបចំនូវកិច្ចព្រមព្រៀងសមិទ្ធកម្ម ដែលកិច្ចព្រមព្រៀងសមិទ្ធកម្មអនុវត្ត ៣ កម្រិត គឺ៖ ទី១) រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងក្រសួង ស្ថាប័នសាមី, ទី២) រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ននឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង ស្ថាប័នសាមី និងទី៣) រវាងអ្នកគ្រប់គ្រង កម្មវិធីនឹងប្រធានអង្គភាពថវិកា។

**ទី៦)**. ការពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈ៖ យុទ្ធសាស្ត្រស្តីពីការកែទម្រង់

ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត ក្នុងគោលបំណងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួមមួយរបស់ជាតិ សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងពង្រឹងសមត្ថភាពប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះមានវិសាលភាពគ្របដណ្តប់លើគ្រប់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន រួមមាន៖ ថវិកាជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជននិងនៅគ្រប់កម្រិតរដ្ឋបាល ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល។ ជាលទ្ធផល ក្របខ័ណ្ឌគតិយុត្តគន្លឹះចំនួន ៣ ត្រូវបានរៀបចំ រួមមាន៖ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលត្រូវឱ្យដាក់ឱ្យប្រើប្រាស់តាមរយៈព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, និងអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល។ បន្ថែមពីនេះ គណៈកម្មការវិនិយោគសាធារណៈ និងលេខាធិការដ្ឋាន ត្រូវបានបង្កើតឡើងដើម្បីដើរតួជាទ្វារបាលលើការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ជាទិសដៅ គោលការណ៍ណែនាំលម្អិតស្តីពីកម្មវិធីវិនិយោគសាធារណៈនិងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈបាននឹងកំពុងសិក្សានិងធ្វើបច្ចុប្បន្នកម្ម។

**ទី៧)**. ការគ្រប់គ្រងបំណុលសាធារណៈ៖ ស្ថានភាពនៃបំណុលសាធារណៈកម្ពុជាត្រូវបានវាយតម្លៃថាមាន **"ចីរភាព"** និង **"ហានិភ័យកម្រិតទាប"** ដែលពិដាននៃការខ្ចីប្រចាំឆ្នាំត្រូវបានរក្សានិងអនុវត្តទៅតាមគោលការណ៍គន្លឹះទាំង ៥ ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨។ គិតត្រឹមឆ្នាំ២០២៤, រាល់សូចនាករគន្លឹះទាំងអស់សុទ្ធតែស្ថិតនៅក្រោមអនុបាតគោលក្នុងនោះ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈធៀបនឹងផសស មានកម្រិត ១៩,៣% ធៀបនឹងអនុបាតគោល

ជំពូកទី១

៥៥% និងអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងផសស មានត្រឹមកម្រិត ១៩% ធៀបនឹងអនុបាតគោល ៤០%។ បន្ថែមពីនេះ មូលបត្ររដ្ឋត្រូវបានបោះផ្សាយជាលើកដំបូងក្នុងឆ្នាំ២០២២ ក្នុងទំហំ ៣០០ លានដុល្លារអាមេរិក ក្នុងគោលបំណងកៀរគរហិរញ្ញប្បទានបន្ថែមដើម្បីគាំទ្រគម្រោងវិនិយោគសាធារណៈ ហើយក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានបោះផ្សាយមូលបត្ររដ្ឋក្នុងទំហំទឹកប្រាក់ប្រមាណ ៣០១,៣០ ប៊ីលានរៀល ស្មើនឹង ៦៨%នៃទំហំសរុបសុំការអនុញ្ញាតក្នុងឆ្នាំ២០២៤។

**ទី៨)**. ការកែទម្រង់ប្រព័ន្ធថវិកានៅថ្នាក់ក្រោមជាតិ៖ ប្រព័ន្ធថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបាននិងកំពុងកែលម្អ ក្នុងទិដ្ឋភាព ៣ រួមមាន ការកសាងក្របខ័ណ្ឌរយៈពេលមធ្យម, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, សមាហរណកម្មថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, និងការបង្កើនធនធានថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង ក្របខ័ណ្ឌថវិការយៈពេលមធ្យម (Medium Term Budget Framework - MTBF) ឆ្នាំ២០២៥-២០២៧ ត្រូវបានរៀបចំរួចរាល់ក្នុងឆ្នាំ២០២៤ និងត្រូវបានសម្រេចដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៥, រីឯថវិការបស់រដ្ឋបាលរាជធានី ខេត្តទាំង ២៥ ត្រូវបានរៀបចំនិងអនុវត្តក្នុងទម្រង់ជាថវិកាកម្មវិធី និងបានតម្រឹមជាបណ្ដើរៗជាមួយនឹងថវិការបស់មន្ទីរជំនាញ ក៏ដូចជាថវិកាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផងដែរ។ រីឯ ទំហំធនធានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើនជាប្រចាំតាមរយៈយន្តការសំខាន់ៗដូចជា ការបង្កើនអត្រាវិភាជន៍ប្រចាំឆ្នាំដល់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់, យន្តការបែងចែកចំណូលសារពើពន្ធរបស់រាជធានី ខេត្ត ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់, ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងការត្រៀមគិតគូរនូវមូលនិធិភាតរភាព សម្រាប់ឆ្នាំ២០២៧ ខាងមុខ ផងដែរ។

**ទី៩)**. មុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច៖ បទដ្ឋានគតិយុត្តគន្លឹះមួយត្រូវបានរៀបចំឡើងដើម្បីបញ្ចៀសការអនុវត្តស្ទួនគ្នានៃមុខងារទាំងពីរ ពោលគឺអនុក្រឹត្យលេខ

១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្ដីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច។ លើសពីនេះ ការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដា ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈត្រូវបានរៀបចំកែសម្រួលដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។ នៅថ្នាក់ក្រោមជាតិ អង្គភាពសវនកម្មផ្ទៃក្នុងនឹងត្រូវបង្កើតឡើងនៅក្នុងរដ្ឋបាលរាជធានី ខេត្ត អនុលោមតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥។

សមិទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកែប្រែជាបណ្ដើរៗនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងមូលស្របតាមស្តង់ដាអន្តរជាតិ។ ស្ថានភាពកង្វះសាច់ប្រាក់ ត្រូវបានដោះស្រាយទាំងស្រុង ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពសន្សំប្រាក់បម្រុង ដើម្បីអនុវត្តវិធានការគោលនយោបាយបន្ទាន់និងតាមការចាំបាច់នានា។ ដាក់ស្ដែងការតម្លើងបៀវត្សដល់មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ត្រូវបានផ្ដល់ជូនជារៀងរាល់ឆ្នាំក្នុងអត្រា ៧ ភាគរយ រហូតដល់ឆ្នាំ២០១៩ មុននឹងការមកដល់នៃវិបត្តិកូវីដ-១៩។ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់កូវីដ-១៩ វិធានការពង្រឹងភាពស៊ាំក្នុងសហគមន៍ត្រូវបានអនុវត្តដោយការបញ្ជាទិញនិងប្រើប្រាស់វ៉ាក់សាំងដើម្បីការពារអាយុជីវិតប្រជាជនកម្ពុជា រាជរដ្ឋាភិបាលក៏មានលទ្ធភាពក្នុងអនុវត្តវិធានការអន្តរាគមន៍រក្សាលំនឹងជីវភាពប្រជាជននិងវិធានការរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនផងដែរ តាមរយៈការដាក់ឱ្យអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ និងការអនុគ្រោះផ្នែកពន្ធដល់ប្រតិបត្តិករក្នុងវិស័យទេសចរណ៍និងអាកាសចរណ៍ដល់ចុងឆ្នាំ២០២២។

**គ. បញ្ហាប្រឈម**

ទោះបីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានវឌ្ឍនភាពនិងសមិទ្ធផលដូចបានគូសបញ្ជាក់ខាងលើក្ដី ចំណុចប្រឈមមួយចំនួនទាមទារការបន្តយកចិត្តទុកដាក់

ដោះស្រាយ ដើម្បីសម្រេចជាសារវន្តនូវមូលដ្ឋានគន្លឹះឈានឆ្ពោះទៅការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មប្រកបដោយជោគជ័យ ដែលមានដូចតទៅ៖

**ទី១)**. ការកៀរគរចំណូលទទួលរងផលប៉ះពាល់ដោយកំណើនជាបន្តបន្ទាប់ទាំងវិសាលភាពនិងភាពស៊ីជម្រៅ នៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងភាពមិនប្រាកដប្រជានៃកំណើនសេដ្ឋកិច្ចសកល ជាមួយនឹងភាពបែកខ្ញែកនៃភូមិសាស្ត្រនយោបាយ

**ទី២)**. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទោះបីជាសម្រេចបានជាសារវន្ត ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ប៉ុន្តែនៅមិនទាន់អាចផលិតបាននូវរបាយការណ៍ឱ្យបានគ្រប់ជ្រុងជ្រោយ និង មិនទាន់បានធ្វើស្វ័យប្រវត្តិកម្មលើការអនុវត្តថវិកាពេញលេញនៅឡើយ មានន័យថា ការអនុវត្តថវិកានៅត្រូវប្រើក្រដាសស្នាមផងនិងប្រើ FMIS ផង ហើយនីតិវិធីមួយចំនួនមានលក្ខណៈជាន់គ្នា។ ម្យ៉ាងវិញការសន្ទានកម្មទិន្នន័យនៃ FMIS ទៅនឹងប្រព័ន្ធផ្សេងទៀត ជាពិសេស SARMIS នៅជាចំណុចប្រឈម ដែលទាមទារឱ្យមានការគិតគូរឱ្យបានគត់មត់ក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**ទី៣)**. ការអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកាពិតមែនតែត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ ប៉ុន្តែគុណភាពនៃកម្មវិធីចាំបាច់ត្រូវកែសម្រួល ទាំងខ្លឹមសារទាំងរចនាសម្ព័ន្ធ និងទាំងសមិទ្ធកម្ម។ លើសពីនេះ ការរៀបចំកម្មវិធីរបស់ក្រសួង ស្ថាប័នមួយចំនួននៅចំណុះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ដែលធ្វើឱ្យមានការលំបាកខ្លះក្នុងការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ ក៏ដូចជាការផ្សារភ្ជាប់កម្មវិធីទៅនឹងការអនុវត្តជាក់ស្តែង។ ម្យ៉ាងទៀត ក្រសួង ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ក៏មានតិចតួចដែរ

**ទី៤)**. នីតិវិធីនៃការអនុវត្តថវិកាត្រូវបានពន្លឿនច្រើន ប៉ុន្តែនៅមិនទាន់អាចធានាបាន

នូវភាពធាប់រហ័ស ភាពត្រឹមត្រូវ និងភាពអាចប៉ាន់ប្រមាណបាន តាមការរំពឹងទុកនៅឡើយ។ ការងារនេះមិនមែនជាការងារដាច់ដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏ជាការងារផ្ទាល់របស់ក្រសួង ស្ថាប័នផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលមួយចំនួនហើយលើបញ្ហានេះ ក៏ប៉ុន្តែក្រសួង ស្ថាប័នសាមី ក៏ត្រូវខិតខំកាត់បន្ថយនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លាភាពផ្ទៃក្នុងរបស់ខ្លួនផងដែរ

**ទី៥).** ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតែជាបញ្ហាប្រឈមដ៏សំខាន់ដែលជាចំណែកមួយនៃការគ្រប់គ្រងធនធានសាធារណៈ។ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទាំងជាទ្រព្យហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ ត្រូវការនូវការយកចិត្តទុកដាក់ច្រើនថែមទៀត ខណៈដែលផ្នែកផ្សេងៗនៃការកែទម្រង់កំពុងមានវឌ្ឍនភាពល្អទៅមុខ

**ទី៦).** ខណៈដែលការរៀបចំថវិកាត្រូវបានធ្វើឡើងតាមកម្មវិធី ការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀត តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំ ឬអ្នកគ្រប់គ្រង គឺទទួលខុសត្រូវជាសំខាន់លើសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត ចំណែកការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង ស្ថាប័ន

**ទី៧).** ភាពចាំបាច់ក្នុងការបន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រនិងឆ្លើយតបទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសឆ្ពោះទៅ "**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**"។

### ១.២.១.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

#### ក. សមិទ្ធផល

ក្នុងរយៈពេលជាង២២ឆ្នាំនេះ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការបានកសាងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំ

ស្របតាមគោលការណ៍ អភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានភាពធន់ ខ្លាំង និងវៃឆ្លាតក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារ ធនធាន និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ជារួម គិតមកដល់ពេលនេះ ដោយមានការចូលរួមគាំទ្រពីការកែទម្រង់គន្លឹះ និងការកែទម្រង់តាមវិស័យនានា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាបានជំរុញឱ្យការអនុវត្តកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

### ក.១. ការដឹកនាំការងារកែទម្រង់ និងសម្របសម្រួលការងារកែទម្រង់

- ដើម្បីធានាដល់ការដឹកនាំ សម្របសម្រួលកែទម្រង់ឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើស្ថាប័នថ្នាក់ជាតិក្នុងដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកែទម្រង់ដ៏មានសារៈសំខាន់នេះ ស្របតាមច្បាប់រៀបចំអង្គការ។ ផ្អែកតាមការវិវឌ្ឍនៃកែទម្រង់នេះពីមួយដំណាក់កាលទៅមួយដំណាក់កាលបានតម្រូវឱ្យមានភាពចាំបាច់ក្នុងការពិនិត្យ និងដើម្បីធានាបាននូវការលើកកម្ពស់ភាពជាម្ចាស់ក្នុងការដឹកនាំ ការសម្របសម្រួល ការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យន្តការដឹកនាំ សម្របសម្រួលកែទម្រង់នេះ ត្រូវបានកែសម្រួលជាបន្តបន្ទាប់ រួមមាន ការកែសម្រួលសមាសភាព **គ.ជ.អ.ប**. ឱ្យស្របទៅតាមការវិវឌ្ឍកែទម្រង់និងការរៀបចំសមាសភាពរាជរដ្ឋាភិបាលនៃនីតិកាលនីមួយៗ ការកែសម្រួលអនុគណៈកម្មាធិការនានានៃ **គ.ជ.អ.ប**. ពីប្រាំអនុគណៈកម្មាធិការមកត្រឹម៣អនុគណៈកម្មាធិការ ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាម

ក្រសួងពាក់ព័ន្ធ និងនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។

- ការពង្រីកនិងពង្រឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិពីមួយដំណាក់កាលទៅមួយដំណាក់កាល គឺមានវិសាលភាពកាន់តែទូលំទូលាយពាក់ព័ន្ធគ្រប់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានលក្ខណៈសាំញ៉ាំស្មុគស្មាញ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ (២០១០-២០២០) និងដំណាក់កាលទី២ (២០២១-២០៣០) ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមឱ្យមានការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិលើកទី១ ស្តីពី "កែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ វេទិកានេះមានគោលបំណងវាយតម្លៃអំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងការដាក់ចេញនូវការតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឡើងរៀងរាល់៣ឆ្នាំម្តង ដោយចាប់ផ្តើមពីឆ្នាំ២០២៤នេះតទៅ។

### ក.២. ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ

- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតថ្នាក់

ត្រូវបានរៀបចំឡើង និងកែសម្រួលជាបន្តបន្ទាប់ឱ្យកាន់តែមានភាពជន់មាំ មានសមត្ថភាព និងលទ្ធភាពក្នុងការគ្រប់គ្រង ការចាត់ចែង ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោតជាសកល និងអសកលស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការរៀបចំ និងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធគ្រប់គ្រងតាមគោលការណ៍អភិបាលកិច្ច ប្រព័ន្ធកសាងផែនការដែលមានការចូលរួមពីប្រជាពលរដ្ឋ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ នាឆ្នាំ២០២០ កន្លងមកនេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានកែសម្រួលឡើងវិញ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នចំនួន **២០** ចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលអាចម្ចាស់ការក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារ និងការប្រើប្រាស់ធនធានរបស់ខ្លួន ព្រមទាំងមានសមត្ថភាពក្នុងការដឹកនាំ សម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍនានាដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

- ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលបានផ្ទេរមុខងារសំខាន់ៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន មុខងារក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ការផ្តល់សេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះ មុខងារក្នុងវិស័យសុខាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល និងមុខងារពាក់ព័ន្ធវិស័យអប់រំ យុវជន និងកីឡា។ តាមរយៈមុខងារដែលបានផ្ទេរទាំងនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាព និងសមត្ថភាព

ក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះ-ស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានបានឆាប់រហ័ស និងទាន់ពេលវេលា ជាពិសេស ការគ្រប់គ្រង និងការចាត់វិធានការទប់ស្កាត់ ថែទាំ និងព្យាបាលអ្នកជំងឺក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវិដ-១៩ក្នុងរយៈពេលជា២ឆ្នាំកន្លងមកនេះ និងការជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។

- វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ការពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស រួមមានមុខងារចំនួន៣ (**១.មុខងារគ្រប់គ្រងការអប់រំកុមារតូច ២.មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និង៣.មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ**) តាមរយៈ អនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ មុខងារចំនួន៥៥ក្នុងវិស័យចំនួន២០ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេស ដែលមុខងារទាំងនេះពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាអាទិ៍ មុខងារ ក្នុងវិស័យអប់រំ កសិកម្ម អនាម័យ បរិស្ថាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូច ដូចជា ផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត អគ្គិសនីភ្លើង ប្រព័ន្ធធារាសាស្ត្រ សាលារៀន។

**ក.៣. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំ និងកែសម្រួលជាបន្តបន្ទាប់ ដោយបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួន តាំងពីដំណាក់កាលនៃការប្រឡងជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ពិន័យ ការបណ្តេញ



ជំពូក១

ចេញ ការដាក់ឱ្យចូលនិវត្តន៍ និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិក លើកលែងតែការជ្រើសរើស ការបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រូពេទ្យ។ ស្របពេលជាមួយនឹងការផ្ទេរមុខងារ បុគ្គលិករដ្ឋបាល និងបុគ្គលិកជំនាញប្រមាណ **១០ ម៉ឺននាក់** ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះបុគ្គលិកក្រសួងមហាផ្ទៃចំនួន**ជាង ៧.៥០០ នាក់** បុគ្គលិកសុខាភិបាលចំនួន**ជាង ២០.០០០ នាក់** បុគ្គលិកអប់រំចំនួនប្រមាណ**ជាង ៧០.០០០ នាក់** និងបុគ្គលិកជំនាញបច្ចេកទេសពីក្រសួង ស្ថាប័នតាមវិស័យនានាចំនួនប្រមាណ **៨.០០០ នាក់**។

## ក.៤. វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ក.៤.១. វិមជ្ឈការហិរញ្ញវត្ថុ

- ពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានបង្កើត និងដាក់ឱ្យប្រតិបត្តិការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក និងការបង្កើតប្រភពចំណូលនានារបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិ ព្រមទាំងប្រព័ន្ធរៀបចំ និងអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដើម្បីជានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ រាជរដ្ឋាភិបាលបាន (១).បង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ដែលជាប្រព័ន្ធផ្ទេរធនធានថវិកាពីថវិកាជាតិទៅឱ្យឃុំ សង្កាត់ក្នុងអត្រា២%នៃចំណូលចរន្តថវិកាជាតិក្នុងឆ្នាំ២០០៣ និងបានបង្កើនដល់៣,៥%ក្នុងឆ្នាំ២០២៥ ព្រមទាំងបានផ្ទេរធនធានបន្ថែមពីថវិកាជាតិជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយផ្នែកអភិវឌ្ឍមូលដ្ឋានក្នុងអត្រាប្រចាំឆ្នាំ១%ចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០២៥ (២).បង្កើតមូលនិធិក្រុង ស្រុកដែលជាប្រព័ន្ធផ្ទេរធនធានថវិកាពីថវិកាជាតិទៅក្រុង ស្រុកក្នុងអត្រា០,៨% នៃចំណូលចរន្តថវិកាជាតិក្នុងឆ្នាំ២០១៣ និងបានបង្កើនដល់

១,៦% ក្នុងឆ្នាំ២០២៥។ ទន្ទឹមនេះ ក៏បានផ្ទេរធនធានថវិកាពីប្រភពនានាបន្ថែមទៀតទៅឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើឱ្យថវិកាថ្នាក់ក្រោមជាតិមានការកើនឡើងពី **១០៥.៦៨៧ លានរៀល** ប្រហាក់ប្រហែលនឹង **២៧,១០ លានដុល្លារអាមេរិក**នៅឆ្នាំ២០០២ ដល់ **៧.១៩៤ ប៊ីលានរៀល** ប្រហាក់ប្រហែលនឹង **១.៧៥៥ លានដុល្លារអាមេរិក** នៅឆ្នាំ២០២៥។ បើគិតចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលការផ្ទេរថវិកាសរុបប្រមាណ **៤៣.៦៤១ ប៊ីលានរៀល** ប្រហាក់ប្រហែលនឹង **១០.៥៨០ លានដុល្លារអាមេរិក** សម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមធន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។ ធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៦ឆ្នាំចុងក្រោយនេះរួមមានដូចខាងក្រោម៖

| រដ្ឋបាលថ្នាក់ក្រោមជាតិ | ធនធានហិរញ្ញវត្ថុតាមឆ្នាំនីមួយៗ (គិតជាលានដុល្លារ) | | | | | |
|---|---|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | សរុប |
| រាជធានី ខេត្ត | ៥៤៤ | ៧០៦ | ៨៣៨ | ៨៦៩ | ៨៦៧ | ៣.៨២៤ |
| ក្រុង ស្រុក | ១២១ | ១៤០ | ១៦៤ | ៥៥៨ | ៥៧៩ | ១.៥៦២ |
| ឃុំ សង្កាត់ | ១៧៥ | ២០៩ | ២៥៥ | ៣០៧ | ៣៤៣ | ១.២៨៩ |
| សរុប | ៨៤០ | ១.០៥៥ | ៨២២ | ១,៧៣៤ | ១,៧៨៩ | ៦.៦៧៥ |

### ក.៤.២. ប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ

- ប្រព័ន្ធកសាងផែនការ គឺជាប្រព័ន្ធអភិបាលកិច្ចដ៏សំខាន់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធ្វើសេចក្តីសម្រេចចិត្តតាមបែបប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាក្នុងការកំណត់ចក្ខុវិស័យ គោលដៅ ក្របខ័ណ្ឌអភិវឌ្ឍន៍ដែលក្រុមប្រឹក្សាចង់ឱ្យសម្រេចបាននៅក្នុងអាណត្តិរបស់ខ្លួន។ ច្បាប់រៀបចំអង្គការ បានតម្រូវឱ្យក្រុម-ប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានកាតព្វកិច្ចរៀបចំផែនការអភិវឌ្ឍន៍

រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីធ្វើជាឧបករណ៍ដ៏មានសារៈ-សំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការជំរុញដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាននីមួយៗ។ ដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំដាក់ឱ្យអនុវត្ត និងកែលម្អជាបណ្តើរៗ ដើម្បីធានាឱ្យមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិផង ព្រមទាំងឱ្យមានប្រសិទ្ធភាពក្នុងការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋផង សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមូលដ្ឋានបម្រើឱ្យការវិភាគ ការកំណត់បញ្ហា និងការកំណត់តម្រូវការអភិវឌ្ឍតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីធានាដល់ការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសុក្រឹតភាពក្នុងការឆ្លើយតប និងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

## ក.៥. ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

- ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក៏ត្រូវបានលើកកម្ពស់ និងមានលក្ខណៈកាន់តែឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅប្រចាំថ្ងៃតាមមូលដ្ឋាននីមួយៗ ដែលក្នុងមួយឆ្នាំៗ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាកម្មប្រមាណជាង **២.០០០ គម្រោង**។ ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារជាជម្រើស រដ្ឋបាលថ្នាក់ក្រោមជាតិ បានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង **២.០០០**

**គម្រោង**ក្នុងមួយឆ្នាំៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

- ការផ្តល់សេវាសាធារណៈក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មជាបណ្តើរៗ ដើម្បីបង្កភាពងាយស្រួល និងឆាប់រហ័សជូនប្រជាពលរដ្ឋ។ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបានរៀបចំបង្កើតឡើង និងបន្តពង្រឹង ពង្រីកឱ្យដំណើរការយ៉ាងសកម្មនៅទូទាំងប្រទេស ដោយបានបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់នានា រួមមានសេវារដ្ឋបាលប្រមាណជាង **៨០០ ប្រភេទ** ក្នុងវិស័យចំនួន១៤។ ការិយាល័យប្រជាពលរដ្ឋ (Ombudsman) ក៏ត្រូវបានពង្រឹង និងពង្រីកឱ្យមានដំណើរការនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ការិយាល័យប្រជាពលរដ្ឋ គឺជាយន្តការអព្យាក្រឹត្យមួយរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការបំពេញការងារ និងការផ្តល់សេវានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់គុណភាពសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- ទន្ទឹមនេះ ការងារគណនេយ្យភាពសង្គម ក៏ត្រូវបានដំណើរការយ៉ាងល្អប្រសើរនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់ ដែលតាមរយៈការងារគណនេយ្យភាពសង្គមនេះ បានផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មាន និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានានៅមូលដ្ឋាន ការចូលរួមក្នុងការអនុវត្តដោយផ្ទាល់ក្នុងដំណើរការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងការចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ជំពូក ១

ទៅលើដំណើរការនៃការផ្តល់សេវាសាធារណៈ និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ននេះ ការងារគណនេយ្យភាពសង្គមបាននិងកំពុងអនុវត្តយ៉ាងសកម្មនៅរដ្ឋបាលឃុំ សង្កាត់ចំនួន **១.៥៤៥** សាលាបឋមសិក្សាចំនួន **៦.៨២២** និងមណ្ឌលសុខភាពចំនួន **១.២៣៦** ព្រមទាំងការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន **៣៧**។

### ខ. បញ្ហាប្រឈម

ទោះបីការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងរយៈពេលកន្លងមកនេះបានបង្កើតនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើនពាក់ព័ន្ធនឹងការកែលម្អគុណភាពសេវាសាធារណៈ និងការជំរុញការអភិវឌ្ឍនៅតាមមូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តជំរុញ និងដោះស្រាយ។ បញ្ហាប្រឈមជាគន្លឹះទាំងនោះ រួមមាន៖

- ការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ សង្គមស៊ីវិល និងសាធារណជនអំពីការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះនៅមានកម្រិត។ ការទទួលខុសត្រូវក្នុងភាពជាម្ចាស់ក្នុងការអនុវត្តកម្មវិធីកែទម្រង់របស់ក្រសួង ស្ថាប័នអនុវត្តពាក់ព័ន្ធនានាក៏នៅមានកម្រិត។
- ទោះបីរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមកក៏ដោយ ក៏នៅមិនទាន់មានលក្ខណៈសមស្របទាំងស្រុងទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅឡើយ ដែលចាំបាច់ត្រូវបន្តពិនិត្យ និងកែសម្រួលឡើងវិញបន្ថែម។
- ការបែងចែកមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់

មានភាពច្បាស់លាស់ ដែលតម្រូវឱ្យមានការពិនិត្យកែលម្អលើការបែងចែកមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវទាំងនេះឡើងវិញ។

- ការផ្ទេរបុគ្គលិក ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់មានលក្ខណៈសមស្របតាមចំនួន និងទំហំមុខងារដែលបានផ្ទេរ ព្រមទាំងពុំទាន់មានដំណើរការដោយរលូននៅឡើយ ដែលប្រការនេះក៏ត្រូវមានការពិនិត្យ និងកែលម្អបន្ថែមទៀត។
- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បំពេញតួនាទីពេញលេញជាអង្គធ្វើសេចក្ដីសម្រេចចិត្តលើផែនការនិងថវិការបស់ខ្លួន ការតាមដានត្រួតពិនិត្យលើការអនុវត្តសេចក្ដីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សា ព្រមទាំងការបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួននោះឡើយ។
- ទោះបីប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្ដើរៗក៏ដោយ ក៏ការអនុវត្តជាក់ស្ដែងនៅពុំទាន់បាន អនុវត្តឱ្យបានពេញលេញតាមប្រព័ន្ធ និងមានប្រសិទ្ធភាពខ្ពស់នៅឡើយ។ ជាមួយគ្នានេះ ការខ្វះចំនួនបុគ្គលិក (ជាពិសេសនៅថ្នាក់ក្រុងស្រុក) និងសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏នៅមានកម្រិតក៏ជាបញ្ហាប្រឈមដែលត្រូវផ្ដោតការយកចិត្តទុកដាក់ដោះស្រាយផងដែរ។ ការរៀបចំប្រព័ន្ធអភិបាលកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅពុំទាន់បានបញ្ជ្រាប និងអនុវត្តបានពេញលេញនៅក្នុងការបំពេញការងារជាទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ ដែលប្រការនេះចាំបាច់ត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយឱ្យកាន់តែមានប្រសិទ្ធភាព។

### ១.២.១.៣. វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ

វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈវឌ្ឍនភាពនៃការអនុវត្តការងារក្នុងក្របខ័ណ្ឌ ចំនួន២ គឺ ទី១.វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈនិង ទី២.ការកែទម្រង់រដ្ឋបាលសាធារណៈក្នុងក្របខ័ណ្ឌគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គិតត្រឹមខែមីនា ឆ្នាំ២០២៥) ដែលរួមមានដូចខាងក្រោម៖

**ក. ការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា**

**១. ការអនុវត្តវិធានការគន្លឹះទី១៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព**

- បានរៀបចំ និងដាក់ចេញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល
- បានរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ស្របតាមនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល**សរុបចំនួន ១៦ លើក (ត្រូវជា ៤១ ដង)** ដោយមាន**បេក្ខជនប្រមាណ ១២ម៉ឺននាក់** បានចូលរួមការប្រឡងប្រជែង ដោយជ្រើសរើសបានមន្ត្រីរាជការក្របខ័ណ្ឌសរុប **៤៤៤៧ នាក់**
- បានរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីគោលការណ៍រួមនៃការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ រួមទាំងសេចក្ដីព្រាងលិខិត-បទដ្ឋានគតិយុត្តផ្សេងៗទៀតដើម្បីគាំទ្រដល់ការដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យនេះ
- បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មសម្រាប់

មន្ត្រីរាជការក្របខ័ណ្ឌ និងមន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារបម្រើការងារនៅក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានរៀបចំសេចក្តីព្រាងឯកសារណែនាំស្តីពីការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងនិងសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តឯកសារណែនាំនេះ
- បានរៀបចំសេចក្តីព្រាងបឋមថ្នាលព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ
- បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ២០២៥-២០២៨។

**ក្រសួងមុខងារសាធារណៈ បានកត់សម្គាល់នូវផលជះជាវិជ្ជមានក្នុងការអនុវត្តវិធានការគន្លឹះទី១ ដូចខាងក្រោម៖**

- បានចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ និងសុចរិតភាពនៅក្នុងរដ្ឋបាលសាធារណៈ
- បានបង្កើនជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ សាធារណជន និងមន្ត្រីរាជការលើយន្តការប្រឡង និងប្រព័ន្ធជ្រើសរើសមន្ត្រីរាជការដោរួមរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងលើកកម្ពស់យុត្តិធម៌សង្គម
- ផ្តល់ឱកាសទាក់ទាញអ្នកមានសមត្ថភាពខ្ពស់ឱ្យចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ មានន័យថាមូលធនមនុស្សប្រកបដោយសក្តានុពលត្រូវបានជ្រើសរើស និងរក្សាទុកក្នុងរដ្ឋបាលសាធារណៈ ដើម្បីរួមគ្នាធ្វើការសម្រេចឱ្យបាននូវចក្ខុវិស័យរបស់កម្ពុជា
- មន្ត្រីដែលបានជ្រើសរើសចូលបម្រើការងារឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព និងជាមន្ត្រីមានជំនាញវិជ្ជាជីវៈ និងសមត្ថភាពស្របតាមមុខតំណែងដែលបានជ្រើសរើស និងបំពេញតម្រូវការពិតប្រាកដរបស់អង្គភាព ព្រមទាំងងាយស្រួលក្នុងការផ្តល់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍសមត្ថភាពបន្ថែមនៅពេល

ជំពូកទី១

ខាងមុខ
- ប្រព័ន្ធនៃការជ្រើសរើសមន្ត្រីមានលក្ខណៈគុណាធិបតេយ្យ ដែលនឹងបង្កើតវប្បធម៌នៃគុណាធិបតេយ្យក្នុងរដ្ឋបាលសាធារណៈ
- បានចូលរួមបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ
- ជំរុញ និងបង្កើនការខិតខំរៀនសូត្រ សិក្សាស្វែងយល់បន្ថែមរបស់សិស្ស និស្សិត មន្ត្រីរាជការ និងសាធារណជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ
- កាត់បន្ថយចំណាយបន្ទុកបុគ្គលិករបស់រាជរដ្ឋាភិបាល តាមរយៈការជ្រើសរើសមន្ត្រីរាជការប្រកប ដោយគុណវុឌ្ឍិ និងស្របតាមចំនួនដែលបានកំណត់ក្នុងផែនការជ្រើសរើសប្រចាំឆ្នាំ
- ផ្តល់នូវឱកាសការងារជូនដល់សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សា និងមានបំណងបំពេញការងារក្នុងវិស័យសាធារណៈ។

**២. វិធានការគន្លឹះទី២៖ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព**

- បានរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន
- បានរៀបចំ និងដាក់ចេញនូវសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ស្តីពីការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការពិនិត្យឡើងវិញ និងវិភាគមុខងារនិងរចនាសម្ព័ន្ធ ចំនួន ២ លើក ដូចខាងក្រោម៖

**លើកទី១៖** ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួង

យុត្តិធម៌, ក្រសួងសុខាភិបាល, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
**លើកទី២៖** ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងបរិស្ថាន, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងពាណិជ្ជកម្ម, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងទេសចរណ៍, ក្រសួងរ៉ែ និងថាមពល។

- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចែករំលែកបទពិសោធនិងចំណេះដឹង ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួង ស្ថាប័ន ដែលបាន និងកំពុងអនុវត្តការពិនិត្យឡើងវិញ ការវិភាគមុខងារនិងរចនាសម្ព័ន្ធ ចំនួន ៤ លើក ដូចខាងក្រោម៖

(១) វគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនា-សម្ព័ន្ធក្រសួង ស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន **កាលពីថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ២០២៤**

(២) សិក្ខាសាលាស្តីពីការវិភាគមុខងារ និងការពង្រឹងការអនុវត្តវិស័យសាធា-រណៈ **កាលពី ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤**

(៣) សិក្ខាសាលាស្តីពីឧត្តមានុវត្តន៍នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន **កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤**

(៤) សិក្ខាសាលាស្តីពី "ការពិនិត្យឡើងវិញ និងការវិភាគមុខងារ៖ កែទម្រង់រចនាសម្ព័ន្ធដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃវិស័យសាធារណៈ" **កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤**

- បាននិងកំពុងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ន និងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលថ្នាក់ក្រោមជាតិ

- បានរៀបចំសេចក្តីព្រាងសារាចរស្តីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ និងបានដាក់ឆ្លងកិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃ **គ.ម.រ.**
- បានធ្វើការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំនិងនវានុវត្តន៍សម្រាប់ថ្នាក់-ដឹកនាំជាន់ខ្ពស់ក្នុងមុខតំណែងចាប់ពីកម្រិតប្រធាននាយកដ្ឋាន រហូតដល់រដ្ឋលេខាធិការសម្រាប់ថ្នាក់ជាតិ និងចាប់ពីកម្រិតអភិបាលក្រុង ស្រុក ខណ្ឌ រហូតដល់ អភិបាលរាជធានី-ខេត្ត ឬ មុខតំណែងប្រហាក់ប្រហែលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ២០២៤-២០២៨
- បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រលើកកម្ពស់ប្រសិទ្ធភាពការងារ ២០២៤-២០២៨
- បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារស្តីពីការរៀបចំប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងការពង្រាយមន្ត្រីរាជការ
- បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារទស្សនាទាន និងសេចក្តីណែនាំស្តីពីនិយាមនីតិវិធីប្រតិបត្តិការងារ
- បាននិងកំពុងរៀបចំសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីសាធារណៈ។

**ក្រសួងមុខងារសាធារណៈ បានកត់សម្គាល់នូវផលជះជាវិជ្ជមានក្នុងការអនុវត្តវិធានការគន្លឹះទី២ ដូចខាងក្រោម៖**

- ក្រសួង ស្ថាប័ន បានចាប់ផ្តើមផ្តល់ការចាប់អារម្មណ៍និងយកចិត្តទុកដាក់ក្នុងការចូលរួមពិនិត្យស្ថានភាពសុខភាពរបស់ក្រសួង ស្ថាប័នខ្លួន ដើម្បីជានាប្រសិទ្ធភាពការងារនិងការរៀបចំរចនាសម្ព័ន្ធឱ្យមានរបៀបរៀបរយឡើងវិញ ដើម្បីបំពេញមុខងារឆ្លើយតបនឹងការកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ និង

គោលនយោបាយរបស់រាជរដ្ឋាភិបាល

- ក្រសួង ស្ថាប័នបានពង្រឹងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងវត្តមានរបស់មន្ត្រី
- ក្រសួង ស្ថាប័នបានគិតគូរក្នុងការរៀបចំនិយាមនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងការកែលម្អសេវាសាធារណៈដែលទទួលបន្ទុក
- ក្រសួង ស្ថាប័ន បានគិតគូរក្នុងការរៀបចំនិយាមនីតិវិធីប្រតិបត្តិសម្រាប់អង្គភាពក្រោមឱវាទក្នុងគោលដៅពង្រឹង និងបង្កើនប្រសិទ្ធភាពការងារ
- បង្កើនផលិតភាពរបស់មន្ត្រីតាមរយៈការពង្រឹង និងការអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំ
- ចូលរួមកាត់បន្ថយចំណាយដែលមិនចាំបាច់និងមិនចំគោលដៅ ឬចំណាយលើមុខងារដែលស្ទួន
- ជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការពង្រឹងគុណភាពនិងផលិតភាពស្ថាប័នក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងធុរជន
- ប្រជាពលរដ្ឋអាចទទួលបាននូវសេវាសាធារណៈប្រកបដោយគុណភាព និងកាន់តែប្រសើរឡើង។

### ៣. វិធានការគន្លឹះទី៣៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព

- បានរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា តាមរយៈសេចក្តីសម្រេចលេខ ៤១៦៥/២៤ មស.សសរ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៃការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាល

ជំពូកទី១

សាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

- បានរៀបចំ និងដាក់ឱ្យអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធការរៀបចំគណៈកម្មការវាយតម្លៃការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៃការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ
- បានរៀបចំសេចក្តីព្រាងឯកសារទស្សនាទានស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

**ក្រសួងមុខងារសាធារណៈ បានកត់សម្គាល់នូវផលជះជាវិជ្ជមានក្នុងការអនុវត្តវិធានការគន្លឹះទី៣ ដូចខាងក្រោម៖**

- លើកទឹកចិត្តបន្ថែមទៀតដល់មន្ត្រីរាជការស៊ីវិល ក្នុងការបំពេញតួនាទីឱ្យកាន់តែប្រសើរឡើង
- ជំរុញ និងលើកទឹកចិត្តដល់មន្ត្រីរាជការក្នុងការពង្រឹងនិងបង្កើនសមិទ្ធកម្មរបស់ខ្លួនតាមរយៈការបង្កើនផលិតភាពការងារ បង្កើតគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ និងផ្តល់សេវាសាធារណៈកាន់តែប្រសើរជូនប្រជាពលរដ្ឋ
- ជំរុញឱ្យមន្ត្រីរាជការមានការខិតខំបង្កើនសមត្ថភាព អភិវឌ្ឍន៍ជំនាញ និងការប្រកួតប្រជែងដើម្បីភាពរីកចម្រើនរបស់ខ្លួន និងស្ថាប័ន
- ចូលរួមលើកកម្ពស់វិស័យអាទិភាពដូចជាអប់រំ និងសុខាភិបាលឱ្យកាន់តែមានភាពល្អប្រសើរតាមរយៈការរៀបចំចលនាប្រលងប្រណាំង និងការប្រកួតប្រជែងជាអង្គភាពផ្តល់សេវាសាធារណៈគំរូ។

## ខ. ការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

### ១. ការងារបរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ

- បានប្រមូលចងក្រង និងពិនិត្យលើកម្រងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ បានចំនួន១៩ ក្រសួង ស្ថាប័ន
- បានប្រមូលចងក្រងឯកសារគោលនយោបាយសេវាសាធារណៈនិងឯកសារទស្សនាទាននៃការបង្កើតការិយាល័យច្រកចេញចូលតែមួយដើម្បីជាមូលដ្ឋានក្នុងការពង្រឹងការអនុវត្តការងារនៅតាមយន្តការច្រកចេញចូលតែមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ
- បានផ្តល់ធាតុចូលលើ សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការរៀបចំសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច២០២៥-២០២៨ ផ្អែកតាមការស្នើសុំរបស់ក្រុមការងារអន្តរក្រសួង រៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច តាមរយៈលិខិតលេខ ៥៦០៣/២៤ មស.គកស ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤។

### ២. ការងារលើកកម្ពស់ឧត្តមភាពសេវាសាធារណៈ

- បានរៀបចំ និងដាក់ចេញនូវប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤ ដែលផ្តោតលើវិទ្យាល័យ និងសាលាមត្តេយ្យសិក្សាសម្រាប់វិស័យអប់រំ និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល
- បានរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំនួន ៥លើក នៅខេត្តចំនួន៧ រួមមាន ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពត ខេត្តកំពង់ស្ពឺ និង

ជំពូកទី១

ខេត្តសៀមរាប

- បានរៀបចំទស្សនកិច្ចសិក្សាស្ដីពី ឧត្តមានុវត្តន៍ និងនវានុវត្តន៍របស់មន្ទីរពេទ្យមូលដ្ឋាននៅព្រះរាជាណាចក្រថៃ សម្រាប់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលឆ្នាំ២០២៣ និងគណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ **គ.ម.វ**. ចំនួន២លើក
- បានដាក់ចេញនូវឯកសារណែនាំ ស្ដីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សា វិទ្យាល័យ មន្ទីរពេទ្យបង្អែកផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ គំរូ
- បានរៀបចំនិងដាក់ចេញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាលឆ្នាំ២០២៣
- បានរៀបចំ និងធ្វើបច្ចុប្បន្នភាពតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សា អនុវិទ្យាល័យ និងមណ្ឌលសុខភាពគំរូ សម្រាប់ការត្រៀមអនុវត្តនៅឆ្នាំ ២០២៥
- បានចុះវាយតម្លៃនៅទីតាំងជាក់ស្ដែងនៃបេក្ខភាពជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុង វិស័យសុខាភិបាល សរុបចំនួន៖ មន្ទីរពេទ្យបង្អែកផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត ៣ (CPA3) ចំនួន១០, មន្ទីរពេទ្យបង្អែកផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត ២ (CPA2) ចំនួន១០ និងមន្ទីរពេទ្យបង្អែកផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត ១ (CPA1) ចំនួន១០។

### ៣. ការងារគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស

- បានរៀបចំសេចក្ដីព្រាងបឋមនៃព្រះរាជក្រឹត្យ ស្ដីពីលក្ខន្តិកៈដោយឡែកនៃអង្គគ្រូបង្រៀន និងអង្គសុខាភិបាលដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល

- បាននិងកំពុងសិក្សាការរៀបចំកែលម្អនីតិវិធីក្នុងការគ្រប់គ្រងធនធានមនុស្ស
- បាននិងកំពុងសិក្សាស្រាវជ្រាវមុខតំណែងវិជ្ជាជីវៈ និងលក្ខខណ្ឌបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល។

### ៤. ការងារកសាងសមត្ថភាពមន្ត្រី

- បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ជំនាន់ទី៦ ដែលមានរយៈពេល៧សប្តាហ៍ដែលមានសមាសភាពមកពីក្រសួងស្ថាប័នថ្នាក់ជាតិ ចំនួន៣១ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន២៥ រាជធានី ខេត្ត
- បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យអំពីការបណ្តុះបណ្តាលមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌក្នុងប្រទេស និងតំបន់ដើម្បីជាធាតុចូលក្នុងការរៀបចំឯកសារក្របខ័ណ្ឌទស្សនាទានស្តីពីការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល
- បានរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនាទានស្តីពីការបណ្តុះបណ្តាលមន្ត្រីសម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង
- បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពប្រតិបត្តិឆ្នាំ២០២៥ ដែលផ្តោតលើ (១).ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រវត្តិសមត្ថភាពការងារ (២).សិក្សានិងវិភាគពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញតាមក្រសួងស្ថាប័ន (៣).ការអភិវឌ្ឍសមត្ថភាពមន្ត្រី និង(៤).រៀបចំប្រព័ន្ធគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល
- បានរៀបចំសេចក្តីព្រាងឯកសារស្តីពីវេទិកាភាពជាអ្នកដឹកនាំ។

## ១.២.១.៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌

### ក. សមិទ្ធផល

ក្នុងរយៈពេលជាង ២០ឆ្នាំ នៃការអនុវត្តការងារកែទម្រង់ច្បាប់ និងតុលាការ ក្រោមការដឹកនាំប្រកបដោយឆន្ទៈមោះមុត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាល ដែលមានក្រសួងយុត្តិធម៌ជាសេនាធិការដឹកនាំ

ជំពូកទី១

វិស័យនេះ សម្រេចបាននូវសមិទ្ធផលធំៗគួរជាទីមោទនៈ ជាអាទិ៍៖

**ទី១-ការកសាងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា៖** រាជរដ្ឋាភិបាល សម្រេចបាននូវការកសាង និងធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ដែលមានភាពរឹងមាំ និងគ្រប់ជ្រុងជ្រោយ ដើម្បីបម្រើឱ្យសេចក្ដីត្រូវការចាំបាច់នានារបស់សង្គម-សេដ្ឋកិច្ច ជាពិសេស ការកសាងនូវច្បាប់គ្រឹះធំៗ ដែលបម្រើឱ្យវិស័យយុត្តិធម៌ រួមមាន ក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមរដ្ឋប្បវេណី, ក្រមនីតិវិធីរដ្ឋប្បវេណី, ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងកសាងបាននូវច្បាប់សម្រាប់បម្រើឱ្យវិស័យផ្សេងទៀតជាច្រើន។

**ទី២- ការកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបម្រើឱ្យវិស័យយុត្តិធម៌៖** អគារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានារបស់សាលាជម្រះក្ដី និងអង្គការអយ្យការអមសាលាជម្រះក្ដីនៅទូទាំងប្រទេស ត្រូវបានកសាង និងកែលម្អ ដែលនេះគឺជាផ្នែកមួយនៃការពង្រឹងសមត្ថភាពស្ថាប័ន សំដៅពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។

**ទី៣- ការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌៖** ជាលទ្ធផលនៃការអនុវត្តការងារកែទម្រង់ច្បាប់ និងតុលាការ គិតត្រឹមឆ្នាំ២០២៥, បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ផលិតបានធនធានជាចៅក្រម, ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, អាជ្ញាសាលា និង សារការី សរុបចំនួន ២.១៣០ នាក់ ក្នុងនោះ ចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ៥៩៧ នាក់, ក្រឡាបញ្ជី សរុបចំនួន ១.៤៦៨ នាក់ (ក្នុងនោះមន្ត្រីសុក្រឹតការក្រឡាបញ្ជីមានចំនួន ៦១៦ នាក់), អាជ្ញាសាលា សរុបចំនួន ២៨ នាក់, សារការី សរុបចំនួន ៣៧ នាក់។

**ទី៤- ការបង្កើតសេវាយុត្តិធម៌ឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ៖** រាជរដ្ឋាភិបាល បានដាក់ឱ្យដំណើរការនូវសាលាដំបូង និងអយ្យការអមសាលាដំបូងនៅគ្រប់បណ្ដារាជធានីខេត្តនៅទូទាំងប្រទេស និងបានបង្កើតនិងដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍នៅតាម

តំបន់ចំនួន៣ បន្ថែមលើសាលាឧទ្ធរណ៍និងមហាអយ្យការ អមសាលាឧទ្ធរណ៍ភ្នំពេញ រួមមាន សាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ, សាលាឧទ្ធរណ៍និងមហា-អយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍និងមហាអយ្យការសមសាលាឧទ្ធរណ៍ត្បូងឃ្មុំ សំដៅបង្កិតសេវាយុត្តិធម៌ ឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ។

**ទី៥- ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌៖** ការដាក់ឱ្យដំណើរការនូវអង្គភាពរដ្ឋបាលតុលាការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីជួយគាំទ្រលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈរបស់សាលាជម្រះក្តីទាំងអស់ ក្នុងគោលបំណងកែលម្អការបម្រើសេវាជូនមុខនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី និងលើកកម្ពស់ការយកចិត្តទុកដាក់លើចំណាត់ការសំណុំរឿងរបស់ចៅក្រម និងព្រះរាជអាជ្ញា។ ទន្ទឹមនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសំណុំរឿងតាមប្រព័ន្ធបច្ចេកវិទ្យាក៏ត្រូវបានរៀបចំដាក់ឱ្យដំណើរការនៅតាមសាលាដំបូងរាជធានី ខេត្តមួយចំនួនផងដែរ។

**ទី៦- ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌ តាមរយៈការលើកកម្ពស់យន្តការនៃការផ្តល់សេវាជំនួយផ្នែកច្បាប់៖** កន្លងមក រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋក្រីក្រដែលមិនមានលទ្ធភាពផ្នែកហិរញ្ញវត្ថុក្នុងការពឹងពាក់រកមេធាវី តាមរយៈយន្តការប្រតិភូគណៈមេធាវីប្រចាំការនៅតាមសាលាដំបូងរាជធានី-ខេត្ត ដែលជាយន្តការបង្កើតឡើងដោយកិច្ចសហការរវាងក្រសួងយុត្តិធម៌ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសិទ្ធិទទួលបានយុត្តិធម៌ (Access to Justice) របស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គម។ យន្តការនេះទទួលបានកញ្ចប់ថវិកាពីរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំ ហើយដែលកញ្ចប់ថវិកាប្រចាំឆ្នាំនេះកើនឡើងជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ពីចំនួនទឹកប្រាក់ ២០០ លានរៀល នៅឆ្នាំ ២០០៣ រហូតដល់ចំនួនទឹកប្រាក់ ២ ៦០០ លានរៀល នៅឆ្នាំ២០២៥ នេះ។ បន្ថែមពីលើយន្តការនេះ រាជរដ្ឋាភិបាលក៏បានបង្កើតឱ្យមាននូវយន្តការមេធាវីស្ម័គ្រចិត្តផ្សេងៗ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, ក្រុមមេធាវីរាជរដ្ឋាភិបាល, ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ព្រមទាំងយន្តការនៃការផ្តល់សេវាមេធាវីដោយឥតគិតកម្រៃជូនដល់

ជំពូកទី១

ជនក្រីក្ររបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

**ទី៧- ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច៖** ទន្ទឹមនឹងការគិតគូរយកចិត្តទុកដាក់លើការលើកកម្ពស់ជីវភាព និងកិត្តិយសរបស់ចៅក្រម និងព្រះរាជអាជ្ញា, យន្តការអធិការកិច្ចរបស់ក្រសួងយុត្តិធម៌ និងយន្តការវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពង្រឹងជាបន្តបន្ទាប់ សំដៅលើកកម្ពស់វិន័យការងារ ក្រមសីលធម៌ និងសេចក្ដីថ្លៃថ្នូររបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការផ្សេងទៀត។

**ទី៨- ការរៀបចំដាក់ឱ្យដំណើរការ និងការលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖** យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងវិស័យនានា ជាពិសេសវិស័យពាណិជ្ជកម្ម, វិស័យការងារ, វិស័យដីធ្លី ត្រូវបានដាក់ឱ្យដំណើរការ និងទទួលបានការគាំទ្រជាបន្តបន្ទាប់។ ទន្ទឹមនេះ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (**អ.ដ.ក.**) ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលជាយន្តការដោះស្រាយវិវាទថ្មីមួយបន្ថែមលើយន្តការដោះស្រាយវិវាទដែលមានស្រាប់នៅកម្ពុជា សំដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការ, បង្ខិតយន្តការដោះស្រាយវិវាទឱ្យកៀកប្រជាជន និងធានាបាននូវភាពសុខដុមរមនានៅក្នុងសហគមន៍ និងមូលដ្ឋាន។

គិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ មកដល់ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៤ នេះ **អ.ដ.ក.** បានចាត់ការសំណុំរឿងបានចំនួន **៦៦** ករណី ក្នុងចំណោមសំណុំរឿងដែលទទួលបានសរុបចំនួន **២៩៣** ករណី ដោយក្នុងនោះសំណុំរឿងចំនួន **៣៤** ករណី ត្រូវបានសម្រុះសម្រួលដោះស្រាយដោយជោគជ័យ, សំណុំរឿងចំនួន **១៩** ករណី ត្រូវបានលើកចោលដោយសារខុសសមត្ថកិច្ច ឬខុសលក្ខខណ្ឌនៃការធ្វើបណ្ដឹង, សំណុំរឿងចំនួន ១៣ ករណី ត្រូវបានបិទបញ្ចប់ដោយសារភាគីមិនទទួលយកការសម្រុះសម្រួល។ សំណុំរឿងចំនួន **២២៧** ករណី កំពុងស្ថិតក្នុងចំណាត់ការរបស់ **អ.ដ.ក.**។

**ទី៩-ការជំរុញនិងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការ និង ការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ៖**

➤ **យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី ខេត្ត៖**

ក្រសួងយុត្តិធម៌ សម្រេចបានជោគជ័យក្នុងការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី ខេត្ត ដោយក្នុងនោះសំណុំរឿងចាស់ៗដែលនៅសល់ជាច្រើនឆ្នាំពីមុនមក ត្រូវបានដោះស្រាយ។ ជារួម តាមរយៈយុទ្ធនាការនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេសបានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះទាំងដំណាក់កាលអយ្យការ ទាំងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ សរុបចំនួនជាង ៣៧.៩០០ រឿង ស្មើនឹង ៩៦ % នៃសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះសរុបជាង ៣៩.៥០០ រឿង ( សំណុំរឿងដែលត្រូវបានជំនុំជម្រះរួចមានចំនួនជាង ១២.៦០០ រឿង ស្មើនឹង ៩៧% នៃចំនួនសំណុំរឿងសរុបជាង ១៣.០០០ រឿង ក្នុងដំណាក់កាលជំនុំជម្រះ )។ បន្ថែមពីនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស ក៏បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មី បានចំនួនជាង ៦២.៨០០ រឿង ស្មើនឹងជាង ៧៨% នៃចំនួនសំណុំរឿងចូលថ្មីសរុបជាង ៨០.៤០០ រឿង។ ទន្ទឹមនេះ យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត មិនត្រឹមតែអាចជួយដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត និងចូលរួមចំណែកក្នុងការដោះស្រាយភាពចង្អៀតណែននៅតាមពន្ធនាគារបានយ៉ាងច្រើនប៉ុណ្ណោះទេ ប៉ុន្តែយុទ្ធនាការនេះក៏បានជួយលើកកម្ពស់សមត្ថភាពស្ថាប័នតុលាការ ក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋផងដែរ។

➤ **យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ**

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌បានប្រកាសដាក់ចេញនូវយុទ្ធនាការចំនួន ២ ព្រមពេលជាមួយគ្នា នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌កម្ពុជាសំដៅពង្រឹង និងលើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ដែលក្នុងនោះរួមមាន៖ **( ១ )- យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ** និង **( ២ )- យុទ្ធ-**

**នាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ**។ ក្នុងរយៈពេល ១ ឆ្នាំនៃការអនុវត្តយុទ្ធនាការ គិតត្រឹមថ្ងៃទី៩ ខែមករា ឆ្នាំ២០២៥ គណៈបញ្ជាការដឹកនាំយុទ្ធ-នាការ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេស សម្រេចបាននូវលទ្ធផលការងារដូចខាងក្រោម៖

**ទី១-** តុលាការគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសបានចាត់ការសំណុំរឿង ទាំងរឿងព្រហ្មទណ្ឌ ទាំងរឿងរដ្ឋប្បវេណី និងរឿងក្តីដទៃទៀត បានចំនួន **១៨៨.៩៤២ ស្មើនឹង ៨២,៤១% នៃសំណុំរឿងសរុបចំនួន ២២៩.២៧២** ទាំងសំណុំរឿងដែលមានមុនពេលប្រកាសបើកយុទ្ធនាការ និងសំណុំរឿងដែលចូលថ្មី ក្រោយពេលប្រកាសបើកយុទ្ធនាការ។

**ទី២-** ក្នុងរយៈពេល ១ឆ្នាំ កន្លងទៅនេះ គិតចាប់តាំងពីពេលគណៈបញ្ជាការដឹកនាំយុទ្ធនាការ បានប្រកាសទទួលបណ្តឹងពីប្រជាពលរដ្ឋទាំងអស់ ដែលយល់ឃើញថា ចំណាត់ការរបស់តុលាការលើសំណុំរឿងរបស់ខ្លួនមានភាពមិនប្រក្រតី ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងមកកាន់លេខាធិការដ្ឋាននៃគណៈបញ្ជាការដឹកនាំយុទ្ធនាការ ចំនួន **២ ៤១៣ បណ្តឹង** ប៉ុន្តែមាន **១៧ បណ្តឹង** ដែលមិនអាចបញ្ជូនទៅចាត់ការបាន។ ដូច្នេះ បណ្តឹងរបស់ប្រជា-ពលរដ្ឋ ដែលគណៈបញ្ជាការដឹកនាំយុទ្ធនាការ ត្រូវចាត់ការមានចំនួនសរុប **២ ៣៩៦ បណ្តឹង**។ ជាលទ្ធផល គិតត្រឹមថ្ងៃទី៩ ខែមករា ឆ្នាំ២០២៥៖

- គណៈបញ្ជាការដឹកនាំយុទ្ធនាការ បានចាត់ការបណ្តឹងរបស់ប្រជាពលរដ្ឋរួចសរុបចំនួន **២ ១០១ ករណី** ស្មើនឹង **៨៧,៦៨%** ដោយក្នុងនោះ៖
  - ករណីស្នើសុំជំរុញ និងពន្លឿននីតិវិធីតុលាការ ចំនួន **១ ១៦៣ ករណី** ស្មើនឹង **៤៨,៥៣%**
  - ករណីដែលម្ចាស់បណ្តឹងបង្ហាញនូវកង្វល់អំពីភាពមិនប្រក្រតីចំពោះសំណុំរឿងរបស់ខ្លួនដែលកំពុងស្ថិតក្នុងចំណាត់ការរបស់តុលាការ **៣៧១ ករណី** ស្មើនឹង **១៥,៤៨%**
  - ករណីដែលរកពុំឃើញមានភាពមិនប្រក្រតី ហើយតុលាការសម្រេចដោយមាន

សំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ និងច្បាស់លាស់ ចំនួន **៤៩៦ ករណី** ស្មើនឹង **២០,៧០%**

- ករណីដែលភាគីវិវាទព្រមព្រៀង បញ្ជូនទៅដោះស្រាយតាមរយៈការសម្រុះសម្រួល ផ្សះផ្សាចំនួន **៨ ករណី**
- ករណីដែលអាចមានតម្រុយសង្ស័យថាមានភាពមិនប្រក្រតី មានចំនួន **៦៣ ករណី** ស្មើនឹង **២,៦២%** ក្នុងនោះ បានចាត់ឱ្យចុះធ្វើអធិការកិច្ចចំនួន **៣៧ ករណី** ស្នើសុំឱ្យជំនុំជម្រះសាជាថ្មី ចំនួន **១៦ ករណី** ធ្វើអធិបញ្ញាឱ្យចោទប្រកាន់ **៦ ករណី** និងផ្ទេរសមត្ថកិច្ច **៤ ករណី**។ ក្នុងចំណោមករណី ដែលបានចាត់ឱ្យចុះធ្វើអធិការកិច្ចទាំង **៣៧ ករណី** បានរកឃើញភាពមិនប្រក្រតី ហើយបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន **៧ ករណី**។ គិតជាសរុប ករណីដែលរកឃើញមានភាពមិនប្រក្រតីមានត្រឹមតែ **៣៣ ករណី** ស្មើនឹង **១,៣៧%** តែប៉ុណ្ណោះ។

• សំណុំរឿងនៅសល់ និងកំពុងចាត់ការដោយគណៈបញ្ជាការដឹកនាំយុទ្ធនាការ មានចំនួន **២៩៥ ករណី** ស្មើនឹង **១២,៣១%**។

ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅក្នុងស្នូលមុំទី៤ "**ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌**" និងវិធានការគន្លឹះទី៥ "**ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌**" របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** វិស័យយុត្តិធម៌សម្រេចបាននូវលទ្ធផល ដូចខាងក្រោម៖

- បានដាក់ឱ្យអនុវត្តនៅយន្តការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ
- បានដាក់ឱ្យអនុវត្តការនៅយន្តការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

- បានកំណត់សំណើសំណុំរឿងអាទិភាពចំនួនបួនប្រភេទគឺ សំណុំរឿងអគ្រានុ-កូលដ្ឋាន សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ សំណុំរឿងគ្រឿងញៀន និងសំណុំរឿងទាក់ទងនឹងក្មេងទំនើង
- បានដាក់ឱ្យដំណើរការអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- បាននិងកំពុងកសាង និងធ្វើទំនើបកម្មច្បាប់ក្នុងវិស័យយុត្តិធម៌
- បាននិងកំពុងកសាង និងពង្រឹងធនធានមនុស្សក្នុងវិស័យយុត្តិធម៌ (ការដាក់ដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញតុលាការ)
- បាននិងកំពុងកសាង និងកែលម្អបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ក្រសួងយុត្តិធម៌ និងសាលាជម្រះក្តីមួយចំនួន
- បាននិងកំពុងរៀបចំការធ្វើឌីជីថលូបនីយកម្មនៃប្រព័ន្ធយុត្តិធម៌។

### ខ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើ វិស័យយុត្តិធម៌ ក៏នៅជួបប្រទះបញ្ហា-ប្រឈមសំខាន់ៗមួយចំនួនដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃច្បាប់ និងប្រសិទ្ធភាពនៃការលើកកម្ពស់សេវាយុត្តិធម៌ និងជំនឿទុកចិត្តពីសាធារណជនលើវិស័យនេះ ដែលរួមមានជាអាទិ៍៖

- សមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងវិស័យយុត្តិធម៌នៅមានកម្រិតហើយមិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងតម្រូវការការងារ និងចំនួននៃសំណុំរឿងដែលមានការកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ
- ការពង្រឹងការងារអធិការកិច្ចនៅមិនទាន់អាចអនុវត្តបានពេញលេញនៅឡើយជាពិសេស លើផ្នែកវិន័យ ក្រមសីលធម៌ និងលើផ្នែកគុណភាពនៃចំណាត់ការសំណុំរឿងរបស់ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់
- ការយល់ដឹងអំពីច្បាប់នៅមានកម្រិតដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃ

ការអនុវត្តច្បាប់ និងការចូលរួមគោរពច្បាប់ពីសាធារណជន

- សមត្ថភាពឆ្លើយតបក្នុងការផ្តល់សេវាកម្មច្បាប់ និងជំនួយផ្នែកច្បាប់នៅមានកម្រិត
- ក្របខ័ណ្ឌច្បាប់ចាំបាច់មួយចំនួនលែងឆ្លើយតបទៅនឹងស្ថានភាពវិវត្តជាក់ស្តែងរបស់សង្គម-សេដ្ឋកិច្ចហើយក្របខ័ណ្ឌច្បាប់ចាំបាច់មួយចំនួនទៀតលែងបម្រើឱ្យសេចក្តីត្រូវការក្នុងវិស័យយុត្តិធម៌ ហើយក្របខ័ណ្ឌច្បាប់មួយចំនួនទៀតមិនទាន់បានបង្កើតឡើងតាមការគ្រោងទុក
- កង្វះនូវក្របខ័ណ្ឌច្បាប់ និងយន្តការច្បាស់លាស់សម្រាប់ជំរុញ និងលើកកម្ពស់ការប្រើប្រាស់ និងធានាប្រសិទ្ធភាពនៃការសម្របសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាពិសេស ការដោះស្រាយវិវាទតាមរយៈយន្តការសន្ទានកម្ម។

ជារួម វិស័យយុត្តិធម៌ ត្រូវបានទទួលស្គាល់ថាជាសសរស្តម្ភមួយដ៏សំខាន់ ដែលបានរួមចំណែកក្នុងការពង្រឹងសុខសន្តិភាព ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាគ្រឹះសម្រាប់វិបុលភាព និងភាពសុខសាន្តរបស់ប្រទេសជាតិ និងប្រជាជន ប្រកបដោយនិរន្តរភាព។ ទោះបីជាប្រព័ន្ធយុត្តិធម៌កម្ពុជា ត្រូវបានកែលម្អមួយកម្រិតធំហើយក៏ដោយ ប្រព័ន្ធយុត្តិធម៌កម្ពុជា នៅមានបញ្ហាប្រឈមដែលទាមទារត្រូវដោះស្រាយក្នុងស្មារតីបុរេសកម្ម បន្ទាន់ និងជាប់ជាប្រចាំ ដើម្បីពង្រឹងទាំងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ ទាំងគុណភាពនៃយុត្តិធម៌ សំដៅបង្កើនជំនឿទុកចិត្តពីសាធារណជនលើវិស័យនេះ។

## គ. ដំណោះស្រាយ

ដើម្បីដោះស្រាយនូវស្ថានភាពចំពោះមុខ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា **គ.ភ.ប.ឃ.** នឹងផ្តោតការយកការយកចិត្តទុកដាក់លើកម្មវិធីអាទិភាព ចំនួន ៨ រួមមាន៖

ទី១- ការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ

ទី២- ការលើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ទី៣- ការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

ទី៤- ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌

ទី៥- ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់នៅក្នុងសង្គម

ទី៦- ការលើកកម្ពស់ការផ្តល់ជំនួយផ្នែកច្បាប់

ទី៧- ការកសាង និងការធ្វើទំនើបកម្មច្បាប់ក្នុងវិស័យយុត្តិធម៌

ទី៨- ការដាក់ឱ្យដំណើរការតុលាការជំនាញ។

### ១.២.១.៥. កម្មវិធីកែទម្រង់ច្បាប់

#### ក. ការងារក្របខ័ណ្ឌគោលនយោបាយ

បន្ទាប់ពី រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានពិនិត្យឃើញអំពីវិសាលភាព សារៈសំខាន់ និងភាពចាំបាច់នៃការជំរុញល្បឿននៃការកែទម្រង់ច្បាប់ រាជរដ្ឋាភិបាលបានសម្រេចធ្វើវិចារណកម្មស្ថាប័ន នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយបង្កើតស្ថាប័នពីរដាច់ពីគ្នា គឺគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រី តាមព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានដឹកនាំ និងដាក់ចេញនូវទិសដៅច្បាស់លាស់ក្នុងការដឹកនាំសម្របសម្រួលការផ្តល់ប្រឹក្សាការតាក់តែងការត្រួតពិនិត្យការអនុវត្ត និងការដោះស្រាយវិវាទនៃច្បាប់ ដោយត្រូវធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការអនុវត្តច្បាប់។ កម្ពុជាត្រូវការប្រព័ន្ធច្បាប់មួយដែលផ្អែកលើនីតិរដ្ឋ ដើម្បីការពារឯករាជ្យ បូរណភាពទឹកដី ភាពជាម្ចាស់ ការពារសិទ្ធិមនុស្ស និងកម្មសិទ្ធិឯកជន យុត្តិធម៌សង្គម ព្រមទាំងគាំទ្រដល់សេដ្ឋកិច្ចទីផ្សារដែលរស់រវើក ក៏ដូចជាការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទាំងមូល។

#### ខ. ការតាក់តែងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការបានរៀបចំកិច្ចប្រជុំនិងបង្កើតក្រុមការងារ ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ សេចក្តី-ព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលនេះ ត្រូវបានរៀបចំ

ឡើងដោយយកចិត្តទុកដាក់និងពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយពីគ្រប់តួអង្គនិងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ជាមគ្គុទេសក៍បង្ហាញផ្លូវ សម្រាប់ដឹកនាំ សម្របសម្រួល និងជំរុញអនុវត្តការងារកែទម្រង់ច្បាប់ ឲ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្តិ និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ជាមគ្គុទេសក៍បង្ហាញផ្លូវក្នុងការដឹកនាំ សម្របសម្រួល ការផ្ដល់ប្រឹក្សា ការតាក់តែង ការត្រួតពិនិត្យការអនុវត្ត និងការដោះស្រាយវិវាទគតិយុត្ត ដោយកំណត់ដាក់ចេញយុទ្ធសាស្ត្រគន្លឹះចំនួន ៤ គឺ៖

| | |
|---|---|
| **យុទ្ធសាស្ត្រទី ១** | **ដឹកនាំនិងសម្របសម្រួលចងក្រង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** |
| **យុទ្ធសាស្ត្រទី ២** | **ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** |
| **យុទ្ធសាស្ត្រទី ៣** | **ដឹកនាំនិងសម្របសម្រួលពិនិត្យនិងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** |
| **យុទ្ធសាស្ត្រទី ៤** | **ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្ត និងការពារនីត្យានុកូលភាព** |

### គ. ការតាក់តែងគោលការណ៍ណែនាំស្ដីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្ដី-ព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

គោលការណ៍ណែនាំស្ដីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ និងត្រូវបានប្រកាសឱ្យប្រើតាមរយៈអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងដោយឈរលើទស្សនវិជ្ជានីតិរដ្ឋ (Rule of Law) ដែលរដ្ឋនីមួយៗត្រូវ



ជំពូកទី១

តែមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ ដែលធានាបាននូវសិទ្ធិ សេរីភាព កម្មសិទ្ធិឯកជននិងសាធារណៈ ការពារបាននូវតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមភាពចំពោះមុខច្បាប់ធ្វើឱ្យការគ្រប់គ្រងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍ ប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត រដ្ឋនីមួយៗត្រូវរៀបចំឱ្យមានប្រព័ន្ធនៃការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់ឱ្យបានហ្មត់ចត់ ដើម្បីធានាឱ្យមានយុត្តធម៌ក្នុងសង្គម។ ក្នុងន័យនេះ ការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលបម្រើឱ្យនីតិរដ្ឋត្រូវឈរលើគោលការណ៍ណែនាំមួយដែលក្រសួងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាលយកទៅអនុវត្ត ដើម្បីធានាថា ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះមានគុណភាព សង្គតិភាព អនុលោមភាព សាមញ្ញភាព ចីរភាព សន្តិសុខគតិយុត្ត និងប្រសិទ្ធភាព។

### ឃ. ការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់

យោងតាមសេចក្តីសម្រេចលេខ០៧ សសរ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតគណៈកម្មការ និងអនុគណៈកម្មការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារជំនាញការផ្នែកច្បាប់នៅក្នុងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ **គ.ក.ក.ច**. បានរៀបចំគោលការណ៍ស្នើសុំជ្រើសរើស និងធ្វើសេចក្តីជូនដំណឹងជ្រើសរើសមន្ត្រីជំនាញការផ្នែកច្បាប់ដោយនីតិវិធីនៃការជ្រើសរើស ត្រូវបានរៀបចំយ៉ាងហ្មត់ចត់ប្រកបដោយសុក្រឹតភាព ដោយបានចែកចេញជា៣ដំណាក់កាល រួមមាន៖ (១) ការសម្រិតសម្រាំងលើគុណវុឌ្ឍិរបស់បេក្ខជន, (២) វិញ្ញាសាសរសេរ (ចំណេះដឹងនិងបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញច្បាប់ ការប្រើប្រាស់ភាសាខ្មែរលើការសង្ខេបខ្លឹមសារនិងទម្រង់ និងការសរសេរជាភាសាអង់គ្លេស ឬ/និង បារាំង) និង(៣) វិញ្ញាសារផ្ទាល់មាត់។ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានផ្សព្វផ្សាយអំពីការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់ នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤ មានបេក្ខជនដាក់ពាក្យសរុបចំនួន១៧៣រូប ហើយបន្ទាប់ពីធ្វើការសម្រិតសម្រាំងយ៉ាងល្អិតល្អន់ដោយផ្តោតលើ

កម្រិតសញ្ញាបត្រ គួបផ្សំនឹងបទពិសោធន៍ការងារ បេក្ខជនចំនួន១៥៩រូប ត្រូវបានជ្រើសរើសឲ្យបន្តទៅវគ្គវិញ្ញាសាសរសេរ និងមានបេក្ខជនចំនួន៣៣រូបប៉ុណ្ណោះដែលឈានដល់វគ្គវិញ្ញាសារផ្ទាល់មាត់ ដោយដំណាក់កាលលើកទី១ គណៈកម្មការប្រឡងសម្រេចជ្រើសរើសបេក្ខជនតែ ៨រូបប៉ុណ្ណោះ លើចំនួន១៥រូប និងនៅក្នុងដំណាក់កាលលើកទី២ គណៈកម្មការប្រឡងសម្រេចជ្រើសរើសបេក្ខជនតែ៥រូបប៉ុណ្ណោះ លើចំនួន១៨រូប។

### ង. ការងារផ្សេងៗទៀត

- បាននិងកំពុងរៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ **អ.គ.ក.ច.**
- បាននិងកំពុងរៀបចំទស្សនាទានស្តីពីនីតិរដ្ឋ
- បាននិងកំពុងរៀបចំទស្សនាទានស្តីពីប្រព័ន្ធច្បាប់កម្ពុជា
- បាននិងកំពុងរៀបចំទស្សនាទានក្រមរដ្ឋបាល
- បាននិងកំពុងរៀបចំទស្សនាទានក្រមពាណិជ្ជកម្ម
- បាននិងកំពុងរៀបចំផែនការអភិវឌ្ឍស្ថាប័នសម្រាប់ **គ.ក.ច.**។

### ច. បញ្ហាប្រឈម

ទោះបីជាកម្មវិធីកែទម្រង់ច្បាប់ សម្រេចបាននូវសមិទ្ធផលជាច្រើនក៏ការអនុវត្តបានជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- សង្គតិភាពនៃច្បាប់ជាធរមាន (មិនស៊ីចង្វាក់គ្នា ប្រទាំងប្រទើស ផ្ទុយគ្នា មិនឯកភាពគ្នា ទាំងលើការប្រើប្រាស់ពាក្យច្បាប់ ទស្សនាទានច្បាប់ ទាំងការកំណត់ខ្លឹមសារ ឬអភិក្រមនៃការបកស្រាយខ្លឹមសារច្បាប់)៖ បទប្បញ្ញត្តិនៅក្នុងវិស័យច្បាប់តែមួយ អាចមានពាក្យប្រើច្រើនក្នុងន័យតែមួយ ឬមានន័យច្រើនដោយប្រើត្រឹមពាក្យតែមួយ ឬពាក្យតែមួយមានន័យខុសគ្នា ក៏ដូចជាពីវិស័យច្បាប់មួយទៅកាន់វិស័យច្បាប់មួយទៀត
- សង្គតិភាពនៃមធ្យោបាយតាក់តែងច្បាប់ (ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មាន

និន្នាការប្រែប្រួលទៅតាមជំនួយផ្នែកច្បាប់/ប្រព័ន្ធច្បាប់បរទេសដែលមិនទាន់មានឧបករណ៍វាយតម្លៃអំពីសមានគតិភាព, ភាពសមស្រប ឬភាពចាំបាច់រវាងច្បាប់និងស្ថានភាពសង្គម សេដ្ឋកិច្ច វប្បធម៌ និងវឌ្ឍនភាពផ្នែកបច្ចេកវិទ្យា និងភាពផ្សារភ្ជាប់ ទៅនឹងស្ថានភាពសង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី ទំនៀម-ទម្លាប់ ឱ្យបានសមស្រប)

- គម្លាតរវាងគោលនយោបាយ/យុទ្ធសាស្ត្រនិងច្បាប់ និងគម្លាតរវាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តកម្រិតអនុវត្ត ឬកម្រិតបទប្បញ្ញត្តិនិងប្រសិទ្ធភាពជាក់ស្តែង
- បញ្ញានុភាពបទដ្ឋានគតិយុត្ត ក្រោយបទដ្ឋានគតិយុត្តត្រូវបានអនុម័ត (ភាពមិនច្បាស់លាស់ខាងផ្នែកខ្លឹមសារនៃបទដ្ឋានគតិយុត្តដែលនាំឱ្យមានការបកស្រាយខុសៗគ្នា អាស្រ័យទៅតាមទស្សនវិជ្ជាច្បាប់ខុសៗគ្នា នៃប្រព័ន្ធច្បាប់ខុសៗគ្នា មានប្រព័ន្ធប្រពៃណី ប្រព័ន្ធ Civil Law និងប្រព័ន្ធ Common Law)
- ប្រសិទ្ធភាពនៃការអនុវត្ត (កង្វះយន្តការជាក់លាក់ ក្នុងការពិនិត្យនិងវាយតម្លៃគុណភាព និងសមានគតិភាពនៃការតាក់តែង សុក្រឹតភាពនៃការបកស្រាយខ្លឹមសារបទដ្ឋានគតិយុត្តដែលមិនច្បាស់លាស់ និងប្រសិទ្ធភាពនៃការអនុវត្ត)
- ការបែកចែក និងកំណត់តួនាទីនិងភារកិច្ច លើការងាររៀបចំច្បាប់ និងលិខិត-បទដ្ឋានគតិយុត្តរវាងអគ្គនាយកដ្ឋាន/អង្គភាពជំនាញបច្ចេកទេស និងអង្គភាពទទួលបន្ទុកនីតិកម្ម បានចោទជាបញ្ហានៃទំនាស់ផលប្រយោជន៍នានា ដែលអាចកើតមានឡើងពីការកសាងបទដ្ឋានគតិយុត្ត និងការគោរពមុខងារនិងភារកិច្ចតាមគោលការណ៍នីត្យានុកូលភាព តក្កវិជ្ជាគតិយុត្ត និងប្រតិតុល្យភាពនៃមុខងារ
- ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានយន្តការច្បាស់លាស់ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនៅឡើយ ដែលខុសប្លែកពីបណ្តាប្រទេសមួយចំនួន ដែលមានច្បាប់ សម្រាប់កំណត់អំពីការតាក់តែងច្បាប់ថែមទៀត ជាក់ស្តែង ការកំណត់ការផ្ទេរមុខងារ និងធនធានទាំង៥៥មុខងារ និង២០

វិស័យ ពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- យន្តការផ្សព្វផ្សាយច្បាប់មិនទាន់មានប្រសិទ្ធភាពនិងទូលំទូលាយ និងឌីជីថលូបនីយកម្មផ្លូវការ
- សមត្ថភាពធនធានមនុស្ស និងអង្គភាពទទួលបន្ទុកការងារច្បាប់/នីតិកម្ម នៅមានកម្រិត ទាំងសត្យានុម័ត និងអត្តនោម័តិ
- កង្វះកិច្ចសហការនិងអន្តរសកម្មរវាងតួអង្គអនុវត្តច្បាប់នានា ស្របតាមអភិក្រមជាគន្លឹះនៃយុទ្ធសាស្ត្របញ្ចកោណ គឺ "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"
- កង្វះការបង្កើតឧបករណ៍អភិបាលកិច្ចគាំទ្រការអនុវត្តច្បាប់ (កម្រងសម្រង់, មគ្គុទេសក៍នីតិសាស្ត្រ, អត្ថបទព្រឹត្តិបត្រច្បាប់, អត្ថាធិប្បាយគតិយុត្ត, មគ្គុទេសក៍ប្រឹក្សាច្បាប់...)
- កង្វះធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងផែនការសកម្មភាពអនុវត្តមុខងារនីតិកម្មគាំទ្រការងារកែទម្រង់។

## ១.២.២. សមិទ្ធផលនិងបញ្ហាប្រឈមនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ

ការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលរួមមាន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់ច្បាប់ មានទំនាក់ទំនងជាមួយគ្នាជាច្រើនកម្រិត ខ្លះក្នុងកម្រិតជាពីរការដ្ឋានកែទម្រង់ ខ្លះក្នុងកម្រិតជាបីការដ្ឋានកែទម្រង់ និងខ្លះទៀតអាចទាំងប្រាំការដ្ឋានកែទម្រង់។

ជាសារវតារ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្មរវាងការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល យន្តការសម្របសម្រួលមួយត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់បី

រួមមាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យន្តការនេះមានរបបប្រជុំប្រចាំត្រីមាសនិងរបៀបវារៈនៃកិច្ចប្រជុំផ្ទាល់ខ្លួន ដែលកំណត់ដោយប្រធានប្ដូរវេន តាមរយៈការសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ពីរផ្សេងទៀត។ កិច្ចប្រជុំប្ដូរវេននេះ ធ្វើឡើងក្នុងគោលបំណងពិនិត្យ សម្របសម្រួល និងលើកសំណើដោះស្រាយបញ្ហាប្រទាក់ក្រឡារវាងកម្មវិធីកែទម្រង់ទាំងបី ដែលក្នុងនោះរបាយការណ៍នៃកិច្ចប្រជុំត្រូវបានគោរពរាយការណ៍ជូនប្រធានគណៈកម្មាធិការទាំង ៣។

នៅឆ្នាំ២០១៨ យន្តការខាងលើបានបញ្ចូលកម្មវិធីកែទម្រង់មួយបន្ថែមទៀត គឺកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលយន្តការនេះត្រូវបានហៅថា យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល ដែលហៅកាត់ថា "**យ.ស.ក.**" ផ្អែកតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម ស ខេង** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ស្របតាមទស្សនវិស័យនេះ អនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាល ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដើម្បីធានាសុខដុមនីយកម្មរវាងកម្មវិធីកែទម្រង់ទាំង ៤ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ ដូច្នេះ **យ.ស.ក.** បានប្រែក្លាយជាយន្តការកាន់តែមានភាពជាក់លាក់ ដោយមានផែនការសកម្មភាពប្រចាំឆ្នាំដែលត្រូវបានអនុម័តដោយអគ្គលេខាធិការនិងប្រធានលេខាធិការដ្ឋាននៃគណៈ-កម្មាធិការកែទម្រង់ទាំង ៤។ អនុលោមតាមអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ **យ.ស.ក.** បានរៀបចំជាយន្តការតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពតាមរយៈកិច្ចប្រជុំផ្លាស់វេនប្រចាំត្រីមាសនិងប្រចាំឆ្នាំក្រោម

ទម្រង់ជាវិបស្សនា ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៤។ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំនិងគោរពរាយការណ៍ជូនប្រធានគណៈ-កម្មាធិការទាំងបួនដើម្បីពិនិត្យនិងអនុម័ត។

នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា ចាប់ពីឆ្នាំ២០២៣ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ត្រូវបានដឹកនាំដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ដែលដឹកនាំដោយក្រសួងយុត្តិធម៌និងតុលាការកំពូល រីឯការកែទម្រង់ច្បាប់ត្រូវបានដឹកនាំដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ដែលដឹកនាំដោយទីស្ដីការគណៈរដ្ឋមន្ត្រី។ ក្នុងបរិការណ៍ថ្មីនេះ អនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាល ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងជំនួសដោយអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

តាមរយៈ **យ.ស.ភ.** នេះ តំណាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់គន្លឹះទាំង ៥ បានចុះស្វែងយល់ការអនុវត្តការងារកែទម្រង់គន្លឹះទាំង ៥ ដោយផ្ទាល់នៅខេត្តប៉ៃលិន និងបាត់ដំបងនៅខែមីនា ឆ្នាំ២០២៤ និងបានបំពេញទស្សនកិច្ចសិក្សារួមគ្នានៅប្រទេសណូវែលហ្សេឡង់ស្ដីពីការកែទម្រង់អភិបាលកិច្ចនិងវិស័យសាធារណៈចំពោះការគ្រប់គ្រងសាធារណៈជំនាន់ថ្មី នៅខែកុម្ភៈ ឆ្នាំ២០២៥។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើ **យ.ស.ភ.** នៅបន្តជួបប្រទះកិច្ចប្រឈមជាបន្តបន្ទាប់ពាក់ព័ន្ធនឹងអភិក្រម អាទិភាព ទស្សនាទាន និងជំហានជាយុទ្ធសាស្ត្រនៃការកែទម្រង់ទាំងប្រាំ ដែលមានភាពប្លែកគ្នា ទាំងវិសាលភាព ទាំងភាពស៊ីជម្រៅនិងទស្សន-វិស័យ។ អាស្រ័យហេតុនេះ សុខដុមនីយកម្មនៃកិច្ចការកែទម្រង់គន្លឹះ នៅបន្តជាកិច្ចការអាទិភាពនិងចាំបាច់ សម្រាប់ឈានទៅសម្រេចទស្សនវិស័យ "**ឯកភាពនៃប្រព័ន្ធតួអង្គតែមួយ**" របស់រាជរដ្ឋាភិបាល។

ជំពូកទី១

## ១.៣. ស្ថានភាពបច្ចុប្បន្ន

### ១.៣.១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចក្ខុវិស័យច្បាស់លាស់គឺប្រែក្លាយ "***ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្ដោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ***" ។

ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់យកតាំងពីចុងឆ្នាំ២០០៤ រហូតមក នូវយុទ្ធសាស្ត្រកែទម្រង់ "**បោះជំហានជាដំណាក់កាល**" (Platform Approach) គឺបោះជំហានថ្មីទៅក្នុងដំណាក់កាលថ្មី ដោយថែរក្សាជំហានដែលសម្រេចបានជោគជ័យកន្លងទៅផង ថែមទាំងរៀបចំត្រៀមខ្លួនតម្រង់ឆ្ពោះទៅកាន់ជំហានខាងមុខបន្ទាប់ទៀតផង។ ក្នុងន័យនេះ កិច្ចការ ៣យ៉ាង ត្រូវបំពេញក្នុងពេលដំណាលគ្នាគឺ៖ ១) ថែរក្សានិងពង្រឹងបន្ថែមនូវសមិទ្ធផលដែលសម្រេចបានក្នុងដំណាក់កាលមុន ២) ស្ថាបនាសមិទ្ធផលដែលត្រូវសម្រេចឱ្យបានក្នុងដំណាក់កាលបច្ចុប្បន្ន និង ៣) រៀបចំត្រៀមខ្លួនកសាងសមិទ្ធផលថ្មីៗ នៅដំណាក់កាលខាងមុខ។

ផ្អែកលើយុទ្ធសាស្ត្រកែទម្រង់ខាងលើ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានគ្រោងទុកថានឹងបញ្ចប់នៅឆ្នាំ២០១៥។ ប៉ុន្តែ បទពិសោធន៍ បានបង្ហាញថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាត្រូវការរយៈពេលបន្ថែមទៀត គឺសរុបប្រមាណ ២៣ ឆ្នាំ ដោយគ្រោងជាថ្មីថានឹងសម្រេចបញ្ចប់នៅ ឆ្នាំ២០២៧ ហើយដែលនៅពេលនោះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជានឹងត្រូវបានផ្លាស់ប្ដូរទាំងស្រុងទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្ដោតលើជាតុចេញ ឬលទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ។

## យុទ្ធសាស្ត្រកែទម្រង់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




ចាប់តាំងពីការសម្រេចជាវឌ្ឍនភាពក្នុងខឿន ឬដំណាក់កាលទី១ ដល់ទី៣ ការងារសេសសល់មួយចំនួននៅតែបន្តមាននិងទាមទារឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបន្តអនុវត្តក្នុងការកសាងមូលដ្ឋានគ្រឹះឱ្យបានរឹងមាំនិងដើម្បីរក្សាបានចីរភាពនៃប្រព័ន្ធទាំងមូល។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅក្នុងដំណាក់កាល ៣ បូក ២ ដែលមានសុពលភាពអនុវត្តសម្រាប់រយៈពេល ២ ឆ្នាំ គឺឆ្នាំ២០២១-២០២២។ ៣ បូក ២ គឺបានន័យថាការបន្ថែមរយៈពេលចំនួន ២ ឆ្នាំទៀតសម្រាប់ការអនុវត្តដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលត្រូវបានគ្រោងពីដំបូងថានឹងបញ្ចប់នៅឆ្នាំ២០២០ និងចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" នៅក្នុងឆ្នាំ២០២១។

ការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាល ៣ បូក ២ (២០២១-២០២២) ក្នុងរយៈពេល ២ឆ្នាំនេះ បានសម្រេចសមិទ្ធផលជាមូលដ្ឋានគ្រឹះដែលចាំបាច់និងគ្រប់គ្រាន់សម្រាប់ការ

បោះជំហានទៅមុខនិងចាប់ផ្ដើមអនុវត្តដំណាក់កាលទី៤"**គណនេយ្យភាពសមិទ្ធកម្ម**" ចាប់ពីឆ្នាំ២០២៣ តាមការរំពឹងទុក។

ក្នុងដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្របខ័ណ្ឌផែនការសកម្មភាពរួម (CAP4) ឆ្នាំ២០២៣-២០២៧ ដែលត្រូវអនុម័តដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងក្លាយជាផែនទីចង្អុលផ្លូវដើម្បីសម្រេចបាននូវចក្ខុវិស័យ នោះគឺការប្រែក្លាយ"***ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្ដោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ***"។

### ១.៣.២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបាន និងកំពុងអនុវត្តតាមរយៈកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមដំណាក់កាលនីមួយៗ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី១ត្រូវបានអនុវត្តបញ្ចប់នៅចុងឆ្នាំ២០២០។ ក្នុងការបន្តកិច្ចដំណើរការកែទម្រង់នេះ រាជរដ្ឋាភិបាលបានសម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី២ (២០២១-២០៣០) ដែលមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

#### ១.៣.២.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ គឺ "***ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈនិងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្ដល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ននិងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅ***

***ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០***"។

ដើម្បីឆ្ពោះទៅដល់ការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធ សិទ្ធិអំណាច មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពសមស្របក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃការវិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច និងសង្គម។ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានសមត្ថភាពពេញលេញក្នុងការផ្តល់សេវាសាធារណៈ ដើម្បីចូលរួមគាំទ្រដល់ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាន ព្រមទាំងបង្កើនសុខភាព ការអប់រំ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទន្ទឹមគ្នានេះ ការទទួលខុសត្រូវដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវធានាថា ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងសមធម៌សង្គម រួមទាំងការធានាឱ្យស្ត្រី ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះទទួលបានឱកាសស្មើភាពគ្នាក្នុងការទទួលបានឱកាសផ្នែកសេដ្ឋកិច្ច និងសេវាសង្គមនានា។

### ១.៣.២.២. គោលបំណង

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានគោលបំណង "***លើកកម្ពស់ការផ្តល់សេវានិងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាបន្ន សមធម៌ និងយុត្តិធម៌តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់-ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង***"។

ដើម្បីឆ្ពោះទៅដល់ការសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវជំរុញដល់ការរៀបចំប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបទំនើប និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ព្រមទាំងត្រូវមានបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈសម្រាប់ដំណើរការប្រព័ន្ធទាំងនេះប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិ-

ភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានផែនការដែលឆ្លុះបញ្ចាំងពីតម្រូវការជាអាទិភាពនានានៅតាមមូលដ្ឋាននីមួយៗ តាមរយៈការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវទទួលបាននូវធនធានហិរញ្ញវត្ថុ និងសិទ្ធិអំណាចកាន់តែច្រើនបន្ថែមទៀតក្នុងការធ្វើការសម្រេចនានាពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួន។ តួនាទី នីតិវិធីអនុវត្តការងារ និងសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវមានការពង្រឹងដើម្បីក្លាយជាអង្គដ៏សំខាន់ក្នុងការធានានូវគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

### ១.៣.២.៣. គោលដៅ

គោលដៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម-ជាតិនៅឆ្នាំ២០៣០គឺ "***រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ***"។

ដើម្បីធានាដល់ការសម្រេចបានគោលដៅនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវផ្តោតទៅលើការរៀបចំអនុវត្តតាមសមាសភាគ និងសមិទ្ធផលរំពឹងទុកនានាដូចខាងក្រោម៖

- **សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកែទម្រង់**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការគ្រប់គ្រងការងារកែទម្រង់ទាំង

នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះក្នុងការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន៖

១). ការបន្តពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ **គ.ជ.អ.ប**. អនុគណៈកម្មាធិការនានានៃ **គ.ជ.អ.ប**. គណៈកម្មការដឹកនាំការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការដឹកនាំសម្របសម្រួលកិច្ចដំណើរការកែទម្រង់ស្របតាមផែនការអនុវត្តនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកែទម្រង់នេះជាមួយកម្មវិធីកែទម្រង់ផ្សេងទៀតដូចជា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់យុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ជាដើម។

២). ការពង្រឹងយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន និងការប្រាស្រ័យទាក់ទង ដើម្បីធានាថាស្ថាប័នពាក់ព័ន្ធទាំងអស់ និងសាធារណៈជនមានការយល់ដឹងកាន់តែទូលំទូលាយអំពីចក្ខុវិស័យ គោលបំណង គោលដៅ និងលទ្ធផលរំពឹងទុកនានានៃកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

៣). ការលើកកម្ពស់ការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការតាមដំណាក់កាលនីមួយៗ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

៤). ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំបង្កើតស្ថាប័នថ្នាក់ជាតិដែលមានតួនាទី និងការទទួលខុសត្រូវជាក់លាក់ និងច្បាស់លាស់ក្នុងការផ្តល់ការគាំទ្រ និងការត្រួតពិនិត្យលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៥). ការពង្រឹងតួនាទីសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបំពេញតួនាទីផ្តល់មតិយោបល់ និងអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់-ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។

**➢ សមាសភាគទី២៖ រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការកំណត់ឱ្យច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមប្រភេទ និងចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចជា រដ្ឋបាលតំបន់ទីក្រុងធំ រដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ ព្រមទាំងការជំរុញឱ្យមានការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន៖

១). ការសិក្សា និងការបែងចែកឱ្យបានច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះ

- ក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវមានមុខងារស្នូលសំខាន់ៗពាក់ព័ន្ធនឹង ១). ការសិក្សាស្រាវជ្រាវដើម្បីជំរុញការអភិវឌ្ឍ និងនវានុវត្តន៍តាមវិស័យជំនាញរបស់ខ្លួន ២). ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេសសម្រាប់កំណត់ស្តង់ដាសេវា ៣). ការគាំទ្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៤). ការអនុវត្តមុខងារជាយុទ្ធសាស្ត្រធំៗមួយចំនួន។

- រដ្ឋបាលខេត្តត្រូវរៀបចំប្រែក្លាយជារដ្ឋបាលដែលមានរចនាសម្ព័ន្ធគ្រប់គ្រងតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ផ្អែកតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការបំពេញមុខងារជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអនុវត្តមុខងារនានាដែលរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នបានធ្វើប្រតិភូកម្មឱ្យ ២). ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តមុខងារផ្តល់សេវាសាធារណៈ ការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋានស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាដែលបានកំណត់ ការសម្របសម្រួលជាមួយរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង ៣). ការអនុវត្តមុខងារ ឬគម្រោងក្នុងវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងឬមានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រទូទាំងខេត្តដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបាន។
- រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់នឹងត្រូវរៀបចំប្រែក្លាយជារដ្ឋបាលមូលដ្ឋានដែលមានស្វ័យភាព សមត្ថភាព និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈនានាដោយផ្ទាល់ជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលមូលដ្ឋានទាំងនេះនឹងត្រូវរៀបចំឱ្យមានមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈពិសេសផ្សេងៗគ្នាស្របតាមសក្តានុពល និងស្ថានភាពផ្សេងៗគ្នារវាងទីប្រជុំជន និងតំបន់ជនបទ។ រដ្ឋបាលមូលដ្ឋានទាំងនេះមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការកំណត់តម្រូវការ និងបញ្ហាប្រឈមនានានៅតាមមូលដ្ឋានតាមរយៈដំណើរការកសាងផែនការ ដោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន និងការពង្រឹងអនុវត្តការងារ

គណនេយ្យភាពសង្គម ២). ការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន និងផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានបច្ចេក-ទេស និងស្តង់ដាសេវាដែលបានកំណត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និង ៣).ការរៀបចំ និងអនុវត្តការងារគណនេយ្យភាពជាមួយប្រជាពលរដ្ឋ តាមរយៈយន្តការទទួលសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។

- រដ្ឋបាលរាជធានី ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងជារដ្ឋបាលក្រុងមេត្រូប៉ូលីតែនដែលមានលក្ខណៈពិសេសដោយឡែកពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ ត្រូវរៀបចំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលបង្កលទ្ធភាពឱ្យរដ្ឋបាលនេះអាចបំពេញមុខងារជារដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋានផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលនេះក៏មានលទ្ធភាពក្នុងការពង្រីកការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួន ដែលបច្ចុប្បន្ននេះ រាជធានីភ្នំពេញរួមមានតំបន់រណបជាច្រើនដែលត្រូវបានកាត់ចេញពីខេត្តជាប់ព្រំប្រទល់នានា ដាក់បញ្ចូលឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី (ដែលតំបន់រណបទាំងនេះពុំទាន់មានការអភិវឌ្ឍដូចគ្នានឹងខណ្ឌនានាដែលស្ថិតនៅតំបន់កណ្តាលនៃរាជធានី) ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ ការទទួលខុសត្រូវជាចម្បងរបស់រដ្ឋបាលរាជធានីរួមមានដូចជា ការរៀបចំផែនការទីក្រុង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការរៀបចំនិងការផ្តល់សេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចរាចរណ៍ ការគ្រប់គ្រងសំណល់រឹងនិងរាវ ការងារបរិស្ថាននិងអនាម័យ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់និងសុវត្ថិភាពសាធារណៈ និងមុខងារមួយចំនួនទៀត។

២). ការពិនិត្យ និងការកែលម្អនូវទំនាក់ទំនងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ

និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងក្រសួង ស្ថាប័នថ្នាក់ជាតិ ស្របតាមមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ។

៣). ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាដល់ការលើកកម្ពស់ការដឹកនាំ ការធ្វើសេចក្ដីសម្រេចចិត្តក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

៤). ការបន្តលើកកម្ពស់ខ្សែគណនេយ្យភាពទាំងបីពោលគឺ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខ្ពស់ជាង និងចំពោះថ្នាក់ជាតិ គណនេយ្យភាពផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងជាពិសេសគណ-នេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

៥).ការកែលម្អយន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិ ដើម្បីជានាដល់ការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការបំពេញការងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមស្វ័យភាព សិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

➢ **សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

សមាសភាគនេះផ្ដោតលើការសម្រេចបាននូវសមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្ដីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញ វិជ្ជាជីវៈជាប្រចាំ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផល

ជំពូកទី១

រំពឹងទុកនេះ រួមមាន៖

១). ការរៀបចំអង្គមន្ត្រីរាជការដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល មានបទពិសោធន៍ការងារ មានចំណេះដឹង និងបំពេញការងារក្នុងវិស័យជំនាញវិជ្ជាជីវៈតែមួយនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងដើម្បីធានាដល់ការដាក់បញ្ចូលមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងអង្គមន្ត្រីរាជការនីមួយៗដែលធានាដល់ការលើកទឹកចិត្តមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

២). ការជំរុញ និងការពង្រឹងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវឱ្យបានពេញលេញក្នុងការជ្រើសរើស ការគ្រប់គ្រង និងការរៀបចំបុគ្គលិករបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានបុគ្គលិកក្នុងចំនួនសមស្របដែលមានសមត្ថភាពជំនាញវិជ្ជាជីវៈ និងមានបទពិសោធន៍ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ បុគ្គលិកម្នាក់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានលក្ខខណ្ឌការងារច្បាស់លាស់ដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃប្រចាំឆ្នាំដែលនឹងត្រូវអនុវត្តជាប្រចាំ។

៣).ការរៀបចំឱ្យមានប្រព័ន្ធលើកទឹកចិត្តសមស្របដល់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការលើកទឹកចិត្តផ្នែកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ ការដំឡើងថ្នាក់ ឋានន្តរស័ក្តិមុខតំណែង និងការលើកទឹកចិត្តផ្សេងទៀត ដើម្បីលើកកម្ពស់ឆន្ទៈម្ចាស់ការ និងមនសិការវិជ្ជាជីវៈក្នុងការបំពេញការងារ ព្រមទាំងលើកទឹកចិត្តបុគ្គលិកស្ម័គ្រចិត្តទៅបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

៤). ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាពសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិស្របជាមួយនឹងការពិព័ណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ៗ។

៥). ការពង្រឹងកិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋានលើការរៀបចំស្តង់ដាកម្មវិធីសិក្សា កម្មវិធី បណ្តុះបណ្តាល សម្ភារៈបណ្តុះបណ្តាល និងការរៀបចំគ្រូឧទ្ទេស

ក៏ដូចជាការអនុវត្តវគ្គបណ្តុះបណ្តាលនានាដោយផ្ទាល់ដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជិតស្និទ្ធជាមួយស្ថាប័នជំនាញផ្នែកបណ្តុះបណ្តាលនានា ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ជាមួយគ្នានេះ ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោម-ជាតិត្រូវរៀបចំឡើងដោយផ្អែកជាមូលដ្ឋានលើវិធីសាស្ត្រផ្សេងៗ រួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពលើប្រធានបទជាក់លាក់ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាដោយខ្លួនឯង។

➢ **សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកដែលពាក់ព័ន្ធនឹងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាសភាគនេះត្រូវអនុវត្តដោយមានកិច្ចសហការ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីកែទម្រង់ និងក្រសួង ស្ថាប័នអនុវត្តនានា ជាពិសេសជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងផែនការ។ កិច្ចការជាអាទិភាពដែលត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន៖

១). ការពិនិត្យ និងការកែសម្រួលកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងារថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបន្សុីគ្នារវាងកិច្ចដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាមួយកម្មវិធីវិនិយោគបីឆ្នាំរំកិល ផ្អែកលើទិន្នន័យ និងព័ត៌មានច្បាស់លាស់អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងអំពីធនធានហិរញ្ញវត្ថុដែលអាចព្យាករណ៍បាន។

២). ការពិនិត្យមើលឡើងវិញ និងការបង្កើនធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ ការបង្កើនប្រភពចំណូលមូលដ្ឋានដែលបានមកពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពិចារណាក្នុងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធ និងលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីៗបន្ថែមទៀត និងការផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានមានភ្ជាប់លក្ខខណ្ឌ និងតាមរយៈការបង្កើតនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុបន្ថែមទៀតដូចជា ការបង្កើតមូលនិធិភាតរភាពសំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ ព្រមទាំងកញ្ចប់ថវិកាពិសេសសម្រាប់ជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច។

៣). ការពង្រឹងការអនុវត្តសវនកម្ម និងការអធិការកិច្ចលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ធនធាន និងទ្រព្យសម្បត្តិទាំងនោះត្រូវបាន ចាត់ចែង និងប្រើប្រាស់ស្របតាមនីតិវិធីដែលបានកំណត់ និងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

៤). ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការវិនិយោគក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា។

➤ **សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**

សមាសភាគនេះផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកដែលពាក់ព័ន្ធការរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ កិច្ចការជាអាទិភាពដែល

ត្រូវរៀបចំ និងអនុវត្តដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមាន៖

១). ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ព្រមទាំងការកំណត់ឱ្យមានគោលការណ៍បែបបទ និងនីតិវិធីច្បាស់លាស់ សាមញ្ញ និងងាយស្រួលក្នុងការប្រតិបត្តិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់

២). ការពង្រឹង និងការកែលម្អនូវយន្តការនានា ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋដោយឆាប់រហ័ស តម្លាភាព សមធម៌ និងប្រកបដោយលក្ខណៈងាយស្រួល

៣). ការរៀបចំ និងគាំទ្រឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុធន្ធានុសិទ្ធិក្នុងទំហំសមស្រប និងមានធនធានមនុស្សប្រកបដោយសមត្ថភាព និងជំនាញវិជ្ជាជីវៈជាក់លាក់ ព្រមទាំងប្រកបដោយមនសិការវិជ្ជាជីវៈក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

៤). ការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាអ្នកផ្តល់សេវាដ៏ល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពដោយត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការ វិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ

៥). ការបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោម-ជាតិ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី នីមួយៗប្រកបដោយភាពជឿជាក់ និងឈរលើស្មារតីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋដោយស្មោះត្រង់។

បន្ថែមលើសមាសភាគទាំង៥ខាងលើនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប-

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) នឹងផ្តោតលើកិច្ចការអន្តរវិស័យមួយចំនួនដែលរួមមាន ៖

➤ **ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម៖**

កិច្ចការអន្តរវិស័យនេះផ្តោតលើការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិក ការរៀបចំផែនការ និងធនធាន ព្រមទាំងការចាត់ចែងការផ្តល់-សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង និងមិនប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនពិការ ក្រុមជនងាយរងគ្រោះនានាក្នុងសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌។

### ១.៣.៣. វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដើម្បីលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។ ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានរៀបចំឡើងដែលផ្តោតជាអាទិភាពលើ៖ ទី១.ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ទី២.ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព និង ទី៣.ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

### ១.៣.៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌

ផ្អែកតាមស្ថានភាពបច្ចុប្បន្ន **គ.ក.ប.យ.** បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ២០២៥-២០៣៥ ស្របតាមចក្ខុវិស័យនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល គឺ "**ការពង្រឹងនិងលើកកម្ពស់នីតិរដ្ឋ តាមរយៈការពង្រឹង**

**គុណភាព និងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌ដើម្បីលើកកម្ពស់ការគោរពសិទ្ធិ និងសេរីភាពបុគ្គល លើកកម្ពស់យុត្តិធម៌នៅក្នុងសង្គមពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម និងបង្កើនជំនឿទុកចិត្តពីសាធារណជនលើវិស័យច្បាប់និងយុត្តិធម៌ សំដៅរួមចំណែកសម្រេចឱ្យបាននូវការថែរក្សាសុខសន្តិភាព ភាពសុខដុមរមនា និងវិបុលភាពនៃសង្គមជាតិ។**"

សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ២០២៥-២០៣៥ គឺជាផែនទីបង្ហាញផ្លូវកម្រិតគោលនយោបាយសម្រាប់ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលកំណត់ច្បាស់លាស់អំពីចក្ខុវិស័យ ទិសដៅយុទ្ធសាស្ត្រ សកម្មភាពអាទិភាព និងផែនការសកម្មភាពរយៈពេល១០ឆ្នាំ ក្នុងគោលបំណង "**ពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីសម្រេចឱ្យបាននូវការកសាង និងអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌មួយប្រកបដោយប្រសិទ្ធភាព ស្ថិរភាព និរន្តរភាព និងទទួលបាននូវជំនឿទុកចិត្តពីសាធារណជន**"។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ទិសដៅយុទ្ធសាស្ត្រចំនួន ៥ នឹងត្រូវកំណត់ដាក់ចេញ រួមមាន៖

- ទិសដៅយុទ្ធសាស្ត្រទី១៖ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃច្បាប់ក្នុងវិស័យយុត្តិធម៌
- ទិសដៅយុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ
- ទិសដៅយុទ្ធសាស្ត្រទី៣៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ទិសដៅយុទ្ធសាស្ត្រទី៤៖ ការលើកកម្ពស់ការផ្ដល់សេវាកម្មច្បាប់ និងជំនួយផ្នែកច្បាប់
- ទិសដៅយុទ្ធសាស្ត្រទី៥៖ ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌។

## ១.៣.៥. កម្មវិធីកែទម្រង់ច្បាប់

ស្របតាមមុំទី៤នៃស្នូលនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងពង្រឹងនិងលើក-កម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃច្បាប់។ ផ្អែកតាមស្ថានភាពបច្ចុប្បន្ន និងមូលដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រខាងលើនេះ **គ.ក.ច.** សម្រេចកំណត់យកនូវចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្រគន្លឹះដូចខាងក្រោម៖

### ១.៣.៥.១. ចក្ខុវិស័យ

ចក្ខុវិស័យ នៃ **គ.ក.ច.៖ "ជានិម្មាបនករនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសកល"**។

### ១.៣.៥.២. បេសកកម្ម

បេសកកម្ម នៃ **គ.ក.ច.៖ "ដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជា ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា"**។

### ១.៣.៥.៣. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រគន្លឹះ នៃ **គ.ក.ច.** ត្រូវបានកំណត់ ដូចខាងក្រោម៖

១. ដឹកនាំនិងសម្របសម្រួលចងក្រងនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

២. ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិ-យុត្ត

៣. ដឹកនាំនិងសម្របសម្រួលពិនិត្យនិងវាយតម្លៃគុណភាពនិងប្រសិទ្ធភាពនៃការតាក់តែងនិងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

៤. ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្តនិងការពារនីត្យានុកូលភាព។

### ១.៣.៥.៤. យុទ្ធសាស្ត្រគាំទ្រ

យុទ្ធសាស្ត្រគន្លឹះទាំង៤ខាងលើនេះ ត្រូវអនុវត្តដោយមានយុទ្ធសាស្ត្រគាំទ្រដែលដឹកនាំរៀបចំ និងសម្រប សម្រួលដោយអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ដែលនឹងត្រូវរៀបចំជា ក្របខ័ណ្ឌផែនការប្រតិបត្តិលម្អិតសម្រាប់ធានាការអនុវត្តយុទ្ធសាស្ត្រគាំទ្រ ដោយផ្តោតអាទិភាពលើ កិច្ចការគន្លឹះ៤ ដូចតទៅ៖

១. រៀបចំផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ

២. រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤

៣. រៀបចំប្រព័ន្ធឌីជីថលូបនីយកម្ម សម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤ ក្នុងយុគសម័យឌីជីថល

៤. រៀបចំផែនការអភិវឌ្ឍស្ថាប័ន សម្រាប់ **គ.ក.ច.**។

បន្ទាប់ពីក្របខ័ណ្ឌយុទ្ធសាស្ត្រ **គ.ក.ច.** ត្រូវបានអនុម័ត អគ្គលេខាធិការដ្ឋាន **គ.ក.ច.** នឹងត្រូវរៀបចំ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដោយឡែករបស់ខ្លួនដើម្បីគាំទ្រដល់ការដឹកនាំនិងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ **គ.ក.ច.** ខាងលើ។

### ១.៣.៥.៥. យុទ្ធសាស្ត្រគាំទ្រ គ.ក.ច.

យុទ្ធសាស្ត្រគន្លឹះទាំង៤ខាងលើនេះត្រូវអនុវត្តដោយមានយុទ្ធសាស្ត្រគាំទ្រដែលដឹកនាំរៀបចំ និងសម្រប សម្រួលដោយអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ដែលនឹងត្រូវរៀបចំជា ក្របខ័ណ្ឌផែនការប្រតិបត្តិលម្អិតសម្រាប់ធានាការអនុវត្តយុទ្ធសាស្ត្រគាំទ្រ ដោយផ្តោតអាទិភាពលើ កិច្ចការគន្លឹះ៤ ដូចតទៅ៖

១. រៀបចំផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ

២. រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤

៣. រៀបចំប្រព័ន្ធឌីជីថលូបនីយកម្ម សម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤ ក្នុង

យុគសម័យឌីជីថល

៤. រៀបចំផែនការអភិវឌ្ឍស្ថាប័ន សម្រាប់ **គ.ក.ច.**។

បន្ទាប់ពីក្របខ័ណ្ឌយុទ្ធសាស្ត្រ **គ.ក.ច.** ត្រូវបានអនុម័ត អគ្គលេខាធិការដ្ឋាន **គ.ក.ច.** នឹងត្រូវរៀបចំ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដោយឡែករបស់ខ្លួន ដើម្បីគាំទ្រដល់ការដឹកនាំនិងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ **គ.ក.ច.** ខាងលើ។

### ១.៣.៥.៦. យន្តការគាំទ្រ គ.ក.ច.

ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ និងភាពប្រទាក់ក្រឡាក្នុងការសម្របសម្រួលការងារជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ **គ.ក.ច.** រៀបចំបង្កើតគណៈ-កម្មការជំនាញទទួលបន្ទុកតាមវិស័យ និងក្រុមការងារកែទម្រង់ច្បាប់តាមក្រសួង ស្ថាប័ន ស្របតាមព្រះរាជក្រឹត្យជាធរមាន។ គណៈកម្មការជំនាញ មានតួនាទីសម្របសម្រួលនៅអម **គ.ក.ច.** រីឯក្រុមការងារកែទម្រង់ច្បាប់ មានតួនាទីសម្របសម្រួល នៅអមក្រសួងស្ថាប័ន។

#### ក. គណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ

អនុលោមតាមមាត្រា៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ **គ.ក.ច.** អាចបង្កើតគណៈកម្មការជំនាញតាមវិស័យ ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ក.ច.** ដែលក្នុងនោះ គណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ ចំនួន៤ គួរត្រូវបានគិតគូររៀបចំបង្កើតឡើង ដូចខាងក្រោម៖

១. គណៈកម្មការទទួលបន្ទុកនីតិសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា៖ សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងរ៉ែនិងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងទេសចរណ៍, ក្រសួងការងារនិងបណ្ដុះបណ្ដាល

វិជ្ជាជីវៈ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងផែនការ, ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

២. គណៈកម្មការទទួលបន្ទុកនីតិរដ្ឋបាលសាធារណៈ និងនីតិអន្តរជាតិ ៖ សម្រប-សម្រួលជាមួយក្រសួងមុខងារសាធារណៈ ក្រសួងអធិការកិច្ច ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានទទួលបន្ទុកកិច្ចការព្រំដែន។

៣. គណៈកម្មការទទួលបន្ទុកនីតិសង្គមកិច្ច វប្បធម៌ និងបរិស្ថាន៖ សម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងធម្មការនិងសាសនា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។

៤. គណៈកម្មការទទួលបន្ទុកនីតិសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការពារជាតិ៖ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌។

### ខ. ក្រុមការងារកែទម្រង់ច្បាប់តាមក្រសួង ស្ថាប័ន

អនុលោមតាមមាត្រា៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការងារកែទម្រង់ច្បាប់ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

### គ. យន្តការស្ថាប័នអន្តរវិស័យ

ក្រៅពីយន្តការគាំទ្រខាងលើ យន្តការស្ថាប័នអន្តរវិស័យមួយចំនួនទៀត អាចត្រូវបានរៀបចំបង្កើតឡើង សម្រាប់គាំទ្រការអនុវត្តវិធានការយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖

១. គណៈកម្មការជាតិការពារនីត្យានុកូលភាព

២. គណៈកម្មការជាតិភាសាច្បាប់។

# ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល

**ចក្ខុវិស័យ**

គ.ក.ច. ជានិម្មាបនករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជានិងគុណតម្លៃសាកល

**បេសកកម្ម៖** ដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជា ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា

ដំណាក់កាលទី១
ពិនិត្យានុការូបនីយកម្មគតិយុត្ត

ដំណាក់កាលទី២
សុខដុមការូបនីយកម្មគតិយុត្ត

ដំណាក់កាលទី៣
ឯកសណ្ឋានូបនីយកម្មនៃប្រព័ន្ធច្បាប់

ដំណាក់កាលទី៤
បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ

**យុទ្ធសាស្ត្រគន្លឹះទី១៖**
ដឹកនាំនិងសម្របសម្រួល ចងក្រងនិងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី២៖**
ដឹកនាំនិងសម្របសម្រួល រៀបចំក្របខ័ណ្ឌតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី៣៖**
ដឹកនាំនិងសម្របសម្រួល ពិនិត្យនិងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែងនិងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី៤៖**
ដឹកនាំនិងសម្របសម្រួល រៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្តនិងការពារនីត្យានុកូលភាព

**យន្តការគាំទ្រទី១៖**
គណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ

**យន្តការគាំទ្រទី២៖**
ក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័ន

**យន្តការគាំទ្រទី៣៖**
យន្តការស្ថាប័នអន្តរវិស័យ

**យុទ្ធសាស្ត្រគាំទ្រទី១៖**
រៀបចំផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ

**យុទ្ធសាស្ត្រគាំទ្រទី២៖**
រៀបចំស្តង់ដារប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤

**យុទ្ធសាស្ត្រគាំទ្រទី៣៖**
រៀបចំប្រព័ន្ធឌីជីថលលូបនីយកម្មសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤ ក្នុងយុគសម័យឌីជីថល

**យុទ្ធសាស្ត្រគាំទ្រទី៤៖**
រៀបចំផែនការអភិវឌ្ឍស្ថាប័នសម្រាប់ គ.ក.ច.

# ជំពូកទី២.
# ចក្ខុវិស័យស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## ២.១. ចក្ខុវិស័យនិងបេសកកម្ម

### ២.១.១. ចក្ខុវិស័យ

កម្មវិធីកែទម្រង់គន្លឹះទាំង ៥ មានចក្ខុវិស័យដោយឡែកពីគ្នាទៅតាមវិសេសភាព និងវិស័យរៀងៗខ្លួន ដែលមានដូចតទៅ៖

| កម្មវិធីកែទម្រង់ | ឆ្នាំគោលដៅ | ចក្ខុវិស័យ |
|---|---|---|
| កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២០២៧ | ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ |
| កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ២០៣០ | ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈនិងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ |

| កម្មវិធីកែទម្រង់ | ឆ្នាំគោលដៅ | ចក្ខុវិស័យ |
|---|---|---|
| វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា | ២០២៨ | ធានាឱ្យបាននូវរដ្ឋបាលសាធារណៈដែលមានលក្ខណៈខ្លាំង ស្អាតស្អំ ឆ្លាតវៃ និងផ្ដោតលើប្រជាជនជាស្នូល តាមរយៈការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា តាមរយៈ៖<br>ទី១-ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព<br>ទី២- ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព<br>ទី៣-ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។ |
| កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ | ២០៣០ | ពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌ ជូនប្រជាជនប្រកបដោយភាពឆាប់រហ័ស ងាយស្រួល សុចរិតភាព ភាពត្រឹមត្រូវ និងយុត្តិធម៌ |
| កម្មវិធីកែទម្រង់ច្បាប់ | ២០៤៥ | ជានិម្មាបនករនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល |

យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល មិនមានគោលដៅសំយោគនិងបង្រួមចក្ខុវិស័យនៃកម្មវិធីកែទម្រង់នីមួយៗ ទៅជាចក្ខុវិស័យតែមួយនោះទេ ដោយគោរពគោលការណ៍ភាពជាម្ចាស់ និងគោលការណ៍សុខដុមនីយកម្ម។

ផ្ទុយទៅវិញ ចក្ខុវិស័យដែលស្នើឡើងគឺជាចក្ខុវិស័យរបស់អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៥ ដែលជាអ្នកសម្របសម្រួលស្នូល ដើម្បីជានាឱ្យការងារកែទម្រង់គន្លឹះទាំង ៥ មានសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងសុខដុមនីយកម្មនឹងគ្នា។

ដូចនេះ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់គន្លឹះទាំង ៥ សម្រេចកំណត់ចក្ខុវិស័យរួមដូចតទៅ៖

| | |
|---|---|
| **ចក្ខុវិស័យ** | **សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** |

### ២.១.២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យរួមខាងលើ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់គន្លឹះទាំង ៥ នឹងអនុវត្តផែនការសកម្មភាពរួមគ្នា នៅក្នុងបេសកកម្មគន្លឹះមួយគឺ៖

| | |
|---|---|
| **បេសកកម្ម** | **ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព នៃភាពប្រទាក់ប្រឡាគ្នាជាអន្តរកែទម្រង់ ស្របតាមអតិក្រម ជវភាពនៃប្រព័ន្ធតួអង្គតែមួយ** |

## ២.២. ក្របខ័ណ្ឌផែនការសកម្មភាពរួមនិងប្រភពធនធានថវិកា

### ២.២.១. ក្របខ័ណ្ឌផែនការសកម្មភាពរួម

សមិទ្ធផល បញ្ហាប្រឈម និងបទពិសោធន៍ ក្នុងរយៈពេលប្រមាណ ១១ ឆ្នាំកន្លងមកនេះ នៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល គឺជាមូលដ្ឋានដ៏មានសារៈសំខាន់និងជាសត្យានុម័ត ដើម្បីជាការពិចារណាលើកាលានុវត្តភាពនិងអាទិភាពនៃសកម្មភាព ដែលអាចរៀបចំឡើងប្រកបដោយប្រសិទ្ធភាពនិងសក្ដិសិទ្ធិភាព។

ក្នុងន័យនេះ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់គន្លឹះទាំង ៥ បានពិនិត្យនិងពិចារណាលើសកម្មភាព ដោយសម្រួចផ្ដោតលើសកម្មភាពទាំងឡាយដែលយន្តការកិច្ចការកែទម្រង់គន្លឹះទាំង ៥ ជាយន្តការការងារដែលមាន "**សមានគតិភាព**" ជាងគេ និងអាចអនុវត្តទៅបានលទ្ធផលដោយ "**សក្ដិសិទ្ធិភាព**" ជាងគេ។

នេះជាកាលានុវត្តភាពដែលអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់គន្លឹះទាំង ៥ ត្រូវពិចារណាបង្កើតជាសកម្មភាព ដោយប្រកាន់អភិក្រម "**ស្រាល ស្រួច និងស្រេច**"។

ស្ថិតក្នុងស្មារតីនេះ និងដើម្បីសម្រេចបាននូវចក្ខុវិស័យនិងបេសកកម្មគន្លឹះខាងលើ អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់គន្លឹះទាំង ៥ សម្រេចដាក់ចេញក្របខ័ណ្ឌផែនការសកម្មភាពរួម ដែលមានលម្អិតជាយុទ្ធសាស្ត្រ ចំនួន ៣ និងគាំទ្រដោយកម្មវិធីចំនួន ១២ ដែលមានដូចតទៅ ៖

| **ចក្ខុវិស័យ** | **សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** |
|---|---|
| **បេសកកម្ម** | **ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្ដិសិទ្ធិភាពនៃភាពប្រទាក់ក្រឡាគ្នាជាអន្តរកែទម្រង់ ស្របតាមអភិក្រមជាភាពនៃប្រព័ន្ធតួអង្គតែមួយ** |

| អភិក្រម | ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីសក្តិសិទ្ធិភាពនិងសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល |
|---|---|
| យុទ្ធសាស្ត្រ | ១. សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ |
| កម្មវិធី | ១.១. កំណត់និងរៀបចំមុខងារនិងរចនាសម្ព័ន្ធ |
| | ១.២. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ |
| | ១.៣. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស |
| | ១.៤. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន/ប្រព័ន្ធឌីជីថល |
| យុទ្ធសាស្ត្រ | ២. សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម |
| កម្មវិធី | ២.១. រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា |
| | ២.២. រៀបចំនិងសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច |
| | ២.៣. ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់គន្លឹះ |
| | ២.៤. រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ន និង គុណភាពសេវាសាធារណៈ |
| យុទ្ធសាស្ត្រ | ៣. សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ |
| កម្មវិធី | ៣.១. រៀបចំនិងសម្របសម្រួលកិច្ចដំណើរការនិងការគាំទ្រកម្មវិធីកែទម្រង់គន្លឹះ |
| | ៣.២. រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់គន្លឹះ |

| | |
|---|---|
| | **៣.៣. រៀបចំនិងសម្របសម្រួលវិធានការនិងយន្តការលើកទឹកចិត្តនិងស្មារតីទទួលខុសត្រូវ** |
| | **៣.៤. រៀបចំនិងសម្របសម្រួលទស្សនកិច្ចសិក្សានៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស** |

## ២.២.១.១. យុទ្ធសាស្ត្រទី១ ៖ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ

យុទ្ធសាស្ត្រនេះមានគោលដៅធ្វើឱ្យការងារកែទម្រង់គន្លឹះ ក្លាយជា "ប្រព័ន្ធតួអង្គតែមួយ" ពោលគឺ ការងារកែទម្រង់ទាំង៥ អាចបំពេញការងាររៀងៗខ្លួន ដោយមិនជាន់គ្នា តែត្រូវប្រទាក់ក្រឡាគ្នា តាមរយៈយន្តការសម្របសម្រួលនិងសហការគ្នា ដើម្បីសម្រេចនូវចក្ខុវិស័យ បេសកកម្ម គោលបំណង និងកម្មវិធីនៃការងារកែទម្រង់នីមួយៗប្រកបដោយប្រសិទ្ធភាព។

ថ្វីត្បិតកម្មវិធីកែទម្រង់នីមួយៗ ស្ថិតក្រោមសមត្ថកិច្ចដឹកនាំអនុវត្តដោយក្រសួងដោយឡែកពីគ្នា សកម្មភាពកែទម្រង់ជាក់ស្តែងភាគច្រើន គឺអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀត ដែលនេះគឺជាលក្ខណៈពិសេសជាប្រព័ន្ធនិងប្រទាក់ក្រឡានៃកម្មវិធីកែទម្រង់គន្លឹះ ខាងលើនេះ។ ទំនាក់ទំនងជាប្រព័ន្ធនិងប្រទាក់ក្រឡានេះ មានមិនត្រឹមតែរវាងក្រសួង ស្ថាប័នដឹកនាំការងារកែទម្រង់ (តួអង្គនិម្មាបនករកែទម្រង់) ជាមួយនឹងក្រសួង ស្ថាប័នអនុវត្តការងារកែទម្រង់ (តួអង្គប្រតិបត្តិករកែទម្រង់) តែប៉ុណ្ណោះទេ លើសពីនេះនឹងរឹតតែសំខាន់ជាងនេះ នោះគឺទំនាក់ទំនងនិងភាពប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់នីមួយៗ ឬនិម្មាបនកម្មកែទម្រង់នីមួយៗតែម្តង គឺ***ការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល***។

### ក. កំណត់និងរៀបចំមុខងារនិងរចនាសម្ព័ន្ធ

មុខងារនៅទីនេះ សំដៅដល់វិចារណកម្មមុខងារនៅក្នុងចំណោមក្រសួង ស្ថាប័នថ្នាក់ជាតិនិងការផ្ទេរមុខងាររវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ការផ្ទេរមុខងារ តែងតែទាមទារឱ្យមានការគិតគូរទន្ទឹមគ្នានូវការផ្ទេរធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ទើបការអនុវត្តមុខងារដែលត្រូវបានផ្ទេរអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

ក្នុងន័យនេះ កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនឹងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់មុខងារនិងរចនាសម្ព័ន្ធ ជាអាទិ៍ការបង្កើត ការលុបចោល និងបញ្ចូលនូវរចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងការបង្កើត ឬផ្ទេរមុខងារ រវាងថ្នាក់ជាតិ រវាងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ទាំងពីរ ដែលអាចមានបច្ច័យលើការងារហិរញ្ញវត្ថុ ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

**ខ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ**

ជាសត្យានុម័ត ការអនុវត្តមុខងារនិងភារកិច្ចរបស់ក្រសួង ស្ថាប័ន ត្រូវមានថវិកាគាំទ្រ។ នៅក្នុងបរិបទដែលសមិទ្ធកម្មក្លាយជាគោលដៅនៃការគ្រប់គ្រងក្នុងរដ្ឋបាលសាធារណៈកម្ពុជា ថវិកាមិនត្រឹមតែជាការគាំទ្រដល់ការបំពេញមុខងារនិងភារកិច្ចតែប៉ុណ្ណោះទេ តែថវិកាគឺជាឧបករណ៍នៃគោលនយោបាយ ឬថវិកាត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ឬនិយាយម្យ៉ាងទៀត ការប្រើប្រាស់ថវិកាត្រូវសម្រេចលទ្ធផលដែលបានគ្រោងទុក។ នេះគឺជាគោលនយោបាយថវិកាសមិទ្ធកម្ម នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយឡែក នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់គន្លឹះ ហិរញ្ញវត្ថុ ឬថវិកា ត្រូវគាំទ្រនិងមានសង្គតិភាពទៅនឹងគោលនយោបាយវិមជ្ឈការ គោលនយោបាយធនធានមនុស្ស និងគោលនយោបាយច្បាប់និងប្រព័ន្ធយុត្តិធម៌ផងដែរ។

កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ដែលមានបច្ច័យលើមុខងាររចនាសម្ព័ន្ធ ធនធានមនុស្ស និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាអាទិ៍ការរៀបចំរចនាសម្ព័ន្ធកម្មវិធីនិងរចនាសម្ព័ន្ធស្ថាប័ន ការផ្ទេរធនធានហិរញ្ញវត្ថុទៅតាមមុខងារ រចនាសម្ព័ន្ធ ឬធនធានមនុស្សដែលត្រូវបានផ្ទេរ។

### គ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស

ការកែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើសមាសធាតុគន្លឹះចំនួន ៣ គឺ ការកែទម្រង់និងអភិវឌ្ឍសមត្ថភាពស្ថាប័ន ការកែទម្រង់ប្រព័ន្ធបៀវត្ស និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលសំដៅដល់មន្ត្រីរាជការ។ បេសកកម្មទាំង ៣ នេះ មានទំនាក់ទំនងនិងគាំទ្រដល់កម្មវិធីកែទម្រង់ ៣ ផ្សេងទៀតដោយផ្ទាល់ គឺ មុខងារ និងហិរញ្ញវត្ថុ។

ក្នុងន័យនេះ កម្មវិធីនេះប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានបច្ច័យលើការកែទម្រង់មុខងារ រចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាអាទិ៍ការបំពាក់សមត្ថភាពក្នុងការអនុវត្តការងារកែទម្រង់ទាំង៥ ការបណ្តុះភាពជាអ្នកដឹកនាំនិងឆន្ទៈក្នុងការអនុវត្តការងារកែទម្រង់, ការផ្ទេរធនធានមនុស្សទៅតាមមុខងារនិងរចនាសម្ព័ន្ធ, ការលើកទឹកចិត្តតាមលទ្ធភាពហិរញ្ញវត្ថុដែលអាចទ្រទ្រង់បាន។

### ឃ. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន/ប្រព័ន្ធឌីជីថល

ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ "បច្ចេកវិទ្យា" ត្រូវបានកំណត់ជារបៀបវារៈអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ នេះ ផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល បន្ថែមលើអាទិភាព ៤ ដែលមានស្រាប់រួមមាន មនុស្ស ទឹក ផ្លូវ ភ្លើង។ គោលនយោបាយគន្លឹះចំនួន ២ ត្រូវបានដាក់ចេញរួមមាន ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។

ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដោយកំណត់យកចក្ខុវិស័យ "***កសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើកដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មីនិងលើកកម្ពស់សុខុមាលភាពសង្គមផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី***"។ ក្របខ័ណ្ឌគោលនយោបាយនេះ ផ្តោតលើ

សមាសធាតុចំនួន ៥ ដែលចែកចេញជាគ្រឹះចំនួន២ (ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និងការកសាងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល) និងសសរស្ដម្ភចំនួន ៣ (ការកសាងពលរដ្ឋឌីជីថល ការកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល)។ ក្របខ័ណ្ឌគោលនយោបាយនេះ ត្រូវដឹកនាំអនុវត្តដោយក្រុម-ប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថលដែលមាននាយករដ្ឋមន្ត្រីជាប្រធានដោយចែកចេញជាគណៈកម្មាធិការចំនួន ៣ គឺ គណៈកម្មាធិការសេដ្ឋកិច្ចឌីជីថលនិងធុរកិច្ចឌីជីថល គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។

ដោយឡែក គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ មានចក្ខុវិស័យ "***កសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែប្រសើរ***"។ គោលនយោបាយនេះ បានកំណត់នូវយុទ្ធសាស្ត្រចំនួន ១០ រួមមាន ទី១.ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល, ទី២.ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ, ទី៣.ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល, ទី៤.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាប្រៃសណីយ៍, ទី៥.ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល, ទី៦.ការធ្វើបរិវត្តកម្មរដ្ឋាភិ-បាលឌីជីថលនិងសេវាសាធារណៈ, ទី៧.ការកសាងមូលធនមនុស្សឌីជីថល, ទី៨.ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល,ទី៩.ការរៀបចំកិច្ចសហការជាមួយក្រុម-ហ៊ុនបច្ចេកវិទ្យាឌីជីថល និងទី១០.ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល។

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ផ្នែកអភិបាលកិច្ចសាធារណៈ (Public Governance Reform) ដែលសំដៅដល់កម្មវិធីកែទម្រង់ជាប្រព័ន្ធអន្តរកែទម្រង់ទាំង ៥ នេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនទៀតបាននិងកំពុងដំណើរការស្រាប់ ដែលរួមមានជាសារវ័ន្តដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) ជាដើមដែលនៅក្នុង

នោះមានអនុប្រព័ន្ធជាច្រើនទៀតដែលគាំទ្រដល់ប្រព័ន្ធមេទាំងនេះ។

ជាក់ស្តែង ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) គឺប្រព័ន្ធជាស្នូល ដែលត្រូវទទួលនូវទិន្នន័យតាមរយៈការធ្វើសន្ធានកម្មពីប្រព័ន្ធដទៃជាច្រើនរួមមាន ប្រព័ន្ធព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS), ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS), ប្រព័ន្ធបញ្ជរតែមួយជាតិ, ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម ។ល។ ដោយឃើញពីកំណើននៃការធ្វើឌីជីថលូបនីយកម្មកិច្ចប្រតិបត្តិការការងារជាបន្តបន្ទាប់និងដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃអភិបាលកិច្ចទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងក្នុងគោលបំណង **"ធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថលប្រកបប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព"** ដោយឈរលើគោលការណ៍ចំនួន ៣ គឺ ទី១.គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, ទី២.គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ និងទី៣.គោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព ដែលបានដាក់ចេញក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។

កម្មវិធីនេះត្រូវប្រមូលផ្តុំនូវសកម្មភាពពាក់ព័ន្ធការសម្របសម្រួលនិងការបង្កើនប្រសិទ្ធភាពនៃការងារកែទម្រង់មុខងារ រចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងធនធាន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអាចជាប្រព័ន្ធតែមួយ ឬប្រព័ន្ធដោយឡែកៗពីគ្នា។ រីតសំខាន់ជាងនេះ អ្វីដែលជាគោលបំណងអាទិភាពនៅក្នុងកម្មវិធីមួយនេះ នោះគឺការដាក់ចេញនូវសកម្មភាពពាក់ព័ន្ធនឹងសុខដុមនីយកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ ដើម្បីធានាថាប្រព័ន្ធទាំងនោះគាំទ្រឱ្យគ្នា សុខដុមនឹងគ្នា ប្រទាក់ក្រឡាគ្នា ដោយមិនប្រទាំងប្រទើសគ្នា ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពសម្រាប់គាំទ្រគោល-

នយោបាយកម្រិតរដ្ឋាភិបាលផ្ដោតលើឌីជីថលូបនីយកម្មនៃរដ្ឋបាលសាធារណៈ សំដៅរដ្ឋាភិបាលឌីជីថល និងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចឌីជីថល ដូចបានរៀបរាប់ខាងលើ។

### ២.២.១.២. យុទ្ធសាស្ត្រទី២. សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

សមិទ្ធកម្ម គឺជាគោលដៅគន្លឹះនៃអភិបាលកិច្ចសាធារណៈនិងជាគោលដៅគន្លឹះនៃការកែទម្រង់ផងដែរ។ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការទទួលខុសត្រូវលើលទ្ធផល ឬនិយាយម្យ៉ាងទៀត គណនេយ្យភាពលើសមិទ្ធកម្ម គឺជាគោលដៅនៃដំណាក់កាលទី៤ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់មួយនេះ។ ដោយឡែក សម្រាប់សេចក្ដីព្រាងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ សមិទ្ធកម្ម គឺជាមធ្យោបាយផងនិងជាគោលដៅចុងក្រោយផងដែលត្រូវបានលើកឡើងដូចជា ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មស្ថាប័នសាធារណៈ និងគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ ជាដើម។ ទន្ទឹមនេះ ផ្អែកលើឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ កម្ពុជាបានជ្រើសរើសយក "**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**" (Performance Informed Budgeting) ជាទិសដៅជាក់លាក់ ដើម្បីកសាងប្រព័ន្ធថវិការបស់ខ្លួនស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

ក្នុងន័យនេះ យុទ្ធសាស្ត្រនេះប្រមូលផ្ដុំនូវកម្មវិធីនិងសកម្មភាពពាក់ព័ន្ធការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ជាអាទិ៍ការរៀបចំនិងសម្របសម្រួលអង្គភាពថវិកាឱ្យបន្សុីគ្នាជាមួយមុខងារនិងរចនាសម្ព័ន្ធ, ការសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច, ការពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់គន្លឹះ ព្រមទាំងការរៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិងគុណភាពសេវាសាធារណៈ។

#### ក. រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា

អង្គភាពថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត។ គិតត្រឹមឆ្នាំ២០២៤ អង្គភាពថវិកាសរុបមានចំនួន ៩៣៩ ដែលក្នុងនោះ មាន ៦០៣ ជាអង្គភាពថវិកានៅតាមថ្នាក់មូលដ្ឋាន (មន្ទីររាជធានី ខេត្ត) ដែល

ជំពូក២

សុទ្ធសឹងជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, និង ៣៣៦ ជាអង្គភាពថវិកានៅថ្នាក់កណ្តាល។ ក្នុងចំណោម អង្គភាពថវិកានៅថ្នាក់កណ្តាលទាំង ៣៣៦ មានតែអង្គភាពចំនួន ១២០ ឬស្មើនឹង៣៦% ជាអង្គភាពថវិកាអាណាបកផ្ទេរសិទ្ធិពេញលេញ។ ដូចនេះ ការងារដែលបាននិងកំពុងបន្តពង្រឹងនិងពង្រីក គឺការពិនិត្យលទ្ធភាពនិងវាយតម្លៃលក្ខណៈសម្បត្តិរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ននីមួយៗដើម្បីតម្លើងតួនាទីឱ្យទៅជាអង្គភាពថវិកាបន្ថែមទៀត, ការវាយតម្លៃលក្ខណៈសម្បត្តិនិងតម្លើងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, ការវាយតម្លៃដើម្បីពង្រឹងការអនុវត្តសិទ្ធិអំណាចរបស់អង្គភាពថវិកាជារួម និងចុងក្រោយគឺការពិនិត្យលើការរៀបចំនិងការអនុវត្តថវិកាកម្មវិធីជារួមរបស់ក្រសួង ស្ថាប័ន ជាពិសេសគឺការផ្សារភ្ជាប់ឱ្យកាន់តែមានប្រសិទ្ធភាពរវាងរចនាសម្ព័ន្ធគ្រប់គ្រងនិងរចនាសម្ព័ន្ធគោល-នយោបាយ។

កាលពីឆ្នាំ២០២៣ គណនេយ្យភាពរបស់អង្គភាពថវិកាចំពោះសមិទ្ធកម្មត្រូវបានកើនឡើងមួយកម្រិតទៀតតាមរយៈការអនុវត្ត "**កិច្ចព្រមព្រៀងសមិទ្ធកម្ម**" (Performance Agreement) ដែលនឹងមានជា ៣ កម្រិតនៃកិច្ចព្រមព្រៀង គឺ៖ ទី១) កិច្ចព្រម-ព្រៀងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួង ស្ថាប័ន, ទី២) រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួងស្ថាប័នសាមី និងទី៣) កិច្ចព្រមព្រៀងរវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា ដែលនៅពេលនោះមានក្រសួងស្ថាប័នចំនួន ៧ ប៉ុណ្ណោះដែលបានសាកល្បងអនុវត្ត។ សម្រាប់ឆ្នាំ២០២៥, គ្រប់ក្រសួងស្ថាប័នទាំងអស់នឹងត្រូវអនុវត្តសាកល្បងនូវកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតខាងលើ។

ក្នុងន័យនេះ យុទ្ធសាស្ត្រនេះនឹងប្រមូលផ្តុំនូវសកម្មភាពដែលមានភាពប្រទាក់ក្រឡាគ្នារវាងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកាងារកែទម្រង់រដ្ឋបាលសាធារណៈក៏ដូចជាការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ក្នុងគោលបំណងបង្កើតនិងបង្កើនចំនួន

អង្គភាពថវិកានិងអង្គភាពថវិកាអាណាបកផ្ទេរសិទ្ធិពេញលេញ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត សំដៅដល់ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងចុងក្រោយគឺពង្រឹងប្រសិទ្ធភាពសេវាសាធារណៈ។

### ខ. រៀបចំនិងសម្របសម្រួលការងារសវនកម្មនិងអធិការកិច្ច

សម្រាប់បរិបទកម្ពុជា សវនកម្មនិងអធិការកិច្ចគឺជាមុខងារគន្លឹះនៃប្រព័ន្ធត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអាចលម្អិតចេញជាបួនមុខងារបន្ថែមទៀត គឺសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្រៅ អធិការកិច្ចហិរញ្ញវត្ថុ និងអធិការកិច្ចទូទៅ។

សម្រាប់សវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជានិម្មាបនករនៃប្រព័ន្ធ ជាអ្នករៀបចំគោលនយោបាយនិងរៀបចំស្តង់ដាសវនកម្មផ្ទៃក្នុង សម្រាប់ក្រសួង ស្ថាប័នយកទៅអនុវត្តតាមរយៈអង្គភាពឬនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ខ្លួន។ សម្រាប់អធិការកិច្ចហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋ។ សវនកម្មផ្ទៃក្រៅគឺជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិ។ ចុងក្រោយ អធិការកិច្ចលើគ្រប់វិស័យ ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងអធិការកិច្ច ដែលជាអធិការកិច្ចរបស់រាជរដ្ឋាភិបាលផ្អែកលើអតិក្រមតាមបណ្តឹង ផ្អែកលើហានិភ័យ តាមសំណើ មានភាពមិនប្រក្រតី និងតាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

ដោយឡែក នៅក្នុងគ្រប់ក្រសួង ស្ថាប័នថ្នាក់កណ្តាល សុទ្ធតែមាននូវនាយកដ្ឋានឬអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពទទួលបន្ទុកអធិការកិច្ច ក្រោមឈ្មោះជាអគ្គាធិការដ្ឋាន។ នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏គ្រោងបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅក្នុងកម្រិតរដ្ឋបាលរាជធានី ខេត្តផងដែរ។

គោលបំណងនៃសុខដុមនីយកម្មការកែទម្រង់គន្លឹះត្រង់កម្មវិធីនេះ គឺសុខដុមនីយកម្មនៃការបំពេញមុខងារនិងភារកិច្ចសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្រៅ អធិការកិច្ចហិរញ្ញវត្ថុ

និងអធិការកិច្ចទូទៅរបស់រាជរដ្ឋាភិបាល ទាំងក្នុងក្របខ័ណ្ឌសុខដុមនីយកម្មផ្ទៃក្នុងក្រសួង ស្ថាប័នសាមីនីមួយៗ និងក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរវាងក្រសួង ស្ថាប័នធ្វើសវនកម្ម/អធិការកិច្ចជាមួយនឹងក្រសួង ស្ថាប័នទទួលរងសវនកម្ម/អធិការកិច្ចផងដែរ។

**គ. ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់គន្លឹះ**

ការពិនិត្យនិងតាមដានសមិទ្ធកម្ម ជាក្របខ័ណ្ឌឬយន្តការដែលប្រើប្រាស់នូវវិធីសាស្ត្រនៃការវាយតម្លៃនិងផ្ទៀងផ្ទាត់មួយជាក់លាក់នូវយុទ្ធសាស្ត្រ ឬផែនការសកម្មភាព ធៀបនឹងលទ្ធផលដែលសម្រេចបានពីការអនុវត្តជាក់ស្តែង ដោយមានការកំណត់នូវក្របខ័ណ្ឌពេលវេលា សូចនាករសមិទ្ធកម្មគន្លឹះ គោលដៅ លទ្ធផលរំពឹងទុកជាក់លាក់។

សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការពិនិត្យវាយតម្លៃសមិទ្ធកម្មជាប្រចាំ ត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត ដោយផ្អែកលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនិងរបាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ននីមួយៗ។

**ឃ. រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិងគុណភាពសេវាសាធារណៈ**

ប្រសិទ្ធភាពស្ថាប័ន សំដៅដល់លក្ខខណ្ឌដែលស្ថាប័នអាចសម្រេចការងាររបស់ខ្លួនតាមស្ថានភាពនិងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងស្ថាប័នរបស់ខ្លួនផ្ទាល់ ដូចជា៖

- អ្នកដឹកនាំកំណត់នូវចក្ខុវិស័យ បេសកកម្ម គោលដៅច្បាស់លាស់សម្រាប់អ្នកអនុវត្តការងារ ហើយគូសបង្ហាញផ្លូវដើរនិងមធ្យោបាយ ទៅសម្រេចឱ្យបាននូវចក្ខុវិស័យ បេសកកម្ម គោលដៅទាំងនោះ ប្រកបដោយផលិតភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព
- អ្នកដឹកនាំនិងគ្រប់គ្រងកំណត់និងរៀបចំប្រព័ន្ធនិងកិច្ចដំណើរការការងារ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធនិងមុខងារ ដោយបន្សុីគ្នាជាមួយការកំណត់និងការ

បែងចែកការងាររបស់អ្នកអនុវត្តការងារ ព្រមទាំងយន្តការនៃការសម្រេចការងារ

➢ អ្នកអនុវត្តការងារមានសមត្ថភាពនិងឆន្ទៈសម្រេចបាននូវលទ្ធផលការងារតាមការរំពឹងទុកទៅតាមមុខងារនិងភារកិច្ចដែលត្រូវបានប្រគល់ឱ្យដោយស្ថាប័ន។

ប្រសិទ្ធភាពស្ថាប័ន ចូលរួមចំណែកសម្រេចបាននូវស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ គឺការកែទម្រង់ និង ការពង្រឹង អភិបាលកិច្ច ដែលមានបេសកកម្មចំនួន ២ គឺទី១- រក្សានិងថែបំប៉នសុខសន្តិភាព និងទី២- កសាងនិងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ ព្រមទាំងគោលដៅយុទ្ធសាស្ត្រទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១រួមមាន៖ (១) កំណើនសេដ្ឋកិច្ច (២) បង្កើតការងារទាំងបរិមាណ និងគុណភាព (៣) កាត់បន្ថយភាពក្រីក្រទាបជាង ១០% (៤) ពង្រឹងសមត្ថភាពអភិបាលកិច្ចនិងលើកកម្ពស់គុណភាពស្ថាប័ន និង (៥) ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

### ២.២.១.៣. យុទ្ធសាស្ត្រទី៣ ៖ សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ

តាមរយៈយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះនេះ យន្តការសម្របសម្រួលជាកិច្ចប្រជុំប្រចាំត្រីមាស ត្រូវបានពង្រឹងបន្ថែមដោយការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់គន្លឹះ។ យន្តការសម្របសម្រួលដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការកែទម្រង់ចំនួន ៣ ត្រូវបានតម្លើងកម្រិតមកជាអនុក្រឹត្យ។

កិច្ចដំណើរការនៃការងារកែទម្រង់គន្លឹះ កាន់តែមានមូលដ្ឋាននិងយន្តការច្បាស់លាស់ជាងមុន។ សកម្មភាពពាក់ព័ន្ធនឹងប្រព័ន្ធដំណើរការនេះ នឹងត្រូវលម្អិតនៅក្រោមកម្មវិធីនីមួយៗនៃយុទ្ធសាស្ត្រទី៣នេះ។

#### ក. រៀបចំនិងសម្របសម្រួលកិច្ចដំណើរការនិងការគាំទ្រកម្មវិធីកែទម្រង់គន្លឹះ

កិច្ចដំណើរការនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់គន្លឹះ ត្រូវបានកំណត់ដោយអនុក្រឹត្យមួយដែលនៅក្នុងនោះបានបញ្ជាក់អំពីយន្តការផ្លាស់ប្តូរវេនប្រចាំត្រីមាសរវាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ, តួនាទីនិងភារកិច្ចរបស់ប្រធាន

ទទួលវេន, ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ, របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងរបបកិច្ចប្រជុំ ជាដើម។

### ខ. រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់គន្លឹះ

ការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់គន្លឹះ អាចត្រូវបានរៀបចំក្នុងគោលបំណងច្រើនយ៉ាង ដូចតទៅ៖

- ការរៀបចំកម្មវិធីបណ្តុះបណ្តាលរួមគ្នារវាងកម្មវិធីកែទម្រង់គន្លឹះជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើប្រធានបទពាក់ព័ន្ធនឹងអភិបាលកិច្ចនិងជាពិសេសលើប្រធានបទដែលពាក់ព័ន្ធនឹងការងារអន្តរកែ-ទម្រង់។ យន្តការនេះអាចរៀបចំទៅបានប្រកបដោយប្រសិទ្ធភាពដោយហេតុថាក្រសួងដឹកនាំកម្មវិធីកែទម្រង់នីមួយៗសុទ្ធសឹងតែមាននូវស្ថាប័នបណ្តុះ-បណ្តាលរៀងៗខ្លួន ក្នុងនោះរួមមាន សាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ **កសហវ**. បណ្ឌិត្យសភា-ភូមិន្ទយុត្តិធម៌កម្ពុជានៃក្រសួងយុត្តិធម៌ និងសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ
- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ឬពិភាក្សាលើប្រធានបទជាក់លាក់ណាមួយដែលមានលក្ខណៈអន្តរកែទម្រង់
- ការរៀបចំផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សេងៗដូចជា ខិតប័ណ្ណ វីដេអូ និងការផ្សព្វផ្សាយផ្សេងៗទៀតនៅតាមគ្រឹះស្ថានសិក្សា ចំពោះសាធារណជនជាទូទៅ។

### គ. រៀបចំនិងសម្របសម្រួលវិធានការនិងយន្តការលើកទឹកចិត្តនិងស្មារតីទទួល-ខុសត្រូវ

សមិទ្ធកម្មគឺជាមូលដ្ឋាននៃវិធានការលើកទឹកចិត្តនិងការរឹតត្បិត។ ការលើកទឹកចិត្តកើតមាននៅពេលដែលសមិទ្ធកម្មឬលទ្ធផលបានសម្រេចតាមគោលដៅរំពឹងទុកឬលើសពី

គោលដៅ ឬអាចមានការចំណាយធនធានឬពេលវេលាតិចជាងការកំណត់។ ការរឹតត្បិតអាចកើតមាននៅពេលដែលលទ្ធផលរំពឹងទុកមិនត្រូវបានសម្រេចឬក៏ការសម្រេចបានលទ្ធផលនោះបានចំណាយធនធានឬពេលវេលាលើសពីការកំណត់ទុកជាមុន។ ការលើក-ទឹកចិត្តឬរឹតត្បិត អាចមានរូបភាពក្រោមទម្រង់ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ដែលអាចជាការផ្តល់ជូននូវសម្ភារៈ មុខតំណែង កិត្តិយស ការសរសើរ ឬដំណើរទស្សនកិច្ចជាដើម។ ការអនុវត្តវិធានការបែបនេះគឺជាកត្តាមួយដែលចូលរួមចំណែកជំរុញឱ្យស្ថាប័នសាធារណៈ និងការបម្រើសេវាសាធារណៈកាន់តែមានប្រសិទ្ធភាព។

ជាឧទាហរណ៍ជាក់ស្តែង នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានបង្កើតឡើងដើម្បីផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន ក៏ប៉ុន្តែចំនួនអ្នកត្រូវទទួលបានប្រាក់ឧបត្ថម្ភ និងចំនួនប្រាក់ឧបត្ថម្ភត្រូវទទួលបានត្រូវផ្អែកលើគុណភាពនិងប្រសិទ្ធភាពនៃផែនការសកម្មភាពកែទម្រង់និងការអនុវត្តផែនការនេះ និងសមិទ្ធកម្មដែលសម្រេចបានជាប្រចាំឆ្នាំនៃផែនការសកម្មភាពកែទម្រង់នោះ។

### ឃ. រៀបចំនិងសម្របសម្រួលទស្សនកិច្ចសិក្សានៅតាមការដ្ឋានកែទម្រង់ក្នុង និងក្រៅប្រទេស

ទស្សនកិច្ចសិក្សានៅក្នុងប្រទេស គឺជាការចុះទៅសង្កេតផ្ទាល់នៅតាមស្ថាប័ន អង្គភាព ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យសិក្សាពីបទពិសោធន៍ជាក់ស្តែង វឌ្ឍនភាព កិច្ច-ដំណើរការ និងជាពិសេសបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តដែលត្រូវបានសម្រេចដោយរាជរដ្ឋាភិបាល។ ការចុះទស្សនកិច្ចនេះមានអត្ថ-ប្រយោជន៍ចំពោះអ្នករៀបចំគោលនយោបាយនិងអ្នករៀបចំទិសដៅកែទម្រង់ ដើម្បីបានយល់ដឹងពីសភាពការណ៍ពិតជាក់ស្តែងនិងផ្តល់ឱកាសពិចារណាអំពីការផ្សារភ្ជាប់រវាងគោលនយោបាយនិងប្រសិទ្ធភាពនៃការអនុវត្ត។

ដោយឡែក ទស្សនកិច្ចសិក្សានៅក្រៅប្រទេស ក៏ជាវិធីសាស្ត្រមួយទៀតដែលមិនអាចខ្វះបាន ដោយហេតុថាបេសកកម្មបែបនេះផ្តល់នូវមេរៀននិងបទពិសោធន៍ល្អៗជាឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីអាចដកស្រង់យកមកពិចារណា ពិនិត្យ និងសម្រួចរៀបចំនូវគោលនយោបាយទាំងឡាយតម្រូវសម្រាប់បរិការណ៍រដ្ឋបាលនិងសង្គមកម្ពុជា។

### ២.២.២. ប្រភពធនធានថវិកាគាំទ្រ

ដើម្បីអនុវត្តក្របខ័ណ្ឌផែនការសកម្មភាពខាងលើប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានដែលដឹកនាំលើសកម្មភាពនីមួយៗត្រូវទទួលខុសត្រូវលើការរៀបចំនិងគ្រោងធនធានថវិកាគាំទ្រ ដែលអាចត្រូវបានប្រើប្រាស់ពីប្រភពដូចខាងក្រោម៖

១. ថវិកាប្រចាំឆ្នាំនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកម្មវិធីកែទម្រង់នីមួយៗ

២. ថវិកាគាំទ្ររបស់ដៃគូអភិវឌ្ឍន៍

៣. មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៤. ថវិការដ្ឋ

៥. ផ្សេងៗ។

## ក្របខ័ណ្ឌចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

**សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**

**ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព នៃភាពប្រទាក់ប្រទាគ្នាជាអន្តរកែទម្រង់ ស្របតាមអភិក្រមជាវភាពនៃប្រព័ន្ធតួអង្គតែមួយ**

| យុទ្ធសាស្ត្រទី១ | យុទ្ធសាស្ត្រទី២ | យុទ្ធសាស្ត្រទី៣ |
|---|---|---|
| សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ | សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ |
| កម្មវិធី | កម្មវិធី | កម្មវិធី |
| ១.១. កំណត់និងរៀបចំមុខងារ និង រចនាសម្ព័ន្ធ | ២.១. រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា | ៣.១. រៀបចំនិងសម្របសម្រួលកិច្ចដំណើរការនិងការគាំទ្រកម្មវិធីកែទម្រង់គន្លឹះ |
| ១.២. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ | ២.២. រៀបចំនិងសម្របសម្រួលការងារសវនកម្ម និង អធិការកិច្ច | ៣.២. រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់គន្លឹះ |
| ១.៣. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស | ២.៣. ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់គន្លឹះ | ៣.៣. រៀបចំនិងសម្របសម្រួលវិធានការនិងយន្តការលើកទឹកចិត្តនិងស្មារតីទទួលខុសត្រូវ |
| ១.៤. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន/ប្រព័ន្ធឌីជីថល | ២.៤. រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិង គុណភាពសេវាសាធារណៈ | ៣.៤. រៀបចំនិងសម្របសម្រួលទស្សនកិច្ចនៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស |

ជំពូកទី២

## ២.៣. យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

### ២.៣.១. មុខងារនិងភារកិច្ច

**យ.ស.ក.** ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាសរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.ក.** មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **យ.ស.ក.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយ ជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយតាមបង្គាប់របស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- តាមដានរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារដែលមានចរិតអន្តរកែទម្រង់ ដោយប្រើប្រាស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាមជ្ឈមណ្ឌលកណ្តាលក្នុងការសម្របសម្រួលនិងបូកសរុបរបាយការណ៍រួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈរដ្ឋបាលរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព

សុខដុមនីយកម្មការកែទម្រង់ទាំង ៥ នៃរាជរដ្ឋាភិបាល

- ➢ រៀបចំនិងកំណត់របៀបវារៈប្រជុំ **យ.ស.ក.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- ➢ រៀបចំនិងជានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- ➢ រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- ➢ រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗ គឺជា "ប្រធាន **យ.ស.ក.**" ប្រចាំត្រីមាសនោះ។ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬអនុប្រធានលេខាធិការដ្ឋានទទួលបន្ទុកដឹកនាំជំនួសបាន។

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាព ដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីជានាការចូលរួមអនុវត្ត **យ.ស.ក.** ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗគឺជាប្រធាន **យ.ស.ក.** ប្រចាំត្រីមាសនោះ។ ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

ប្រធាន **យ.ស.ក.** ត្រូវជានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ខាងលើ

ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។ ប្រធាន **យ.ស.ក.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។ ទន្ទឹមនឹងនេះ ប្រធាន **យ.ស.ក.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ចូលរួមប្រជុំបានតាមការចាំបាច់។ ប្រធាន **យ.ស.ក.** អាចអញ្ជើញ ដៃគូអភិវឌ្ឍន៍នានា ចូលរួមប្រជុំបានតាមការចាំបាច់។

### ២.៣.២. ការរៀបចំផែនការសកម្មភាពនិងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព

**យ.ស.ក.** ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្ដាហ៍ទី៤ នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១ នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំនិងបូកសរុបផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំង៥ មានសិទ្ធិចេញសេចក្ដីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

## ២.៣.៣. កិច្ចប្រជុំប្រចាំត្រីមាស

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាសត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **យ.ស.ក.** នៃត្រីមាសបន្ទាប់។

របាយការណ៍កិច្ចប្រជុំត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **យ.ស.ក.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

ក្នុងករណីដែលអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខាន ឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស តាមចិរវេលាខាងលើ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបាន ដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

## ២.៣.៤. យន្តការសម្របសម្រួលកម្រិតមន្ត្រីបច្ចេកទេស

**យ.ស.ក.** គឺជាយន្តការសម្របសម្រួលដើម្បីសម្រិតសម្រាំងបញ្ហាប្រឈមនិងលើកសំណើជាជម្រើសដំណោះស្រាយជូនប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ។ ជាធម្មតា យន្តការនេះត្រូវជួបប្រជុំជាប្រចាំត្រីមាសនិងប្រចាំឆ្នាំ ឬតាមការចាំបាច់។ ដោយឡែក ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃកិច្ចដំណើរការប្រចាំថ្ងៃនៃការងារកែ-ទម្រង់គន្លឹះនេះ យន្តការសម្របសម្រួលកម្រិតបច្ចេកទេសមួយ ត្រូវបានបង្កើត ក្នុងកម្រិតមន្ត្រីបច្ចេកទេសធ្វើការរួមគ្នា។

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ អាចរៀបចំតែងតាំងសមាស-ភាពមន្ត្រីបង្គោលកម្រិតបច្ចេកទេសរបស់សាមីអង្គភាពនីមួយៗ សម្រាប់ **ឃ.ស.ភ.**។

មន្ត្រីបង្គោលកម្រិតបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ មានមុខងារនិងភារកិច្ច ដូចតទៅ៖

- សម្របសម្រួលនិងសហការជាមួយនឹងមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងពិភាក្សារៀបចំរបាយការណ៍ ឯកសារនានា និងជាពិសេសរបៀបវារៈ សម្រាប់កិច្ចប្រជុំប្រចាំត្រីមាស នៃ **ឃ.ស.ភ.**
- រៀបចំនិងដឹកនាំកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេស ជាមួយនឹងក្រុមមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ ៤ ផ្សេងទៀត តាមវេនប្រចាំត្រីមាសដែលត្រូវទទួលបន្ទុកនិងតាមការចាំបាច់
- ចូលរួមកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេសតាមការកោះប្រជុំរបស់ក្រុមមន្ត្រីបង្គោលនៃអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដែលជាប្រធានទទួលវេនប្រចាំត្រីមាសនីមួយៗ
- រៀបចំជំនួយស្មារតីនិងបូកសរុបរបាយការណ៍ សម្រាប់និងមុនកិច្ចប្រជុំប្រចាំត្រីមាសនីមួយៗ
- សម្របសម្រួលនិងសហការជាមួយនឹងលេខាធិការដ្ឋានកែទម្រង់ ៤ ផ្សេងទៀត តាមការចាំបាច់។

គួរបញ្ជាក់ថា ក្រុមមន្ត្រីបង្គោលនៃលេខាធិការដ្ឋានកែទម្រង់ដែលត្រូវដឹកនាំវេនប្រចាំត្រីមាស គឺជាអ្នកទទួលខុសត្រូវដឹកនាំនិងកោះហៅប្រជុំក្រុមមន្ត្រីបង្គោលផ្សេងទៀតនៅក្នុងត្រីមាសនោះ។

# សន្និដ្ឋាន

“**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**” នេះ គឺជាមគ្គុទេសក៍បង្ហាញផ្លូវសម្រាប់កម្មវិធីកែទម្រង់គន្លឹះទាំង ៥ ដែលគូសរំលេចអំពីការប្តេជ្ញាចិត្តនិងឆន្ទៈឥតងាករេនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំការកែទម្រង់និងការពង្រឹងអភិបាលកិច្ច ទុកជាស្នូល ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ជាពិសោធន៍ជាក់ស្តែង ការអនុវត្តកម្មវិធីកែទម្រង់នីមួយៗ ដែលរួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ អាចមានវិសាលភាពប្រទាក់ក្រឡាគ្នាជាច្រើនកន្លែង ច្រើនកម្រិត អាស្រ័យទៅតាមជំហានយុទ្ធសាស្ត្រ និងលំដាប់អាទិភាពនៃការងារកែទម្រង់នីមួយៗ ដែលបង្កើតបានជាកាលានុវត្តភាពថ្មីនៃការកសាងជវភាពនិងសហថាមភាពនៃទំនាក់ទំនងកិច្ចសហការ និងការគាំទ្រជូនគ្នាទៅវិញទៅមក ពីសំណាក់ការដ្ឋានកែទម្រង់មួយទៅកាន់ការដ្ឋានកែទម្រង់មួយទៀត។

ទោះជាយ៉ាងណាក៏ដោយ មគ្គុទេសក៍នេះ ពុំមានគោលបំណងគ្របដណ្តប់គ្រប់ទិដ្ឋភាពនិងស្ថានភាពនៃភាពប្រទាក់ក្រឡាគ្នារបស់ការដ្ឋានកែទម្រង់ទាំងអស់នោះទេ ពោលគឺនៅលើដំណើរផ្លូវនៃការអនុវត្ត **យ.ស.ភ.** ស្ថានការណ៍ថ្មីៗ អាចនឹងកើតមានឡើង ទៅតាមបរិបទនិងភាពជាក់ស្តែងនៃការដ្ឋានកែទម្រង់នីមួយៗ ដែលប្រការនេះតម្រូវឱ្យ **យ.ស.ភ.** ប្រើប្រាស់សិល្បសាស្ត្រនៃការកែទម្រង់ ប្រកបដោយស្មារតី “រៀនផងធ្វើផង”, “ពិនិត្យផង ប្រមើលផង” និង “ប្រាកដនិយមផង មហិច្ឆតានិយមផង”។

របាយការណ៍របស់អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ

អាចទុកជាស្តង់ដារវិជ្ជាជីវៈ សម្រាប់វាស់វែងវឌ្ឍនភាពនៃការអនុវត្ត **យ.ស.ក.** ដែលទទួលខុសត្រូវដោយអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាននីមួយៗនៅចំពោះមុខប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់នីមួយៗរៀងខ្លួនផង និងសម្រាប់វាស់វែងអំពីវិសាលភាពនៃកិច្ចសហការនិងការគាំទ្រគ្នាទៅវិញទៅមកពីអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់មួយទៅកាន់អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់មួយផ្សេងទៀតផង។ ក្នុងស្មារតីនេះ របាយការណ៍លទ្ធផលនៃ **យ.ស.ក.** ប្រចាំត្រីមាសនីមួយៗនិងប្រចាំឆ្នាំ គឺជាមូលដ្ឋាននៃការពិនិត្យនិងសម្រេចរបស់ប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់នីមួយៗ ក្នុងការជំរុញប្រសិទ្ធភាពនៃការកែទម្រង់រៀងខ្លួនផង និងសុខដុមនីយកម្មនៃអន្តរកែទម្រង់ផង។ ប្រសិទ្ធភាពនៃការកែទម្រង់នីមួយៗ និងសុខដុមនីយកម្មនៃអន្តរកែទម្រង់ពីរឬច្រើននៃកិច្ចការកែទម្រង់គន្លឹះ នឹងចូលរួមចំណែកយ៉ាងសកម្មដល់សមិទ្ធកម្មនៃស្នូលយុទ្ធសាស្ត្របញ្ចកោណ គឺ "**ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច**" របស់រាជរដ្ឋាភិបាល។

ចក្ខុវិស័យ នឹងក្លាយជាប្រទីបបំភ្លឺមាគ៌ាប្រសិទ្ធភាពនៃការកែទម្រង់ នៅពេលដែលយុទ្ធសាស្ត្រត្រូវបានកែផ្លាស់ឱ្យក្លាយជាលទ្ធផលជាក់ស្តែងជាឧត្តមប្រយោជន៍ដល់ស្ថាប័នសាធារណៈ សេវាសាធារណៈ និងសេចក្តីសុខរបស់ប្រជាពលរដ្ឋ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ អនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធទី២ ៖ អនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាល (និរាករណ៍)

ឧបសម្ព័ន្ធទី៣ ៖ ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ លើលិខិតលេខ ៥៥៩១ សហវ.លស.អគហ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥

ឧបសម្ព័ន្ធទី៤ ៖ ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លើលិខិតលេខ ៥០៩៤ សហវ.លស.អគហ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥

ឧបសម្ព័ន្ធទី៥ ៖ របាយការណ៍ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ ស្តីពីលទ្ធផលកិច្ចប្រជុំប្តូរវេននៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលត្រីមាសទី១ ឆ្នាំ២០២៥

ឧបសម្ព័ន្ធទី៦ ៖ របាយការណ៍ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥ ស្តីពីលទ្ធផលនៃការចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកែទម្រង់អភិបាលកិច្ចនិងវិស័យសាធារណៈការគ្រប់គ្រងសាធារណៈជំនាន់ថ្មី

ឧបសម្ព័ន្ធទី៧ ៖ របាយការណ៍ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥ ស្តីពី "វិបស្សនាប្រចាំឆ្នាំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

(យ.ស.ក.)" ខេត្តសៀមរាប

ឧបសម្ព័ន្ធទី៨ ៖ របាយការណ៍ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំស្ដីពី "យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល"

ឧបសម្ព័ន្ធទី៩ ៖ របាយការណ៍ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.)

ឧបសម្ព័ន្ធទី១០ ៖ របាយការណ៍ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីលទ្ធផលស្ដីពី "វិបស្សនាយន្តការកិច្ចការកែទម្រង់ ៣ បូក ២ នៃរាជរដ្ឋាភិបាល"

ឧបសម្ព័ន្ធទី១១ ៖ របាយការណ៍ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំស្ដីពី "ការអនុវត្តការងារកែទម្រង់ ៣ បូក ២ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ"

ឧបសម្ព័ន្ធទី១២ ៖ របាយការណ៍ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំ២០២៣ នៃយន្តការសម្របសម្រួលការទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល (យ.ស.ក.)

ឧបសម្ព័ន្ធទី១៣ ៖ របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំត្រីមាសទី១ និង ត្រីមាសទី២ នៃលេខាធិការដ្ឋានកំណែទម្រង់ ៣ បូក ១ ឆ្នាំ២០២៣

ឧបសម្ព័ន្ធទី១៤ ៖ របាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីលទ្ធផលនៃទស្សនកិច្ចសិក្សានៅសាធារណរដ្ឋកូរ៉េនៃគណៈប្រតិភូអគ្គលេខាធិការ-ដ្ឋាននិងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី១៥ ៖ របាយការណ៍ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពី "សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១"

ឧបសម្ព័ន្ធទី១៦ ៖ របាយការណ៍ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីការស្នើសុំពិនិត្យ

និងសម្រេចលើសេចក្តីព្រាងឯកសារ "ចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ បី បូកមួយនិងសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់ បី បូក មួយ និង សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមយកម្មការកែទម្រង់បីបូកមួយ"

ឧបសម្ព័ន្ធទី១៧ ៖ របាយការណ៍ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ស្តីពីចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខ-ដុមនីយកម្មកែទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី១៨ ៖ របាយការណ៍ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃវិបស្សនាលើកទី២ នៃកម្មវិធីកែទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី១៩ ៖ របាយការណ៍ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី២០ ៖ របាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ

ឧបសម្ព័ន្ធទី២១ ៖ របាយការណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ បី បូក មួយ

ឧបសម្ព័ន្ធទី២២ ៖ របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារ កែទម្រង់ បី បូក មួយ

ឧបសម្ព័ន្ធទី២៣ ៖ របាយការណ៍ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួល ការងារកែទម្រង់ បី បូក មួយ

ឧបសម្ព័ន្ធទី២៤ ៖ របាយការណ៍ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួល ការងារកែទម្រង់ បី បូក មួយ

ឧបសម្ព័ន្ធទី២៥ ៖ របាយការណ៍ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួល ការងារកែទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី២៦ ៖ របាយការណ៍ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២០ នៃយន្តការសម្របសម្រួលការងារកែ-ទម្រង់ ៣ បូក ១

ឧបសម្ព័ន្ធទី២៧ ៖ របាយការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្នុងក្របខ័ណ្ឌការដ្ឋានកំណែទម្រង់ទាំង ៣ បូក មួយ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩

ឧបសម្ព័ន្ធទី២៨ ៖ របាយការណ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាក្នុងក្របខ័ណ្ឌនៃការងារ កែទម្រង់ទាំង៣ និង លេខា-ធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ឧបសម្ព័ន្ធទី២៩ ៖ របាយការណ៍ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីលទ្ធផលនៃសិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល

ឧបសម្ព័ន្ធទី៣០ ៖ សេចក្តីសម្រេចរួមលេខ០០៦ សហវ ចុះថ្ងៃទី១៩ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើត យន្តការ សម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ (និរាករណ៍)

ឧបសម្ព័ន្ធទី៣១ ៖ ផែនការសកម្មភាពឆ្នាំ២០២៥ នៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី១. អនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២១៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

១/៥

- បានឃើញអនុក្រឹត្យលេខ ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

ត្រូវបានបង្កើត **យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ដែលសរសេរជាអក្សរកាត់ថា "**យ.ស.គ.**" ដើម្បីធានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**ជំពូកទី២**

**មុខងារនិងភារកិច្ច**

**មាត្រា២ .-**

**យ.ស.គ.** ជាយន្តការដឹកនាំនិងសម្របសម្រួលផ្ទាល់វេនប្រចាំត្រីមាស រវាងលេខាធិការដ្ឋាននៃគណៈ-កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.គ.** មានភារកិច្ចដូចតទៅ៖

២/៥

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **ឃ.ស.អ.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបង្គាប់របស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- តាមដានរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារដែលមានចរិតអន្តរកែទម្រង់ ដោយប្រើប្រាស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាមជ្ឈមណ្ឌលកណ្ដាលក្នុងការសម្របសម្រួលនិងបូកសរុបរបាយការណ៍រួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈរដ្ឋបាលរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ទាំង ៥ នៃរាជរដ្ឋាភិបាល
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **ឃ.ស.អ.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

## ជំពូកទី៣
## ការប្រព្រឹត្តទៅ

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាពដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **ឃ.ស.អ.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

**មាត្រា៥ .-**

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗគឺជាប្រធាន **ឃ.ស.អ.** ប្រចាំត្រីមាសនោះ។ ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

៣/៥

ប្រធាន **ឃ.ស.ក.** ត្រូវជានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា ៤ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។

ប្រធាន **ឃ.ស.ក.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

**មាត្រា៦ .-**

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។

**មាត្រា៧ .-**

ប្រធាន **ឃ.ស.ក.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ចូលរួមប្រជុំបានតាមការចាំបាច់។

ប្រធាន **ឃ.ស.ក.** អាចអញ្ជើញ ដៃគូអភិវឌ្ឍនានា ចូលរួមប្រជុំបានតាមការចាំបាច់។

**មាត្រា៨ .-**

**ឃ.ស.ក.** ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬ លេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

**មាត្រា៩ .-**

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំង៥ មានសិទ្ធិចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

**មាត្រា១០ .-**

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **ឃ.ស.ក.** នៃត្រីមាស បន្ទាប់។

របាយការណ៍កិច្ចប្រជុំ ត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

៤/៥

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **យ.ស.ក.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

**មាត្រា១១ .-**

ក្នុងករណីដែលអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសតាមបរិវេណខាងលើ អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបានដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

អនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ នៃរាជរដ្ឋាភិបាលនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៨/៨

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធទី២. អនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាល (និរាករណ៍)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៤១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

១

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១._**

អនុក្រឹត្យនេះ មានគោលបំណង ធានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលតទៅនេះហៅថា **យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល** និងសរសេរជាអក្សរកាត់ថា "**យ.ស.គ.**"។

**មាត្រា២._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាល ដែលមានទំនាក់ទំនងជាមួយនឹងកម្មវិធីកែទម្រង់ទាំង ៤ ខាងលើ។

**ជំពូកទី២**

**មុខងារ និង ភារកិច្ច**

**មាត្រា៣._**

**យ.ស.គ.** ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាសរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

**មាត្រា៤._**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.គ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **យ.ស.គ.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗ ព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបញ្ជារបស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- រៀបចំនិងចងក្រងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **យ.ស.គ.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

២

**មាត្រា៥.-**

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗ គឺជា "**ប្រធាន ឃ.ស.គ.**" ប្រចាំត្រីមាសនោះ។ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

ប្រធាន **ឃ.ស.គ.** ត្រូវធានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា ៤ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព ឥណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។

ប្រធាន **ឃ.ស.គ.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

ប្រធាន **ឃ.ស.គ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ឬ ដៃគូអភិវឌ្ឍន៍នានា ចូលរួមប្រជុំបានតាមការចាំបាច់។

**មាត្រា៦.-**

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។

**មាត្រា៧.-**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាព ដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **ឃ.ស.គ.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

## ជំពូកទី៣
## កិច្ចដំណើរការ

**មាត្រា៨.-**

**ឃ.ស.គ.** ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤ នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

**មាត្រា៩.-**

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវទទួលបន្ទុកសម្របសម្រួលនិងបូកសរុបរបាយការណ៍វឌ្ឍនភាពដែលស្ថិតក្រោមការទទួលបន្ទុករបស់ខ្លួន និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានដែលជាប្រធានទទួលវេន យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែបន្ទាប់ ដើម្បីបូកសរុបសម្រាប់កិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំងបួន អាចចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

៣

**មាត្រា១០.-**

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **ឃ.ស.គ.** នៃត្រីមាសបន្ទាប់។

របាយការណ៍កិច្ចប្រជុំ ត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **ឃ.ស.គ.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

**មាត្រា១១.-**

ក្នុងករណីដែលអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស តាមចិរវេលាខាងលើ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបាន ដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

៥

# ឧបសម្ព័ន្ធទី៣

# ឧបសម្ព័ន្ធទី៣. ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ លើលិខិតលេខ ៥៥៩១ សហវ.លស.អគហ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៥៩១ សហវ.លស.អគហ

ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
ចូល
លេខ: ៤៩៩៨
ថ្ងៃ 03.06.2025
ម៉ោង: 8h.38

ថ្ងៃ ... ខែ ... ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា គ.ស. ២០២៥

**សូមគោរពជូន**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** ការស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់ក្នុងបុព្វកថាដាក់ឱ្យអនុវត្ត "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**"។

**យោង ៖** ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លើលិខិតលេខ ៥០៩៤ សហវ.លស.អគហ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា អនុលោមតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** ខ្ញុំនឹងទៅចូលរួមជាគណៈអធិបតីក្នុង **ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** នៅដើមខែកក្កដា ឆ្នាំ២០២៥ នេះ។ ក្នុងន័យនេះ ខ្ញុំបានរៀបចំនូវបុព្វកថាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** ដើម្បីដាក់ឱ្យអនុវត្ត **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ដែលជាកម្មវត្ថុនៃការបោះពុម្ពនិងផ្សព្វផ្សាយដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចធិបតី** មេត្តាពិនិត្យនិងសម្រេចចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់លើសេចក្តីព្រាងបុព្វកថា ដូចមានគោរពភ្ជាប់ជូនមកជាមួយ ដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

យល់ព្រម
06.06.25

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ឧបសម្ព័ន្ធទី៣

# ឧបសម្ព័ន្ធទី៤

# ឧបសម្ព័ន្ធទី៤. ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លើលិខិតលេខ ៥០៩៤ សហវ.លស.អគហ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៩៤ សហវ.លស.អគហ

ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
ចូល លេខ: 1742 ថ្ងៃ: 20.ឧសភា.2025 ម៉ោង: 14.39

ថ្ងៃ ... ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០២៥

**សូមគោរពជូន**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** ការស្នើសុំគោរពអញ្ជើញវត្តមានដ៏ខ្ពង់ខ្ពស់ក្នុង "**ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**"។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដើម្បីធានាសុខដុមនីយកម្មរវាងកម្មវិធីកែទម្រង់ចំនួន ៥ រួមមាន **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ច្បាប់ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌**។ អនុលោមតាមអនុក្រឹត្យនេះ អគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ទាំង ៥ មានបេបប្រជុំប្រចាំត្រីមាសនិងប្រចាំឆ្នាំដោយផ្លាស់វេនដឹកនាំពិភាក្សា សម្របសម្រួល និងដោះស្រាយបញ្ហាដែលមានចរិតប្រទាក់ក្រឡាជាអន្តរកែទម្រង់ សំដៅគាំទ្រការកែទម្រង់អភិបាលកិច្ចដែលជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

បច្ចុប្បន្ននេះ អគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ទាំង ៥ កំពុងរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារ "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**" និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ របស់ខ្លួន ដោយរំពឹងថានឹងរួចរាល់ក្នុងពេលដ៏ខ្លីខាងមុខនេះដើម្បីគោរពស្នើសុំបុព្វកជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី**។ ក្នុងន័យនេះ ខ្ញុំសូមគោរពស្នើសុំវត្តមានជាអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវចក្ខុវិស័យនិងយុទ្ធសាស្ត្រនេះ នៅក្នុងកាលបរិច្ឆេទណាមួយក្នុងអំឡុងសប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៥ ឬនៅក្នុងកាលបរិច្ឆេទសមស្របណាមួយផ្សេងទៀត តាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី**។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាជ្រាបពិនិត្យ និងសម្រេច ឬមានការណែនាំជាយថាហេតុដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

20.05.25

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ឧបសម្ព័ន្ធទី៤

# ឧបសម្ព័ន្ធទី៥

# ឧបសម្ព័ន្ធទី៥. របាយការណ៍ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីលទ្ធផលកិច្ចប្រជុំប្ដូរវេននៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលត្រីមាសទី១ ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:

ចូលថ្ងៃទី 12/05/25 ម៉ោង........
លេខ: 2508015

ថ្ងៃ............ ខែ............ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា គ.ស. ២០២៥

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ៖** ការស្នើសុំពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់លើរបាយការណ៍លទ្ធផលស្ដីពីកិច្ចប្រជុំប្ដូរវេននៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.ក.**) ត្រីមាសទី១។

**យោង ៖** លិខិតលេខ ២៤៧ សហវ/ អគហ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ កិច្ចប្រជុំប្ដូរវេននៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.ក.**) ប្រចាំត្រីមាសទី១ ត្រូវបានរៀបចំឡើងក្នុងរយៈពេលមួយថ្ងៃពេញនៅសណ្ឋាគារ រ៉ាហ្វល លើ រ៉ូយ៉ាល់ (Raffles Hotel Le Royal) ក្រោមការដឹកនាំដោយប្រធានប្ដូរវេនរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការសម្របសម្រួលគាំទ្ររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កិច្ចប្រជុំនេះមានការចូលរួមពី **ឯកឧត្តម ចាន់ សុធា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**លគ.ជ.អ.ប.**), **ឯកឧត្តម កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (**អ.គ.ក.ប.យ.**), **ឯកឧត្តម លី ច័ន្ទតុលា** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**អ.គ.ក.ច.**), **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**អ.គ.ក.ស.**) និងរូបខ្ញុំផ្ទាល់តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ព្រមទាំងមានការអញ្ជើញចូលរួមពីអង្គភាពក្រោមឱវាទក្រសួងនៃការដ្ឋានកែទម្រង់ទាំង៥ សរុបប្រមាណ ៥០រូប។

កិច្ចប្រជុំនេះបានពិភាក្សាលើរបៀបវារៈ និងសម្រេចជាលទ្ធផលគន្លឹះដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ដូចតទៅ៖

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទំព័រ ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
S.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: 855-23-430 791 Fax: 855-23-430 745

ឧបសម្ព័ន្ធ

**ក. កិច្ចដំណើរការនៃអង្គប្រជុំ**

កិច្ចប្រជុំបានដំណើរការដោយមានរបៀបវារៈគន្លឹះចំនួន៣ រួមមាន៖

**១.** កិច្ចពិភាក្សាលើការរៀបចំពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

**២.** របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆមាសទី១ ឆ្នាំ២០២៥

**៣.** វឌ្ឍនភាពនៃបច្ចុប្បន្នកម្មចក្ខុវិស័យ យុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ ស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

**៤.** ផ្សេងៗ ៖ កិច្ចពិភាក្សាលើការគាំទ្រលើការរៀបចំ គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួង-ស្ថាប័ន, ការពង្រឹងនិងពង្រីកអង្គភាពថវិកា និងលទ្ធផលនៃវេទិការវាងរាជរដ្ឋាភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ. ចំណុចស្នើសុំការពិនិត្យនិងសម្រេច**

**១.** អង្គប្រជុំបានពិភាក្សានិងសម្រេចស្នើសុំលើការរៀបចំពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដូចតទៅ៖

- រៀបចំពិធីប្រកាសដាក់ឱ្យអនុវត្ត ***ក្នុងរយៈពេល ១ព្រឹក*** និងមានសមាសភាពចូលរួមប្រមាណ ៤២៥ រូប
- កិច្ចដំណើរការនៃពិធីប្រកាសនឹងត្រូវរៀបចំជាលំដាប់លំដោយដូចតទៅ៖
  - ចាប់ផ្តើមដោយរបាយការណ៍គន្លឹះជាបន្តបន្ទាប់របស់ឧបនាយករដ្ឋមន្ត្រីទាំង ៥ រូប ដែលជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់នីមួយៗ ដូចតទៅ៖ ១) ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**, ២) ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា**, ៣) ឯកឧត្តម **កើត រិទ្ធ**, ៤) ឯកឧត្តម **វង្សី វិស្សុត**, និង ៥) ឯកឧត្តម **ហ៊ុន ម៉ានី**
  - បន្ទាប់ពីរបាយការណ៍គន្លឹះទាំង៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងថ្លែងសុន្ទរកថាដ៏ខ្ពង់ខ្ពស់ប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
  - ចុងបញ្ចប់នៃកម្មវិធី **សម្តេចធិបតី** នឹងប្រគល់ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ ជូនដល់ឧបនាយករដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ។

**២.** អង្គប្រជុំបានសម្រេចស្នើសុំរៀបចំលិខិតគោរពស្នើសុំវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** នៅក្នុងសប្តាហ៍ទី៤ ខែមិថុនា ឬនៅក្នុងកាលបរិច្ឆេទសមស្របផ្សេងទៀតណាមួយសម្រេចដោយ **សម្តេចធិបតី** (ដូចមានលិខិតគោរពភ្ជាប់ជូនមកជាមួយ)។

**៣.** អង្គប្រជុំបានសម្រេចស្នើសុំបោះពុម្ពឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ចំនួន ១០០០ច្បាប់។

**៤.** អង្គប្រជុំបានសម្រេចឯកភាពកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ សម្រាប់ការផ្តល់ធាតុចូលចុងក្រោយពីគ្រប់ភាគីពាក់ព័ន្ធ លើសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ និងសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដើម្បី **អ.គ.ហ.** ចូលរួមបូកសរុប។

ទំព័រ ២

**៥. អ.គ.ក.ប.យ.** ជាប្រធានប្ដូរវេននៃកិច្ចប្រជុំ **យ.ស.ក.** ប្រចាំត្រីមាសទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ពិនិត្យ និងសម្រេច ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការរង**
**នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហៀល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ គ.ស. ២០២៥
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការស្តីទី នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ប៉ែន ធីរុទ្ធ**

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦
រាជធានីភ្នំពេញ ថ្ងៃទី 13 ខែ គ.ស. ២០២៥
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ទំព័រ ៣

# ឧបសម្ព័ន្ធទី៦

# ឧបសម្ព័ន្ធទី៦. របាយការណ៍ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥ ស្តីពី លទ្ធផលនៃការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកែទម្រង់អភិបាលកិច្ចនិងវិស័យសាធារណៈការគ្រប់គ្រងសាធារណៈជំនាន់ថ្មី



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:......................................................

22 4 25 ម៉ោង 25 6 180 7

**របាយការណ៍**

**ស្តីពី**

**លទ្ធផលនៃការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកែទម្រង់អភិបាលកិច្ចនិងវិស័យសាធារណៈ-ការគ្រប់គ្រងសាធារណៈជំនាន់ថ្មី**

( Public governance and public sector reform-New Public Management to today )

**នៅប្រទេសណូវែល ហ្សេឡង់**

នៅរវាងថ្ងៃចន្ទ ១២ រោច ខែមាឃ ដល់ថ្ងៃសុក្រ ២ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ គណៈប្រតិភូអន្តរកែទម្រង់ចំនួន ៣០ រូបបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលចំនួន ៥ ថ្ងៃលើប្រធានបទស្តីពីការកែទម្រង់អភិបាលកិច្ចនិងវិស័យសាធារណៈ-ការគ្រប់គ្រងសាធារណៈជំនាន់ថ្មី ( Public governance and public sector reform-New Public Management to today ) នៅសាកលវិទ្យាល័យវែលលីងតុន ( Wellington Uni Professional ) ប្រទេសណូវែល ហ្សេឡង់។

គណៈប្រតិភូនេះមានសមាសភាពថ្នាក់ដឹកនាំដូចតទៅ ៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៖ ឯកឧត្តមបណ្ឌិត **រ៉ោហ៊ើល ចំរើន** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឯកឧត្តម **ស៊ាង ផល្លា** អនុរដ្ឋលេខាធិការនិងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។
- ក្រសួងមុខងារសាធារណៈ ៖ ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការនិងជាអនុប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, ឯកឧត្តម **ឈុន សុជាតិ** រដ្ឋលេខាធិការនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលោកជំទាវ **ឈី ចិន្តា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី ៖ឯកឧត្តម **ស៊ា ម៉ៅ** រដ្ឋលេខាធិការនិងជាអនុប្រធានប្រចាំការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងឯកឧត្តម **ម៉ែន ប៊ុនឈា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- ក្រសួងយុត្តិធម៌ ៖លោកជំទាវ **ឌី ម៉ូឡានី** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ក្រសួងមហាផ្ទៃ ៖ ឯកឧត្តម **ជ័យ សម្បត្តិផល្លា** តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

វគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះបានគ្របដណ្តប់ទៅលើប្រធានបទគន្លឹះៗដែលមានដូចតទៅ៖ ១) ប្រព័ន្ធសមិទ្ធកម្មសាធារណៈ (NZ's public performance system), ២) ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ (NZ's local government system), ៣) ការគ្រប់គ្រងជាយុទ្ធសាស្ត្រនិងកិច្ចសហការលើគោលនយោបាយ (Strategic management and policy collaborations) និង ៤) ការអញ្ជើញមកចូលរួមធ្វើបទបង្ហាញដោយផ្ទាល់ពីស្ថាប័នសាធារណៈមួយចំនួនរបស់រដ្ឋាភិបាលណូវែល ហ្សេឡង់។

អាសយដ្ឋាន: ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

វគ្គបណ្តុះបណ្តាលរយៈពេល ៥ ថ្ងៃនេះ បានផ្តល់ចំណេះដឹងជាសារវន្តជាច្រើនដល់គណៈប្រតិភូមកពីគ្រប់ការដ្ឋានកែទម្រង់ទាំង ៥ ដែលមានលទ្ធផលជារួមដូចតទៅ ៖

**ក. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ក.១. ប្រព័ន្ធគណនេយ្យភាពនិងសុចរិតភាពនៃរដ្ឋបាលសាធារណៈ** ___ *ឧទ្ទេសនាមដោយសាស្ត្រាចារ្យ Michael Maccaulay នៃសាកលវិទ្យាល័យ Victoria of Wellington និង តំណាងនៃ Office of the Ombudsman*

គណនេយ្យភាពនិងសុចរិតភាពនៃរដ្ឋបាលសាធារណៈជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពអភិបាលកិច្ចនៃរដ្ឋបាលនូវែលហ្សេឡង់។ គោលការណ៍និងគុណតម្លៃគាំទ្រប្រព័ន្ធគណនេយ្យភាពនិងសុចរិតភាពត្រូវបានកំណត់ក្នុងច្បាប់ស្តីពីសេវាសាធារណៈឆ្នាំ២០២០ ( Public Service Act 2020 ) ដែលមានខ្លឹមសារដូចតទៅ៖

| **គោលការណ៍** | **គុណតម្លៃ** |
|---|---|
| *<u>មិនប្រកាន់និន្នាការនយោបាយ</u>*<br>១. អនុវត្តក្នុងស្មារតីមិនប្រកាន់និន្នាការនយោបាយនិង | *<u>Impartial</u>*<br>១. បម្រើទៅកាន់សាធារណជនដោយយុត្តិធម៌ ដោយគ្មានមូលដ្ឋានលំអៀង |
| *<u>Free and frank advice ( សេរីភាពនិងសច្ចៈភាពនៃការផ្តល់យោបល់ )</u>*<br>២.នៅពេលផ្តល់យោបល់ជូនរដ្ឋមន្ត្រី ត្រូវអនុវត្តក្នុងស្មារតីដោយសេរីភាពនិងមានសច្ចៈភាព | *<u>គណនេយ្យភាព ( Accountable )</u>*<br>២.ទទួលខុសត្រូវលើការងារ, សកម្មភាព, និងការសម្រេចចិត្ត |
| *<u>គុណាធិបតេយ្យក្នុងការតែងតាំង</u>*<br>៣.តែងតាំងដោយផ្អែកលើសមិទ្ធកម្មនិងគុណាធិបតេយ្យ | *<u>ក្រមសីលធម៌ ( Ethical )</u>*<br>៣.អនុវត្តដោយសុចរិត, បើកចំហ, និងតម្លាភាព |
| *<u>រដ្ឋាភិបាលបើកចំហរ</u>*<br>៤.បណ្តុះនិងពង្រីកបរិយាកាសបើកចំហក្នុងរដ្ឋាភិបាល | *<u>ការគោរព ( Respectful )</u>*<br>៤.បម្រើជូនសាធារណជនដោយសេចក្តីថ្លៃថ្នូរ, សេចក្តីមេត្តា និងបម្រើដោយដាក់ខ្លួន |
| *<u>ការគ្រប់គ្រងនិងដឹកនាំ ( Stewardship )</u>*<br>៥. បុរេសកម្មក្នុងការពង្រីកការគ្រប់គ្រងនិងដឹកនាំលើសេវាសាធារណៈរបស់ស្ថាប័នខ្លួន ដោយគ្របដណ្តប់លើ<br>៥.១.សមត្ថភាព លទ្ធភាព និងភាពពាក់ព័ន្ធរយៈពេលវែង<br>៥.២.ចំណេះដឹងនិងព័ត៌មាននៃស្ថាប័ន<br>៥.៣.ប្រព័ន្ធនិងកិច្ចដំណើរការ<br>៥.៤.ទ្រព្យសកម្ម<br>៥.៥.លិខិតបទដ្ឋានគតិយុត្តដែលអនុវត្ត។ | *<u>ការឆ្លើយតប ( Responsive )</u>*<br>៥.ស្វែងយល់និងបំពេញតម្រូវការនិងសេចក្តីចង់បានរបស់សាធារណជន |

ដើម្បីធានាប្រសិទ្ធភាពនៃក្របខ័ណ្ឌគណនេយ្យភាពនិងសុចរិតភាពនៃរដ្ឋបាលសាធារណៈ, ស្ថាប័នគន្លឹះ ៣ ត្រូវបានបង្កើតឡើងជាតួអង្គនិម្មាបនករលើការធានាអំពីប្រសិទ្ធភាពការអនុវត្តក្របខ័ណ្ឌសុចរិតភាពនេះ ដែលរួមមាន Public Service Commission, Office of Auditor-General, និង Office of the Ombudsman ។

- Public Service Commission ( PSC ) ជាស្ថាប័នក្រោមអំណាចនីតិប្រតិបត្តិ ដែលបង្កើតឡើងដោយ Public Service Act 2020 តែបំពេញមុខងារដោយឯករាជ្យលើការធានាអំពីក្របខ័ណ្ឌសុចរិតភាពនិងគណនេយ្យ

២

ភាពរបស់រដ្ឋបាលសាធារណៈ។ PSC អនុវត្តការងារពាក់ព័ន្ធនឹងការពង្រឹងអភិបាលកិច្ចនិងភាពជាអ្នកដឹកនាំក្នុងរដ្ឋបាលសាធារណៈ, ការតែងតាំងមន្ត្រីជាន់ខ្ពស់, ការអភិវឌ្ឍសមត្ថភាព, ការតាមដានសមិទ្ធកម្មនិងគណនេយ្យភាព, សុចរិតភាពនិងក្រមសីលធម៌ ។ល។ សិទ្ធិអំណាចនៃ PSA ផ្តោតលើការដាក់ចេញនូវបទដ្ឋាននានាគាំទ្រសុចរិតភាពនិងគណនេយ្យភាព, ការស៊ើបអង្កេតនិងបណ្តឹង, លទ្ធភាពក្នុងការប្រមូលព័ត៌មាន និងការចូលទៅក្នុងបរិវេណ (Power to enter premise)។ បន្ថែមពីនេះ PSC មានបន្ទាត់គណនេយ្យភាពដោយឡែកជាមួយនឹងស្ថាប័ននីតិប្បញ្ញត្តិ ដោយត្រូវរាយការណ៍អំពីសមិទ្ធកម្មរបស់ស្ថាប័នខ្លួន។

- Office of the Auditor-General (OAG) ជាស្ថាប័នសវនកម្មកំពូលនៃនូវែលហ្សេឡង់ ដែលបង្កើតដោយ Public Audit Act 2001 និងមានបន្ទាត់គណនេយ្យភាពដោយផ្ទាល់ទៅនឹងស្ថាប័ននីតិប្បញ្ញត្តិ។ តួនាទីនៃ OAG ផ្តោតលើការអនុវត្តសវនកម្មទៅលើរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងគោលដៅពង្រឹងគណនេយ្យភាពនិងតម្លាភាពនៃការប្រើប្រាស់ធនធានរបស់រដ្ឋ។
- Office of the Ombudsmen ជាអង្គភាពក្រោមរចនាសម្ព័ន្ធរបស់ស្ថាប័ននីតិប្បញ្ញត្តិ ដែលត្រូវបានបង្កើតឡើងតាមរយៈច្បាប់ Ombudsmen Act 1975។ Office of the Ombudsmen ដឹកនាំដោយប្រធាន (Chief Ombudsman) មួយរូប ដែលតែងតាំងដោយប្រមុខរដ្ឋ តាមរយៈការផ្តល់យោបល់របស់ស្ថាប័ននីតិប្បញ្ញត្តិ។ មុខងារគន្លឹះនៃ Office of the Ombudsmen រួមមាន៖
  - ស៊ើបអង្កេតលើពាក្យបណ្តឹងពីសារធារណជនទៅពាក់ព័ន្ធនឹងកំហុស, ភាពលំអៀង, ភាពមិនសមហេតុផលក្នុងការអនុវត្តរបស់រដ្ឋបាលសាធារណៈ
  - ធានាលើការតម្លាភាពនៃព័ត៌មាន តាមរយៈ Official information Act 1982
  - អធិការកិច្ចលើមណ្ឌលឃុំឃាំង ដើម្បីគាំពារការអនុវត្តដោយខុសឆ្គងពីស្តង់ដានៃសិទ្ធិមនុស្ស និង Optional Protocol to the convention against torture (OPCAT)
  - បណ្តុះការពង្រឹងរដ្ឋបាលកិច្ចល្អ តាមរយៈការរៀបចំគោលការណ៍ណែនាំនិងយន្តការពង្រឹងសមត្ថ-ភាពនានា។

វិសាលភាពនៃសិទ្ធិអំណាចរបស់ Office of Ombudsmen មានភាពទូលំទូលាយដែលអាចគ្របដណ្តប់លើក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពដែលទទួលការឧបត្ថម្ភពីរដ្ឋ លើកលែងតែ ការអនុវត្តរបស់ស្ថាប័នមួយចំនួនជាក់លាក់រួមមាន៖ Ministers of the Crown, អង្គភាពប៉ូលីស, យោធា និងស្ថាប័នក្នុងអំណាចតុលាការ។

**ក.២.ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** *ឧទ្ទេសនាមដោយសាស្ត្រាចារ្យ Thy Phoung Truong នៃសាកលវិទ្យាល័យ Victoria of Wellington*

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃនូវែលហ្សេឡង់ ត្រូវបានកំណត់ដោយបទដ្ឋានគតិយុត្តិគន្លឹះៗមួយចំនួនដូចជា៖ Public Finance Act 1989, State Sector Act 1988, Crown Entities Act 2004, Local Government Act 2002, Official Information Act 1982, Ombudsmen Act 1975, Public Audit Act 2001 -ល-។

ការិយបរិច្ឆេទថវិកាសាធារណៈនៃនូវែលហ្សេឡង់ ចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា ជារៀងរាល់ឆ្នាំ។ វដ្តថវិកាបែងចែកជាជំហាន ដូចជា៖

- ដំណាក់កាលរៀបចំ (ខែវិច្ឆិកា-មេសា)៖ ដោយផ្អែកលើ Fiscal Strategy Report (FSR), Long-Term Fiscal Statement និង Investment statement, ក្រសួង-ស្ថាប័នរៀបចំសំណើគម្រោងថវិកា (budget bids) មកក្រសួងហិរញ្ញវត្ថុ ដោយភ្ជាប់នឹងគម្រោងការងារ (proposed initiatives)។ ក្រសួងហិរញ្ញវត្ថុពិនិត្យនិងវាយតម្លៃអំពីគម្រោងថវិកានឹងអាទិភាពរបស់រដ្ឋាភិបាល។ បន្ទាប់មក គណៈរដ្ឋមន្ត្រីពិនិត្យនិងអនុម័តលើគម្រោងវិភាជន៍ថវិកា ផ្អែកតាមមតិយោបល់របស់ក្រសួងហិរញ្ញវត្ថុនិងអាទិភាពរបស់រដ្ឋាភិបាល។
- ដំណាក់កាលអនុម័ត (ខែឧសភា)៖ មាន ៣ ជំហាន រួមមាន Budget Day, ការពិនិសច្ច័យគម្រោងថវិកា និងការអនុម័តច្បាប់ថវិកា (Appropriation Acts)។ Budget Day ជាកាលបរិច្ឆេទដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុដាក់ជូនសំណើថវិកា (Budget) ជូនស្ថាប័ននីតិប្បញ្ញត្តិ ដែលសំណើថវិកាមានឯកសារគន្លឹះ ៣ រួមមាន៖ គម្រោងឥណ

៣

ទាន (Appropriation bills), សុន្ទរកថាអំពីគម្រោងថវិកា (Budget Speech) និង គម្រោងថវិកាលម្អិត (ចំណូល,ចំណាយ និងការព្យាករណ៍នានា)។ គម្រោងថវិកានឹងត្រូវពិភាក្សានិងត្រួតពិនិត្យពិនិសច្ឆ័យដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលមានគណៈកម្មការបច្ចេកទេសនានាទទួលបន្ទុក។ ក្រោយមានការឯកភាព, គម្រោងឥណទាន (Appropriation bills) ត្រូវបានអនុម័តជាច្បាប់ថវិកា (Appropriation Acts) ដែលផ្ដល់សិទ្ធិចំណាយជូនរដ្ឋាភិបាលតាមឥណទានដែលបានកំណត់។

- ដំណាក់កាលអនុវត្ត ៖ ក្រសួង-ស្ថាប័នទទួលបានថវិកាតាមទំហំឥណទាន ដែលកំណត់ដោយច្បាប់។ ក្រសួង-ស្ថាប័នត្រូវរៀបចំរបាយការណ៍អនុវត្តថវិកានិងសមិទ្ធកម្មផ្អែកតាមគម្រោង។ ក្នុងករណីចាំបាច់, ក្រសួងហិរញ្ញវត្ថុនឹងស្នើសុំគណៈរដ្ឋមន្ត្រីដើម្បីសម្រេចអំពីការកែសម្រួលថវិកា (Budget In-Year Adjustment)។
- ការរាយការណ៍និងសវនកម្ម៖ ជារៀងរាល់ខែនិងត្រីមាស, ក្រសួង-ស្ថាប័នរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មកកាន់ក្រសួងហិរញ្ញវត្ថុ។ នៅបញ្ចប់ការិយបរិច្ឆេទនៃឆ្នាំនីមួយៗ, ក្រសួង-ស្ថាប័នត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ហើយរបាយការណ៍នេះត្រូវឯងសវនកម្មហិរញ្ញវត្ថុ ដោយស្ថាប័នសវនកម្មកំពូល (Office of the Auditor-General – OAG)។ នៅក្នុងកម្រិតរដ្ឋាភិបាលទាំងមូល, ក្រសួងហិរញ្ញវត្ថុប្រមូលផ្ដុំរបាយការណ៍ហិរញ្ញវត្ថុពីគ្រប់រដ្ឋបាលទាំងអស់ទៅជា Crown Financial Statement និងដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ។
- ការពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម៖ ត្រូវបានបែងចែកជា ៣ ទិដ្ឋភាព រួមមាន សវនកម្មសមិទ្ធកម្ម, ការវាយតម្លៃដោយគណៈកម្មការបច្ចេកទេស និង Post-Implementation Review។ OAG អនុវត្តសវនកម្មសមិទ្ធកម្មលើក្រសួង-ស្ថាប័ន ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃកម្មវិធីរដ្ឋាភិបាលនិងសេវាសាធារណៈជាក់ស្ដែង។ បន្ថែមពីនេះ ស្ថាប័ននីតិប្បញ្ញត្តិអាចកំណត់ឱ្យគណៈកម្មការបច្ចេកទេស ដើម្បីត្រួតពិនិត្យឡើងវិញពីការអនុវត្តធនធានរបស់រដ្ឋធៀបនឹងសមិទ្ធកម្មរបស់ក្រសួង-ស្ថាប័ន។ ម្យ៉ាងវិញទៀត ក្រសួង-ស្ថាប័នរៀបចំ Post-Implementation Review ដើម្បីពិនិត្យឡើងវិញអំពីការអនុវត្តគម្រោងការងារខ្លួន និងវាយតម្លៃលើលទ្ធផល ព្រមទាំងទាញជាពិសោធន៍។




Figure 1 - Source: The Treasury New Zealand, 2011, Putting It Together: An Explanatory Guide to New Zealand's State Sector Financial Management System , Figure 1: Key Documents in the Financial Management Cycle

- ស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ៖ រដ្ឋាភិបាលនូវែលហ្សេឡង់អនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរពេញលេញគ្រប់ដំណាក់លើវដ្តថវិកាទាំងមូល ដែលចាប់ផ្ដើមពីទិដ្ឋភាពនៃការរៀបចំថវិកា, ការអនុវត្តថវិកា, ការកត់

៤

ត្រា និងការរាយការណ៍ ខណៈដែលប្រទេសភាគច្រើនអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរសម្រាប់ការកត់ត្រានិងរបាយការណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។

- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងសវនកម្ម៖ ក្នុងទិដ្ឋភាពនៃការអនុវត្តនិងរាយការណ៍ហិរញ្ញវត្ថុ, ក្រសួងស្ថាប័ននីមួយៗ រៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងត្រូវឆ្លងកាត់ការធ្វើសវនកម្មហិរញ្ញវត្ថុដោយស្ថាប័នសវនកម្មកំពូល ( OAG – Office of the Auditor-General )។ ជាការអនុវត្ត ស្ថាប័នសវនកម្មកំពូលបានប្រតិភូកម្មការងារឱ្យក្រុមហ៊ុនសវនកម្មឯកជន ដើម្បីអនុវត្តជំនួសក្នុងនាមស្ថាប័នខ្លួន។
- ហានិភ័យហិរញ្ញវត្ថុ៖ Fiscal risk estimate ជាយន្តការដែលរដ្ឋាភិបាលវាយតម្លៃទៅលើហានិភ័យជុំវិញការប្រើប្រាស់ធនធានរបស់រដ្ឋក្នុងកម្រិតរដ្ឋាភិបាល។ Fiscal risk ត្រូវបានវាយតម្លៃដោយផ្អែកលើចំណែកនៃ Balance sheet របស់រដ្ឋាភិបាលក្នុង ៣ ទិដ្ឋភាព រួមមានទិដ្ឋភាពសង្គម, ទិដ្ឋភាពហិរញ្ញវត្ថុ, និងទិដ្ឋភាពពាណិជ្ជកម្ម ដោយបង្ហាញអំពីហានិភ័យដែលរដ្ឋពុំមានបំពេញសេវាជូនសាធារណៈមកពីកត្តាទ្រព្យសកម្មនិងបំណុល, បន្ទុកនិងចំណាយរបស់រដ្ឋនាពេលមធ្យមខាងមុខ ឬលទ្ធភាពដែលរដ្ឋអាចសម្រេចបានលើគោលដៅពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម នានា។
- Investor Confidence Rating ( ICR )៖ គឺជាអត្រាមួយដែលឆ្លុះបញ្ចាំងអំពីសមិទ្ធកម្មវិនិយោគ ( Investment performance ) និងកម្រិតនៃជឿទុកចិត្តរបស់ភាគីពាក់ព័ន្ធលើលទ្ធភាពនៃការគ្រប់គ្រងទ្រព្យសកម្មនិងគម្រោងវិនិយោគរបស់ស្ថាប័នឬអង្គភាពនីមួយៗ។ លទ្ធផល ICR ត្រូវធ្វើឡើងរយៈពេល ៣ ឆ្នាំម្តង ដែលត្រូវសម្រេចដោយគណៈរដ្ឋមន្ត្រី លើស្ថាប័ន និង Crown Entities ដែលមានអាទិភាពខ្ពស់លើការវិនិយោគ។
- Capital charge៖ ការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ដើមទុនរបស់រដ្ឋតាមរយៈយន្តការ Capital charge។ Capital charge គឺជាថ្លៃចំណាយដែលស្ថាប័នសាធារណៈថ្នាក់ជាតិប្រើប្រាស់ដើមទុននិងទ្រព្យសកម្មរបស់រដ្ឋ ដើម្បីអនុវត្តកិច្ចការងាររបស់ខ្លួន។ ក្រសួង-ស្ថាប័នថ្នាក់ជាតិនីមួយៗ ត្រូវគ្រោងនូវទំហំ Capital charge និងកំណត់ជាចំណាយរបស់ខ្លួនក្នុងរបាយការណ៍អនុវត្តសម្រាប់ក្រសួងហិរញ្ញវត្ថុ (The Treasury)។ ក៏ប៉ុន្តែ Capital charge នេះមិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុកម្រិតរដ្ឋាភិបាលឡើយ ដោយហេតុថានេះពុំមែនជាចំណូលឬចំណាយជាក់ស្តែងរបស់រដ្ឋឡើយ។

## ខ. រដ្ឋបាលថ្នាក់ក្រោមជាតិណូវែល ហ្សេឡង់ *នរៀសនាមដោយលោកបណ្ឌិត Mike Reid ទីប្រឹក្សាប្រចាំរដ្ឋបាលថ្នាក់ក្រោមជាតិញ៉ូវហ្សេលេន*

### ខ.១. អត្តិភាពនិងគោលបំណង

ណូវែល ហ្សេឡង់ជាប្រទេសមួយក្នុងចំណោមប្រទេសពា ដែលមានរដ្ឋធម្មនុញ្ញឥតសរសេរ។ អត្តិភាព សិទ្ធិអំណាច និង តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិណូវែល ហ្សេឡង់ អាស្រ័យទាំងស្រុងទៅលើឆន្ទៈរបស់អង្គនីតិប្បញ្ញត្តិ ដែលមានន័យថាស្ថាប័ននីតិប្បញ្ញត្តិអាចបង្កើនឬបន្ថយចំនួនរដ្ឋបាលថ្នាក់ក្រោមជាតិបាន (ជាករណីជាក់ស្តែងនៅឆ្នាំ១៩៨៩ រដ្ឋបាលថ្នាក់ក្រោមជាតិមាន ចំនួន៨២៨ បន្ថយមកត្រឹម ចំនួន៧៨ នៅឆ្នាំ២០២៥ )។

- សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រគល់ឡើងដោយច្បាប់ចំនួនពាសំខាន់ៗគឺ ១). ច្បាប់ស្តីពីការបោះឆ្នោតរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០០១ ( Local Electoral Act ) ២ ). ច្បាប់ស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០០២ ( Local Government Act ) និង៣ ) ច្បាប់ស្តីពីការកំណត់អត្រាពន្ធអចលនទ្រព្យឆ្នាំ២០០២ ( Local Government Rating Act )
- គោលបំណងនៃការបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិមានយ៉ាងហោចចំនួន២សំខាន់ៗគឺ ១). ពង្រីកការសម្រេចចិត្តឱ្យដល់កម្រិតមូលដ្ឋាន ដែលមានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារក្នុងនាមនិងក្នុងផលប្រយោជន៍ប្រជាពលរដ្ឋមូលដ្ឋាន និង២ ). លើកកម្ពស់សុខុមាលភាពសង្គម សេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌ទាំងក្នុងពេលបច្ចុប្បន្ននិងទាំងរក្សាចីរភាពសម្រាប់អនាគត។

### ខ.២. ការរៀបចំនិងប្រព្រឹត្តទៅ

រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ណូវែល ហ្សេឡង់ទាំងអស់មានចំនួន ៧៨ ដែលត្រូវបានបែងចែកជា២កម្រិត គឺ កម្រិតតំបន់ (Region) មានចំនួន១១ និងកម្រិតមូលដ្ឋាន (territory) មានចំនួន៦៧ ហើយដែលតួនាទី សិទ្ធិ

៥

អំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលទាំង២កម្រិតនេះ ត្រូវបានបែងចែកនិងកំណត់យ៉ាងច្បាស់លាស់ដោយច្បាប់។

- រដ្ឋបាលកម្រិតតំបន់ ផ្តោតសំខាន់ជាចម្បងទៅលើកិច្ចការនិងមុខងារមួយចំនួនរួមមាន ១). ការគ្រប់គ្រងបរិស្ថានដែលពាក់ព័ន្ធនឹងការបញ្ចេញកាកសំណល់ទៅក្នុងដី ទឹកនិងអាកាស ព្រមទាំងការគ្រប់គ្រងធនធានទាំងនៅក្រោម ទាំងនៅលើដីនិងទឹក ២). ការរៀបចំផែនការមេសម្រាប់តំបន់ ៣). ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនសាធារណៈក្នុងតំបន់ ៤). ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ ៥). ការគ្រប់គ្រងគ្រោះមហន្តរាយក្នុងតំបន់ និង ៦). ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនិងសម្របខ្លួននឹងការប្រែប្រួលអាកាសធាតុ
- រដ្ឋបាលកម្រិតមូលដ្ឋាន ផ្តោតសំខាន់ទៅលើកិច្ចការនិងមុខងារមួយចំនួនដែលមានបច្ច័យលើជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរួមមាន ១). ការផ្តល់សេវាសាធារណៈជាមូលដ្ឋានរួមមាន ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ការគ្រប់គ្រងសំរាម ការកសាងនិងថែទាំផ្លូវនៅក្នុងមូលដ្ឋាន ២). ការលើកកម្ពស់សុខុមាលភាពមូលដ្ឋានរួមមាន ការបង្កើតបណ្ណាល័យ សួនច្បារ ឧទ្យានជាតិ កន្លែងលេងកម្សាន្តសម្រាប់កុមារ ៣). ការរៀបចំផែនការនិងអភិវឌ្ឍការប្រើប្រាស់ដីនៅក្នុងមូលដ្ឋាន ៤). ការត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តច្បាប់ ៥). ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានតាមរយៈការគាំទ្រធុរកិច្ចក្នុងមូលដ្ឋាន (Local business) ព្រមទាំងការជំរុញនិងលើកកម្ពស់ទេសចរណ៍ និង៦). ការឆ្លើយតបនឹងគ្រោះមហន្តរាយ តាមរយៈកិច្ចសហការជាមួយរដ្ឋបាលតំបន់ក្នុងការត្រៀមខ្លួននិងឆ្លើយតបជាមួយនឹងគ្រោះមហន្តរាយ។

**ខ.៣. លក្ខណៈពិសេសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ណូវែល ហ្សេឡង់ ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានលក្ខណៈពិសេសដាច់ដោយឡែកដាច់ចេញពីរដ្ឋបាលកណ្តាល។ លក្ខណៈពិសេសអាចមើលឃើញក្នុងរូបភាពសំខាន់ៗរួមមាន៖

- ទិដ្ឋភាពរដ្ឋបាល៖ រដ្ឋបាលថ្នាក់ក្រោមជាតិ មានស្វ័យភាពរដ្ឋបាលពេញលេញដាច់ចេញពីរដ្ឋបាលកណ្តាលដែលមានន័យថារដ្ឋបាលកណ្តាលមិនមានសិទ្ធិជ្រៀតជ្រែកក្នុងការដឹកនាំគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ។ រដ្ឋបាលថ្នាក់ក្រោមជាតិមានក្រុមប្រឹក្សាភិបាលមួយដែលកើតចេញពីការបោះឆ្នោត (៣ឆ្នាំម្តង) ដែលមានតួនាទីរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងជាអ្នកតែងតាំងនាយកប្រតិបត្តិ (Chief Executive) តាមរយៈកិច្ចសន្យាការងារដែលមានរយៈពេលប្រាំឆ្នាំ។ តួនាទីគន្លឹះរបស់នាយកប្រតិបត្តិរួមមាន ១). គ្រប់គ្រងការងារប្រចាំថ្ងៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងការជ្រើសរើសនិងគ្រប់គ្រងបុគ្គលិក ២). អនុវត្តគោលនយោបាយដែលបានអនុម័តដោយក្រុមប្រឹក្សា ៣). គ្រប់គ្រងហិរញ្ញវត្ថុនិងអនុវត្តថវិកាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត និង៤). ជាតំណាងក្រុមប្រឹក្សានៅចំពោះមុខរដ្ឋបាលកណ្តាល វិស័យឯកជននិងប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ទិដ្ឋភាពហិរញ្ញវត្ថុ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ មានស្វ័យភាពហិរញ្ញវត្ថុដាច់ចេញពីរដ្ឋបាលកណ្តាល ដែលមានន័យថាការរៀបចំនិងអនុម័តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមិនតម្រូវឱ្យមានការអនុម័តយល់ព្រមពីរដ្ឋបាលកណ្តាលនោះទេ។ ស្វ័យភាពហិរញ្ញវត្ថុនេះកើតចេញពីប្រភព៥យ៉ាងរួមមាន ១). ការប្រមូលពន្ធដែលក្នុងនោះផ្អែកតាមច្បាប់ រដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកកំណត់និងប្រមូលពន្ធលើអចលនទ្រព្យ (ស្មើនឹង៥៨%នៃប្រភពចំណូលសរុប) ២). ការប្រមូលកម្រៃប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ស្មើនឹង១៦%នៃប្រភពចំណូលសរុប) ៣). ឧបត្ថម្ភធនពីរដ្ឋបាលកណ្តាលសម្រាប់គម្រោងសេវាសាធារណៈជាក់លាក់ (ស្មើនឹង១៦%នៃប្រភពចំណូលសរុប) ៤). ការផ្តល់អាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ស្មើនឹង៧%នៃប្រភពចំណូលសរុប) និង៥). ភាគកម្មដែលកើតចេញពីការវិនិយោគ (ស្មើនឹង៣%នៃប្រភពចំណូលសរុប)។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុឬធនាគារពាណិជ្ជដើម្បីគាំទ្រគម្រោងវិនិយោគសាធារណៈរបស់ខ្លួន
- ការត្រួតពិនិត្យ៖ រដ្ឋបាលថ្នាក់ក្រោមជាតិរងការត្រួតពិនិត្យមួយចំនួនទាំងពីរដ្ឋបាលកណ្តាលទាំងពីសាធារណជនលើការងារមួយចំនួនរួមមាន ១). រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាពនិង

៦

ផែនការថវិកាប្រចាំឆ្នាំដែលត្រូវឆ្លងកាត់ការប្រឹក្សាយោបល់ជាសាធារណៈនិងជាកាតព្វកិច្ច ២). រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដែលរបាយការណ៍នេះត្រូវឆ្លងសវនកម្មពីអគ្គសវនករជាតិ និង៣). ផែនការអភិវឌ្ឍ ៣០ឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវឆ្លងសវនកម្មមួយដងក្នុងរយៈពេល១០ឆ្នាំ។

**គ. ប្រព័ន្ធសមិទ្ធកម្មសាធារណៈរបស់ប្រទេសនូវែលហ្សេឡង់**

**គ.១. ប្រព័ន្ធសមិទ្ធកម្មសាធារណៈរបស់ប្រទេសនូវែលហ្សេឡង់** *ឧទ្ទេសនាមដោយលោកសាស្ត្រាចារ្យបណ្ឌិត Wonhyuk Cho*

ប្រធានបទនេះ បានគូសរំលេចអំពីគោលដៅយុទ្ធសាស្ត្ររបស់ប្រទេសនូវែលហ្សេឡង់ ឆ្នាំ២០២៤-២០២៨ ដែលជាឯកសារផ្លូវការតម្រង់ទិសសម្រាប់សកានិងវិស័យសាធារណៈនូវែលហ្សេឡង់ ក្នុងការចូលរួមដល់ការសម្រេចនូវសន្តិសុខ វិបុលភាព និងនិរន្តរភាពរបស់ប្រទេស។ ទន្ទឹមនឹងនេះ ប្រធានបទ ក៏បានផ្តោតសំខាន់ទៅប្រព័ន្ធសមិទ្ធកម្មសាធារណៈរបស់ប្រទេសនូវែលហ្សេឡង់ ដែលមាននូវទីភ្នាក់ងារកណ្តាលចំនួន ៥ ដែលមានតួនាទីចម្បងក្នុងការសម្របសម្រួលនិងគ្រប់គ្រងសមិទ្ធកម្មសេវាសាធារណៈ រួមមាន៖ ក្រសួងនាយករដ្ឋមន្ត្រីនិងខុទ្ទកាល័យ (The Department of the Prime Minister and Cabinet), គណៈកម្មការសេវាសាធារណៈ (the Public Service Commission), រតនាគារ (the Treasury), ក្រសួងនីតិកម្ម (the Ministry for Regulation) និងទីភ្នាក់ងារវិនិយោគសង្គម (the Social Investment Agency)។

បន្ថែមពីនេះ បទឧទ្ទេសនាមបានរំលេចនូវកម្មវិធីត្រួតពិនិត្យលើការបង្កើនសមិទ្ធកម្មរបស់គណៈកម្មការសេវាសាធារណៈរបស់ប្រទេសណូវែល ហ្សេឡង់ ដែលជាគំនិតផ្តួចផ្តើមសម្រាប់ការបង្កើនសមិទ្ធកម្មរបស់ទីភ្នាក់ងារនិងប្រព័ន្ធទាំងឡាយនៃវិស័យសាធារណៈ ក្នុងគោលដៅជួយសម្រួចអាទិភាពរបស់រដ្ឋាភិបាល និងពាំនាំលទ្ធផលនិងសមិទ្ធកម្មសម្រាប់ប្រជាជននូវែលហ្សេឡង់។

លោកសាស្ត្រាចារ្យបណ្ឌិត បានលើកឡើងអំពីក្របខ័ណ្ឌនិងយន្តការគាំទ្រសមិទ្ធកម្មសាធារណៈ ដោយតម្រូវមានការចូលរួមពីគ្រប់អង្គភាពសាធារណៈ ដោយសមិទ្ធកម្មសង្គម (social performance) មានការផ្សារភ្ជាប់នឹងថវិកាសុខុមាលភាពសង្គម (well-being budget)។ ម្យ៉ាងវិញទៀត បន្ថែមនិងក្រៅពីខ្លឹមសារនៃបទឧទ្ទេសនាមលោកសាស្ត្រាចារ្យ បានណែនាំសិក្ខាកាមទាំងអស់ដោយបែងចែកជា ៤ ក្រុម ដើម្បីជជែកពិភាក្សាលើក្របខ័ណ្ឌវិនិយោគសង្គមរបស់ប្រទេសកម្ពុជាដោយផ្តោតលើអាទិភាពនៃគោលនយោបាយ ភាគីពាក់ព័ន្ធ និងទិសដៅសម្រាប់អនាគតផងដែរ។

ក្រោយពីកិច្ចពិភាក្សា លោកសាស្ត្រាចារ្យ បានលើកឡើងអំពីអភិក្រមវិនិយោគសង្គម (Social Investment Approach) ដែលជាក្របខ័ណ្ឌមួយនៃសមិទ្ធកម្មសាធារណៈរបស់ប្រទេសណូវែល ហ្សេឡង់ ដោយធានាការចំណាយវិនិយោគសាធារណៈផ្សារភ្ជាប់នឹងសមិទ្ធកម្មឬលទ្ធផលចុងក្រោយ និងមានគោលការណ៍មួយចំនួនដោយបញ្ចៀសនូវការវិនិយោគរយៈពេលខ្លីនិងលក្ខណៈចំណាយមិនប្រចាំ (short-term and one-off) និងអនុលោមតាមវិធីសាស្ត្រជាប្រព័ន្ធដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ទិន្នន័យវិភាគ (data-based) ភស្តុតាង (evidence-based) សម្រាប់ការបង្កើនសមិទ្ធកម្មដល់សុខុមាលភាពសង្គម។ អភិក្រមនេះ ត្រូវបានអនុវត្តទូទៅគាំទ្រដល់សមិទ្ធកម្មពាក់ព័ន្ធនឹងសុខុមាលភាពសង្គម ទន្ទឹមនឹងទីភ្នាក់ងារវិនិយោគសង្គម មានមុខងារជាអាទិ៍ការកំណត់ស្តង់ដាសម្រាប់ការវិនិយោគសង្គម ដើម្បីធានាសង្គតិភាពរវាងទីភ្នាក់ងាររដ្ឋាភិបាលនិងអ្នកផ្គត់ផ្គង់ ការប្រឹក្សានិងសម្របសម្រួលលើការបង្កើនហេដ្ឋារចនាសម្ព័ន្ធទិន្នន័យនិងភស្តុតាងចាំបាច់សម្រាប់ការវិនិយោគសង្គម សហការជាមួយទីភ្នាក់ងារផ្សេងទៀតលើការអនុវត្តការវិនិយោគសង្គម និងដឹកនាំការត្រួតពិនិត្យជាប្រចាំលើចំណាយវិស័យសង្គមធៀបនឹងលទ្ធផលចុងក្រោយ។

**គ.២. បទបង្ហាញដោយសិក្ខាកាមកម្ពុជា តាមប្រធានបទចំនួន ៤**

វគ្គទី២នេះ ត្រូវបានចាប់ផ្តើមនាពេលរសៀលថ្ងៃដដែល ដោយសិក្ខាកាម ត្រូវបានបែងចែកជា ៤ ក្រុម រួមមាន៖

១. ក្រុមទី១ ពិភាក្សាលើប្រធានបទ ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ"

២. ក្រុមទី២ ពិភាក្សាលើប្រធានបទ ស្តីពី "ប្រព័ន្ធសមិទ្ធកម្មសាធារណៈ"

៣. ក្រុមទី៣ ពិភាក្សាលើប្រធានបទ ស្តីពី "ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ" និង

៤. ក្រុមទី៤ ពិភាក្សាលើប្រធានបទ ស្តីពី "កិច្ចសហការគោលនយោបាយ (public collaboration)"។

ការពិភាក្សាក្រុមប្រើប្រាស់រយៈពេល ៣០ នាទី ដោយផ្តោតលើការពិភាក្សាចំពោះ ៣ សំណួរ រួមមាន៖ ១)-តើសិក្ខាកាមអាចទាញចេញជាមេរៀនអ្វីខ្លះពីប្រធានបទ? ២)-តើអ្វីដែលសិក្ខាកាមភ្ញាក់ផ្អើលខ្លាំងលើអតិក្រមរបស់ប្រទេសនូវែលហ្សេឡង់លើប្រធានបទ? និង៣)-តើអ្វីដែលសិក្ខាកាមមានចំណាប់អារម្មណ៍ក្នុងការអនុវត្តនៅក្នុងប្រទេសកម្ពុជាវិញ? បន្ទាប់មក ក្រុមនីមួយៗ ត្រូវបានផ្តល់បទបង្ហាញនៃលទ្ធផលកិច្ចពិភាក្សាក្រុម ដល់សិក្ខាកាមនៃវគ្គបណ្តុះបណ្តាល ដោយមានខ្លឹមសារគន្លឹះ ដូចតទៅ៖

➢ ប្រធានបទ ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" បានរំលេចអំពី៖
  - ទិដ្ឋភាពទូទៅនិងការប្រៀបធៀបនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈប្រទេសនូវែលហ្សេឡង់
  - ចំពោះមេរៀនគន្លឹះដែលទទួលបានពីប្រធានបទនេះពីប្រទេសនូវែលហ្សេឡង់ រួមមាន៖ បម្រែបម្រួលបន្ទាត់គណនេយ្យភាពនៃរដ្ឋាភិបាល, ការកែទម្រង់សាធារណៈគន្លឹះ អនុលោមតាមច្បាប់ហិរញ្ញវត្ថុសាធារណៈឆ្នាំ ១៩៨៩ ដោយផ្តោតលើប្រព័ន្ធគណនេយ្យមូលដ្ឋានបង្គរ និងការផ្តោតលើការគ្រប់គ្រងវិស័យសាធារណៈបែបទំនើប (New public management - NPM), រដ្ឋបាលថ្នាក់ក្រោមជាតិ មានស្វ័យភាពក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួនដោយមិនចាំបាច់មានការយល់ព្រមពីរដ្ឋាភិបាលកណ្តាល និងអាចខ្ចីពីទីផ្សារដោយអនុលោមច្បាប់រដ្ឋបាលថ្នាក់ក្រោមជាតិ, និងការិយបរិច្ឆេទឆ្នាំសារពើពន្ធគឺចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា
  - ចំណុចចំណាប់អារម្មណ៍ពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈប្រទេសនូវែលហ្សេឡង់ គឺកម្រិតនៃបន្ទាត់គណនេយ្យភាព, ការផ្លាស់ប្តូរឱកាសមិទ្ធកម្មទៅជាវប្បធម៌សមិទ្ធកម្ម ពោលគឺលទ្ធផលចុងក្រោយត្រូវរួមផ្សំការពិចារណាទាំងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងលទ្ធផលចុងក្រោយដែលគ្រោងសម្រេច, និងទស្សនាទាននៃ Capital Charge
  - មេរៀនដែលអាចពិចារណាអនុវត្តនៅប្រទេសកម្ពុជាបាន ក្រុមពិភាក្សាបានលើកអំពីការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ វប្បធម៌សមិទ្ធកម្ម និងទស្សនាទាននៃ Capital Charge។

➢ ប្រធានបទ ស្តីពី "ប្រព័ន្ធសមិទ្ធកម្មសាធារណៈ" បានផ្តោតលើចំណុច ដូចតទៅ៖
  - មេរៀនគន្លឹះពីប្រធានបទនេះ រួមមាន៖ ប្រព័ន្ធរដ្ឋបាលសាធារណៈរបស់ប្រទេសណូវែល ហ្សេឡង់ មានការញែកដាច់រវាងមុខងារមន្ត្រីនយោបាយនិងមន្ត្រីបច្ចេកទេស, រដ្ឋមន្ត្រីត្រូវបានបែងចែកមុខងារទទួលបន្ទុកក្រសួង ស្ថាប័នជាកញ្ចប់ (Portfolio) ពោលរដ្ឋមន្ត្រីមួយរូបអាចទទួលបន្ទុកក្រសួងលើសពីមួយ, ប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិជាអ្នកកំណត់គោលនយោបាយរួមសម្រាប់ជាតិ, ការជ្រើសរើសមន្ត្រីគឺជាសិទ្ធិស្វ័យសម្រេចដោយអ្នកគ្រប់គ្រងជំបូង (first-line manager) ដែលស្ថិតក្រោមឋានានុក្រមរបស់អគ្គនាយកក្រសួង ស្ថាប័ន (Chief Executive - CE), មន្ត្រីដែលត្រូវបានជ្រើសរើស ត្រូវបម្រើការក្រោមកិច្ចសន្យាការងារ, ក្របខ័ណ្ឌវាយតម្លៃសមិទ្ធកម្មគឺត្រូវបានផ្តោតគ្រប់ទិដ្ឋភាពនិងគ្រប់កម្រិត រួមមានសមិទ្ធកម្មស្ថាប័ន សមិទ្ធកម្មបុគ្គល និងសមិទ្ធកម្មគោលនយោបាយ ពោលសមិទ្ធកម្មផ្តោតលើការកសាងសមត្ថភាពជាប្រចាំ
  - ចំណុចចំណាប់អារម្មណ៍ខ្លាំងពីប្រធានបទ គឺ ១)-បៀវត្សរបស់មន្ត្រីបច្ចេកទេស ខ្ពស់ជាងមន្ត្រីនយោបាយ ពោលបៀវត្សរបស់អគ្គនាយក ខ្ពស់ជាងរដ្ឋមន្ត្រី ២)-ការជ្រើសរើសមន្ត្រីត្រូវរៀបចំតាមក្រសួង ស្ថាប័ន ដោយមានតម្រូវការជាក់លាក់ និងស្ថិតក្រោមសិទ្ធិស្វ័យសម្រេចរបស់ក្រសួង ស្ថាប័ននោះ ដោយមិនមានការរៀបចំជ្រើសរើសថ្នាក់ជាតិ និង ៣)-ក្របខ័ណ្ឌសមិទ្ធកម្ម ត្រូវបានពង្រឹងខ្លាំង ទាំងមន្ត្រីនយោបាយនិងមន្ត្រីបច្ចេកទេស និងត្រូវបានពង្រឹងតាមរយៈយន្តការស្ថាប័នដល់បុគ្គលក្រោមទម្រង់កិច្ចសន្យា និងយន្តការធានាដោយមានស្ថាប័នសួលថ្នាក់ជាតិ ពោលធានាការចូលរួមដល់ការសម្រេចដល់គោលដៅយុទ្ធសាស្ត្ររបស់ជាតិ

៨

ចំណេះដឹងពីប្រធានបទ ដែលពិចារណាសម្រាប់កម្ពុជា គឺការពិចារណាបន្ថែមលើការបង្កើនបៀវត្សមន្ត្រីបច្ចេកទេស, ការពិចារណាបន្ថែមលើការជ្រើសរើសមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ និងការកសាងក្របខ័ណ្ឌសមិទ្ធកម្មសាធារណៈ។

- ➢ ប្រធានបទ ស្តីពី "ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ" បានបង្ហាញនូវលទ្ធផលដូចតទៅ៖
  - មេរៀនគន្លឹះពីប្រធានបទនេះ ដោយមានការយល់ដឹងអំពីប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ប្រទេសនូវ៉ែលហ្សេឡង់ រួមមានរចនាសម្ព័ន្ធ គោលបំណងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មុខងារក្រុមប្រឹក្សាដែនដីនិងតំបន់ ទ្រឹស្តីការគ្រប់គ្រងវិស័យសាធារណៈបែបទំនើប គោលការណ៍សិទ្ធិសម្រេច និងគោលការណ៍តម្លាភាពនិងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - ចំណុចចំណាប់អារម្មណ៍ពីអតិក្រមរបស់ប្រទេសនូវ៉ែលហ្សេឡង់លើប្រធានបទនេះ គឺរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសនូវ៉ែលហ្សេឡង់មានចំនួនតិច ដោយមានការបែងចែកមុខងារច្បាស់លាស់, ស្វ័យភាពខ្លាំង (រួមមានការកំណត់កម្រៃ ការយកពន្ធ សិទ្ធិសម្រេច ការលើកកម្ពស់សិទ្ធិសហគមន៍ ជំនឿទុកចិត្តពីពលរដ្ឋ), ប្រព័ន្ធរៀបចំផែនការរយៈពេលវែង (រយៈពេល១០ឆ្នាំ ដោយមានការពិនិត្យកែសម្រួលរៀងរាល់៣ឆ្នាំម្តង និងរយៈពេល ៣០ ឆ្នាំចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ), យន្តការសម្របសម្រួលរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋាភិបាលថ្នាក់ជាតិ ដោយមានការរៀបចំវេទិកាប្រចាំឆ្នាំ, តួនាទីសមាគមរដ្ឋបាលថ្នាក់ក្រោមជាតិនិងតួនាទីរបស់អគ្គនាយកនៅរដ្ឋបាលថ្នាក់ជាតិ (ករណីបៀវត្ស ការគ្រប់គ្រងនិងជ្រើសរើសបុគ្គលិកជាដើម), តួនាទីអគ្គសវនករលើសវនកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ, និងនត្ថិភាពនៃការផ្ទេរមុខងារជាខ្ទង់ទៅពីរដ្ឋបាលថ្នាក់ជាតិ
  - ចំណេះដឹងពីប្រធានបទនេះដែលអាចដកស្រង់និងពិចារណាលើករណីកម្ពុជារួមមាន៖ ការពិនិត្យលើចំណុចខ្លាំងនិងចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាដោយការពិចារណាលើគ្រប់ធាតុផ្សំជាអាទិ៍ ទ្រឹស្តី ការអនុវត្ត បរិបទជាក់ស្តែង ទិដ្ឋភាពវប្បធម៌ និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា, ការពង្រឹងស្វ័យភាពមូលដ្ឋាន, ការលើកកម្ពស់សិទ្ធិរបស់សមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ, ការចូលរួមរបស់សាធារណៈជនសម្រាប់ការកសាងជំនឿទុកចិត្តសាធារណៈ, ការពង្រឹងសមត្ថភាពរបស់ថ្នាក់ក្រោមជាតិ និងការកសាងក្របខ័ណ្ឌការគ្រប់គ្រងសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ➢ ប្រធានបទ ស្តីពី "កិច្ចសហការគោលនយោបាយ (public collaboration)"៖
  - មេរៀនគន្លឹះពីប្រធានបទនេះ រួមមាន៖ ១)-ការវិវត្តខ្លាំងនៃតួនាទីនៃការចូលរួមរបស់ពលរដ្ឋ ដោយប្រែក្លាយពីទស្សនៈពលរដ្ឋជាអតិថិជន ទៅទស្សនៈមួយដែលពលរដ្ឋចូលរួមជាសហផលិតកម្ម (co-production) និង២)- សហអភិបាលកិច្ច (Co-Governance) ដែលកិច្ចសហការនេះ ជាដំណើរបន្តឥតដាច់និងការកសាងទំនាក់ទំនងរយៈពេលវែង ដោយតម្រូវមានការចូលរួមរួមគ្នាខ្សែច្រវ៉ាក់ផលិតកម្មនិងតម្លៃ ក្នុងការរៀបចំផែនការ ការផ្តល់សេវា ឬការត្រួតពិនិត្យសេវាសាធារណៈជាដើម។
  - ចំណុចចំណាប់អារម្មណ៍ពីប្រធានបទនេះ គឺ៖ ១)-ការផ្តោតលើភាពបត់បែន (Flexibility) ដោយស្ថាប័នសាធារណៈតែងតែសម្របសេវារបស់ខ្លួនទៅតាមបម្រែបម្រួលជាក់ស្តែងរបស់សង្គម និង ២)-តួនាទីជនជាតិភាគតិចក្នុងអភិបាលកិច្ច ដោយគោលនយោបាយរបស់ប្រទេសនូវ៉ែលហ្សេឡង់តែងតែចងភ្ជាប់ទៅនឹងសន្ធិសញ្ញា Waitangi ពោលការគិតគូរដល់ជនជាតិដើម Maori
  - ចំណេះដឹងពីប្រធានបទ ដែលពិចារណាសម្រាប់កម្ពុជា រួមមាន៖ ១)-ការបង្កើនការចូលរួមរបស់ពលរដ្ឋក្នុងការរៀបចំផែនការ ការសម្រេចចិត្ត និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ និង ២)-ការរៀបចំនូវវេទិកា ឬគណៈកម្មាធិការសម្រាប់ការចូលរួមផ្តល់ការ។

វគ្គបណ្តុះបណ្តាលនេះបានបញ្ចប់ដោយជោគជ័យនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ដោយបានផ្តល់ពុទ្ធិនិង បទពិសោធន៍ផ្នែកអនុវត្តដ៏មានតម្លៃដល់គណៈប្រតិភូទាំង៣០ រូប។

ថ្ងៃពុធ ១២ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥
**អ្នកធ្វើរបាយការណ៍**

**លី ឌុង**

បានឃើញនិងសូមគោរពជូន
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ
កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ដើម្បីពិនិត្យនិងជ្រាបជារបាយការណ៍
ថ្ងៃ ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៥
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការស្តីទី**
**នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ែល ចំរើន**

ថ្ងៃ ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

១០

# ឧបសម្ព័ន្ធទី៧

ឧបសម្ព័ន្ធទី៧

# ឧបសម្ព័ន្ធទី៧. របាយការណ៍ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥ ស្តីពី "វិបស្សនាប្រចាំឆ្នាំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.) ខេត្តសៀមរាប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ: ២១៧ កសហវ/អគកហ

ទូទៅនីយ៍ ក.ស.ហ.វ.
បានទទួលថ្ងៃទី 8/4/25 ម៉ោង.........
លេខ: 2.506290

ថ្ងៃ[illegible]កើតខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា គ.ស. ២០២៥

សូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ៖** ការស្នើសុំពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់លើរបាយការណ៍លទ្ធផលស្តីពី "វិបស្សនាប្រចាំឆ្នាំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.ក.**)"។

**យោង** ៖- លិខិតលេខ ២០១៧ សហវ.ល.ស.អគហ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ១៦៣ និង ១៦៤ សហវ/អគហ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាខ្ពង់ខ្ពស់ថា កាលពីថ្ងៃពុធ-ព្រហស្បតិ៍ ១៣-១៤កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៥ វិបស្សនាប្រចាំឆ្នាំស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការ សម្របសម្រួល និងសហការដឹកនាំដោយខ្ញុំផ្ទាល់ តាងនាមដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **ឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានប្រចាំការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់, **ឯកឧត្តម លី ច័ន្ទតុលា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**អ.គ.ក.ច.**), **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**អ.គ.ក.ស.**), **ឯកឧត្តម ជ័យ សម្បត្តិផល្លា** ប្រធានអង្គភាពភាគនិងអភិវឌ្ឍគោលនយោបាយ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**លគ.ជ.អ.ប.**), **ឯកឧត្តម នុប សុចនធិសុទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (**អ.គ.ក.ប.យ.**) និងមានការអញ្ជើញចូលរួមពីអង្គភាពក្រោមឱវាទក្រសួងនៃការដ្ឋានកែទម្រង់ទាំង៥ សរុបប្រមាណ ១០០រូប។

វិបស្សនានេះបានពិភាក្សាលើរបៀបវារៈ និងសម្រេចជាលទ្ធផលគន្លឹះដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ដូចតទៅ៖

អគារលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
gsc@pfm.gov.kh
admin@pfm.gov.kh

ទំព័រ ១

ទូរស័ព្ទ: (+៨៥៥) ៨៥ ៧៧៧ ៩២០
Phone: (+855) 85 777 920
gsc@pfm.gov.kh
admin@pfm.gov.kh

**ក. កិច្ចដំណើរការនៃវិបស្សនាប្រចាំឆ្នាំ**

**១. ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥**

➢ របៀបវារៈនាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ត្រូវបានបែងចែកជា ២វគ្គ ដោយ វគ្គទី១ អំពីការចាប់ផ្តើមអង្គវិបស្សនាដោយមានរបាយការណ៍គន្លឹះរបស់តំណាងអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់ទាំង៥ ដែលមានខ្លឹមសារសង្ខេប ដូចតទៅ៖

- តាងនាម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និង **ឯកឧត្តម រស់ សីលវ៉ា** ខ្ញុំបានចាប់ផ្តើមមតិបើកអង្គវិបស្សនាដោយសង្កត់ធ្ងន់ពីសារតារ កម្មវត្ថុនៃវិបស្សនា ទស្សនាទាននៃកម្មវិធីកែទម្រង់នីមួយៗ ភាពទៀងទាត់នៃរបបកិច្ចប្រជុំប្រចាំត្រីមាសក្នុងក្របខ័ណ្ឌនៃ **ឃ.ស.ក.** ដឹកនាំដោយអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាន ដែល **អ.គ.ហ.** សម្របសម្រួលជាលេខាធិការដ្ឋាននៃ **ឃ.ស.ក.** ក្នុងការរៀបចំកំណត់កាលបរិច្ឆេទប្រជុំ លិខិតអញ្ជើញ របាយការណ៍ ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដើម្បីលើកយកការងារអាទិភាព បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយរួមគ្នាជាជំហានយុទ្ធសាស្ត្រ នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំតាមត្រីមាសនីមួយៗ។ ជាមួយគ្នានេះ ការរៀបចំចក្ខុវិស័យគឺផ្តោតសំខាន់លើការធ្វើសុខដុមនីយកម្មរវាងកម្មវិធីកែទម្រង់គន្លឹះទាំង៥ ដែលមានគោលបំណងចំនួន២៖ ១)- ដោះស្រាយបញ្ហាចំពោះមុខ និង ២)- រៀបចំជំហានយុទ្ធសាស្ត្រនាពេលអនាគត ទន្ទឹមនឹងការរៀបចំផែនការត្រូវគិតគូរអំពីសមិទ្ធិលទ្ធភាពដែលអាចអនុវត្តនិងសម្រេចបាន

- **ឯកឧត្តម លី ច័ន្ទតុលា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃ **អ.គ.ក.ច.** បានលើកឡើងថានេះជាការចូលរួមជាលើកទី១ ក្នុងវិបស្សនាប្រចាំឆ្នាំនៃ **ឃ.ស.ក.** នេះ និងលើកអំពីសារបាននៃកម្មវិធីកែទម្រង់ច្បាប់ស្របពេលដែល **អ.គ.ក.ច.** ជាអង្គភាពថ្មីដែលត្រូវការធនធានមនុស្សបន្ថែម និងបានលើកឡើងសំណើសកម្មភាពបន្ថែមបន្ទាប់ពីវិបស្សនា សម្រាប់សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ នៃ **ឃ.ស.ក.** ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់នៃរាជរដ្ឋាភិបាល

- **ឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានប្រចាំការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានលើកឡើងអំពីការផ្សារភ្ជាប់គ្នារវាងក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមការងារកែទម្រង់ច្បាប់ដែលតម្រូវឱ្យមានការបង្កើតក្រុមការងារនីតិកម្មតាមក្រសួង-ស្ថាប័ន

- **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃ **អ.គ.ក.ស.** បានលើកឡើងអំពីប្រសាសន៍គាំទ្រដល់ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើ **ឃ.ស.ក.** និងបានលើកឡើងអំពីសសរស្តម្ភនៃកម្មវិធីទាំង៥ រួមមាន៖ មុខងារ ហិរញ្ញវត្ថុ ធនធានមនុស្ស ច្បាប់ និងយុត្តិធម៌។ វិបស្សនាប្រចាំឆ្នាំនេះ ពិតជាមានសារៈសំខាន់ដែលមានតួនាទីក្នុងការជួយសម្របសម្រួល និងជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីបង្កើននូវកិច្ចសហការក្នុងក្របខ័ណ្ឌនៃ **ឃ.ស.ក.** និងរៀបចំផែនការក្នុងការអភិវឌ្ឍមន្ត្រីជំនាញហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់ទាំង៤ ផ្សេងទៀត

- **ឯកឧត្តម ជ័យ សម្បត្តិផល្លា** ប្រធានអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយ នៃ **ល.គ.ជ.អ.ប.** បានលើកឡើងថា យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ត្រូវបានគាំទ្រដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីបើកវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដើម្បីជំរុញការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌនៃ **ឃ.ស.ក.**

- **ឯកឧត្តម ទុប សុធនវិសុទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ តំណាង **អ.គ.ក.ប.យ.** បានលើកឡើងអំពីវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាពិសេសការបង្កើត

ទំព័រ ២

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការកសាងធនធានមនុស្ស ដែលបង្ហាញអំពីទិដ្ឋភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌។

- វគ្គទី២ ការធ្វើបទបង្ហាញចំនួន២ រួមមាន៖ បទបង្ហាញទី១ ស្ដីពី "របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៤ និងសេចក្ដីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ នៃ **ឃ.ស.ក.**" និងបទបង្ហាញទី២ ស្ដីពី "ការធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល" ដោយមន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**។ បន្ទាប់ពីបទបង្ហាញទាំង២ អង្គភាពក្រោមឱវាទក្រសួងនៃការដ្ឋានកែទម្រង់ទាំង៥ បានផ្ដល់ជាមតិយោបល់ទៅលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៤ និងសេចក្ដីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ នៃ **ឃ.ស.ក.** បន្ថែមពីនេះ អង្គសិក្ខាសាលាបានឯកភាពវិធីសាស្ត្រវាយតម្លៃរបស់ក្រុមការងារ។

សម្រាប់របៀបវារៈ នាពេលរសៀលថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ គឺកិច្ចពិភាក្សាតាមក្រុមចំនួន៣ ដែលប្រព្រឹត្តទៅរយៈពេល ៣ម៉ោង ដូចតទៅ៖

- **ក្រុមទី១៖** យុទ្ធសាស្ត្រទី១ ស្ដីពីសុខដុមនីយកម្មប្រព័ន្ធការងារនៃ **ឃ.ស.ក.** និងយុទ្ធសាស្ត្រទី២ ស្ដីពីសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មដឹកនាំសម្របសម្រួលដោយ **ឯកឧត្តម ជ័យ សម្បត្តិផល្លា**
- **ក្រុមទី២៖** យុទ្ធសាស្ត្រទី៣ ស្ដីពីសុខដុមនីយកម្មប្រព័ន្ធដំណើរការនៃ **ឃ.ស.ក.** ដឹកនាំសម្របសម្រួលដោយ **ឯកឧត្តម ឈុន សុជាតិ**
- **ក្រុមទី៣៖** បច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដឹកនាំសម្របសម្រួលដោយ **ឯកឧត្តម លី ច័ន្ទតុលា ឯកឧត្តមបណ្ឌិត ស៊ា រ៉ៅ** និង **ឯកឧត្តម នុប សុធនវិសុទ្ធ**។

២. ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥

របៀបវារៈនាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ ត្រូវបានរៀបចំមួយព្រឹក ដោយមានបទបង្ហាញលទ្ធផលកិច្ចពិភាក្សាក្រុមទាំង៣ និងមានការពិភាក្សាលម្អិតទៅលើប្រធានបទនីមួយៗ ដូចជាការកំណត់សម្រួចសកម្មភាព សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ ការបន្ថែមសកម្មភាពថ្មី ក្របខ័ណ្ឌចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃ **ឃ.ស.ក.** និងក្របខ័ណ្ឌឯកសារបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

**ខ. លទ្ធផលនៃអង្គសិក្ខាសាលា និងសំណើសុំការសម្រេច**

បន្ទាប់ពីបានពិនិត្យពិភាក្សាលម្អិតលើរបៀបវារៈរយៈពេល ១ថ្ងៃ កន្លះ អង្គសិក្ខាសាលាបានសំយោគ បូកសរុប និងឯកភាពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ពិនិត្យនិងសម្រេចជំនួងខ្ពស់ដូចតទៅ៖

១. ក្របខ័ណ្ឌចក្ខុវិស័យនិងយុទ្ធសាស្ត្រ

- ចក្ខុវិស័យ៖ **សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល**
- បេសកកម្ម៖ **ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព នៃភាពប្រទាក់ប្រឡាក្នាជាអន្តរកែទម្រង់ ស្របតាមអតិក្រមដចភាពនៃប្រព័ន្ធតួអង្គតែមួយ**
- យុទ្ធសាស្ត្រ៣៖
    - យុទ្ធសាស្ត្រទី១៖ **សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ**
    - យុទ្ធសាស្ត្រទី២៖ **សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម**
    - យុទ្ធសាស្ត្រទី៣៖ **សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ**
- កែសម្រួលក្របខ័ណ្ឌកម្មវិធីចំនួន១៖ ឈ្មោះកម្មវិធី ១.៤. កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន/ប្រព័ន្ធឌីជីថល។

២. **ឯកភាពលើការបន្ថែមសកម្មភាពដូចតទៅ៖**
- ការបង្កើតក្រុមការងារនីតិកម្មតាមក្រសួង-ស្ថាប័ន
- ការរៀបចំវេទិកាស្ដីពី "ជំនុំច្បាប់ទំនើប" នៅត្រីមាសទី៣ ឆ្នាំ២០២៥
- ការរៀបចំវេទិកាស្ដីពី "នីតិកម្ម និងការកែទម្រង់" នៅត្រីមាសទី៣ ឬ ត្រីមាសទី៤ ឆ្នាំ២០២៥
- ការរៀបចំវេទិកាស្ដីពី "ការការពារនីត្យានុកូលភាព និងវិវាទគតិយុត្ត" នៅត្រីមាសទី២ ឆ្នាំ២០២៥
- ការរៀបចំវេទិកាស្ដីពី "ការចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍នៃការដ្ឋានកែទម្រង់ទាំង៥" នៅត្រីមាសទី៣ ឬ ត្រីមាសទី៤ ឆ្នាំ២០២៥។

៣. **របបប្រជុំនៃ គ.ស.ក. ប្រចាំត្រីមាស ដោយ អ.គ.ហ. សម្របសម្រួលជាលេខាធិការដ្ឋាន នៃ គ.ស.ក.**
- ប្រចាំត្រីមាសទី១៖ **ល.គ.ជ.អ.ម.** ជាប្រធានប្ដូរវេន
- ប្រចាំត្រីមាសទី២៖ **អ.គ.ក.ប.ឃ.** ជាប្រធានប្ដូរវេន
- ប្រចាំត្រីមាសទី៣៖ **អ.គ.ក.ច.** ជាប្រធានប្ដូរវេន
- កិច្ចប្រជុំប្រចាំឆ្នាំ និងបែស្បនា៖ **អ.គ.ហ.** ជាប្រធានប្ដូរវេន។

៤. **ឯកភាពកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥** សម្រាប់អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននីមួយៗ មានលទ្ធភាពផ្ដល់សេចក្ដីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ កែសម្រួល និងខ្លឹមសារសម្រាប់បច្ចុប្បន្នកម្មឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល មក **អ.គ.ហ.**។

៥. **ឯកភាពនិងគោរពស្នើសុំរៀបចំនិងបោះពុម្ពឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលជាផ្លូវការ នៅត្រីមាសទី២ ឆ្នាំ២០២៥។**

៦. ឯកភាពលើការកំណត់របបប្រជុំនៃ **គ.ស.ក.** ប្រចាំត្រីមាសនីមួយៗ មានវត្តមានចូលរួមដោយអគ្គលេខាធិការ និងប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកម្មវិធីកែទម្រង់ទាំង៥ ជាចាំបាច់ ដើម្បីសម្របសម្រួលដឹកនាំកិច្ចប្រជុំនេះ។

៧. ឯកភាពនិងគោរពស្នើសុំរៀបចំពិធីប្រកាសដាក់ឱ្យអនុវត្ត **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** រយៈពេល ១ថ្ងៃពេញ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០២៥ ដែលអាចរៀបចំជាពីរជម្រើសដូចតទៅ៖
- **<u>ជម្រើសទី១ ៖</u>** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងដំណើរការដូចតទៅ៖
  - សូមគោរពអញ្ជើញវត្តមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ថ្លែងនូវរបាយការណ៍គន្លឹះ ពេលព្រឹកជូន **សម្ដេចធិបតីនាយករដ្ឋមន្ត្រី**
  - គោរពអញ្ជើញ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដឹកនាំកិច្ចពិភាក្សាបន្តនាពេលព្រឹក
  - សូមគោរពអញ្ជើញ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដឹកនាំកិច្ចពិភាក្សានាពេលរសៀល
  - សូមគោរពអញ្ជើញ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បូកសរុបនាពេលល្ងាចបញ្ចប់កម្មវិធី។

ទំព័រ ៥

- **<u>ជម្រើសទី២</u> ៖** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងដំណើរការដូចតទៅ៖
  - សូមគោរពអញ្ជើញវត្តមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ថ្លែងនូវរបាយការណ៍គន្លឹះ ពេលព្រឹកជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី**
  - សម្រាប់ការដឹកនាំកិច្ចពិភាក្សា អាចរៀបចំជាជម្រើសផ្សេងទៀតអាចជា **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ**
  - សូមគោរពអញ្ជើញ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បូកសរុបនាពេលល្ងាចបញ្ចប់កម្មវិធី។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ពិនិត្យ និងសម្រេច ឬមានការណែនាំបន្ថែមដោយជាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការរង**
**នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហៀល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃ ខែ ឆ្នាំ ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា គ.ស. ២០២៥
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំ ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ មេសា គ.ស. ២០២៥
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ទំព័រ ៥

# ឧបសម្ព័ន្ធទី៩

# ឧបសម្ព័ន្ធទី៨. របាយការណ៍ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីលទ្ធផលនៃកិច្ចប្រជុំស្តីពី "យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:......................................

25.2.25
25009/3 M

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ៖** ការស្នើសុំពិនិត្យនិងផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់លើរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំស្តីពី "យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល"។

**យោង ៖** លិខិតលេខ ០៧៩ សហវ/អគហ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថានាថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហ៊ើល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរង នៃ **អ.គ.ហ.** ដោយមានការចូលរួមពីតំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញ និងជំនួយការមន្ត្រីជំនាញនៃ **អ.គ.ហ.** សរុបចំនួនប្រមាណ ៣៥រូប ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈចំនួន២ ដូចតទៅ៖

- កិច្ចដំណើរការ និងលទ្ធផលរំពឹងទុកនៃទស្សនកិច្ចសិក្សាស្តីពី "Public Governance and Public Sector Reform – NPM to Today" នៅប្រទេសនូវែលហ្សេឡង់
- របាយការណ៍វឌ្ឍនភាពការងារប្រចាំឆ្នាំ២០២៤ និងសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ នៃចក្ខុវិស័យនិងយុទ្ធសាស្ត្រសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

កិច្ចប្រជុំ បានសម្រេចជាលទ្ធផលគន្លឹះដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ដូចតទៅ៖

**ក. កិច្ចដំណើរការនៃកិច្ចប្រជុំ**

កិច្ចប្រជុំនេះ ដំណើរការពិភាក្សាតាមរបៀបវារៈ ដូចតទៅ៖

- របៀបវារៈទី១ ការធ្វើបទបង្ហាញអំពីកិច្ចដំណើរ និងលទ្ធផលរំពឹងទុកនៃទស្សនកិច្ចសិក្សាស្តីពី "Public Governance and Public Sector Reform – NPM to Today" នៅប្រទេសនូវែលហ្សេឡង់ ដោយ **លោក ឌុន្នី សុត្រា** មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.** ដែលផ្តោតទៅលើចំណុចសំខាន់ៗ ចំនួន៥ រួមមាន៖ ១. ការស្វែងយល់ពីគោលការណ៍ស្នូលនិងអភិក្រមនៃការកែទម្រង់តាមបែបការគ្រប់គ្រងរដ្ឋបាលសាធារណៈទំនើប (New Public Management) ២. ការស្វែងយល់ពីកម្រិតនៃការឆ្លើយតបរបស់រដ្ឋចំពោះការផ្តល់សេវាទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ៣. ការវិភាគឥទ្ធិពលនៃការពង្រឹងការគ្រប់គ្រងវិស័យឯកជនរបស់រាជរដ្ឋាភិបាលនៃប្រទេសនូវែលហ្សេឡង់ ៤. ការស្វែងយល់ពីឧត្តមានុវត្តន៍និងចំណុចប្រឈមរបស់រាជរដ្ឋាភិបាលនៃប្រទេសនូវែលហ្សេឡង់ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ រដ្ឋបាលសាធារណៈ ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និង ៥. ការចុះពិនិត្យដោយផ្ទាល់នៅតាមស្ថាប័នសាធារណៈក្នុងក្របខ័ណ្ឌការដ្ឋានកែទម្រង់របស់ប្រទេសនូវែលហ្សេឡង់។ លទ្ធផលរំពឹងទុកនៃដំណើរ

ទំព័រ ១

Phone: (+855) 23 800 666

ទស្សនកិច្ចនេះ នឹងផ្តល់ធាតុចូលសម្រាប់ទិសដៅការងារជាអាទិភាព នៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (**យ.ស.គ.**) សម្រាប់ឆ្នាំ២០២៥ និងចូលរួមចំណែកក្នុងការធ្វើបច្ចុប្បន្នកម្មឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

- របៀបវារៈទី២ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២៤ និងសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ នៃចក្ខុវិស័យនិងយុទ្ធសាស្ត្រសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដោយ **លោក ស៊ុន គីមហោង** មន្ត្រីជំនាញ នៃ **អ.គ.មា.** ដោយបានបូកសរុបបឋមដែលទទួលបានពីគ្រប់ភាគីពាក់ព័ន្ធ។ បន្ទាប់ពីការធ្វើបទបង្ហាញទាំង២ខាងលើ តំណាងលេខាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាន បានផ្តល់ជាមតិយោបល់

និងលើកឡើងនូវសំណូមពរ ដូចតទៅ៖

- **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានលើកឡើងថាទស្សនកិច្ចសិក្សានៅប្រទេសនូវែលហ្សេឡង់ គឺជាការដកស្រង់បទពិសោធន៍ដ៏សំខាន់ និងផ្តល់ធាតុចូលបន្ថែមលើការអភិវឌ្ឍការងារកែទម្រង់រដ្ឋបាលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះ **ឯកឧត្តម** ក៏បានឯកភាពលើគម្រោងវិបស្សនាប្រចាំឆ្នាំ **យ.ស.គ.** និងស្នើឱ្យមានការបែកចែកជា៣ក្រុមពិភាក្សា ដែលផ្តោតទៅលើការពិភាក្សាតាមយុទ្ធសាស្ត្រ និងការធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្រពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។
- **ឯកឧត្តម រ៉ែន ម៉ិនឈា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**អ.គ.ក.ច.**) បានស្នើសុំការជួយគាំទ្របច្ចេកទេសនៃការរៀបចំផែនការសកម្មភាពរបស់ **អ.គ.ក.ច.** និងស្នើពិចារណាបន្ថែមលើសកម្មភាពដែលមានចរិតអន្តរកែទម្រង់ក្នុងការធ្វើកិច្ចការងាររួមគ្នា ប្រទាក់ក្រឡាគ្នា និងជួយគ្នាទៅវិញទៅមក។
- **ឯកឧត្តម ជ័យ សម្បត្តិថណ្ណា** ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) បានឯកភាពលើរបាយការណ៍វឌ្ឍនភាពនៃផែនការសកម្មភាពឆ្នាំ២០២៤ និងសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ ខាងលើ។ ទន្ទឹមនេះ លេខាធិការដ្ឋាន **គ.ជ.អ.ប.** ត្រូវទទួលជាប្រធានប្តូរវេនប្រចាំត្រីមាសទី៤ ឆ្នាំ២០២៤ នៃ **យ.ស.គ.** និងបានស្នើសុំបង្រួមកិច្ចប្រជុំប្រចាំត្រីមាសទី៤ នៃ **យ.ស.គ.** ក្នុងរបៀបវារៈវិបស្សនាប្រចាំឆ្នាំ **យ.ស.គ.** រួមគ្នាតែម្តង។

## ខ. លទ្ធផល និងសំណើសុំការសម្រេច

ជាការបូកសរុប និងលទ្ធផលនៃកិច្ចប្រជុំ អង្គប្រជុំបានឯកភាពលើចំណុចគន្លឹះ ដូចតទៅ៖

១. គម្រោងវិបស្សនាប្រចាំឆ្នាំ **យ.ស.គ.**

- កាលបរិច្ឆេទ៖ ថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៥
- ទីតាំង៖ ខេត្តសៀមរាប
- អង្គភាពចូលរួមមានតំណាងអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ទាំង៥ និងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងដឹកនាំការងារកែទម្រង់ទាំង៥
- របៀបវារៈនៃកិច្ចពិភាក្សាបែងចែកជា ៣ក្រុមពិភាក្សា រួមមាន៖ ក្រុមទី១ ពិភាក្សាលើយុទ្ធសាស្ត្រទី១ ស្តីពីសុខដុមនីយកម្មប្រព័ន្ធការងារនៃ **យ.ស.គ.** និងយុទ្ធសាស្ត្រទី២ ស្តីពីសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម, ក្រុមទី២ ពិភាក្សាលើយុទ្ធសាស្ត្រទី៣ ស្តីពីសុខដុមនីយកម្មប្រព័ន្ធដំណើរការនៃ **យ.ស.គ.** និងក្រុមទី៣ ពិភាក្សាលើការបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល និងសម្រួចសកម្មភាពអន្តរកែទម្រង់ មានជាអាទិ៍ ការងារសវនកម្មនិងអធិការកិច្ច, ការជំរុញបង្កើនអង្គភាពថវិកានិងការរៀបចំគោលការណ៍ណែនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការរៀបចំក្រុមរដ្ឋបាល ឬ កម្រងសម្រង់រដ្ឋបាល ឬ សការដ្ឋបាល, ការរៀបចំ Guide de légistique, ការតាមដានការផ្ទេរមុខងារ៥៥ និង២០វិស័យ, ទស្សនកិច្ចសិក្សាពីនិត្យលើការងារអន្តរកែទម្រង់នៅខេត្តកំពង់ធំ និងការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់វិស័យយុត្តិធម៌។

២. ការប្រគល់ភារកិច្ចជូន **ឯកឧត្តម ស៊ាង ថណ្ណា** អនុរដ្ឋលេខាធិការ **គសហវ.** និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (**ល.ក.ន.**) និង **លោក ណាន សាមឌី** អនុប្រធាន **ល.ក.ន.** ជួយគាំទ្របច្ចេកទេសនៃការរៀបចំផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន **អ.គ.ក.ច.**។

ទំព័រ ២

៣. របៀបកិច្ចប្រជុំ **យ.ស.ក.** ៖

- ប្រចាំត្រីមាសទី១ នៅសប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥
- ប្រចាំត្រីមាសទី២ នៅសប្តាហ៍ទី៣ ខែកក្កដា ឆ្នាំ២០២៥
- ប្រចាំត្រីមាសទី៣ នៅសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៥
- *ក្នុងក្របខ័ណ្ឌនៃការអនុវត្តការងារ យ.ស.ក. ប្រកបដោយប្រសិទ្ធភាព អ.គ.ហ. សម្របសម្រួលជាលេខាធិការដ្ឋានក្នុងការរៀបចំកំណត់កាលបរិច្ឆេទកិច្ចប្រជុំ លិខិតអញ្ជើញ របាយការណ៍ ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ សម្រាប់ដំណើរការកិច្ចប្រជុំប្រចាំត្រីមាសនីមួយៗ ដែលត្រូវដឹកនាំដោយលេខាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋានទទួលវេនប្រចាំត្រីមាសនីមួយៗ។*

៤. ការកំណត់កិច្ចប្រជុំ **យ.ស.ក.** នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥ វេលាម៉ោង ២:៣០នាទីរសៀល ដើម្បីពិនិត្យពិភាក្សារបៀបវារៈក្នុងវិបស្សនាប្រចាំឆ្នាំ **យ.ស.ក.**។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាបោយការណ៍ ពិនិត្យ និងសម្រេច ឬមានការណែនាំបន្ថែមដោយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ខែ គ.ស. ២០២៥

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់**

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ើល ចំរើន**

បានពិនិត្យនិងសូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ខែ គ.ស. ២០២៥

**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី 4 ខែ 3 គ.ស. ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធទី៦

# ឧបសម្ព័ន្ធទី៩. របាយការណ៍ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួល កិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.)

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
**គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**
**អគ្គលេខាធិការដ្ឋាន**
លេខ: ២២៩/២៤ អគកស.ររក

**សូមគោរពជូន**
**ឯកឧត្តម ហ៊ុន ម៉ាណែត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស.)**

**តាមរយៈ** ៖ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានប្រចាំការនៃ គ.ក.ស.។
**កម្មវត្ថុ** ៖របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល(យ.ស.ក.)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នាថ្ងៃពុធទី៣០ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ៩:០០ នាទីព្រឹក អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងនាមជាប្រធានប្តូរវេន បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.)ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ ដែលដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំដោយ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃការដ្ឋានកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដែលរួមមាន៖

១. **ឯកឧត្តម ចាន់ សុធា** រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
២. **ឯកឧត្តម កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (អ.គ.ប.យ)
៣. **ឯកឧត្តម កេង សុម៉ាឡា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (អ.គ.ប.ច.) និង
៤. **លោក លី ឌុំង** មន្ត្រីជំនាញជាន់ខ្ពស់ តំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.)

ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងអង្គភាពចំណុះក្រសួងមុខងារសាធារណៈ និង ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ក.ស. និងមន្ត្រីជំនាញនៃការដ្ឋានកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល **សរុបប្រមាណ ៥០ រូប** ។

ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ***យន្តការសម្របសម្រួលការកែទម្រង់ការបុកទាំងនៃរាជរដ្ឋាភិបាល*** ត្រូវបានកែសម្រួលមកជា ***យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល*** តាមរយៈអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ដោយមានការចូលរួមពីអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាលចំនួន៥។ កិច្ចប្រជុំប្តូរវេនដែលដឹកនាំសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈនាពេលនេះ អាចចាត់ទុកថាជាកិច្ចប្រជុំដំបូងរបស់យន្តការកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាល ក្រោយការដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យខាងលើ។

កិច្ចប្រជុំបានដំណើរការលើរបៀបវារៈ និងសម្រេចបានលទ្ធផលដែលខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងផ្តល់ការណែនាំដូចតទៅ៖

ទំព័រ ១/៣

**<u>របៀបវារៈទី១៖</u> ការពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ប្រចាំឆមាសទី១ ឆ្នាំ២០២៤**

- ឯកភាពក្នុងការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពផែនការសកម្មភាពសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល សម្រាប់ឆមាសទី១ ឆ្នាំ២០២៤ ឡើងវិញ ក្រោយការពិភាក្សានិងស្នើសុំបំពេញបន្ថែម និងការដ្ឋានកែទម្រង់ទាំងអស់មានរយៈពេល១សប្តាហ៍បន្ទាប់ពីបញ្ចប់កិច្ចប្រជុំនេះ ដើម្បីពិនិត្យកែសម្រួល និងផ្ញើមកក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ក.ស.
- ឯកភាពលើសំណើរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងការបញ្ចូលបន្ថែមនូវសកម្មភាព "ការពង្រឹង និងលើកកម្ពស់ការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន" ទៅក្នុងផែនការសកម្មភាពឆ្នាំ២០២៥ នៃចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល និងស្នើសុំដកសកម្មភាពដែលបានសម្រេចរួចហើយនៅក្នុងឆ្នាំ២០២៤ ចេញពីផែនការសកម្មភាពប្រចាំឆ្នាំ២០២៥។

**<u>របៀបវារៈទី២៖</u> ពិនិត្យលើឯកសារទស្សនទានស្តីពីទស្សនកិច្ចសិក្សាអំពីការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- អង្គប្រជុំបានឯកភាពលើឯកសារទស្សនទានស្តីពីទស្សនកិច្ចសិក្សាអំពីការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលផ្តួចផ្តើមដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ ទស្សនកិច្ចសិក្សារួមគ្នានេះគ្រោងចុះទៅខេត្តកំពង់ធំ ដើម្បីសិក្សាអំពីបញ្ហាប្រឈមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ។ អង្គប្រជុំ បានឯកភាពពេលវេលា នៅក្នុងអំឡុងចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ២០២៤ ដោយជូនលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលបន្ទុកការរៀបចំរួមសម្រាប់ដំណើរទស្សនកិច្ច និងស្នើសុំការគាំទ្រថវិកាក្នុងការអនុវត្តពីអគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**<u>របៀបវារៈទី៣៖</u> ពិនិត្យនិងពិភាក្សាបន្ថែមអំពីការងារបំពេញគ្នា គាំទ្រគ្នា និងជំរុញគ្នា ក្នុងក្របខណ្ឌការកែទម្រង់និងការពង្រឹងអភិបាលកិច្ចរវាងអគ្គលេខាធិការដ្ឋានកែទម្រង់ទាំង៥ ដែលនឹងពិនិត្យលទ្ធភាពក្នុងការជួយគាំទ្រគ្នាទៅវិញទៅមក**

- លេខាធិការដ្ឋាន/អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ទាំងប្រាំ ត្រូវរៀបចំមន្ត្រីបង្គោល ចំនួន ២រូប នៅតាមការដ្ឋានកែទម្រង់នីមួយៗ ដើម្បីបំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងកិច្ចការនៃការអនុវត្តការងាររបស់យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
- គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នឹងរៀបចំវគ្គបណ្តុះបណ្តាលជំនាញផ្នែកច្បាប់ នៅមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌មូលដ្ឋាន ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅគាំទ្រនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នឹងសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងសិក្សាពីភាពប្រទាក់ក្រឡាគ្នានៅក្នុងការអនុវត្តនូវសកម្មភាពនេះ
- ការដ្ឋានកែទម្រង់ទាំង៥នឹងពិនិត្យលទ្ធភាពជាបន្តក្នុងការផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពជូនមន្ត្រីនៅតាមការដ្ឋានកែទម្រង់នីមួយៗ ដោយការប្រើប្រាស់យន្តការផ្ទាល់របស់ការដ្ឋានកែទម្រង់ទាំង៥ ដើម្បីជួយគាំទ្រគ្នាទៅវិញទៅមក *(ឧទាហរណ៍៖ ការដ្ឋានណាមួយត្រូវការការបណ្តុះបណ្តាលជំនាញជាមន្ត្រីហិរញ្ញវត្ថុ គឺអាចស្នើសុំផ្ទាល់ទៅការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីជួយផ្តល់ការបណ្តុះបណ្តាល, ឬ មានតម្រូវការជួយក្នុងកិច្ចការវិភាគមុខងារ ឬរៀបចំការពិពណ៌នាមុខតំណែង ឬ កិច្ចការពាក់ព័ន្ធធនធានមនុស្ស គឺអាចស្នើសុំការគាំទ្រជាបច្ចេកទេសមកការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈដោយផ្ទាល់,...)*
- ការដ្ឋានកែទម្រង់ទាំងប្រាំ នឹងពិនិត្យលទ្ធភាពក្នុងការអញ្ជើញតំណាងអង្គភាពចំណុះក្រសួង ស្ថាប័នដែលពាក់ព័ន្ធសំខាន់ៗ ដើម្បីចូលរួមកិច្ចប្រជុំក្របខណ្ឌយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ

ទំព័រ ២/៣

នៃរាជរដ្ឋាភិបាល ដើម្បីចូលរួមគាំទ្រក្នុងការអនុវត្តការងាររួមគ្នារបស់ការដ្ឋានកែទម្រង់ទាំងប្រាំ ឱ្យកាន់តែមានប្រសិទ្ធភាព។

**<u>របៀបវារៈទី៤៖</u>** បញ្ហាផ្សេងៗ

- តាមសំណើរបស់ប្រធានអង្គប្រជុំ អង្គប្រជុំបានឯកភាពលើសំណើចំនួន៣ ដូចខាងក្រោម៖

១). សំណើលើការធ្វើបច្ចុប្បន្នភាព ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ដើម្បីឱ្យស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការកែសម្រួលយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដោយជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបន្ទុកក្នុងការសម្របសម្រួលរួមរៀបចំការធ្វើបច្ចុប្បន្នភាព និងការបោះពុម្ពផ្សាយ

២). សំណើលើការរៀបចំឱ្យមានជារបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ប្រចាំឆមាស ឬប្រចាំឆ្នាំ ដែលមានការចុះហត្ថលេខាដោយ អគ្គលេខាធិការ និងប្រធានលេខាធិការដ្ឋាន នៃការដ្ឋានកែទម្រង់ទាំងប្រាំ ដើម្បីគោរពរាយការណ៍ជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ដែលជាប្រធានគណៈកម្មាធិការកែទម្រង់ទាំង៥អំពីវឌ្ឍនភាពដែលការដ្ឋានកែទម្រង់ទាំង៥ បានអនុវត្តរួមគ្នាកន្លងមកក្នុងរយៈ៦ខែ ឬ ១ឆ្នាំ។ របាយការណ៍នេះនឹងចាប់ផ្តើម ដោយរបាយការណ៍ប្រចាំឆ្នាំ២០២៤ដោយនឹងត្រូវរៀបចំក្រោមការសម្របសម្រួលពីមន្ត្រីបង្គោលរបស់ការដ្ឋានកែទម្រង់ទាំង៥ រួចដាក់ពិនិត្យពិភាក្សា ក្នុងកិច្ចប្រជុំប្រចាំត្រីមាសទី៤ នៅក្នុងខែធ្នូឆ្នាំ២០២៤ ដែលដឹកនាំសម្របសម្រួលកិច្ចប្រជុំប្តូរវេនដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។

៣). សម្រាប់ការរៀបចំកិច្ចប្រជុំប្តូរវេនបន្ទាប់ គឺទទួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងផ្តល់អនុសាសន៍ណែនាំបន្ថែមដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

**ឈុន_សុជាតិ**

បានពិនិត្យ និងសូមគោរពជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**
មេត្តាជ្រាបជារបាយការណ៍និងស្នើសុំអនុសាសន៍ណែនាំបន្ថែមដ៏ខ្ពង់ខ្ពស់។
ថ្ងៃ ព្រហ ៧កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ២០២៤

**រដ្ឋលេខាធិការប្រចាំការ និងជា**
**អនុប្រធានប្រចាំការនៃ គ.ក.ស.**

**យក់ ប៊ុនណា**

07.11.2024

**ហ៊ុន_ម៉ានី**

ទំព័រ ៣/៣

**ឧបសម្ព័ន្ធ**

# ឧបសម្ព័ន្ធទី១០

# ឧបសម្ព័ន្ធទី១០. របាយការណ៍ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីលទ្ធផលស្ដីពី "វិបស្សនាយន្តការកិច្ចការកែទម្រង់ ៣ បូក ២ នៃរាជរដ្ឋាភិបាល"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:..................................................

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ** ៖ ការស្នើសុំពិនិត្យនិងសម្រេចលើរបាយការណ៍លទ្ធផលនៃវិបស្សនាយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ២ នៃរាជរដ្ឋាភិបាល។

**យោង** ៖ ស្មារតីកិច្ចប្រជុំកម្មវិធីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ២ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថានាថ្ងៃចន្ទ ៦រោច និងថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ និងទី៣០ ខែមេសា ឆ្នាំ២០២៤ វិបស្សនានៃយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ២ នៃរាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការ សម្របសម្រួល និងសហដឹកនាំដោយខ្ញុំផ្ទាល់ តាងនាមដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំង **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**អ.គ.ក.ស.**), **ឯកឧត្តម លឹម សុវណ្ណារ៉ា** តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**អ.គ.ក.ច.**), **ឯកឧត្តម ជ័យ សម្បត្តិផល្លា** តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**ល.គ.ជ.អ.ប.**), **លោកជំទាវ សុន សុខាលីដា** តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (**អ.គ.ប.យ.**) ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអគ្គនាយកដ្ឋានក្រោមឱវាទ **កសហវ.** ព្រមទាំងមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**)។

វិបស្សនានេះ ត្រូវបានរៀបចំក្នុងគោលបំណងពិនិត្យនិងពិភាក្សាលើរបៀបវារៈដូចតទៅ៖

១. ការត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពនៃចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

១

ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

២. សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៤ របស់យន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង៥ នៃរាជរដ្ឋាភិបាល

៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង៥ នៃរាជរដ្ឋាភិបាល

៤. ផ្សេងៗ។

វិបស្សនា បានរៀបចំប្រព្រឹត្តទៅ ស្របតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យនិងសម្រេចដូចតទៅ÷

**ក. កិច្ចដំណើរការនិងកិច្ចពិភាក្សា**

**១. ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤**

សម្រាប់ព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ជាការបើកអង្គវិបស្សនា និងមានការធ្វើបទបង្ហាញដោយមន្ត្រីជំនាញនៃ **អ.គ.ហ.** លើប្រធានបទចំនួន ១ គឺ "**ការត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពនៃចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឬក ២**"។ អង្គវិបស្សនាបានពិភាក្សានិងលើកជាមតិ ដូចខាងក្រោម÷

- តាងនាម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ខ្ញុំបានចាប់ផ្តើមមតិបើកកម្មវិធីដោយសង្កត់ធ្ងន់ពីអត្ថន័យនិងសារៈសំខាន់នៃទិសស្លោកនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ អំពី "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដែលជាអភិក្រមអភិបាលកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាល ដែលមាននូវកម្មវិធីកែទម្រង់ស្នូល ៥ ដែលត្របដណ្តប់គ្រប់ក្រសួង ស្ថាប័ន ឬអាចចាត់ជាសសរស្តម្ភទាំង ៥ ដឹកនាំដោយគណៈកម្មាធិការកែទម្រង់ផ្សេងៗ រួមមាន÷ ១). រដ្ឋបាលសាធារណៈ ២). មុខងារ ៣). ច្បាប់ ៤). យុត្តិធម៌ និង ៥). ហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ ខ្ញុំបានលើកឡើងនូវវឌ្ឍនភាពការងារនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំង ៤ ដំណាក់កាល និងផ្តោតសំខាន់លើដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់គឺគណនេយ្យភាពសមិទ្ធកម្ម ដែលពោងតាមឱ្យមានការចូលរួមយ៉ាងសកម្ម និងជវភាពពីគ្រប់តួអង្គភាគីទាំងតួអង្គនិម្មាបនករ និងតួអង្គប្រតិបត្តិករ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃ **អ.គ.ក.ស.** បានលើកឡើងនូវ២ចំណុច÷ ១). អភិក្រមទាំង ៤ ក្នុងចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការទម្រង់ ៣ ឬក ១ គឺ អភិក្រមទី១ របកគំហើញទាំងមូល ដែលផ្តោតលើការពឹងអាស្រ័យលើការប្រទាក់ក្រឡាគ្នាទៅវិញទៅមក, អភិក្រមទី២ ការរួមចំណែកតាមតួនាទី ដែលបំពេញឱ្យគ្នាទៅវិញទៅមកតាមតួនាទីនិងសមត្ថកិច្ចរបស់ស្ថាប័នកែទម្រង់នីមួយៗ, អភិក្រមទី៣ ការរក្សាភាពជាម្ចាស់និងការគាំទ្រកិច្ចសហការ ដែលគោរពភាពជាម្ចាស់របស់ការដ្ឋានកែទម្រង់នីមួយៗ និងអភិក្រមទី៤ បុរេសកម្ម ដែលប្រមើលមើលនិងត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នា តាមរយៈយន្តការសម្របសម្រួលការកែទម្រង់ទាំង៥នេះ និង ២). វិធានការគន្លឹះទាំង៣ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ សុទ្ធតែមានភាពប្រទាក់ក្រឡាជាមួយការដ្ឋានកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាល ដែលមានផលជះដោយផ្ទាល់លើក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- **ឯកឧត្តម ជ័យ សម្បត្តិផល្លា** តំណាង **ល.គ.ជ.អ.ប.** បានលើកឡើងនូវមតិពាក់ព័ន្ធនឹងវឌ្ឍនភាពនៃកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលឈានដល់ដំណាក់កាលទី២ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកម្មវិធីកែទម្រង់ស្នូល៤ផ្សេងទៀត និងការផ្ទេរមុខងារពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យ

២

រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធ មុខងារ សិទ្ធិអំណាច ធនធាន និងការទទួលខុសត្រូវរបស់ខ្លួន។

- **លោកជំទាវ សុខ សុខាលីដា** តំណាង **អ.គ.ប.ឃ.** បានលើកឡើងពីភាពចាំបាច់និងបន្ទាន់នៃការរៀបចំរចនាសម្ព័ន្ធអង្គភាពចំណុះឱ្យអគ្គលេខាធិការដ្ឋានដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលទើបតែបង្កើតឡើងកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤។
- **ឯកឧត្តម លីម សុខណ្ណា** តំណាង **អ.គ.ក.ច.** បានសាទរចំពោះការបញ្ចូលការដ្ឋានកែទម្រង់ច្បាប់នៅក្នុងយន្តការសម្របសម្រួលអន្តរកែទម្រង់នេះ ទោះបីជារចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានមិនទាន់ត្រូវបានរៀបចំនៅឡើយ។ ទន្ទឹមនេះ តំណាង **អ.គ.ក.ច.** ប្តេជ្ញាជំរុញឱ្យមានការរៀបចំឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រការកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។
- **ឯកឧត្តម គីម កែវមុនីរ័ត្ន** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកាបានចូលរួមជាមតិយោបល់លើ២ចំណុច÷ ទី១. ការផ្ទេរថវិកាទៅដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយតួសរំលេចថាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែងតែជំរុញឱ្យក្រសួង ស្ថាប័នបង្កើនចំនួនអង្គភាពថវិកា ដែលជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទី២. ការផ្ទេរមុខងារទាំង៥៥ នៃ២០វិស័យ គួរពិនិត្យលទ្ធភាពសិក្សាឡើងវិញពីមុខងារដែលគួរផ្ទេរ និងមុខងារដែលមិនគួរផ្ទេរ។ ចំពោះមុខងារដែលបានផ្ទេរ គួរបែងចែកជា៣ប្រភេទ គឺមុខងារដែលត្រូវការថវិកា មុខងារដែលមិនត្រូវការថវិកា និងមុខងារដែលអាចប្រើប្រាស់ពីចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **លោក ផន ចាន់រិទ្ធ** តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ស្នើឱ្យមានកិច្ចប្រជុំកម្រិតបច្ចេកទេសរវាងអគ្គនាយកដ្ឋានដែលពាក់ព័ន្ធជាមួយនឹង **អ.គ.ហ.** ដើម្បីកំណត់អំពីអភិក្រមនិងដំណោះស្រាយសម្រាប់ករណីការផ្ទេរមុខងារទាំង ៥៥ នៃ ២០វិស័យនេះ។

បន្ទាប់ពីមតិយោបល់និងបទបង្ហាញរបស់ក្រុមការងារ ខ្ញុំបានធ្វើការប្តូកសរុបទាក់ទងនឹងការផ្ទេរមុខងារទាំង៥៥ នៃ២០វិស័យ គឺតម្រូវឱ្យធ្វើការពិនិត្យពិចារណាលើ ៣ វិមាត្រ រួមមាន÷ ទី១. **កាលានុវត្តភាព** សំដៅដល់ការផ្ទេរមុខងារគួរពិនិត្យលើកាលានុវត្តភាពថាគួរផ្ទេរឬមិនផ្ទេរ, ទី២. **អាទិភាព** សំដៅដល់ការធ្វើអាទិភាវូបនីយកម្មមុននឹងផ្ទេរមុខងារ និងទី៣. **លទ្ធភាព** សំដៅដល់ការផ្ទេរមុខងារគួរផ្តោតសំខាន់និងផ្សារភ្ជាប់ទៅនឹងធនធាន ទាំងមនុស្សទាំងថវិកា។ ចំពោះផែនការសកម្មភាព ខ្ញុំបានស្នើឱ្យមានការពិចារណាបន្ថែមលើការងារអាទិភាពមួយចំនួន សំដៅសម្រួចនិងផ្តល់លទ្ធភាពគាំទ្រដល់កម្មវិធីកែទម្រង់ច្បាប់ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ឱ្យមានចលនការកែទម្រង់ទន្ទឹមនឹងកម្មវិធីកែទម្រង់ពាផ្សេងទៀត។

ចំពោះរបៀបវារៈនារសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ គឺជាការពិភាក្សាតាមក្រុមចំនួន៣ ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង៥ នៃរាជរដ្ឋាភិបាល (**ឃ.ស.ក.**) និងពិភាក្សាលើសកម្មភាពតាមយុទ្ធសាស្ត្រទាំង៣របស់ **ឃ.ស.ក.** ដោយបែងចែកជា៣ក្រុម ដូចខាងក្រោម÷

- ក្រុមទី១÷ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី១ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ទាំង៥" សម្របសម្រួលដោយ **ល.គ.ជ.អ.ប.**
- ក្រុមទី២÷ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី២ សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម" សម្រប-សម្រួលដោយ **អ.គ.ក.ស.**

៣

ឧបសម្ព័ន្ធ១០

- ក្រុមទី៣៖ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី៣ សុខដុមនីយកម្មការងារគាំទ្រកម្មវិធីកែទម្រង់ទាំង៥" សម្របសម្រួលដោយ **អ.គ.ប.យ.** និង **អ.គ.ក.ច.**។

**២. ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤**

សម្រាប់របៀបវារៈនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ គឺជាការធ្វើបទបង្ហាញស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដោយតំណាង **ល.គ.ជ.អ.ប.** និងបទបង្ហាញរបស់ក្រុមទាំង៣ ដោយមានការពិភាក្សាលម្អិតទៅលើប្រធានបទទាំង៣ និងការបូកសរុបលទ្ធផលនិងលើកទិសដៅសម្រាប់ជំហានបន្ត។ សម្រាប់លទ្ធផលនៃថ្ងៃទី២ រួមមានបទបង្ហាញអំពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដោយបានគូសរំលេចអំពីទស្សនាទានបែបទំនើបនិងតម្រូវឱ្យមានការសិក្សានិងការសាកល្បងអនុវត្តជាក់លាក់ និងបទបង្ហាញតាមក្រុមទាំង៣ដែលតម្រូវឱ្យមានការសម្រួចបន្ថែមទៀតសម្រាប់ជាការកំណត់នូវផែនការសកម្មភាពដែលអាចសម្រេចបាន។

**ខ. លទ្ធផលនៃអង្គចិន្តនា និងសំណើសុំការសម្រេច**

បន្ទាប់ពីបានពិនិត្យពិភាក្សាលម្អិតរយៈពេល ២ថ្ងៃរួចមក អង្គវិបស្សនា បានសំយោគ បូកសរុប និងឯកភាពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ ដូចតទៅ៖

**១. ឈ្មោះយន្តការ៖ "យន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង ៥ នៃរាជរដ្ឋាភិបាល"**

- ដើម្បីឱ្យល្បឿននៃការកែទម្រង់ស្នូលទាំង៥ របស់រាជរដ្ឋាភិបាលអាចដើរទៅទន្ទឹមគ្នាបាន ការដ្ឋានកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការដ្ឋានកែទម្រង់ច្បាប់ ត្រូវចូលរួមយ៉ាងពេញលេញក្នុងយន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង៥របស់រាជរដ្ឋាភិបាល។ ដូចនេះកម្រិតអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់ទាំង៥ បានឯកភាពនិងស្នើសុំកែសម្រួលឈ្មោះយន្តការជា "**យន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង ៥ នៃរាជរដ្ឋាភិបាល**"។ អនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក១ នឹងត្រូវធ្វើបច្ចុប្បន្នភាពបន្ថែម ក្នុងកិច្ចប្រជុំ **យ.ស.គ.** នាពេលខាងមុខ។

**២. ការចុះពិនិត្យសាកល្បងលើការផ្ទេរមុខងារ នៅខេត្តកំពង់ធំ**

- ស្នើរៀបចំទស្សនកិច្ចចុះពិនិត្យសាកល្បងលើមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក និងការពិនិត្យលើនិរន្តរភាពកែទម្រង់ស្នូលទាំង ៥ នៅខេត្តកំពង់ធំ ដោយមានជាការរៀបចំទស្សនាទានឬគម្រោងដោយ **ល.គ.ជ.អ.ប.**។

**៣. ក្របខ័ណ្ឌផែនការសកម្មភាព និងបច្ចុប្បន្នកម្មអនុក្រឹត្យ**

- ស្នើរៀបចំកិច្ចប្រជុំអន្តរកែទម្រង់ទាំង ៥ ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ដើម្បីពិនិត្យនិងសម្រេចកំណត់ចេញជាផែនការសកម្មភាពរួមចុងក្រោយ និងការធ្វើបច្ចុប្បន្នកម្មអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង ៥ នៃរាជរដ្ឋាភិបាល
- ស្នើកំណត់កាលបរិច្ឆេទសម្រាប់អង្គភាពពាក់ព័ន្ធក្នុងការផ្តល់នូវសេចក្តីព្រាងផែនការសកម្មភាពកែសម្រួលមក **អ.គ.ហ.** ត្រឹមថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។

៥

**៨. គោលការណ៍ជំរុញអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ**

- ស្នើសុំគោលការណ៍សម្រាប់រៀបចំកិច្ចប្រជុំដោយឡែកជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានជំនាញរបស់សាមីក្រសួង និងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ **កសហវ.** ដើម្បីពិភាក្សាលើជំរុញអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងន័យគាំទ្រដល់យន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូលទាំង ៥ នៃរាជរដ្ឋាភិបាល។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ពិនិត្យនិងសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ែល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២៤
**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី 16 ខែ 5 ឆ្នាំ២០២៤
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៥

ឧបសម្ព័ន្ធទី១០

# ឧបសម្ព័ន្ធទី១១

# ឧបសម្ព័ន្ធទី១១. របាយការណ៍ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ស្ដីពីលទ្ធផលនៃកិច្ចប្រជុំស្ដីពី "ការអនុវត្តការងារកែទម្រង់ ៣ បូក ២ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:........................................

2407 743
09 04 24 12:08

ថ្ងៃ អង្គារ ៩រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មេសា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ** ÷ ការស្នើសុំការពិនិត្យនិងសម្រេចលើរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំស្ដីពី "ការអនុវត្តការងារកែទម្រង់ ៣ បូក ២ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ"។

**យោង** ÷ - ស្មារតីកិច្ចប្រជុំប្រចាំឆ្នាំ២០២៣ នៃយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល "ឃ.ស.ក."
- លិខិតលេខ ២៥១៤ សហវ.លស.អគហ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថាកាលពីថ្ងៃព្រហស្បតិ៍ ១៣កើត និងថ្ងៃសុក្រ ១៤ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១ និងទី២២ ខែមីនា ឆ្នាំ២០២៤ នៅខេត្តប៉ៃលិន និងខេត្តបាត់ដំបង កិច្ចប្រជុំស្ដីពី "ការអនុវត្តការងារកែទម្រង់ ៣ បូក ២ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ" ត្រូវបានរៀបចំឡើងដោយកិច្ចសហការ សម្របសម្រួល និងសហដឹកនាំដោយខ្ញុំផ្ទាល់ តាងនាមដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **ឯកឧត្តម ខាន់ ចន្ថា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាតំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌, **ឯកឧត្តម ថ្លាក់ ថ្លានីដា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, **ឯកឧត្តម ជ័យ សម្បត្តិវណ្ណា** តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, **ឯកឧត្តម លឹម សុវណ្ណា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់និងជាតំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់, **លោក គោស៊ុំ ម៉ុនសឿន** អភិបាលរងខេត្តប៉ៃលិន និង **លោក អ៊ុយ សុដាច** អភិបាលរងខេត្តបាត់ដំបង។ កិច្ចប្រជុំនេះក៏មានការចូលរួមផងដែរពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ទាំង ៥ អង្គភាពពាក់ព័ន្ធក្រោមឱវាទ **កសហវ.**, អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ, រដ្ឋបាលក្រុង ស្រុក និងមន្ទីរជំនាញចំណុះរដ្ឋបាលខេត្តទាំងពីរ។

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទំព័រទី ១
ទូរស័ព្ទ:(+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ឧបសម្ព័ន្ធទី១១

កិច្ចប្រជុំនេះ ត្រូវបានរៀបចំដោយមានកិច្ចពិភាក្សាពេញអង្គនិងកិច្ចពិភាក្សាលម្អិតតាមរបៀបវារៈ ដោយទទួលបានលទ្ធផល ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យនិងសម្រេចដូចតទៅ៖

**ក. សាវតារនិងគោលបំណង**

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយផ្អែកតាមស្មារតីនិងការឯកភាពកិច្ចប្រជុំប្រចាំឆ្នាំ២០២៣ នៃយន្តការសម្របសម្រួលការកែទម្រង់ ៣ បួក ១ នៃរាជរដ្ឋាភិបាល "**យ.ស.ក.**" កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ លើការសម្រេចចុះបេសកកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណត់យកខេត្តបាត់ដំបងនិងខេត្តប៉ៃលិនជាខេត្តគោលដៅ ដើម្បីស្វែងយល់ពីវឌ្ឍនភាពនិងបញ្ហាប្រឈមជាក់ស្តែង និងផ្តោតលើប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចឆ្លុះបញ្ចាំងលើទិដ្ឋភាពកែទម្រង់ទាំង៤ រួមមាន មុខងារ ហិរញ្ញវត្ថុ មនុស្ស និងច្បាប់ ព្រមទាំងកត្តាសមត្ថភាពជាក់ស្តែង។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយមានវត្តមានតំណាងរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដែលជាតួអង្គថ្មីក្នុង **យ.ស.ក.** ដើម្បីពិនិត្យនិងពិភាក្សាលើ៖

- វឌ្ឍនភាពនិងបញ្ហាប្រឈមជុំវិញការប្រគល់និងអនុវត្តសុខាភិបាលនៅរដ្ឋបាលរាជធានី-ខេត្ត
- ការអនុវត្តមុខងារទាំង៥៥ និង២០ វិស័យ នៅរដ្ឋបាលក្រុង ស្រុក
- រចនាសម្ព័ន្ធថវិកានិងប្រព័ន្ធគណនេយ្យភាពនៃការអនុវត្តមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ. កិច្ចដំណើរការ**

កិច្ចប្រជុំទាំងពីរថ្ងៃ បានផ្សព្វផ្សាយនូវទស្សនាទាន សាវតារ ទស្សនវិស័យ ក្របខណ្ឌចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃយន្តការសម្របសម្រួលការកែទម្រង់ ៣ បួក ១ នៃរាជរដ្ឋាភិបាល "**យ.ស.ក.**"។ បន្ថែមពីនេះ កិច្ចប្រជុំបានលើកអំពីការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលមូលដ្ឋាន ដែលជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីនៅមូលដ្ឋាន ដើម្បីអាចអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងជវភាពតួអង្គតែមួយ ទាំងកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជវភាព ត្រូវបានាយល់តួអង្គនៃកំណែទម្រង់ទាំងមូលរបស់រាជរដ្ឋាភិបាលដែលត្រូវកំណត់នូវ ១)-ការងារស្នូលរបស់កម្មវិធីកែទម្រង់នីមួយៗ ២)- ការងារសហការរបស់កម្មវិធីកែទម្រង់ទាំងអស់ ដែលមានអន្តរសកម្មភាពពាក់ព័ន្ធកំណែទម្រង់ផ្សេងទៀត និង ៣)- ការងារសម្របសម្រួលរបស់កម្មវិធីកែទម្រង់។ កិច្ចប្រជុំ បានប្រព្រឹត្តទៅដូចតទៅ៖

**១. ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ៖**

កិច្ចប្រជុំ ត្រូវបានរៀបចំឡើងនៅខេត្តប៉ៃលិន ដោយមានការសហដឹកនាំដោយថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកម្មវិធីកែទម្រង់ទាំង ៥ និង **លោក គោស៊ុំ ប៊ុនសឿត** អភិបាលរងខេត្តប៉ៃលិន ដែលបានពិភាក្សាលម្អិតទៅតាមរបៀបវារៈដែលខ្ញុំសូមគោរពជូនរំលេចតាមចំណុចកត់សម្គាល់ ដូចតទៅ៖

- *ការអនុវត្តមុខងារទាំង ៥៥ នៃ ២០ វិស័យ ដែលបានផ្ទេរទៅអនុវត្តនៃរដ្ឋបាលក្រុង ស្រុក*
  - *មតិតំណាងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ៖* អនុក្រឹត្យ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង បានសម្រេចផ្ទេរមុខងារទាំង៥៥ នៃ ២០ វិស័យ ដើម្បីអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ប៉ុន្តែកន្លងទៅនេះ ធនធានមនុស្សនិងហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារទាំងនេះ នៅពុំទាន់ផ្ទេរពេញលេញឱ្យរដ្ឋបាលក្រុង ស្រុកនោះទេ។

ទំព័រទី ២

- *មតិតំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ÷* ក្នុងចំណោមមុខងារទាំង ៥៥, មុខងារខ្លះមិនធ្លាប់ត្រូវបានអនុវត្តពីមុនមកទេ ហើយក៏មិនមានការវិភាជថវិកាសម្រាប់គាំទ្រការអនុវត្តដែរ។ មុខងារខ្លះទៀតត្រូវបានអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត ហើយមានការវិភាជថវិកាក្នុងកញ្ចប់របស់ក្រសួង ស្ថាប័នអាណាព្យាបាលនៅថ្នាក់ជាតិ។ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងសហការជាមួយអគ្គនាយកដ្ឋានថវិកា សិក្សាបន្ថែមលើការផ្ទេរធនធានហិរញ្ញវត្ថុពីក្រសួង ស្ថាប័នថ្នាក់ជាតិ ដោយត្រូវគិតគូរពីលំដាប់អាទិភាពផងដែរ។
- *មតិតំណាងលេខាធិការដ្ឋាន គ.ជ.អ.ប.÷* ពេលរៀបចំអនុក្រឹត្យ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, ក្រសួង ស្ថាប័នសុទ្ធសឹងយល់ស្របថាមុខងារទាំង ៥៥ គឺជាមុខងារនៃសេវាសាធារណៈសំខាន់ៗ ដែលគាំទ្រដល់ការអភិវឌ្ឍមូលដ្ឋាននិងបម្រើដល់ផលប្រយោជន៍ប្រជាពលរដ្ឋ។ ហេតុនេះ ធនធានគួរតែវិភាជ ស្របតាមស្មារតីនៃការរៀបចំអនុក្រឹត្យនេះ។
- *មតិរបស់ អ.គ.ហ.÷* អង្គភាពសាធារណៈសុទ្ធសឹងបំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមផ្តល់សេវាសាធារណៈនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ ប៉ុន្តែមិនមែនគ្រប់មុខងារទាំងអស់ត្រូវតែទទួលបានការវិភាជធនធានដូចគ្នានោះទេ ព្រោះលំដាប់អាទិភាពគោលនយោបាយរាជរដ្ឋាភិបាលមានភាពបត់បែន ស្របតាមបរិការណ៍ជាក់ស្តែង ហើយមុខងារមួយចំនួនគឺមិនអាចអនុវត្តបាន ជាឧទាហរណ៍ពាក់ព័ន្ធការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ គឺមិនបានអនុវត្តដោយសារក្នុងក្រុងប៉ៃលិនមិនមានអាងប្រព្រឹត្តកម្មទឹកកខ្វក់។ ទន្ទឹមនោះ ការវិភាជធនធានហិរញ្ញវត្ថុ ដែលកំពុងត្រូវបានពង្រឹងក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងធានានូវគណនេយ្យភាពចំពោះសមិទ្ធកម្ម។

➢ *ស្ថានភាពនៃការអនុវត្តមុខងារសុខាភិបាលនៅក្រុងប៉ៃលិន* បានស្តែងដូចចំណុចដូចតទៅ÷

- កង្វះមន្ត្រីក្នុងការប្រចាំការនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ជាអាទិ៍ពុំមានមន្ត្រីជំនួសនិវត្តន៍ជន
- កង្វះបរិក្ខារនិងសម្ភារសម្រាប់បំពេញការងារ
- អនុវត្តកញ្ចប់ថវិកាឆ្នាំ២០២៣ បានត្រឹម ៨៧% ប៉ុណ្ណោះ ដោយសារបន្ទុកបុគ្គលិក និងខ្វះអ្នកចេះធ្វើផែនការថវិកា រៀបចំនីតិវិធីនិងសំណុំឯកសារអនុវត្តចំណាយថវិកា
- ពុំមានយន្តការក្នុងការពិគ្រោះនិងដោះស្រាយបញ្ហា។

➢ *ស្ថានភាពនៃការអនុវត្តមុខងារដែលបានផ្ទេរទៅអនុវត្តរដ្ឋបាលក្រុងប៉ៃលិន*

- មុនពេលមានការផ្ទេរមុខងារ ៥៥ នៃ ២០វិស័យ ក្រុងប៉ៃលិនមានការិយាល័យផ្តល់សេវាសរុបចំនួន ៥ និងបន្ទាប់ពីការផ្ទេរមុខងារទាំងនេះ ចំនួនការិយាល័យកើនដល់ចំនួន ១៣។
- ការិយាល័យមួយចំនួនប្រឈមនឹងបញ្ហាសមត្ថភាពជាខ្លាំង ជាអាទិ៍ ១)-ការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន នៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិនិត្យនិត្យានុកូលភាពលើដីកានិងសេចក្តីសម្រេចនានា ខ្វះជំនាញផ្នែកផ្លូវច្បាប់ក្នុងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងផ្តល់ការប្រឹក្សាយោបល់ជូនប្រជាពលរដ្ឋ និង ២)-ការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ គឺមិនមានមន្ត្រីបច្ចេកទេសក្នុងការអនុវត្តមុខងារដូចជាការងារសុខភាពសត្វនិងផលិតផលសត្វ, ការអភិវឌ្ឍផ្លូវជនបទ, ការគ្រប់គ្រងផ្សារសហគមន៍, ការត្រួតពិនិត្យ

ទំព័រទី ៣

ឧបសម្ព័ន្ធ ១១

និងរាយការណ៍អំពីបទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ សម្ភារបរិក្ខារទូរគមនាគមន៍និងការធ្វើអាជីវកម្មដោយខុសច្បាប់។

## ២. ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

កិច្ចប្រជុំ ត្រូវបានរៀបចំឡើងនៅនៅខេត្តបាត់ដំបង ដោយមានការសហដឹកនាំដោយថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកម្មវិធីកែទម្រង់ទាំង ៥ និង **លោក អ៊ុយ សុខាទី** អភិបាលរងខេត្តបាត់ដំបង ដែលបានពិភាក្សាលម្អិតទៅតាមរបៀបវារៈដែលខ្ញុំសូមគោរពជូនរំលេច ដូចតទៅ÷

- **ឯកឧត្តម ខាន់ ចណ្ណា**: តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានលើកឡើងពីគោលបំណងនៃកិច្ចប្រជុំ និងបញ្ហាប្រឈម បទពិសោធន៍នៃការអនុវត្តមុខងារដែលបានផ្ទេរមករដ្ឋបាលក្រុងស្រុក។ ឯកឧត្តមក៏បានលើកឡើងអំពីកិច្ចការងារសំខាន់ៗនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ លើការជំរុញនិងពន្លឿនសំណុំរឿងក្តីគ្រប់ជាន់ថ្នាក់ និងដោះស្រាយភាពមិនប្រក្រតីនៅតុលាការគ្រប់ជាន់ថ្នាក់ ដែលបានចាប់ផ្តើមកាលពីឆ្នាំ២០១៩ ដោយផ្តោតលើសំណុំរឿងព្រហ្មទណ្ឌ និងនៅឆ្នាំ២០២៤នេះ នឹងពង្រាតទៅដល់សំណុំរឿងរដ្ឋប្បវេណី។ ឯកឧត្តមក៏បានបញ្ជាក់អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជាការបំពេញបន្ថែមលើយន្តការដែលមានស្រាប់។
- **ឯកឧត្តម ថ្លាក់ ថ្លានីដ្ឋា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានលើកឡើងពីការអនុវត្តការងាររបស់រដ្ឋបាលសាធារណៈ ដែលរាជរដ្ឋាភិបាលផ្តោតចេញលើវិធានការចំនួន ៣ គឺ ១)-ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីថ្មី ២)-ការលើកកម្ពស់ប្រសិទ្ធភាពការងារ ៣)-ការពិនិត្យឡើងវិញអំពីនីយាមនីតិវិធីប្រតិបត្តិ(SOP) ព្រមទាំងការរៀបចំប្រព័ន្ធលើកទឹកចិត្តផ្តោតលើសមិទ្ធកម្មជាដើម។ ឯកឧត្តមក៏បានលើកឡើងអំពីភាពប្រទាក់ក្រឡាជាមួយការដ្ឋានផ្សេងទៀត ព្រមទាំងវឌ្ឍនភាព បញ្ហាប្រឈមនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែង ដែលអាចដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងបានបញ្ជាក់ពីគោលដៅនៃដោះស្រាយបញ្ហាទាំងឡាយដែលមានភាពប្រទាក់ក្រឡា គួរមានការពិភាក្សាដោះស្រាយកម្រិតអន្តរការដ្ឋាន។
- **ឯកឧត្តម ជ័យ សម្បត្តិផល្លា** តំណាង គ.ជ.អ.ប. បានលើកឡើងពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលជាកិច្ចការអភិវឌ្ឍនៅមូលដ្ឋាន ក្នុងនោះក៏មានភាពប្រទាក់ក្រឡាឆ្លាយ៉ាងជិតស្និទ្ធរវាង គ.ជ.អ.ប. ជាមួយកំណែទម្រង់ផ្សេងទៀតដោយបានរៀបចំកែលម្អប្រព័ន្ធគ្រប់គ្រង និងនីតិវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីមានសមត្ថភាព ការទទួលខុសត្រូវ និងភាពជាម្ចាស់ ដែលអាចឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ។ ទៀតសោត ការផ្ទេរមុខងារចំនួន២ ដល់រដ្ឋបាលខេត្ត និងការផ្ទេរមុខងារទាំង៦០ ដល់រដ្ឋបាលក្រុងស្រុកខណ្ឌ ដោយនៅមិនទាន់គិតពីសេវាដែលមាននៅច្រកចេញចូលតែមួយ ព្រមទាំងការផ្ទេរបុគ្គលិកជាង១០ម៉ឺននាក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **ឯកឧត្តម លីម សុវណ្ណា** តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានលើកឡើងពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដែលនឹងមានសមាសភាពគណៈកម្មាធិការ និងក្បាលម៉ាស៊ីនអគ្គលេខាធិការដ្ឋាន នៅពេលឆាប់ៗខាងមុខនេះ។
- **ឯកឧត្តម គីម វ៉ែនចន្ទនីរ័ត្ន** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា បានលើកឡើងអំពីការផ្ទេរមុខងារទាំង៥៥ដល់រដ្ឋបាលក្រោមជាតិ គឺបានផ្តល់ថវិកាជូនផងដែរ ដោយឡែកមិនមែនគ្រប់មុខងារដែលបានផ្ទេរទាំងអស់នោះ ត្រូវតែផ្តល់ថវិកានោះទេ ដោយហេតុថាមុខងារខ្លះគឺជាសកម្មភាពដែលថ្នាក់ក្រោមជាតិត្រូវតែអនុវត្តតែម្តង ទោះបីមិនមាន

ទំព័រទី ៩

ចនបានថវិកាផ្តល់ជូនគំរោយ។ ឯកឧត្តម ក៏បានស្នើដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគិតគូរផងដែរ ចំពោះមុខងារមួយចំនួនដែលបានផ្ទេរទៅនោះដោយមានភ្ជាប់នឹងការរកចំណូល។ ដូចនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចយកធនធានពីចំណូលមិនមែនសារពើពន្ធដែលបានភ្ជាប់នឹងមុខងារដែលបានផ្ទេរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មកចាត់ចែងប្រើប្រាស់ជារួម។

➢ តំណាងអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ បានលើកឡើងអំពីការកើនការិយាល័យរបស់ក្រុង ស្រុក ពី ៥ ទៅ ១១ ការិយាល័យ, ថវិកាក្រុង ស្រុក ជាប្រភេទថវិកាតុល្យភាពដែលចំណូលស្មើចំណាយ។ បន្ថែមពីនេះ អគ្គនាយកដ្ឋានបច្ចុប្បន្ន បាននិងកំពុងពិនិត្យមុខងារណាដែលជាអាទិភាពសម្រាប់ការដោះស្រាយលើការផ្ទេរមុខងារទាំង ៥៥ នៃ ២០ វិស័យនេះ។

កិច្ចប្រជុំ បានពិភាក្សាលើអំពីស្ថានភាព វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តមុខងាររបស់ការិយាល័យនៃរដ្ឋបាលក្រុងបាត់ដំបង និងមុខងារសុខាភិបាលរបស់ខេត្តបាត់ដំបង ដោយបានគូសរំលេចនូវកង្វះសមត្ថភាពរបស់មន្ត្រីមូលដ្ឋាន និងកង្វះចំនួនមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសលើវិស័យសុខាភិបាល និងការស្នើការរៀបចំគោលការណ៍ណែនាំនិងនីតិវិធីបន្ថែមសម្រាប់ណែនាំដល់មន្ត្រីអនុវត្តមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាលើប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ក្នុងន័យនេះ **អ.គ.ម.** និងតំណាងអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានលើកឡើងអំពីសារៈសំខាន់នូវការធានាការផ្ទេរមុខងារ តាមរយៈការសិក្សាជាក់លាក់ និងការកំណត់យន្តការអន្តរការមួយ ដើម្បីធានាការផ្ទេរមុខងារប្រកបដោយជោគជ័យ ខណៈតំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បញ្ជាក់អំពីការងារអាទិភាពរបស់គណៈកម្មាធិការ រួមមានការរៀបចំឱ្យមានការវិភាគមុខងារ ការរៀបចំការជ្រើសរើសមន្ត្រីតាមស្ថានភាពជាក់ស្តែង ការរៀបចំនិយាមនីតិវិធីប្រតិបត្តិ និងការពិចារណាលើការប្រើប្រាស់មន្ត្រីកិច្ចសន្យាជាដើម។

**គ. ការបូកសរុបលទ្ធផលគន្លឹះ**

កិច្ចប្រជុំនៅរដ្ឋបាលខេត្តទាំងពីរ បានគូសរំលេចនូវលទ្ធផលគន្លឹះ ដូចតទៅ÷

**ទី១.** រចនាសម្ព័ន្ធការិយាល័យក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី ៥ ការិយាល័យ ដល់ ១១ ឬ ១៣ ការិយាល័យក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌ ក្រោយពីមានការផ្ទេរមុខងារ ៥៥ នៃ ២០ វិស័យ។

**ទី២.** រចនាសម្ព័ន្ធការិយាល័យជំនាញរបស់មន្ទីរជំនាញ ត្រូវបានបំព្រួញមកត្រឹមការិយាល័យចំណុះរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រឹម ៦ ការិយាល័យ (គិតលើមុខងារជំនាញ) ក្រោយពីមានការផ្ទេរមុខងារ ៥៥ នៃ ២០ វិស័យ។

**ទី៣.** រចនាសម្ព័ន្ធការិយាល័យ នៃ២៣មន្ទីរជំនាញត្រូវបានផ្ទេរឬកាត់បន្ថយ ខណៈមុខងារទាំងនេះ ត្រូវបានសមាហរណកម្មមកការិយាល័យ ចំនួន ១១ ឬ ១៣ ក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង ២០៦ ពោលគឺការិយាល័យមួយគ្របដណ្តប់លើច្រើនវិស័យ។

**ទី៤.** ការកើនឡើងក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពីមុនស្ថិតក្រោមមន្ទីរជំនាញ ២៣ គឺជាបន្ទុកលើការកសាងសមត្ថភាពមន្ត្រីក្នុងការិយាល័យរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ទី៥.** ការផ្ទេរមុខងារទាំង ៥៥ នៃ ២០ វិស័យ គឺមានសេចក្តីត្រូវការក្នុងការសិក្សា វិភាគ និងកសាងយន្តការធានាមួយដើម្បីអាចអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

**ទី៦.** ការពង្រឹងការអនុវត្តមុខងារទាំង ៥៥ នៃ ២០ វិស័យនៅរដ្ឋបាលក្រុង ស្រុក គឺមានភាពប្រទាក់ក្រឡាទៅនឹងយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ទាំង ៣ ប្លុក ២ របស់រាជរដ្ឋាភិបាល។ ការណ៍នេះ តម្រូវឱ្យមានការពិភាក្សាល្អិតល្អន់

ទំព័រទី ៥

ឧបសម្ព័ន្ធ១១

រវាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ទាំង ៥ ហើយស្នើនូវវិធានការជាក់លាក់ សម្រាប់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច ដែលអាចស្ថែងក្នុងទិដ្ឋភាព ដូចតទៅ៖

- *កម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ៖* រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនទាន់សមត្ថភាពយល់ដឹងអំពីគោលការណ៍ នីតិវិធីសម្រាប់រៀបចំសកម្មភាពក្នុងការអនុវត្តមុខងារដែលបានផ្ទេរ ដែលមុខងារដែលបានផ្ទេរដំបូងឡើយជាមុខងារថ្នាក់ជាតិ មានថវិកាលោតទន្ទឹងទូទាំងប្រទេស និងត្រូវបានបំពេញមកអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- *កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖* ក្នុងករណីរដ្ឋបាលក្រុង ស្រុក មិនយល់ដឹងអំពីការកសាងសកម្មភាពគាំទ្រលើការអនុវត្តមុខងារ រដ្ឋបាលក្រុង ស្រុកនឹងមិនមានថវិកាអនុវត្ត ខណៈដែលរដ្ឋបាលក្រុង ស្រុក មិនទាន់បានអនុវត្តនូវថវិកាកម្មវិធី។ ម្យ៉ាងវិញទៀត មុខងារដែលបានផ្ទេរមានមុខងារដែលមិនមានតម្រូវការថវិកា និងមុខងារដែលតម្រូវការថវិកា។ បន្ថែមពីនេះ មុខងារដែលបានផ្ទេរដើមឡើយជាមុខងាររបស់មន្ទីរ ហើយត្រូវបានផ្ទេរមករដ្ឋបាលក្រុង ស្រុក ដែលទាមទារមានការកំណត់បន្ទាត់គណនេយ្យភាពឱ្យបានច្បាស់លាស់ ក្នុងការធានាការកំណត់ទំនាក់ទំនងរវាងថវិកាកម្មវិធីរដ្ឋបាលថ្នាក់ជាតិជាមួយនឹងថវិកាកម្មវិធីរដ្ឋបាលរាជធានី ខេត្ត និងថវិការបស់ក្រុង ស្រុក ខណ្ឌ និងការធានានូវគោលការណ៍ណែនាំនិងនីតិវិធីច្បាស់លាស់។
- *កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ៖* ការផ្ទេរមុខងារទាំង ៥៥ នៃ ២០ វិស័យ ជាការប្តូរចនាសម្ព័ន្ធពី ៥ ការិយាល័យ មកកាន់ ១១ ឬ ១៣ ការិយាល័យនៅរដ្ឋបាលក្រុង ស្រុក ដែលបង្ហាញថាការិយាល័យជំនាញមួយគ្របដណ្តប់លើវិស័យច្រើន និងតម្រូវឱ្យមានការទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើការធានាការអនុវត្តគោលនយោបាយជាតិ។ ទៀតសោត ការផ្ទេរមុខងារនេះ បង្ហាញអំពីកង្វះធនធានមនុស្សសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ។
- *កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌៖* ការផ្ទេរមុខងារនេះ តម្រូវឱ្យមានការពិភាក្សាបន្ថែម ជាពិសេសលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានអាជ្ញាធរជាតិមួយមានសមត្ថកិច្ច។
- *កម្មវិធីកែទម្រង់ច្បាប់៖* ការផ្ទេរមុខងារនេះ ត្រូវឱ្យមានការសិក្សាបន្ថែមលើទិដ្ឋភាពច្បាប់ ក្នុងន័យធានាលើការអនុវត្តប្រកបដោយប្រសិទ្ធភាព នីត្យានុកូលភាព សង្គតិភាពគតិយុត្ត និងសណ្តាប់ធ្នាប់គតិយុត្ត។

**ឃ. សំណើសុំការសម្រេច**

ផ្អែកលើលទ្ធផលគន្លឹះខាងលើ ខ្ញុំបាទសូមគោរពស្នើសុំការពិនិត្យនិងសម្រេចរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** លើកិច្ចការជាជំហានបន្ត ដូចតទៅ៖

**១. ការរៀបចំយន្តការសម្របសម្រួល**

- ស្នើរដ្ឋបាលរាជធានី ខេត្ត កំណត់របបប្រជុំប្រចាំឆមាសជាទៀងទាត់ ដើម្បីដោះស្រាយករណីប្រឈមនានានិងមានរបបរបាយការណ៍ប្រចាំឆមាសកម្រិតរដ្ឋបាលរាជធានី ខេត្ត។ ក្នុងករណីមានបញ្ហាប្រឈមដែលមានថវិកាអន្តរកែទម្រង់ រដ្ឋបាលរាជធានី ខេត្ត អាចប្រើប្រាស់ **ឃ.ស.ក.** ក្នុងការសិក្សា ដោះស្រាយលើករណីប្រឈមទាំងនោះ ជាអាទិ៍ការផ្ទេរមុខងារ ៥៥ នៃ ២០ វិស័យ។
- ស្នើ **អ.គ.ឃ.** ជាតួអង្គសម្របសម្រួលកណ្តាលក្នុង **ឃ.ស.ក.** លើការប្រមូលសរុបរបាយការណ៍ពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទំព័រទី ៦

**២. ការរៀបចំទស្សនកិច្ចសិក្សា**

- ស្នើសុំគោលការណ៍ចុះទស្សនកិច្ចសិក្សាផ្ទាល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ យ៉ាងហោច ២ ដង ក្នុងមួយឆ្នាំ ដើម្បីចុះសិក្សា ពិភាក្សាផ្ទាល់ កំណត់បញ្ហាជាក់លាក់ លើការងារដែលមានចរិតអន្តរកែទម្រង់។

**៣. ការរៀបចំសិក្ខាសាលាថ្នាក់ជាតិ**

- ស្នើសុំគោលការណ៍រៀបចំសិក្ខាសាលាថ្នាក់ជាតិ ដើម្បីពិគ្រោះយោបល់និងលើកសំណើដំណោះស្រាយលើការផ្ទេរមុខងារទាំង ៥៥ នៃ ២០ វិស័យ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមានកម្មវិធីកែទម្រង់ទាំង ៥ ក្រសួង ស្ថាប័ន អង្គភាពនិម្មាបនករ និងប្រតិបត្តិករ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ពិនិត្យ សម្រេច ឬផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ើល ចំរើន**

បានពិនិត្យនិងសូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឆ្នាំ២០២៤

**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី 4 ខែ 4 ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ចំពោះ ៧ **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ឧបសម្ព័ន្ធទី១១

# ឧបសម្ព័ន្ធទី១២

# ឧបសម្ព័ន្ធទី១២. របាយការណ៍ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំ២០២៣ នៃយន្តការសម្របសម្រួលការទម្រង់ ៣ ម្ហូក ១ នៃរាជរដ្ឋាភិបាល ( យ.ស.ក. )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខៈ ១៥២ សហវ/អគហ

2401 290
06.03.24 17:31
P.FM

ថ្ងៃព្រហស្បតិ៍ ១៩ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ** ÷ ការស្នើសុំការពិនិត្យលើរបាយការណ៍កិច្ចប្រជុំប្រចាំឆ្នាំ ២០២៣ នៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ នៃរាជរដ្ឋាភិបាល " យ. ស. ក. "។

**យោង** ÷ លិខិតលេខ ៩៣៣ សហវ.លស.អគហ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីព្រឹកថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤, ខ្ញុំអមដោយមន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំនៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក១ (យ.ស.ក.) នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) ដោយមាន **ឯកឧត្តម ចាន់ សុធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.), **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.រ.), **ឯកឧត្តម ឃ្លោក ដារ៉ា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិនិងអភិវឌ្ឍវិស័យយុត្តិធម៌នៃក្រសួងយុត្តិធម៌ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (គ.ក.ប.យ.), **ឯកឧត្តម អ៊ិត ស៊ីណាត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចប្រជុំនេះក៏មានការចូលរួមផងដែរពីសំណាក់ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទ កសហវ. រួមមាន **ឯកឧត្តម ស៊ាង ផល្លា** អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម កសហវ., **ឯកឧត្តមបណ្ឌិត នី សុវណ្ណ** អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, **ឯកឧត្តម គីម កែវមុនីរ័ត្ន** អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា, និងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គាធិការដ្ឋាន, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រមាណ ៣៨ រូប។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើង ដើម្បីពិនិត្យនិងពិភាក្សាលើរបៀបវារៈ÷

១. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៤

២. ការពិភាក្សាបញ្ចូលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក្នុង យ.ស.ក.

អគារលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ១ ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: (+855) 23 890 666

៣. ផ្សេងៗ។

កិច្ចប្រជុំនេះ បានប្រព្រឹត្តទៅពេញមួយព្រឹក ដែលខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នូវខ្លឹមសារគន្លឹះនៃលទ្ធផលកិច្ចពិភាក្សា ដើម្បីជ្រាបជារបាយការណ៍និងផ្ដល់គោលការណ៍ឯកភាព ឬផ្ដល់អនុសាសន៍ណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់ ដូចតទៅ÷

***១. វឌ្ឍនភាពការងារ និងបញ្ហាប្រឈមក្នុងឆ្នាំ២០២៣***

អង្គប្រជុំបានឯកភាពទាំងស្រុងទៅលើរបាយការណ៍បូកសរុបរបស់ក្រុមការងារ អ.ត.ហ. និងបានកំណត់ចំណុចបញ្ហាប្រឈមជារបៀបវារៈសម្រាប់កិច្ចពិភាក្សាក្នុងវិបស្សនា ៣ បូក ១ ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ។

***២. ផែនការសកម្មភាពប្រចាំឆ្នាំ២០២៤***

ផ្អែកតាមវឌ្ឍនភាពការងារនិងបញ្ហាប្រឈមប្រចាំឆ្នាំ២០២៣ និងសំណើផែនការសកម្មភាពរបស់អង្គភាពនានា អង្គប្រជុំ បានឯកភាពសម្រេចផ្ដល់លទ្ធភាពអង្គភាពដែលស្នើផែនការសកម្មភាពធ្វើការកែសម្រួលបន្ថែម ដើម្បីសម្រេចជាសកម្មភាពអនុវត្តសម្រេចឱ្យបានក្នុងឆ្នាំ២០២៤ ដោយភ្ជាប់អំពីភាពប្រទាក់ក្រឡានៃកម្មវិធីកែទម្រង់នីមួយៗនៃ យ.ស.ក.។ ដោយឡែកសម្រាប់សំណើផែនការសកម្មភាពរបស់អង្គភាព ក្រោមឱវាទ គសហវ. ជាពិសេសអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គប្រជុំសម្រេចផ្ដល់លទ្ធភាពសម្រាប់អង្គភាពធ្វើការកែសម្រួល និងរៀបចំជាសំណើជាក់លាក់ស្នើសុំកិច្ចសម្របសម្រួលរបស់ យ.ស.ក. ដោយរំលេចនូវសាវតារ បញ្ហាប្រឈមពាក់ព័ន្ធនឹងកិច្ចការងារទាំងនោះ។

***៣. ការពិភាក្សាបញ្ចូលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ក្នុង យ.ស.ក.***

ដោយអនុលោមតាមលទ្ធផលដែលមានសម្រេចក្នុងកិច្ចប្រជុំ យ.ស.ក. ត្រីមាសទី១ ឆ្នាំ២០២៣ យ.ស.ក. នឹងពិភាក្សាបញ្ចូលក្រុមប្រឹក្សាអ្នកច្បាប់ ប៉ុន្តែថ្មីៗនេះគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ទើបនឹងបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលជាកត្តាតម្រូវមានកិច្ចពិភាក្សាបន្ថែម។

ក្នុងករណីខាងលើ អង្គប្រជុំបានឯកភាពជាគោលការណ៍ក្នុងការបញ្ចូលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ក្នុង យ.ស.ក. និងដោយមានការឯកភាពពីតំណាងទីស្ដីការគណៈរដ្ឋមន្ត្រីលើសំណើនេះនិងគោរពរាយការណ៍ជូនថ្នាក់ដឹកនាំនៃទីស្ដីការគណៈរដ្ឋមន្ត្រីបន្ទាប់ពីកិច្ចប្រជុំ។ ចំពោះការរៀបចំបញ្ចូលនិងសំណើផែនការសកម្មភាពជាក់លាក់នឹងជាកម្មវត្ថុនៃកិច្ចពិភាក្សាក្នុងវិបស្សនានាពេលខាងមុខ។

***៤. ការកែសម្រួលអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២***

ដោយកត្តាសត្យានុម័តនៃការកែរចនាសម្ព័ន្ធនៃកម្មវិធីកែទម្រង់គន្លឹះ ជាពិសេសវិស័យច្បាប់ និងវិស័យយុត្តិធម៌ និងការឯកភាពជាគោលការណ៍របស់អង្គប្រជុំ លើការបញ្ចូលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ក្នុង យ.ស.ក. អង្គប្រជុំបានឯកភាពកែសម្រួលអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល និងតម្រូវកំណត់ជារបៀបវារៈក្នុងវិបស្សនានាពេលខាងមុខ។

***៥. ការចុះបេសកកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ***

ដើម្បីស្វែងយល់ពីវឌ្ឍនភាពនិងបញ្ហាប្រឈមជាក់ស្ដែង, អង្គប្រជុំ បានឯកភាពលើការរៀបចំទស្សនកិច្ចសិក្សារួមគ្នាទៅកាន់ការដ្ឋានកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងសប្ដាហ៍ទី៣ នៃមីនា ឆ្នាំ២០២៤ ដែលនឹងប្រព្រឹត្តទៅនៅខេត្តបាត់ដំបង និងប៉ៃលិន ផ្ដោតលើប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចឆ្លុះបញ្ចាំងលើទិដ្ឋភាពកែទម្រង់ទាំង៤ រួមមាន មុខងារ ហិរញ្ញវត្ថុ មនុស្ស និងច្បាប់ ព្រមទាំងកត្តាសមត្ថភាពជាក់ស្ដែង ដោយកំណត់ជា ២ វគ្គ ពោលគឺ ១).វេទិកាផ្សព្វផ្សាយកម្មវិធី

២

កែទម្រង់នៃ ឃ.ស.ក. និង ២). ការចុះឧស្សាហកិច្ចផ្ទាល់ទៅទីតាំងផ្ទាល់នៃរដ្ឋបាលក្រុង-ស្រុក។ អ.គ.ហ. ទីងទទួលបន្ទុកសម្របសម្រួលពីគ្រប់តួអង្គ ដើម្បីរៀបចំពាទស្សនាទាននៃទស្សនកិច្ចសិក្សានេះ។

*៦. ការរៀបចំវិបស្សនាប្រចាំឆ្នាំ២០២៣*

អង្គប្រជុំ បានឯកភាពលើការរៀបចំវិបស្សនា ៣ បូក១ នៅខេត្តសៀមរាប នៅថ្ងៃទី២៩ និងទី៣០ ខែមេសា ឆ្នាំ២០២៣ និងកំណត់របៀបវារៈនៃកិច្ចពិភាក្សាលើបញ្ហាប្រឈមនៃការអនុវត្តការងារក្នុងឆ្នាំ២០២៣ សំណើផែនការសកម្មភាពឆ្នាំ២០២៤ និងចំណុចគន្លឹះផ្សេងទៀត ដូចបានគូសរំលេចក្នុងចំណុចខាងលើ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ឬផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ែល ចំរើន**

បានពិនិត្យនិងសូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

..............................................................................

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

៣

# ឧបសម្ព័ន្ធទី១៣

# ឧបសម្ព័ន្ធទី១៣. របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី លទ្ធផលនៃកិច្ចប្រជុំត្រីមាសទី១ និង ត្រីមាសទី២ នៃលេខាធិការដ្ឋាន កំណែទម្រង់ ៣ ប្លុក ១ ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យ គ.ជ.អ.ប.
លេខ: 2305420
ថ្ងៃទី 07/11/23 ម៉ោង 11:47
អ្នកទទួល: PFM

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ: ៦៦៤ សហវ.(អគល)

ថ្ងៃ ពុធ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ២០២៣

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ៖** ការស្នើសុំការពិនិត្យលើរបាយការណ៍កិច្ចប្រជុំត្រីមាសទី១ និងត្រីមាសទី២ នៃលេខាធិការដ្ឋានកំណែទម្រង់ ៣ ប្លុក ១ ឆ្នាំ២០២៣ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។

**យោង ៖** លិខិតលេខ ៣០៤ ល.ស./គ.ជ.អ.ប. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពី ការរៀបចំកិច្ចប្រជុំត្រីមាសទី១ និងត្រីមាសទី២ នៃលេខាធិការដ្ឋានកំណែទម្រង់ ៣ ប្លុក ១ ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីព្រឹកថ្ងៃអង្គារ ១០ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣, ខ្ញុំអមដោយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានជំនាញក្រោមឱវាទ កសហវ. រួមមាន **ឯកឧត្តមបណ្ឌិត ឌី សុវណ្ណ** អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, **ឯកឧត្តម គីម កែវមុនីរ័ត្ន** អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា, និងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គាធិការដ្ឋាន, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ប្រមាណ ១៥ រូប បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី១ និងត្រីមាសទី២ នៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ ដែលសហដឹកនាំដោយ **ឯកឧត្តម ចាន់ សុផា** ប្រធានស្តីទីនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) និងរូបខ្ញុំផ្ទាល់។ កិច្ចប្រជុំនេះក៏ត្រូវបានចូលរួមផងដែរដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃការដ្ឋានកែទម្រង់ពីរផ្សេងទៀត រួមមាន **ឯកឧត្តម ខាន់ វណ្ណៈ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌និងជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និង **ឯកឧត្តម ឈុន សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.រ.**)។ កិច្ចប្រជុំបានកំណត់នូវរបៀបវារៈដើម្បីពិនិត្យនិងពិភាក្សា ដូចតទៅ៖

**១.** វឌ្ឍនភាពនិងបញ្ហាប្រឈម សម្រាប់ត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២៣

**២.** ការរៀបចំផែនការសកម្មភាព សម្រាប់ឆមាសទី២ នៃឆ្នាំ២០២៣

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

១

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

**ឆ.** បញ្ហាផ្សេងៗ។

ដោយនេះជាលើកទីមួយនៃការរៀបចំកិច្ចប្រជុំផ្ទាល់វេននៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ (**យ.ស.ក.**) ជាកិច្ចចាប់ផ្តើម ថ្នាក់ដឹកនាំជាតំណាងអគ្គ/លេខាធិការដ្ឋានកែទម្រង់នីមួយៗបានផ្តល់នូវមតិស្វាគមន៍ដោយគូសរំលេចនូវសារៈសំខាន់និងទស្សនាទាននៃការកសាងឡើងនូវឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ ក៏ដូចជាវឌ្ឍនភាពគន្លឹះៗនៅតាមការដ្ឋានកែទម្រង់គន្លឹះរបស់ខ្លួន ដែលបានគូសរំលេចជាពិសេសលើ ការគ្រោងនឹងបញ្ចប់ការរៀបចំនិងដាក់ឱ្យអនុវត្តត្រឹមត្រីមាសទី៤ ឆ្នាំ២០២៣ ឬ ដើមឆ្នាំ២០២៤ នូវកម្មវិធីជាតិកែទម្រង់គន្លឹះ ២ រួមមាន កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ បន្ទាប់មក មន្ត្រីជំនាញនៃអគ្គ/លេខាធិការដ្ឋានកែទម្រង់នីមួយៗ បានធ្វើបទបង្ហាញនិងរាយការណ៍លម្អិតជូនអង្គប្រជុំនូវរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២៣ នៅតាមការដ្ឋានរបស់ខ្លួន ដើម្បីពិនិត្យនិងពិភាក្សា។ ក្នុងន័យនេះ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នូវខ្លឹមសារគន្លឹះនៃលទ្ធផលកិច្ចពិភាក្សា ដើម្បីជ្រាបជារបាយការណ៍ ឬផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដូចតទៅ÷

- *ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលរាជធានី-ខេត្ត*

ផ្អែកតាមទិសដៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អង្គភាពសវនកម្មផ្ទៃក្នុងនឹងត្រូវបង្កើតនៅតាមរដ្ឋបាលរាជធានី-ខេត្ត។ ក្នុងន័យនេះ លេខាធិការដ្ឋាន **គ.ជ.អ.ប.** បានស្នើឱ្យមានការសិក្សារួមគ្នាក្នុងយន្តការ **យ.ស.ក.** ដោយហេតុថាការងារនឹងតម្រូវឱ្យមានការពិនិត្យឡើងវិញនូវតួនាទីអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ ។

- *ការផ្សព្វផ្សាយនិងបច្ចុប្បន្នកម្មឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "សុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១"*

ស្របតាមជវភាពថ្មីៗនៃការដ្ឋានកែទម្រង់គន្លឹះទាំង ៤ នៃរាជរដ្ឋាភិបាល ពិសេសគឺការត្រៀមដាក់ឱ្យអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, **អ.គ.ហ.** ស្នើឱ្យមានការគិតគូរធ្វើបច្ចុប្បន្នភាពឡើងវិញនូវ ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១ នៅក្នុងឆ្នាំ២០២៤ និងមានការរៀបចំរបាយការណ៍វឌ្ឍនភាពរួមគ្នាដើម្បីគោរពជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**។ ជាការឆ្លើយតប តំណាងលេខាធិការដ្ឋាន **គ.ក.រ.** បានស្នើឱ្យមានការផ្សព្វផ្សាយឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ រួមគ្នាទ្រង់ទ្រាយធំមួយទៀតនាដើម ឆ្នាំ២០២៤ ប៉ុន្តែតំណាងអគ្គ/លេខាធិការដ្ឋាន ៣ ផ្សេងទៀត ស្នើឱ្យមានការស្នើសុំជាគោលការណ៍កម្រិតនយោបាយជាមុន ដោយហេតុថា ឯកសារនេះបានផ្សព្វផ្សាយម្តងរួចមកហើយកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ដែលគួរគិតគូរធ្វើបច្ចុប្បន្នភាពជាមុនសិន។ ដោយឡែកសម្រាប់ការផ្សព្វផ្សាយផ្ទៃក្នុងអគ្គ/លេខាធិការដ្ឋានកែទម្រង់នីមួយៗ, អគ្គ/លេខាធិការដ្ឋានទាំង ៤ បានឯកភាពក្នុងការគាំទ្រគ្នាទៅវិញទៅមកនិងក្នុងស្មារតីភាពជាម្ចាស់។

- *ចលនាប្រឡងប្រណាំងកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ*

ស្របតាមនិន្នាការនៃទិសដៅកែទម្រង់ សិទ្ធិអំណាចនៃរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងបន្តបំពាក់ជូនកាន់តែច្រើនឡើងបន្ថែមទៀតទាំងក្នុងទិដ្ឋភាពមុខងារនិងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលកន្លងមកសមត្ថភាពទទួលយកនិងអនុវត្តឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាទូទៅនៅតែជាបញ្ហាប្រឈម។ ក្នុងន័យនេះ **អ.គ.ហ.** ស្នើឱ្យមានការគិតគូរឡើងវិញពីសមត្ថភាពនៃការគ្រប់គ្រងចំណូល-ចំណាយ សក្តានុពលតំបន់រដ្ឋបាល និងក្របខ័ណ្ឌអភិបាលកិច្ចរបស់រដ្ឋបាលបាលថ្នាក់ក្រោមជាតិ ក្នុងរូបភាពជាការប្រឡងប្រណាំង ដើម្បីគាំទ្រដល់ការធានាបាននូវប្រសិទ្ធភាពនៃការធ្វើ

២

វិមជ្ឈការមុខងារនិងហិរញ្ញវត្ថុ។ កិច្ចការក៏នេះអាចផ្សារភ្ជាប់ជាមួយការរៀបចំប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម ដែលការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ បាននិងកំពុងដឹកនាំរៀបចំផងដែរ។

- *ការពិភាក្សាលើការបញ្ចូលក្រុមប្រឹក្សាអ្នកច្បាប់ក្នុង ឃ.ស.គ.*

ជាទស្សនាទាន **ឃ.ស.គ.** ជាយន្តការសម្របសម្រួលការដ្ឋានកែទម្រង់ផ្តោតលើការកែទម្រង់អភិបាលកិច្ច ក្នុងទិដ្ឋភាព មុខងារ ហិរញ្ញវត្ថុ មនុស្ស និងច្បាប់។ ដោយហេតុថា កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលដឹកនាំដោយក្រសួងយុត្តិធម៌បច្ចុប្បន្នមានវិសាលភាពត្រឹមការងារកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការក្នុងវិស័យយុត្តិធម៌ ខណៈដែលការកែទម្រង់ច្បាប់ជាប្រព័ន្ធទាំងមូលស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី, ដូចនេះ **អ.គ.ហ.** ស្នើឱ្យមានការពិនិត្យអំពីវិសាលភាពនៃមុខងារដឹកនាំការដ្ឋានកែទម្រង់ទាំង ២ នេះ ឱ្យស្របនឹងទស្សនាទានដើមនៃ **ឃ.ស.គ.**។ យ៉ាងណាមិញ ការពិនិត្យលទ្ធភាពបញ្ចូលក្រុមប្រឹក្សាអ្នកច្បាប់មកក្នុងយន្តការ **ឃ.ស.គ.** នេះ ត្រូវស្នើសុំការពិនិត្យនិងសម្រេចរបស់ថ្នាក់ដឹកនាំកម្មវិធីកែទម្រង់ទាំង ៤។

- *សុខដុមនីយកម្មមុខងារសវនកម្មនិងអធិការកិច្ច*

កន្លងមក **អ.គ.ហ.** និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម បានសិក្សាស្រាវជ្រាវលើ និតិសុខដុមនីយកម្មសវនកម្ម និងអធិការកិច្ច ដោយបានចូលរំលេចនូវគតិពិចារណាមួយចំនួន រីឯអគ្គាធិការដ្ឋាន នៃ គសហវ. បាននិងកំពុងដឹកនាំលើការងារនេះដោយមានជំនួយទីប្រឹក្សាបច្ចេកទេសពីទីភ្នាក់ងារបារាំងផងដែរ, ក្នុងន័យនេះ **អ.គ.ហ.** ស្នើឱ្យមានការរៀបចំជាសិក្ខាសាលាថ្នាក់ជាតិរួមគ្នាក្នុងយន្តការ **ឃ.ស.គ.** ដើម្បីកំណត់ជាទិសដៅគោលនយោបាយកែទម្រង់និងសុខដុមនីយកម្មរវាងមុខងារទាំងពីរ ហើយសិក្ខាសាលានេះគួរមានវត្តមានតំណាងរបស់អាជ្ញាធរសវនកម្មជាតិនិងក្រសួងអធិការកិច្ច ផងដែរ។

- *ការចុះពិនិត្យមើលការដ្ឋានកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ*

ដើម្បីស្វែងយល់ពីវឌ្ឍនភាពនិងបញ្ហាប្រឈមជាក់ស្តែង, អគ្គ/លេខាធិការដ្ឋានទាំង ៤ បានឯកភាពលើការរៀបចំទស្សនកិច្ចសិក្សារួមគ្នាទៅកាន់ការដ្ឋានកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ដែលគួរជ្រើសរើសរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ២ ផ្តោតលើប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចឆ្លុះបញ្ចាំងលើទិដ្ឋភាពកែទម្រង់ទាំង៤ រួមមាន មុខងារ ហិរញ្ញវត្ថុ មនុស្ស និងច្បាប់ ព្រមទាំងកត្តាសមត្ថភាពជាក់ស្តែង។

- *ការរៀបចំវិបស្សនាប្រចាំឆ្នាំ២០២៣*

ផ្អែកតាមផែនការសកម្មភាព **ឃ.ស.គ.**, **អ.គ.ហ.** នឹងទទួលវេន **ឃ.ស.គ.** ដើម្បីរៀបចំវិបស្សនាប្រចាំឆ្នាំ២០២៣ អំឡុងត្រីមាសទី១ ឆ្នាំ២០២៤ ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងសម្របសម្រួលរៀបចំផែនការសកម្មភាពថ្មីឆ្នាំ២០២៤ ជាបន្ត។ បន្ថែមពីនេះ អគ្គ/លេខាធិការដ្ឋានទាំង ៤ បានឯកភាពបង្កើតក្របខ័ណ្ឌពេលវេលាផ្សារភ្ជាប់រវាងការរៀបចំវិបស្សនានឹងការចុះពិនិត្យមើលការដ្ឋានកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

- *ការសិក្សាពីភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីកែទម្រង់*

**អ.គ.ហ.** បានស្នើឱ្យមានការសិក្សាលើភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីកែទម្រង់ទាំង ៤ បន្ថែមទៀតដោយផ្អែកលើវឌ្ឍនភាពនិងកម្មវិធីជាតិនៃការដ្ឋានកែទម្រង់នីមួយៗ ដើម្បីជាធាតុចូលសម្រាប់ការរៀបចំសកម្មភាពអនុវត្តរួមគ្នាបានក្នុងយន្តការ **ឃ.ស.គ.**។

- *ការត្រៀមសម្រាប់កិច្ចប្រជុំផ្លាស់វេនបន្ទាប់*

ជាការកំណត់ក្រៅផ្លូវការកន្លងមក **ឃ.ស.គ.** ជាយន្តការដឹកនាំផ្លាស់វេន ចាប់ពីត្រីមាសទី១ ទី២ ទី៣ និងទី៤ ដែល

៣

ដឹកនាំរៀងគ្នាដោយ លេខាធិការដ្ឋាន **គ.ជ.អ.ប.** លេខាធិការដ្ឋាន **គ.ក.ស.** លេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និង **អ.ត.ហ.** ហើយការដឹកនាំយន្តការអាចត្រូវរៀបចំជាទម្រង់សហប្រធាន។ ប៉ុន្តែស្របតាមបរិបទជាក់ស្តែងនិងកិច្ចការមួយចំនួនដែលត្រូវត្រៀមសម្រាប់វិបស្សនាប្រចាំឆ្នាំខាងមុខ, អគ្គ/លេខាធិការដ្ឋានទាំង៤ បានសម្រេចឱ្យមានភាពបត់បែនលើការរៀបចំកិច្ចប្រជុំផ្លាស់វេនសម្រាប់ត្រីមាសទី៣ នៅតាមតម្រូវការវិញ ដោយទុកលទ្ធភាពឱ្យមន្ត្រីបង្គោលសម្របសម្រួលការដ្ឋានកែទម្រង់ ៤ អាចត្រៀមលក្ខណៈបានពីចម្ងាយលើការរៀបចំវិបស្សនាខាងមុខ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ឬផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ✓

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហេង ធីរ៉េន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ២០២៣
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី 3 ខែ 12 ឆ្នាំ២០២៣
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

៥

# ឧបសម្ព័ន្ធទី១៤

# ឧបសម្ព័ន្ធទី១៤. របាយការណ៍ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃទស្សនកិច្ចសិក្សានៅសាធារណរដ្ឋកូរ៉េនៃគណៈប្រតិភូអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ៣ ប្លុក ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:.............................................

**របាយការណ៍**
**ស្តីពី**
**លទ្ធផលនៃទស្សនកិច្ចសិក្សានៅសាធារណរដ្ឋកូរ៉េ**
**នៃគណៈប្រតិភូអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ៣ ប្លុក ១**

កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ កន្លងទៅនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្របសម្រួលរៀបចំទស្សនកិច្ចសិក្សាស្តីពីអភិបាលកិច្ចសាធារណៈនៅតាមក្រសួង-ស្ថាប័នមួយចំនួននៅសាធារណរដ្ឋកូរ៉េ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជាន់ខ្ពស់សរុប ២៦ រូប នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.), លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.), លេខាធិការដ្ឋានគណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ (លេខាធិការដ្ឋាន គ.ក.រ.), លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (លេខាធិការដ្ឋាន គ.ច.ប្រ.) និងលេខាធិការដ្ឋានក្រុមប្រឹក្សាធីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានសមាសភាពថ្នាក់ដឹកនាំដូចតទៅ÷

១. ឯកឧត្តមបណ្ឌិត **វ៉ែហ៊ល មិនរ៉ែន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.គ.ហ.
២. ឯកឧត្តម **ខាន់ សុផា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.
៣. ឯកឧត្តម **ឃួន ស៊ីនាដ** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាប្រធានលេខាធិការដ្ឋាន គ.ក.រ.
៤. ឯកឧត្តម **ខាន់ ចណ្ណា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ច.ប្រ.
៥. ឯកឧត្តម **យ៉េត ទីណល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.គ.ហ.
៦. ឯកឧត្តម **ស៊ាន ផល្លា** អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាធីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទស្សនកិច្ចសិក្សានេះបានទទួលលទ្ធផលយ៉ាងគាប់ប្រសើរជាទីបំផុតដោយប្រមូលបាននូវឧត្តមានុវត្តន៍ បទពិសោធន៍ និងមេរៀនល្អៗជាច្រើនពីតាមស្ថាប័នចំនួន ៤ នៃរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលខ្ញុំសូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យដូចតទៅ÷

**ក. សាវតារនិងគោលបំណង**

កន្លងមក អ.គ.ហ. និងលេខាធិការដ្ឋានក្រុមប្រឹក្សាធីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសហការគ្នាលើកគម្រោងស្រាវជ្រាវមួយចំនួនទើបបានចេញជាឯកសារនិងរបកគំហើញគន្លឹះ ដែលជាសមាសធាតុគន្លឹះនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់អន្តរវិស័យ ៣ ប្លុក ១ ដែលមានដូចជា **ទស្សនាទានស្តីពីសុខដុមនីយកម្មមុខងារសវនកម្មនិងអធិការកិច្ច, គួបផ្សំស្ថាប័ននីតិប្បញ្ញត្តិនិងការិយាល័យជំនាញក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

១

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

**"របកគំហើញសម្រាប់កម្ពុជា"  ឧត្តមានុវត្តន៍លើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងឧត្តមានុវត្តន៍នៃមុខងារនីតិកម្ម។**

ផ្អែកលើលទ្ធផលស្រាវជ្រាវលើគម្រោងទាំង ៤ ខាងលើនេះ ក្រុមការងារស្រាវជ្រាវបានពិនិត្យនិងវាយតម្លៃឃើញថា សាធារណៈរដ្ឋកូរ៉េមាននូវប្រព័ន្ធអភិបាលកិច្ចមួយដែលមានលក្ខណៈពិសេស មិនដូចប្រព័ន្ធទូទៅដែលមាននៅបណ្ដាប្រទេសផ្សេងទៀត ដូចជាវិស័យហិរញ្ញវត្ថុសាធារណៈ វិស័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ វិស័យសវនកម្មនិងអធិការកិច្ច វិស័យនីតិកម្មរបស់រដ្ឋាភិបាល ការរៀបចំការិយាល័យថវិកាជាសេនាធិការរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងវិស័យផ្សេងៗទៀត។

ផ្អែកលើសារតារនិងការពិចារណាល្អិតល្អន់ខាងលើ ក្រុមការងារដែលដឹកនាំដោយឯកឧត្តមបណ្ឌិត **វ៉ាន់ហ៊ិល ច័ន្ទរ៉ឺន** បានសិក្សា សម្របសម្រួល និងពិភាក្សាលើការរៀបចំដំណើរទស្សនកិច្ចសិក្សាមួយនៅសាធារណៈរដ្ឋកូរ៉េដោយមានការចូលរួមពីតំណាងលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតផងដែរ ដោយក្រោយមកគម្រោងនេះបានទទួលនូវគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី។

ជាការគ្រោងទុក ក្រុមការងារគ្រោងរៀបចំការសិក្សានៅក្នុងក្រសួង-ស្ថាប័ននៃសាធារណរដ្ឋកូរ៉េ ចំនួន ៧ ដូចជា ក្រសួងហិរញ្ញវត្ថុ, ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកូរ៉េ, ការិយាល័យថវិកានៃរដ្ឋសភា, ក្រសួងគ្រប់គ្រងមន្ត្រីរាជការ, ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល, ស្ថាប័នសវនកម្មកំពូលរបស់កូរ៉េ និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយ។ ដោយសារកត្តាពេលវេលានិងភាពមមាញឹករបស់ភាគីកូរ៉េផងដែលមិនអាចអនុញ្ញាតឱ្យរៀបចំបាននូវទស្សនកិច្ចនៅគ្រប់ក្រសួង-ស្ថាប័នតាមការគ្រោងទុក ទស្សនកិច្ចសិក្សានេះបានរៀបចំឡើងនៅក្នុងស្ថាប័នចំនួន ៤ គឺ ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកូរ៉េ, ការិយាល័យថវិកានៃរដ្ឋសភា ក្រសួងគ្រប់គ្រងមន្ត្រីរាជការ, ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល។

## ខ. សមាសភាព និងកិច្ចដំណើរការនៃទស្សនកិច្ចសិក្សា

### ខ.១. ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកូរ៉េ (Korea Asset Management Corporation-KAMCO)

ទស្សនកិច្ចនៅក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកូរ៉េ ត្រូវបានទទួលស្វាគមន៍ដោយលោក WON Ho Joon ជា Executive Director of Corporate Support Group និងលោក CHOI Chung Hwa ជា General Manager ព្រមទាំងមន្ត្រីជាន់ខ្ពស់ផ្សេងទៀតនៃស្ថាប័ននេះ។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅប្រទេសកូរ៉េ មិនទទួលបន្ទុកដោយអគ្គនាយកដ្ឋានឬនាយកដ្ឋានក្រោមឱវាទក្រសួងទទួលបន្ទុកហិរញ្ញវត្ថុនោះឡើយ តែគឺស្ថិតក្រោមការទទួលខុសត្រូវរបស់ KAMCO ដែលស្ថាប័ននេះមានលក្ខន្តិកៈជាសហគ្រាសសាធារណៈ។

#### ខ.១.១. ប្រភេទទ្រព្យសម្បត្តិរដ្ឋ

ទ្រព្យសម្បត្តិរដ្ឋត្រូវបានបែងចែកជាពីរប្រភេទគឺ **ទ្រព្យសម្បត្តិរដ្ឋបាល** (Administrative property) **និងទ្រព្យសម្បត្តិទូទៅ** (General property)។

ទ្រព្យសម្បត្តិរដ្ឋបាល រួមមានទ្រព្យសម្បត្តិបម្រើឱ្យការប្រើប្រាស់របស់រដ្ឋបាលមានដូចជា អគារ ផ្ទះស្នាក់នៅរបស់រដ្ឋនិងសាលា, ទ្រព្យសម្បត្តិសម្រាប់ការប្រើប្រាស់ជាសាធារណៈដែលមានដូចជាផ្លូវ ទន្លេ បឹង ផែ និងព្រលានយន្តហោះ ជាដើម សហគ្រាសសាធារណៈដែលមានដូចជាប្រៃសណីយ៍ និងសេវាទូរគមនាគមន៍ និងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការអភិរក្សដូចជាទ្រព្យសម្បត្តិវប្បធម៌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រជាដើម។ និយាយម្យ៉ាងទៀតជាទូទៅ ទ្រព្យសម្បត្តិរដ្ឋបាលនេះមិនមែនជាកម្មវត្ថុនៃការកាន់កាប់ដោយវិស័យឯកជន ឬសម្រាប់ធ្វើសកម្មភាពពាណិជ្ជកម្មនោះឡើយលើកលែងមានការកំណត់ដោយច្បាប់។

២

ដោយឡែក ទ្រព្យសម្បត្តិទូទៅរបស់រដ្ឋ ឬក៏អាចអាចហៅទ្រព្យសម្បត្តិមិនមែនរដ្ឋបាល (Non administrative property) គឺជាទ្រព្យសម្បត្តិទាំងឡាយដែលមិនបម្រើឱ្យគោលបំណងរដ្ឋបាលឬការប្រើប្រាស់សម្រាប់តម្រូវការរដ្ឋបាលនាពេលអនាគត ដែលមានដូចជានុទ្យានសាធារណៈ ព្រៃឈើ ស្ទឹង ឆ្នេរសមុទ្រ ធនធានធម្មជាតិ ដីធ្លី អគារដែលមិនមែនបម្រើឱ្យសកម្មភាពរបស់រដ្ឋបាល។

ខ.១.២. ក្របខណ្ឌស្ថាប័ន

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័នទិញ្ញបនករ* ដោយមានតួនាទីដូចជារៀបចំគោលនយោបាយ, ដាក់ចេញគោលការណ៍ណែនាំនិងបទប្បញ្ញត្តិនៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ត្រួតពិនិត្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងមូលនិធិគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (state property administration fund) ។ល។

*ក្រសួង ស្ថាប័ននៅថ្នាក់កណ្តាលនិងអង្គភាពនៅថ្នាក់មូលដ្ឋាន គឺជាតួអង្គប្រតិបត្តិករនៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលរបស់រដ្ឋ* តាមសមត្ថកិច្ចនិងវិស័យរៀងៗខ្លួន។

*ចំណែកឯ KAMCO គឺជាស្ថាប័នផ្តាច់មុខក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិទូទៅរបស់រដ្ឋ នៅថ្នាក់កណ្តាល។* រដ្ឋបាលថ្នាក់មូលដ្ឋាន មានស្វ័យភាពនៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងអាចទទួលបានប្រតិភូកម្មមុខងារពីរដ្ឋបាលថ្នាក់កណ្តាល។

ខ.១.៣. ក្របខ័ណ្ឌគតិយុត្ត

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅសាធារណរដ្ឋកូរ៉េកំណត់ដោយច្បាប់ស្តីពីទ្រព្យសម្បត្តិរដ្ឋ។ ច្បាប់នេះកំណត់ឱ្យ*រៀបចំផែនការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបង្កើតមូលនិធិគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។*

*ផែនការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ* ត្រូវដឹកនាំនិងរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយតម្រូវឱ្យក្រសួងស្ថាប័នផ្តល់ផែនការដើម្បីត្រួតពិនិត្យនិងបូកសរុបជូនសភាជាតិពិនិត្យអនុម័តជារៀងរាល់ឆ្នាំ។

*មូលនិធិគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ* ត្រូវបានបង្កើតឡើងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលមានប្រភពចំណូលមកពីការធ្វើលទ្ធកម្មនៃកម្មសិទ្ធិ កម្រៃជួល និងពិន័យនិងការដាក់ទណ្ឌកម្មផ្សេងៗ។ មូលនិធិនេះប្រើប្រាស់សម្រាប់ចំណាយលទ្ធកម្មនៃកម្មសិទ្ធិចាំបាច់ ចំណាយលើការអភិវឌ្ឍ រួមបញ្ចូលទាំងចំណាយការប្រាក់ ។

ខ.១.៤. ក្របខ័ណ្ឌគោលនយោបាយ

គោលនយោបាយទ្រព្យសម្បត្តិរដ្ឋនៃសាធារណរដ្ឋកូរ៉េ ផ្តោតទៅលើនវានុវត្តន៍បច្ចេកវិទ្យា និងអន្តរកម្មរវាងរដ្ឋនិងវិស័យឯកជន តាមរយៈវត្ថុបំណងសំខាន់ៗដូចជា *ជំរុញការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋពីសំណាក់វិស័យឯកជន, អភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋជាមួយវិស័យឯកជន, ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋស្របតាមគោលនយោបាយជាតិ និងការបង្កើនគុណតម្លៃទ្រព្យសម្បត្តិរដ្ឋតាមរយៈនវានុវត្តន៍ប្រព័ន្ធគ្រប់គ្រង។*

**ខ.២. ការិយាល័យថវិកានៃរដ្ឋសភា** (National Assembly Budget Office-NABO)

ខស្សេចកិច្ចទៅការិយាល័យថវិកានៃរដ្ឋសភា (NABO) ត្រូវបានទទួលស្វាគមន៍ដោយលោកប្រធាន CHO Euysup ប្រធាន NABO និងថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងទៀតនៃអង្គភាពនេះ។

ខ.២.១. រចនាសម្ព័ន្ធ

សាធារណរដ្ឋកូរ៉េ អនុវត្តប្រព័ន្ធសភាមួយថ្នាក់ គឺរដ្ឋសភាដែលដឹកនាំដោយប្រធាន ១ រូប, អនុប្រធាន ២ រូប និងមានសមាជិកទាំង ៣០០ រូប ដែលបែងចែកជាគណៈកម្មការចំនួន ១៩ ក្នុងនោះមានគណៈកម្មការអចិន្ត្រៃយ៍ចំនួន ១៧ និងគណៈកម្មការពិសេសចំនួន ២។

ការិយាល័យថវិកានៃរដ្ឋសភា (NABO) ត្រូវបានបង្កើតឡើងតាមរយៈវិសោធនកម្មមាត្រា២១និង២២ នៃច្បាប់ស្តីពីរដ្ឋសភា (National Assembly Act) នៅខែកក្កដា ឆ្នាំ២០០៣។ អង្គភាពនេះគាំទ្រដល់ស្ថាប័ននីតិប្បញ្ញត្តិ និងមានគោលដៅធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃតួនាទីអង្គនីតិប្បញ្ញត្តិ ដើម្បីពិនិត្យនិងតាមដានការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការិយាល័យនេះ មានចក្ខុវិស័យ "ក្លាយជាខួរក្បាលរបស់សភា (Think tank) លើកិច្ចការហិរញ្ញវត្ថុសាធារណៈ ដែលបម្រើដល់រដ្ឋសភានៃសាធារណរដ្ឋកូរ៉េនិងប្រជាជន" ដោយមានបេសកកម្មចំនួន ៣ គឺ ÷ (១) ការពិនិត្យស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយលើការវិភាគហិរញ្ញវត្ថុ (Fiscal analysis) និងគោលបំណងនៃកម្មវិធីហិរញ្ញវត្ថុ (Objective fiscal program) (២) ការវិភាគជាក់លាក់លើការព្យាករណ៍ទំហំសារពើពន្ធ (Tax analysis) និងចំណាយ (Cost estimation) (៣) វិភាគនិងព្យាករណ៍ប្រកបដោយភាពជឿទុកចិត្តបានលើស្ថានភាពសេដ្ឋកិច្ច។

NABO ដឹកនាំដោយប្រធាន ១ រូប និងមានបន្ទាត់គណនេយ្យផ្ទាល់ទៅកាន់ប្រធានរដ្ឋសភា (Speaker)។ NABO មានរចនាសម្ព័ន្ធបែងចែកជានាយកដ្ឋានបច្ចេកទេសចំនួន ៤ រួមមាន ១)នាយកដ្ឋានផែនការនិងគ្រប់គ្រង ២)នាយកដ្ឋានវិភាគថវិកា ៣)នាយកដ្ឋានព្យាករណ៍និងវិភាគសារពើពន្ធ និង ៤)ការិយាល័យវិភាគសេដ្ឋកិច្ច។

ខ.២.២. មុខងារនិងភារកិច្ច

NABO មានមុខងារនិងភារកិច្ចគន្លឹះដូចតទៅ÷

- *ការវិភាគថវិកា (Budget analysis)*÷ ពិនិត្យលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ (Budget Bills) និងការទូទាត់ (Account Settlement) ដែលផ្តល់ជូនដោយរដ្ឋាភិបាល និងផលិតជារបាយការណ៍វិភាគជាក់លាក់ជូនរដ្ឋសភាជាមូលដ្ឋានក្នុងការសម្រេចចិត្ត (ក្នុងករណីចាំបាច់ NABO អាចរៀបចំសេចក្តីព្រាងដោយឡែក)។ ក្នុងវដ្តថវិកាប្រចាំឆ្នាំ NABO បោះផ្សាយរបាយការណ៍វិភាគចំនួន ២ គឺ ទី១) របាយការណ៍វិភាគសំណើទូទាត់ក្នុងអំឡុងខែមិថុនាដល់ខែសីហា និងទី២) របាយការណ៍វិភាគសំណើថវិកាប្រចាំឆ្នាំ។
- *ការវិភាគនិងវាយតម្លៃលើកម្មវិធីធំៗ (Major programs) របស់រដ្ឋាភិបាល* ÷ វិភាគលើកម្មវិធីថ្នាក់ជាតិមួយចំនួនដែលមានទំហំចំណាយធំ កម្មវិធីជាគោលនយោបាយសំខាន់របស់រដ្ឋាភិបាល និងកម្មវិធីគ្រប់គ្រងសមិទ្ធកម្មរបស់រដ្ឋាភិបាល។ លទ្ធផលនៃការវិភាគត្រូវបានប្រើប្រាស់ជាជំនួយដល់ស្ថាប័ននីតិប្បញ្ញត្តិក្នុងការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងកម្មវិធីទាំងនោះ។
- *ការព្យាករណ៍ថវិកា (Bill Cost estimates)*÷ ព្យាករណ៍ចំណូលនិងចំណាយតាមរយៈច្បាប់សារពើពន្ធ ឬច្បាប់ផ្សេងទៀតសម្រាប់រយៈពេល ៥ឆ្នាំ បន្ទាប់ពីការអនុម័ត។ ការព្យាករណ៍នេះនឹងក្លាយជាទិន្នន័យមូលដ្ឋានក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធជាបន្តបន្ទាប់ដើម្បីបញ្ជាក់ពីលទ្ធភាពហិរញ្ញវត្ថុនិងពិភាក្សាអំពីជម្រើសគោលនយោបាយ។
- *ការវិភាគប្រព័ន្ធសារពើពន្ធ*÷ ស្រាវជ្រាវនិងវិភាគលើបញ្ហាចម្បងៗនៃប្រព័ន្ធសារពើពន្ធនិងផ្តល់ជាអនុសាសន៍លម្អិតក៏ដូចជាទិសដៅនៃគោលនយោបាយសារពើពន្ធរយៈពេលមធ្យម និងរយៈពេលវែង។
- *ការព្យាករណ៍ហិរញ្ញវត្ថុសាធារណៈរយៈពេលវែងនិងមធ្យម*÷ ផ្អែកលើការព្យាករណ៍នៃចំណូលនិងចំណាយ, NABO រៀបចំការព្យាករណ៍ហិរញ្ញវត្ថុសាធារណៈរយៈពេលវែងនិងមធ្យមសម្រាប់រយៈពេល ៥ ឆ្នាំ ដែលរួមមានចំណូលសុល ចំណាយសុល, សមតុល្យហិរញ្ញវត្ថុ, បំណុល ។ល។
- *ការតាមដានស្ថានភាពសេដ្ឋកិច្ច*÷ តាមដាននិងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចនិងព្យាករណ៍នូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ចជារួម ដើម្បីក្លាយជាមូលដ្ឋានទិន្នន័យជំនួយដល់ការសម្រេចចិត្តរបស់ស្ថាប័នីតិប្បញ្ញត្តិ។
- *ការវិភាគលើបន្ទុកសេដ្ឋកិច្ច* នៃគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល។

៥

- **ការសិក្សាស្រាវជ្រាវ** ៖ តបតាមសំណើរបស់គណៈកម្មការ ឬសមាជិកសភា NABO សិក្សាស្រាវជ្រាវលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.៣. ក្រសួងនីតិកម្មនៃរដ្ឋាភិបាល** (Ministry of Government Legislation-MOLEG)

ទស្សនកិច្ចនៅក្រសួងនីតិកម្មនៃរដ្ឋាភិបាលកូរ៉េ (MOLEG) នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ត្រូវបានទទួលស្វាគមន៍ដោយលោក CHOE Young Chan អគ្គនាយកទទួលបន្ទុកផែនការនិងសម្របសម្រួល និងមន្ត្រីជាន់ខ្ពស់មកពីអង្គភាពនានាៗនៃក្រសួងនេះ។

គ.៣.១. បេសកកម្ម រចនាសម្ព័ន្ធ និងមុខងារ

ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល មានមុខងារគ្រប់គ្រងការរៀបចំ ការបកស្រាយ ការអនុវត្តច្បាប់ និងការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ទាំងក្នុងកម្រិតរាជរដ្ឋាភិបាល ទាំងរវាងក្រសួង-ស្ថាប័នក្រោមឱវាទ ព្រមទាំងក្នុងកម្រិតថ្នាក់ក្រោមជាតិ ដោយមានមុខងារចម្បង ដូចខាងក្រោម÷

- *គ្រប់គ្រងកិច្ចការគតិយុត្តរបស់រដ្ឋាភិបាល* ដោយសម្របសម្រួលការរៀបចំនិងជាធានាការអនុវត្តផែនការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសម្របសម្រួលនិងស្វែងរកមតិរួមលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលខ្វែងគំនិតគ្នា។
- *ប្រឹក្សានិងត្រួតពិនិត្យលើគតិយុត្តភាពនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត* ជាអាទិ៍លើភាពចាំបាច់នៃការរៀបចំ, ឱត្យានុកូលភាព និងវិធីសាស្ត្រផ្នែកទម្រង់នៃការរៀបចំខ្លឹមសារ។ ក្រសួងផ្តល់ប្រឹក្សាច្បាប់ពីជាង ២០០ ដល់ជាង ៣០០ ករណីក្នុងមួយឆ្នាំ។
- *បកស្រាយច្បាប់* ព្រមទាំងបំភ្លឺអត្ថន័យច្បាប់ស្របតាមគោលបំណងនៃការរៀបចំ។ ការបកស្រាយច្បាប់របស់ក្រសួងគឺការបកស្រាយបិទផ្លូវតវ៉ានិងមានអានុភាពគតិយុត្តក្នុងកម្រិតរដ្ឋាភិបាល។ ក្រសួងផ្តល់ការបកស្រាយច្បាប់ប្រមាណជាង ៥០០ សំណើក្នុងមួយឆ្នាំជាមធ្យម។
- *ធានាប្រសិទ្ធភាពនៃលិខិតបទដ្ឋានគតិយុត្ត* ដោយស្រាវជ្រាវនិងធ្វើវិសោធនកម្មបទដ្ឋានគតិយុត្តដែលមានផលប៉ះពាល់អវិជ្ជមានដល់សាធារណជននិងមជ្ឈដ្ឋានធុរកិច្ច។ ក្រសួងធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តចន្លោះពី ៤០០ ទៅ ៦០០ បទដ្ឋានក្នុង១ឆ្នាំ ជាមធ្យម។
- *ផ្តល់ការគាំទ្រលើចំណេះដឹងច្បាប់* តាមរយៈការបណ្តុះបណ្តាលជូនមន្ត្រីរាជការសាធារណៈ ទាំងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធអនឡាញ ជាង ៣ ម៉ឺននាក់ក្នុង១ឆ្នាំ។
- *ផ្សព្វផ្សាយច្បាប់* តាមរយៈប្រព័ន្ធស្វែងរកបទដ្ឋានគតិយុត្តទោលដែលប្រមូលផ្តុំទាំងលិខិតបទដ្ឋានគតិយុត្តរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដែលត្រូវបានរៀបចំប្រកបដោយប្រទាក់ក្រឡា។
- *ផ្លាស់ប្តូរបទពិសោធន៍និងកិច្ចសហការផ្នែកច្បាប់* ដែលតាមរយៈនេះ ក្រសួងបានប្រមូលនិងចងក្រងនូវព័ត៌មានច្បាប់នៃបណ្តាប្រទេសជាដៃគូ ព្រមទាំងអាចផ្តល់ប្រឹក្សាជូនធុរជនកូរ៉េដែលមានបំណងទៅធ្វើធុរកិច្ចនៅតាមបណ្តាប្រទេសទាំងនោះ។

គ.៣.២. ប្រព័ន្ធច្បាប់និងនីតិវិធីរៀបចំច្បាប់

ប្រព័ន្ធច្បាប់នៅប្រទេសកូរ៉េ ហាក់មានលក្ខណៈស្រដៀងគ្នានឹងប្រព័ន្ធនៅកម្ពុជាដែរ ដោយឋានានុក្រមគតិយុត្តមានលំដាប់ពីខ្ពស់មកទាបបំផុត គឺរដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យប្រធានាធិបតី អនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ប្រកាសរបស់រដ្ឋមន្ត្រី ដីកា

៥

ឧបសម្ព័ន្ធទី១៤

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាជិក និងគណៈកម្មការតាមវិស័យរបស់រដ្ឋសភាមានសិទ្ធិស្នើសេចក្ដីស្នើច្បាប់ រីឯរដ្ឋាភិបាលមានសិទ្ធិស្នើសេចក្ដីព្រាងច្បាប់។

សម្រាប់នីតិវិធីរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្រសួងនីតិកម្មរបស់រដ្ឋាភិបាលមានតួនាទីដ៏សំខាន់និងមិនអាចខ្វះបាន នៅគ្រប់កម្រិត ទាំងកម្រិតច្បាប់ ទាំងកម្រិតអនុវត្តច្បាប់ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល គ្រប់គ្រងការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដោយមានតួនាទីជាចំណុចកណ្ដាលក្នុងដំណាក់កាលចំនួនពីរដូចតទៅ៖

- *ដំណាក់កាលរៀបចំផែនការ៖* ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល គ្រប់គ្រង សម្របសម្រួល និងបូកសរុបផែនការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវអនុវត្តដោយរដ្ឋាភិបាល ដែលរួមមានជាអាទិ៍ច្បាប់ ក្រឹត្យ អនុក្រឹត្យ និងប្រកាស។ ផែនការនេះ ត្រូវរៀបចំក្នុងអំឡុងខែតុលា និងត្រូវដាក់ឱ្យប្រើដោយសភាមុនថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់។
- *ដំណាក់កាលអនុវត្ត៖* ការព្រាងលិខិតបទដ្ឋានគតិយុត្តទាំងកម្រិតច្បាប់ និងកម្រិតអនុវត្តច្បាប់ (ក្រឹត្យ អនុក្រឹត្យ និងប្រកាស) ត្រូវឆ្លងការពិនិត្យនិងផ្ដល់យោបល់ទាំងលើទម្រង់ និងគតិច្បាប់ពីក្រសួងនីតិកម្មរបស់រដ្ឋាភិបាល បន្ទាប់ពីក្រសួង-ស្ថាប័នសាមីបានបញ្ចប់ការព្រាងនិងឆ្លងយោបល់អន្តរក្រសួងនិងសាធារណមតិរួចហើយ មុនបន្តទៅក្រុមប្រឹក្សារដ្ឋ ឬទៅរដ្ឋសភា តាមប្រភេទលិខិតបទដ្ឋានគតិយុត្ត។ ជាទម្រង់ ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល ពិនិត្យនិងកែសម្រួលលើការប្រើប្រាស់បច្ចេកសព្ទគតិយុត្ត រីឯខ្លឹមសារវិញ ក្រសួងពិនិត្យ ផ្ដល់យោបល់ និងកែសម្រួល ដោយផ្អែកលើនីត្យានុកូលភាពព្រមទាំងសង្គតិភាពនៃខ្លឹមសារទាំងជាមួយបទដ្ឋានគតិយុត្ត ទាំងជាមួយឯកសារគោលនយោបាយ។

៩.៣.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីតិកម្មរបស់រដ្ឋាភិបាល

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីតិកម្មរបស់រដ្ឋាភិបាលត្រូវបានរៀបចំនិងអភិវឌ្ឍជាបន្តបន្ទាប់តាំងពីឆ្នាំ២០០២ មកនិងបានធ្វើបច្ចុប្បន្នកម្ម និងអភិវឌ្ឍបន្ថែមមុខងារចំនួន ៦។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីតិកម្មរបស់រដ្ឋាភិបាល រួមមានប្រព័ន្ធចម្បងចំនួន ២ ដូចខាងក្រោម៖

- *ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សព្វផ្សាយច្បាប់៖* ប្រព័ន្ធនេះត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយច្បាប់និងបទដ្ឋានគតិយុត្តជាធនធានសម្រាប់សាធារណជន ក្នុងការស្វែងរក និងអាចប្រើប្រាស់ព័ត៌មានពាក់ព័ន្ធច្បាប់និងលិខិតបទដ្ឋានគតិយុត្តប្រកបដោយភាពងាយស្រួល រហ័ស និងសុក្រឹត។
- *ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រការរៀបចំច្បាប់៖* ប្រព័ន្ធនេះត្រូវបានរៀបចំឡើងសម្រាប់គាំទ្រដល់មន្ត្រីរាជការសាធារណៈនៅតាមគ្រប់ដំណាក់កាលចាប់ពីដំណាក់កាលរៀបចំនិងពិនិត្យសេចក្ដីព្រាង រហូតដល់ការប្រកាសឱ្យប្រើនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ ប្រព័ន្ធនេះជាកម្មវត្ថុចម្បងនៃបទបង្ហាញរបស់ក្រសួងសាមី ហើយមានមុខងារចម្បងនៅតាមដំណាក់កាលនៃការរៀបចំ ដូចខាងក្រោម៖
  - *មុខងារផែនការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត៖* មុខងារនេះសម្រួលដល់ការរៀបចំ កំណត់អាទិភាព ពេលវេលា និងព័ត៌មានសំខាន់នៃផែនការរៀបចំច្បាប់និងបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាល។
  - *មុខងារព្រាងបឋមនិងពិនិត្យកែសម្រួល៖* មុខងារនេះគឺជានីតិផលូបនីយកម្មនៃនីតិវិធីរៀបចំច្បាប់ ដូចជាការព្រាង ការប្រជុំពិគ្រោះយោបល់អន្តរក្រសួង ការត្រួតពិនិត្យដោយក្រសួងនីតិកម្ម និងការបញ្ជូនសេចក្ដីព្រាងទៅគណៈរដ្ឋមន្ត្រី។ មុខងារនេះត្រូវបានធ្វើសន្ធានកម្មជាមួយកម្មវិធីតាក់តែងច្បាប់ "Law Editor" ដែលជាកម្មវិធីកុំព្យូទ័រសម្រាប់មន្ត្រីរាជការក្នុងការតាក់តែងច្បាប់ តាមរយៈការបញ្ចូលអត្ថបទវិសោធនកម្ម និងការបង្កើតតារាងប្រៀបធៀបអត្ថបទថ្មីនិងចាស់ដោយស្វ័យប្រវត្តិ, ការពិនិត្យនិងកែសម្រួលការយោងដោយស្វ័យប្រវត្តិ, ការពិនិត្យ

៦

ឧបសម្ព័ន្ធទី១៤

និងធានាសង្គតិភាពលើការប្រើប្រាស់បច្ចេកសព្ទគតិយុត្ត ព្រមទាំងមានមុខងារធានាសង្គតិភាពជាមួយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

- *មុខងារប្រមូលធាតុចូលពីសាធារណជន*÷ ដែលជាថ្នាលសម្រាប់ប្រមូលធាតុចូលពីសាធារណជន ក្នុងការកែលម្អសេចក្តីព្រាង។ មុខងារនេះត្រូវបានធ្វើសន្ទានកម្មជាមួយមជ្ឈមណ្ឌលចូលរួមផ្តល់យោបល់ពីសាធារណៈ ដែលជាថ្នាលអនឡាញសម្រាប់សាធារណជនទទួលព័ត៌មាននិងចូលរួមមតិលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។
- *មុខងារស្វែងរកសមាហរណា*÷ លើមូលដ្ឋានទិន្នន័យជាង ៧៤០ពាន់ឯកសារ រួមមានរបាយការណ៍កិច្ចប្រជុំ របាយការណ៍វាយតម្លៃផលប៉ះពាល់ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មតិប្រឹក្សា។
- *មុខងារពិនិត្យនិងតាមដានវឌ្ឍនភាព*÷ ជួយសម្រួលដល់ការតាមដានសមិទ្ធកម្មនៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅគ្រប់ពេលវេលា (real-time)។

**គ.៤. ក្រសួងគ្រប់គ្រងមន្ត្រីរាជការ** (Ministry of Personnel Management)

ទស្សនកិច្ចនៅក្រសួងគ្រប់គ្រងមន្ត្រីរាជការ បានទទួលស្វាគមន៍ដោយលោក Lee Eunhyo ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត។

គ.៤.១. ទិដ្ឋភាពទូទៅ

ក្រសួងគ្រប់គ្រងមន្ត្រីរាជការត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៨ ដែលមានឈ្មោះថា The Higher Civil Service Examination Commission and the Ministry of Government Administration និងត្រូវបានផ្លាស់ប្តូរឈ្មោះនិងរចនាសម្ព័ន្ធ ជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៤ ទើបមានឈ្មោះថាក្រសួងគ្រប់គ្រងមន្ត្រីរាជការ (Ministry of Personnel Management-MPM)។

គ.៤.២. ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា

ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា (Electronic Human Resource Management System “e-Saram”) គឺជាប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធអេឡិចត្រូនិចស្តង់ដារ ដែលគាំទ្រដល់ការងាររដ្ឋបាលបុគ្គលិកនិងគោលនយោបាយបុគ្គលិកទូទាំងរដ្ឋ ចាប់ពីការជ្រើសរើសបុគ្គលិករហូតដល់ចូលនិវត្តន៍។

តាមរយៈប្រព័ន្ធនេះ ក្រសួង-ស្ថាប័នរដ្ឋនីមួយៗអាចគ្រប់គ្រងកិច្ចការផ្សេងៗទាក់ទងនឹងបុគ្គលិកដូចជាការតែងតាំង ការវាយតម្លៃការអនុវត្ត ការបណ្តុះបណ្តាលអប់រំ កាលវិភាគការងារ និងប្រាក់ខែ។ លើសពីនេះ ទិន្នន័យនិងស្ថិតិផ្សេងៗដែលមាននៅក្នុងប្រព័ន្ធនេះត្រូវបានប្រើប្រាស់ជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រងមន្ត្រី។

**ឃ. របកគំហើញគន្លឹះជាគតិពិចារណា**

**ឃ.១. វិស័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

១. *ប្រភេទទ្រព្យសម្បត្តិរដ្ឋ* ÷ ទ្រព្យសម្បត្តិរដ្ឋកូរ៉េ មាន ២ ប្រភេទធំៗ គឺទ្រព្យសម្បត្តិរដ្ឋបាល (បម្រើឱ្យការបំពេញការងាររបស់ក្រសួងនិងមន្ត្រីរាជការ) និងទ្រព្យសម្បត្តិទូទៅ (អាចបម្រើឱ្យសកម្មភាពពាណិជ្ជកម្មនិងធ្វើអាជីវកម្មរកចំណូលបាន)។

២. *ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ* ÷ ការគ្រប់គ្រងលើប្រភេទទ្រព្យសម្បត្តិទូទៅដែលអាចបម្រើឱ្យសកម្មភាពពាណិជ្ជកម្មនិងធ្វើអាជីវកម្មរកចំណូលបាន ត្រូវបានប្រគល់ទៅឱ្យស្ថាប័នមួយដាច់ដោយឡែកពីក្រសួងហិរញ្ញវត្ថុតែម្តងហើយដែលមានចរិតលក្ខណៈជាសហគ្រាសសាធារណៈ គឺ KAMCO។

៣. *មូលនិធិគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (state property administration fund)* ÷ ក្រសួង-ស្ថាប័ននីមួយៗអាចបង្កើតមូលនិធិគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើងថែមទៀត ដែលបម្រើដល់ការគ្រប់គ្រង ជួសជុល កែលម្អ ថែទាំ និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះប្រកបដោយតម្លាភាពនិងគណនេយ្យភាព។ ជាទូទៅ មូលនិធិនេះមានប្រភពចំណូលចម្បងរកបានមកពីទ្រព្យសម្បត្តិរដ្ឋតែម្តង និងមានប្រភពផ្សេងទៀត។

៤. *ក្របខ័ណ្ឌច្បាប់ដ៏រឹងមាំនិងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដ៏មានប្រសិទ្ធភាព* ពិតជាកត្តាដ៏គន្លឹះនៅក្នុងការធានាការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រកបដោយប្រសិទ្ធភាពនិងបង្កើតបានតម្លៃសេដ្ឋកិច្ចបន្ថែម ជាពិសេសគឺការបង្កើនចំណូលរដ្ឋ។

**ឃ.២. ការិយាល័យថវិការបស់រដ្ឋសភា**

១. *ការពង្រឹងអំណាចរបស់រដ្ឋសភា* ÷ ការិយាល័យថវិការដ្ឋសភា គឺជាអង្គភាពមួយដែលមានតួនាទីដ៏សំខាន់នៅក្នុងការពង្រឹងអំណាចរបស់រដ្ឋសភាជារួមនៅចំពោះមុខរដ្ឋាភិបាល តាមគោលការណ៍ប្រតិតុល្យការ (Check and balances) ជាពិសេស គឺការពង្រឹងតួនាទីរបស់អង្គនីតិប្បញ្ញត្តិនៅក្នុងការផ្តល់មតិលើសេចក្តីព្រាងច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុសាធារណៈ។

២. *ការផ្តល់អនុសាសន៍ទៅរដ្ឋាភិបាល* ÷ NABO គឺជាលេខាធិការរបស់រដ្ឋសភា ដូចនេះមិនអាចនឹងស្នើឱ្យរដ្ឋាភិបាលកែសម្រួលច្បាប់ឬគោលនយោបាយអ្វីនោះឡើយ តែ NABO អាចនឹងផ្តល់អនុសាសន៍បានទៅរដ្ឋាភិបាល ដូចជាអនុសាសន៍លើការកែសម្រួលថវិកា គោលនយោបាយ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ការវាយតម្លៃកម្មវិធី និងវិធានការនានាពាក់ព័ន្ធនឹងតម្លាភាពនិងគណនេយ្យភាពជាដើម។

**ឃ.៣. វិស័យនីតិកម្មកម្ពុជារដ្ឋាភិបាល**

១. *ក្រសួងនីតិកម្មនៃរដ្ឋាភិបាល* ÷ រដ្ឋាភិបាលកូរ៉េប្រើប្រាស់អភិក្រមពីលើមកក្រោម (Top down approach) តែម្តង ដើម្បីធានានិត្យានុកូលភាព ប្រសិទ្ធភាព និងសង្គតិភាពតាមរយៈការបង្កើតជាក្រសួងនីតិកម្មសម្រាប់ធានាគោលការណ៍ទាំងនេះ។ នីតិកម្មជាមុខងារដែលមានសារៈសំខាន់និងមានវិសាលភាពគ្របដណ្តប់ដូចគ្នានឹងមុខងារហិរញ្ញវត្ថុ និងធនធានមនុស្សដែរ ដែលទាមទារឱ្យមានក្រសួងទទួលបន្ទុកច្បាស់លាស់ក្នុងកម្រិតរដ្ឋាភិបាលទាំងមូល។ ក្រសួងនីតិកម្មរបស់រដ្ឋាភិបាលកូរ៉េ ទទួលបន្ទុកលើការងារនីតិកម្មទាំងមូលរបស់រដ្ឋាភិបាល ដោយកំណត់វិធាននិងនីតិវិធីនៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគ្រប់គ្រងនិងសម្របសម្រួល នៅគ្រប់ដំណាក់កាលនៃការរៀបចំបទដ្ឋានគតិយុត្ត ចាប់ពីការរៀបចំផែនការ ការព្រាងខ្លឹមសារ ការអនុម័ត រហូតដល់ការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

២. *ផែនការនីតិកម្មប្រចាំឆ្នាំរបស់រដ្ឋាភិបាល* ÷ មុខងារនីតិកម្ម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងការកំណត់អាទិភាពគោលនយោបាយ។ ជាក់ស្តែង នៅរៀងរាល់ឆ្នាំ ក្រសួងនីតិកម្មរបស់រដ្ឋាភិបាល ដឹកនាំនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នទាំងអស់ ក្នុងការរៀបចំផែនការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវអនុម័តដោយរដ្ឋាភិបាល និងជូនដំណឹងទៅសភា ដើម្បីកំណត់អាទិភាពនៃការរៀបចំបទដ្ឋានគតិយុត្ត ឱ្យមានសង្គតិភាពនៃការអនុវត្តគោលនយោបាយ។

**ឃ.៤. វិស័យមុខងារសាធារណៈ និងការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋាភិបាល**

១. *ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន* ÷ ក្រសួងគ្រប់គ្រងមន្ត្រីរាជការរបស់កូរ៉េ ធ្លាប់ជាប់ចំណាត់ថ្នាក់ទី១ វាយតម្លៃដោយអង្គការ OECD នៅក្នុងឆ្នាំ២០១៧ លើវិស័យទិន្នន័យបុគ្គលិកនៃរដ្ឋាភិបាលថ្នាក់កណ្តាល និងជាប់ចំណាត់ថ្នាក់ទី១ ក្នុងការ

៨

គ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា នៅក្នុងឆ្នាំ២០១៩ ដោយស្ថាប័ន InCise នៃចក្រភពអង់គ្លេស។ តាមរយៈការចាប់យកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង្កើតនូវប្រព័ន្ធជាច្រើនដូចជា e-Saram, PETI ជាដើម ក្រសួងគ្រប់គ្រងមន្ត្រីរាជការរបស់សាធារណរដ្ឋកូរ៉េ ត្រូវបានទទួលស្គាល់ជាសកលថាជាស្ថាប័នគំរូមួយនិងត្រូវបានរៀនសូត្រជាឧត្តមានុវត្តន៍អន្តរជាតិពីអង្គការអន្តរជាតិនិងប្រទេសជាច្រើន។

១០. *ប្រព័ន្ធ e-Saram ÷* ប្រព័ន្ធ e-Saram គឺជាប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលប្រមូលផ្តុំទិន្នន័យចាប់តាំងពីដំណាក់កាលជ្រើសរើស តែងតាំង ចាប់ផ្តើមអាជីពរហូតដល់ការចូលនិវត្តន៍នៃមន្ត្រីរាជការថ្នាក់កណ្តាល។ ប្រព័ន្ធនេះប្រមូលផ្តុំនូវទិន្នន័យទាំងអស់ពាក់ព័ន្ធប្រាក់បៀវត្ស ការវាយតម្លៃសមិទ្ធកម្ម ការបណ្តុះបណ្តាល ការអភិវឌ្ឍសមត្ថភាព និងផលប្រយោជន៍ផ្សេងៗរបស់មន្ត្រីរាជការចំនួន ៣៧០ ០០០ នាក់ដែលធ្វើការនៅក្នុងក្រសួងស្ថាប័នចំនួន ៧៣។ នៅឆ្នាំ២០១៤ ប្រព័ន្ធនេះត្រូវបានពង្រីកឱ្យប្រើបាននៅក្នុងទូរស័ព្ទដៃដែលធ្វើឱ្យមន្ត្រីរាជការអាចប្រើប្រាស់បាននៅគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា។

**ខ. សំណើសម្រាប់ជំហានបន្ត**

ទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េបានទទួលលទ្ធភាពយ៉ាងល្អប្រសើរលើសពីការរំពឹងទុក ជាពិសេសបានផ្តល់ជាធាតុចូលបទពិសោធន៍ល្អៗ និងរបកគំហើញគន្លឹះជាច្រើនសម្រាប់ការពិចារណាសកម្មភាពគន្លឹះៗជាច្រើនក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ ៣ ប្លុក ១ នៅកម្ពុជា។

*នៅក្នុងន័យនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូមគោរពស្នើសុំការពិនិត្យនិងសម្រេចរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ លើលទ្ធភាពសិក្សាលើការរៀបចំកិច្ចសហការក្នុងកម្រិតណាមួយនឹងការរៀបចំដំណើរទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េរបស់ក្រុមការងារម្តងទៀតនាពេលអនាគតជាជំហានបន្តដូចតទៅ÷*

១. ស្នើសុំការពិនិត្យនិងសម្រេចរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឱ្យ អ.គ.ហ. និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនៃកសហវ សិក្សានិងពិនិត្យលទ្ធភាពបង្កើតក្របខ័ណ្ឌកិច្ចសហការក្នុងកម្រិតណាមួយជាមួយនឹងក្រសួងនីតិកម្មរបស់រដ្ឋាភិបាលកូរ៉េ។

២. ស្នើសុំការពិនិត្យនិងសម្រេចជាគោលការណ៍លើការសិក្សានិងពិនិត្យលទ្ធភាពក្នុងការអញ្ជើញតំណាងអគ្គលេខាធិការដ្ឋាននៃរដ្ឋសភានិងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ដើម្បីធ្វើទស្សនកិច្ចសិក្សាទៅកាន់ការិយាល័យថវិកានៃរដ្ឋសភាកូរ៉េ (NABO) នាពេលអនាគត ដោយហេតុថាស្ថាប័នរបស់រដ្ឋសភាកូរ៉េនេះគឺជាស្ថាប័នមានឧត្តមានុវត្តន៍អន្តរជាតិយ៉ាងល្អប្រសើរក្នុងការបំពេញតួនាទីជាលេខាធិការផ្នែកហិរញ្ញវត្ថុសាធារណៈជូនស្ថាប័ននីតិប្បញ្ញត្តិ ដែលនេះគឺជាកាលានុវត្តភាពដើម្បីសិក្សាស្វែងយល់ត្រៀមសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ក្នុងទិសដៅដែលរដ្ឋសភានឹងកាន់តែមានតួនាទីសំខាន់នៅក្នុងការអនុម័តថវិកានិងការត្រួតពិនិត្យថវិកា។

៣. ស្នើសុំរៀបចំទស្សនកិច្ចសិក្សានៅសាធារណរដ្ឋកូរ៉េម្តងទៀត ដើម្បីទៅសិក្សាអំពីស្ថាប័នសវនកម្មកំពូលរបស់កូរ៉េដោយមានសមាសភាពចូលរួមពីតំណាងលេខាធិការដ្ឋានកែទម្រង់ទាំង ៤ និងតួអង្គនិម្មាបនករសំខាន់ៗនៃមុខងារសវនកម្មនិងអធិការកិច្ច ដែលការងារនេះនឹងផ្តល់ធាតុចូលដ៏សំខាន់ដល់ការអនុវត្តសកម្មភាពសុខដុមនីយកម្មមុខងារសវនកម្មនិងអធិការកិច្ចនៅក្នុងក្របខ័ណ្ឌនៃយន្តការសម្របសម្រួល ៣ ប្លុក ១។

៤. ស្នើសុំធ្វើទស្សនកិច្ចសិក្សាជាបន្តនៅសាធារណរដ្ឋកូរ៉េ លើការរៀបចំនិងកិច្ចដំណើរការនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសលើវិមជ្ឈភាពវិមជ្ឈការហិរញ្ញវត្ថុ។

៥

ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣
**អ្នកចុះហត្ថលេខា សរុបគោលនយោបាយការណ៍**

**លី ថ៊ុន**

បានពិនិត្យនិងសូមគោរពជូន
ឯកឧត្តមរដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃ អ.គ.ហ.
ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃ អ.គ.ហ.**

**បណ្ឌិត ហ៊ើល ចរើន**

បានពិនិត្យនិងសូមគោរពជូន
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៣
**រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃ អ.គ.ហ.**

**រស់ សីលវ៉ា**

ថ្ងៃ [illegible] ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ [illegible] ឆ្នាំ២០២៣
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការ**
**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធទី១៥

# ឧបសម្ព័ន្ធទី១៥. របាយការណ៍ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការចក្ខុវិស័យនិងយុទ្ធសាស្ត្រ ស្ដីពី "សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:..........................................

**របាយការណ៍**

**ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ**

**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១"**

កាលពីថ្ងៃពុធ ១៤ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) លេខាធិការ-ដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន **គ.ជ.អ.ប.**) លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (លេខាធិការដ្ឋាន **គ.ក.រ.**) និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (**ល.គ.ច.ប្រ**) បានសហការរៀបចំពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" ក្រោមអធិបតីភាពបើកដ៏ខ្ពង់ខ្ពស់ដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអធិបតីភាពបិទដ៏ខ្ពង់ខ្ពស់បំផុតដោយ **សម្តេចក្រឡាហោម ស ខេង** នាយករដ្ឋមន្ត្រីស្តីទី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង និងមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ពីគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សរុបប្រមាណ ៣៥០ រូប ។

ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនេះត្រូវបានប្រព្រឹត្តទៅពេញមួយថ្ងៃដោយបែងចែកជាពីរវគ្គ គឺវគ្គព្រឹក និងវគ្គរសៀល ដូចតទៅ ៖

**ក - វគ្គព្រឹក**

វគ្គព្រឹកត្រូវបានប្រព្រឹត្តទៅតាម ៤ របៀបវារៈ រួមមាន ទី១) របាយការណ៍គន្លឹះរបស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការនៃ **អ.គ.ហ.**, ទី២) សុន្ទរកថាបើកដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ទី៣) បទបង្ហាញចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" និងទី៤) កិច្ចពិភាក្សាតាមក្រុម ។

**ក.១- កម្មវិធីបើក**

ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការនិងជាអគ្គលេខាធិការនៃ **អ.គ.ហ.** បានថ្លែងរបាយការណ៍គន្លឹះបញ្ជាក់ជូនអង្គពិធីអំពីការរៀបចំឯកសារស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" ដោយបាន...

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧០១ ទូរសារ: ៨៥៥-២៣-៤៣០ ៧..

# 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: 855-23-430 701 Fax: 855-23-430 7..

ឧបសម្ព័ន្ធទី១៥

គូសរំលេចជាសារតារមួយចំនួនថា យន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលត្រូវបានចាប់ផ្តើមអនុវត្តដំបូងពីឆ្នាំ២០១៥ ដែលក្នុងនោះមានការដ្ឋានគន្លឹះ ៣ រួមមាន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ។ យន្តការសម្របសម្រួលនេះផ្តោតលើការរៀបចំឱ្យមានជាវេទិកាប្រជុំប្តូរវេនប្រចាំត្រីមាសរវាងអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានទាំងបី។ ក្រោយមកនៅក្នុងឆ្នាំ២០១៨ តាមរយៈអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ យន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ នេះបានក្លាយទៅជាយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ ៣ បូក ១ ដោយបញ្ចូលកម្មវិធីកែទម្រង់មួយបន្ថែមទៀត គឺកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

បទពិសោធន៍រយៈពេល ៨ ឆ្នាំនៃការអនុវត្តយន្តការសម្របសម្រួលកន្លងមក បានជំរុញអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំង ៤ ឱ្យផ្តួចផ្តើមនិងសាកល្បងបោះជំហានទៅកាន់ដំណាក់កាលមួយកម្រិតទៀត នោះគឺការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមគ្នាមួយ សំដៅមានផែនទីបង្ហាញផ្លូវរួមគ្នាដែលបង្ហាញអំពីទិសដៅនិងសកម្មភាពដែលត្រូវសហការគ្នា សម្របសម្រួល និង/ឬគាំទ្រជូនគ្នាទៅវិញទៅមក ព្រមទាំងបច្ចុប្បន្នកម្មលើយន្តការសម្របសម្រួលដែលមានស្រាប់ ដោយបញ្ចូលលេខាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

**ឯកឧត្តម រស់ សីលវ៉ា** បានសង្កត់ធ្ងន់ថា ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ នេះ មិនត្រូវបានរៀបចំឡើងនៅក្នុងគោលបំណងធ្វើសមាហរណកម្មឬស្ថាប័នភាវូបនីយកម្មនៃការកែទម្រង់រួមគ្នាឡើងវិញនោះឡើយ។ ផ្ទុយទៅវិញ គោលដៅនៃឯកសារនេះគឺជាកំណត់ទស្សនានទ និងជាផែនទីបង្ហាញផ្លូវអំពីយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវធ្វើរួមគ្នាដើម្បីគាំទ្រនិងសហការគ្នាដោយគោរពភាពជាម្ចាស់នៃកម្មវិធីកែទម្រង់នីមួយៗ សំដៅធ្វើឱ្យកិច្ចដំណើរការនិងការអនុវត្តកម្មវិធីកែទម្រង់ទាំង ៤ កាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពបន្ថែមទៀត។

បន្ទាប់មក **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានអញ្ជើញថ្លែងសុន្ទរកថាបើកអង្គពិធី ដោយបានគូសរំលេចអំពីសារតារនៃកិច្ចដំណើរការកែទម្រង់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយភាពឈ្លាសវៃ និងភាពប្រាកដនិយមខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចាប់យកការកែទម្រង់ធ្វើជាយុទ្ធសាស្ត្រគន្លឹះក្នុងការដឹកនាំស្តារនិងកសាងជាតិ ចាប់តាំងពីគ្រាដែលកម្ពុជាបានរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ហើយមកដល់បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តចាត់ទុកការកែទម្រង់ជាអាទិភាពគោល នយោបាយរបស់ខ្លួន ដែលឆ្លុះបញ្ចាំងតាមរយៈការកំណត់ថា "*ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច*" ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ បន្ថែមពីនេះ នៅក្នុងបរិបទសកលលោកនាពេលបច្ចុប្បន្ន ការកែទម្រង់ផ្នែកអភិបាលកិច្ចមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ព្រោះត្រូវពង្រឹងសមត្ថភាពនិងភាពរឹងមាំរបស់ស្ថាប័នសាធារណៈ ក្នុងការឆ្លើយតបដោយវិធានការបង្ការជាបុរេ-សកម្ម បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពចំពោះវិបត្តិជាច្រើនដែលអាចកើតឡើងដោយមិនអាចស្មានទុកបាន ដែលកាន់តែពិបាកដោះស្រាយ និងមានលក្ខណៈកាន់តែស្រួចស្រាលខ្លាំងឡើង។ ៚

ជាចុងក្រោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានផ្តល់អនុសាសន៍ឬអភិក្រមគន្លឹះចំនួន ៤ ដើម្បីជាអាតិសម្រេចឱ្យបាននូវចក្ខុវិស័យ "**សុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១**" និង បេសកកម្ម "**ធានាសង្គតិភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ប្លុក ១**" ជូនអង្គពិធី ដូចតទៅ៖

***ទី១) អភិក្រមរក្សាត់ហើញទាំងមូល*** ដែលសំដៅយល់ប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងដោយមិនអាចខ្វះបាននៅក្នុងបរិយាកាសរួមនៃការកែទម្រង់។ ឧទាហរណ៍ ការផ្ទេរមុខងារតម្រូវឱ្យពិនិត្យនិងរៀបចំជាវិធាននិងនីតិវិធីជាគញ្ចប់ក្នុងពេលតែមួយ ជាមួយនឹងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ការពិនិត្យទិដ្ឋភាពក្របខ័ណ្ឌស្ថាប័ន ច្បាប់និងនីតិវិធី និងប្រព័ន្ធយុត្តិធម៌។ល។

***ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី*** សំដៅលើកម្មវិធីកែទម្រង់នីមួយៗត្រូវបំពេញឱ្យគ្នាមិនអាចខ្វះបាន តាមតួនាទី និងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

***ទី៣) អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ*** គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផង និងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀត។

***ទី៤) អភិក្រមបុរេសកម្ម*** គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហាឬទប់ស្កាត់បញ្ហាមិនឱ្យកើតមានតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

**ក.២ បទបង្ហាញគន្លឹះ**

ជារបៀបវារៈបន្ត **ឯកឧត្តមបណ្ឌិត វ៉ោហ៊ល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** បានធ្វើបទបង្ហាញគន្លឹះជូនអង្គពិធីដោយគូសរំលេចជាខ្លឹមសារនិងទស្សនាទានជារួមនៃឯកសារ ដោយផ្តោតលើ ចក្ខុវិស័យ បេសកកម្ម អភិក្រម និងយុទ្ធសាស្ត្រ ដែលមានដូចតទៅ៖

- ➢ *ចក្ខុវិស័យ*៖ សុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១
- ➢ *បេសកកម្ម*៖ ធានាសង្គតិភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងនិងសម្របសម្រួលកម្មវិធីកែទម្រង់ ៣ ប្លុក ១
- ➢ *អភិក្រម*៖ ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីស័ក្តិសិទ្ធភាពនិងសុខដុមនីយកម្មនៃការកែទម្រង់ទាំង៤
- ➢ *យុទ្ធសាស្ត្រ*៖ មានចំនួន ៣ រួមមាន ទី១) សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ ប្លុក, ទី២) សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម និងទី៣) ខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ៣ ប្លុក ១។

**ក.៣ កិច្ចពិភាក្សាតាមក្រុម**

បន្ទាប់ពីស្តាប់បទបង្ហាញគន្លឹះ សមាជិកនៃអង្គពិធីទាំងមូលត្រូវបានបែងចែកជាក្រុមពិភាក្សាចំនួន ៣ ផ្តោតលើសកម្មភាពដែលបានកំណត់ក្រោមយុទ្ធសាស្ត្រនីមួយៗ ដោយមានការសម្របសម្រួលដោយតំណាងអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាន ៣ ប្លុក ១ ដូចខាងក្រោម៖

- ➢ ក្រុមទី១ ទទួលបន្ទុកយុទ្ធសាស្ត្រទី១ "**សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់**" សម្របសម្រួលដោយតំណាងលេខាធិការដ្ឋាន **គ.ជ.ក.ប.** និង **ល.ច.ប្រ**។

គ

ឧបសម្ព័ន្ធទី១៩

- ក្រុមទី២ ទទួលបន្ទុកយុទ្ធសាស្ត្រទី២ "**សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម**" សម្របសម្រួលដោយ លេខាធិការដ្ឋាន **គ.គ.វ.** ។
- ក្រុមទី៣ ទទួលបន្ទុកយុទ្ធសាស្ត្រទី៣ "**សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់**" សម្របសម្រួលដោយ **អ.គ.ម.** ។

**ខ- ចន្លោះសៀវភៅ**

វគ្គសៀវភៅត្រូវបានប្រព្រឹត្តទៅតាមរបៀបវារៈ ៣ រួមមាន ទី១) បទបង្ហាញកិច្ចពិភាក្សានិងការបូកសរុបលទ្ធផលរួម, ទី២) របាយការណ៍បូកសរុបរបស់ **ឯកឧត្តមបណ្ឌិត ង៉ោល ចំរើន** រដ្ឋលេខាធិការនិងជាអគ្គលេខាធិការរងនៃ **អ.គ.ម.** និងទី៣) សុន្ទរកថាបិទរបស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រីស្តីទី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**ខ.១ ការបង្ហាញ បូកសរុប និងរាយការណ៍លទ្ធផលនៃកិច្ចពិភាក្សា**

លទ្ធផលនៃកិច្ចពិភាក្សាតាមក្រុមនីមួយៗត្រូវបានបង្ហាញដោយតំណាងអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋាន ៣ បូក ១ ដោយមានការសម្របសម្រួលរួមដោយ **ឯកឧត្តមបណ្ឌិត ង៉ោល ចំរើន** រដ្ឋលេខាធិការនិងជាអគ្គលេខាធិការរងនៃ **អ.គ.ម.**។ អង្គពិធីទាំងមូលបានពិនិត្យនិងពិភាក្សាលើលទ្ធផលគន្លឹះនៃកិច្ចពិភាក្សានីមួយៗ ដែលត្រូវបានបូកសរុបនិងគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចតទៅ៖

- ***ក្រុមទី១ ទទួលបន្ទុកយុទ្ធសាស្ត្រទី១*** បានផ្តោតសំខាន់លើសុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ បានពិភាក្សាអំពីការផ្ទេរមុខងារទាំង៥៥ ជូនរដ្ឋបាល ក្រុង/ស្រុក/ខណ្ឌ ការគាំទ្រហិរញ្ញវត្ថុ ធនធានមនុស្ស ការរៀបចំកញ្ចប់ថវិកាគាំទ្រ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ក្រុង/ស្រុក/ខណ្ឌ ការផ្ទេរមុខងារនៅក្នុងលិខិតបទដ្ឋាន ព្រមទាំងស្ថានភាពនៃការអនុវត្តជាក់ស្តែងដែលមានតម្លាភាពនៃបន្ទាត់គណនេយ្យភាពនៃរដ្ឋបាលរាជធានីខេត្តចំពោះការអនុវត្តមុខងារ ។
- ***ក្រុមទី២ ទទួលបន្ទុកយុទ្ធសាស្ត្រទី២*** ស្តីពីសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្មបានពិភាក្សាអំពីបរិមាណនិងសមត្ថភាពនៃអង្គភាពថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សុខដុមនីយកម្មនៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាពលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការយល់ដឹង ឆន្ទៈកែទម្រង់ក៏ដូចជាសមត្ថភាពជំនាញលើការងារកែទម្រង់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិនិងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ***ក្រុមទី៣ ទទួលបន្ទុកយុទ្ធសាស្ត្រទី៣*** សុខដុមនីយកម្មប្រព័ន្ធដំណើរការកែទម្រង់ ដោយផ្តោតសំខាន់ លើការគាំទ្ររបស់យន្តការសម្របសម្រួល ៣ បូក ១ នៅដល់ក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ ក្រោមជាតិ គិតអំពីសមត្ថភាពជំនាញ យន្តការលើកទឹកចិត្ត ស្មារតីទទួលខុសត្រូវ ដោយពិនិត្យនិងចុះទស្សនកិច្ចសិក្សាដោយផ្ទាល់រួមគ្នាទាំង ៤ ការដ្ឋានកែទម្រង់ នៅនឹងក្រសួង ស្ថាប័ន ក៏ដូចជានៅរដ្ឋបាលថ្នាក់ក្រោមជាតិជាអាទិភាពមួយចំនួនដែលអាចមានតម្រូវការចាំបាច់ និងតាមស័ណ្ឋានជាក់ស្តែង ។

៤

**១.២ កម្មវិធីបិទ**

បន្ទាប់ពីបានស្តាប់របាយការណ៍បូកសរុបរួចមក **សម្តេចក្រឡាហោម ស ខេង** រដ្ឋមន្ត្រីស្តីទី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានអញ្ជើញថ្លែងសុន្ទរកថាបិទ ដោយបានវាយតម្លៃខ្ពស់ចំពោះក្រុមការងារអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំង ៤ ដែលបានសហការយ៉ាងជិតស្និទ្ធ រហូតសម្រេចបាននូវឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ នេះ ប្រកបដោយជោគជ័យ។ **សម្តេចក្រឡាហោម** ក៏បានសង្កត់ធ្ងន់ថា កំណែទម្រង់ទាំង៤ ដែលជាកំណែទម្រង់ផ្នែកអភិបាលកិច្ចនិងមានចរិតឆ្លងវិស័យ ហេតុនេះកំណែទម្រង់អន្តរវិស័យពិតជាមានភាពស្មុគស្មាញទាំងក្នុងការរៀបចំ និងការអនុវត្ត។ ដូចនេះដើម្បីសម្រេចបាននូវគោលបំណងរួម ចាំបាច់ត្រូវប្រកាន់យកបុរេលក្ខខណ្ឌមួយចំនួនដូចជា៖

១. *ការបន្តរក្សាឱ្យបាននូវសន្តិភាព ស្ថេរភាពនយោបាយ និងការពង្រឹងបាននូវប្រជាធិបតេយ្យ*៖ ព្រោះថាបើគ្មានសន្តិភាព គ្មានស្ថេរភាពនយោបាយ និងគ្មានប្រជាធិបតេយ្យ នោះរាជរដ្ឋាភិបាលពុំអាចរៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយជោគជ័យបានដែរ។

២. *ឆន្ទៈផ្នែកនយោបាយរបស់រាជរដ្ឋាភិបាល*៖ ការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងសាធារណៈជាកិច្ចការស្មុគស្មាញ ស្មុគស្មាញ ដែលនឹងមានផលប៉ះពាល់ទាំងទៅលើផ្នែកបុគ្គល និងផ្នែកស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវការពេលវេលាពីមធ្យមទៅវែង។ ដូចនេះ ការតាំងចិត្តផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលជារឿងចាំបាច់ ដើម្បីប្រសិទ្ធភាពនៃការអនុវត្តការកែទម្រង់។

៣. *ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ*៖ កំណែទម្រង់ទាំង៤ ជាកំណែទម្រង់ពាក់ព័ន្ធទាំងផ្នែករដ្ឋបាលនិងផ្នែកនយោបាយ និងមានផលប៉ះពាល់ទាំងនៅក្នុងស្ថាប័នរដ្ឋនិងស្ថាប័នមិនមែនរដ្ឋ។ ដូចនេះ ជោគជ័យនៃកំណែទម្រង់ គឺអាស្រ័យដោយការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន សហគមន៍មូលដ្ឋាន និងសាធារណជនទូទៅ។

៤. *ភាពស៊ីសង្វាក់ ភាពប្រទាក់ក្រឡាគ្នា និងសុខដុមនីយកម្ម* រវាងកម្មវិធីកំណែទម្រង់ទាំង ៤ ដែលចាំបាច់ត្រូវបំពេញឱ្យគ្នា និងគាំទ្រគ្នាទៅវិញទៅមក។

មុននឹងបញ្ចប់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រីស្តីទី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្តល់អនុសាសន៍គន្លឹះៗជាប្រទីបបំភ្លឺផ្លូវសម្រាប់ការអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" ដូចតទៅ ៖

**ទី១)** អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួន ត្រូវបន្តកិច្ចសហការគ្នាក្នុងការរៀបចំ និង អនុវត្តផែនការសកម្មភាពរួមនៃកំណែទម្រង់ទាំងបួនឱ្យកាន់តែមានភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ផ្អែកតាមយុទ្ធសាស្ត្រនិងអភិក្រមដែលបានកំណត់ក្នុងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**"។

**ទី២)** អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួនត្រូវរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នេះឱ្យបានទៀងទាត់តាមពេលវេលាដែលបានកំណត់ ដើម្បីតាមដាន ត្រួតពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាពរួម និងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា ព្រមទាំងធ្វើសេចក្តីរាយការណ៍ ជូនគណៈកម្មាធិការសាមីនីមួយៗជាប្រចាំតាមគោលការណ៍កំណត់ ។ ✕

៩

**ទី៣)** ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធត្រូវរៀបចំឱ្យមានយន្តការរួមមួយនៅក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនិមួយៗ សម្រាប់ដឹកនាំ សម្របសម្រួលនិងគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាពរួមប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ស្នូលទាំងបួនប្រកបដោយប្រសិទ្ធភាពជាជាងការរៀបចំបង្កើតនូវយន្តការសម្រាប់ដឹកនាំ សម្របសម្រួល និងគាំទ្រកម្មវិធីកំណែទម្រង់នីមួយៗ ដាច់ដោយឡែកៗពីគ្នា ។

**ទី៤)** ពិនិត្យលទ្ធភាពផ្ដល់ការគាំទ្រធនធាន មធ្យោបាយដល់កម្មវិធីកំណែទម្រង់នីមួយៗឱ្យបានសមស្រប និងស្នើសុំដល់ឯកឧត្ដម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំនិងជាមន្ត្រីនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបន្តផ្ដល់ការគាំទ្រ និងចូលរួមក្នុងកិច្ចដំណើរការនៃកំណែទម្រង់ស្នូលទាំង៤ របស់រាជរដ្ឋាភិបាលឱ្យកាន់តែសកម្មបន្ថែមទៀត ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងរួមនៃកំណែទម្រង់ទាំងនេះ គឺការពង្រឹងគុណភាពអភិបាលកិច្ចដើម្បីបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា ឱ្យបានកាន់តែប្រសើរឡើង។

**ទី៥)** អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួន ត្រូវបន្តសហការគ្នាក្នុងការផ្សព្វផ្សាយ កៀរគរការចូលរួម និងគាំទ្រពីក្រសួងស្ថាប័ន ព្រមទាំងស្ថាប័នមិនមែនរដ្ឋាភិបាលរួម មានដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន សហគមន៍មូលដ្ឋាននិង សាធារណជនទូទៅ ។

ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពី "**សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" បានបញ្ចប់នៅវេលាម៉ោង ៥ ល្ងាច ក្នុងថ្ងៃដដែល ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរតាមការរំពឹងទុក ក្នុងបរិយាកាសសាមគ្គីភាព និងភាតរភាពពីគ្រប់ការដ្ឋានកែទម្រង់និងភាគីពាក់ព័ន្ធ ។

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែមិគសិរ ឆ្នាំខាល ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២
អ្នករៀបចំរបាយការណ៍
**មន្ត្រីជំនាញ**

**បណ្ឌិត ឆាយ សម្បត្តិ**

បានពិនិត្យ និងសូមគោរពជូន
**ឯកឧត្តមអគ្គលេខាធិការ នៃ គ.ក.ហ.**
ថ្ងៃ ពុធ ៤ កើត ខែ បុស្ស ឆ្នាំខាល ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២២
**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការរង នៃ គ.ក.ហ.**

**បណ្ឌិត ម៉ៅ ចំរើន**

បានពិនិត្យនិងសូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ............ ខែ បុស្ស ឆ្នាំខាល ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃ អ.គ.ហ.**

**សេ សីលហ៊ា**

........................................................................................

ថ្ងៃ ខែមិគសិរ ឆ្នាំខាល ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ឧបសម្ព័ន្ធទី១៩**

# ឧបសម្ព័ន្ធទី១៦

# ឧបសម្ព័ន្ធទី១៦. របាយការណ៍ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការស្នើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងឯកសារ "ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ បី បូក មួយនិងសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់ បី បូក មួយ និង សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមយកម្មការកែទម្រង់បីបូកមួយ"

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
លេខ: ០៣៤ លស គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**តាមរយៈ**÷ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ។

**កម្មវត្ថុ** ÷ សំណើសុំការពិនិត្យ និងសម្រេចលើសេចក្តីព្រាងឯកសារ "ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយ សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់បីបូកមួយ និងសេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយ"។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា ចាប់តាំងពីឆ្នាំ២០១៥មក គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឯកភាព និងរៀបចំឱ្យមានយន្តការរួមគ្នារវាងលេខាធិការដ្ឋាននៃកំណែទម្រង់ទាំងបី ដើម្បីសហការ គាំទ្រ និងសម្របសម្រួលលើការអនុវត្តការងារកំណែទម្រង់ទាំងបីឱ្យមានសង្គតិភាព និងសុខដុមនីយកម្មជាមួយគ្នា តាមរយៈការរៀបចំកិច្ចប្រជុំប្តូរវេនប្រចាំត្រីមាសជាទៀងទាត់។ នៅឆ្នាំ២០១៨ អនុវត្តតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** យន្តការសម្របសម្រួលកំណែទម្រង់ទាំងបីក៏បានដាក់បញ្ចូលលេខាធិការដ្ឋានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បន្ថែមទៀត និងបានកែសម្រួលទៅជា "**យន្តការសម្របសម្រួលកំណែទម្រង់បីបូកមួយ**"។

ដោយសារកំណែទម្រង់ទាំង៤ បានឈានចូលដល់ដំណាក់កាលកាន់តែមានភាពស៊ីជម្រៅ ស្មុគស្មាញ និងប្រទាក់ក្រឡាគ្នាកាន់តែខ្លាំងឡើង និងដោយផ្អែកលើចក្ខុវិស័យនៃកម្មវិធីកំណែទម្រង់នីមួយៗ លេខាធិការដ្ឋាននៃកំណែទម្រង់ទាំងបួនបានរួមគ្នាសិក្សា និងរៀបចំឯកសារ**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយ**សម្រាប់ជាផែនទីបង្ហាញផ្លូវដោយកំណត់អំពីយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពជាអាទិភាពដែលត្រូវសហការ គាំទ្រ និងរួមគ្នាអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃកម្មវិធីជាតិនីមួយៗ និងការគោរពភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់គណៈកម្មាធិការកំណែទម្រង់នីមួយៗ សំដៅជំរុញកិច្ចដំណើរការនៃកំណែទម្រង់ទាំង៤សម្រេចបាននូវសមិទ្ធផលនានាប្រកបដោយប្រសិទ្ធភាព។ ដើម្បីធានាដល់ការអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយនេះ លេខាធិការដ្ឋាននៃកំណែទម្រង់ទាំង៤ក៏បានរៀបចំសេចក្តីព្រាងផែនការសកម្ម

ឧបសម្ព័ន្ធទី១៦

ភាពស្ដីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយសម្រាប់អនុវត្តក្នុងរយៈពេល៣ឆ្នាំដំបូង (២០២៣-២០២៥)ផងដែរ។

ជាមួយគ្នានេះដែរ លេខាធិការដ្ឋាននៃគណៈកម្មាធិការកំណែទម្រង់ទាំង៤ក៏បានរៀបចំកែសម្រួលឡើងវិញនូវយន្តការសម្របសម្រួលការងារកែទម្រង់បីបូកមួយ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់យន្តការនេះ តាមរយៈការរៀបចំជាសេចក្ដីព្រាងអនុក្រឹត្យស្ដីពីយន្តការសម្របសម្រួលកំណែទម្រង់បីបូកមួយជំនួសសេចក្ដីសម្រេចរួមស្ដីពីការបង្កើតយន្តការសម្របសម្រួលបីបូកមួយ។

សេចក្ដីព្រាងឯកសារទាំង៣នេះត្រូវបានប្រជុំពិភាក្សារួមគ្នាជាច្រើនលើកច្រើនសារ តាមរយៈកិច្ចប្រជុំផ្ទៃក្នុងនៃលេខាធិការដ្ឋានកែទម្រង់នីមួយៗ កិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់បីបូកមួយ ការធ្វើបេសកកម្មរួមគ្នានៃលេខាធិការដ្ឋានកំណែទម្រង់បីបូកមួយ និងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ដែលមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធមួយចំនួន។

លេខាធិការដ្ឋានគ.ជ.អ.ប. សូមគោរពរាយការណ៍ជូន **សម្ដេច** ដោយសង្ខេបអំពីខ្លឹមសារនៃសេចក្ដីព្រាងឯកសារទាំង៣នេះ ដូចខាងក្រោម៖

**១. អំពីឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយ**

ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់បីបូកមួយ ត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យមានសុខដុមនីយកម្មកំណែទម្រង់បីបូកមួយ សំដៅធានាសង្គតិភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ទាំង៤។ ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រនេះបានឆ្លុះបញ្ចាំងអំពីក្របខណ្ឌស្ថាប័ន ការទទួលខុសត្រូវ និងចក្ខុវិស័យតាមកម្មវិធីកំណែទម្រង់នីមួយៗ អំពីសមិទ្ធផល និងបញ្ហាប្រឈមចម្បងៗតាមកម្មវិធីកំណែទម្រង់នីមួយៗ ព្រមទាំងកំណត់អំពីយុទ្ធសាស្ត្រចំនួន៣ និងកម្មវិធីចំនួន១២ ដែលត្រូវសហការ និងរួមគ្នាអនុវត្ត រួមមានដូចខាងក្រោម៖

- **យុទ្ធសាស្ត្រទី១៖ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់៣បូក១** មាន៤កម្មវិធី រួមមាន៖
  - ១. ការកំណត់ និងការរៀបចំមុខងារនិងរចនាសម្ព័ន្ធ
  - ២. ការកំណត់ ការរៀបចំ និងការសម្របសម្រួលការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
  - ៣. ការកំណត់ ការរៀបចំ និងការសម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស
  - ៤. ការកំណត់ ការរៀបចំ និងការសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។
- **យុទ្ធសាស្ត្រទី២៖ សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** មាន៤កម្មវិធី រួមមាន៖
  - ១. ការរៀបចំ និងការសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា
  - ២. ការរៀបចំ និងការសម្របសម្រួលការងារសេវនកម្ម និងអធិការកិច្ច
  - ៣. ការពិនិត្យ ការតាមដាន និងការវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់៣បូក១
  - ៤. ការរៀបចំ និងការសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ននិងគុណភាពសេវាសាធារណៈ។

2

- **យុទ្ធសាស្ត្រទី៣៖ សម្របសម្រួលការងារគាំទ្រកម្មវិធីកែទម្រង់៣ប្ញក១** មាន៤កម្មវិធី រួមមាន៖
  ១. ការរៀបចំ និងការសម្របសម្រួលកិច្ចដំណើរការ និងការគាំទ្រកម្មវិធីកែទម្រង់ ៣ប្ញក១
  ២. ការរៀបចំ និងការសម្របសម្រួលការអភិវឌ្ឍសមត្ថភាព និងចំណេះដឹងអំពីកម្មវិធីកែទម្រង់ ៣ ប្ញក១
  ៣. ការរៀបចំ និងការសម្របសម្រួលវិធានការនិង/យន្តការលើកទឹកចិត្តនិងស្មារតីទទួលខុសត្រូវ
  ៤. ការរៀបចំ និងការសម្របសម្រួលទស្សនកិច្ចនៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស។

**២. សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការកែទម្រង់បីប្ញកមួយ**

សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការកែទម្រង់បីប្ញកមួយត្រូវបានរៀបចំឡើងសម្រាប់រយៈពេលបីឆ្នាំដំបូង (ចាប់ពីឆ្នាំ២០២៣ដល់ឆ្នាំ២០២៥) ដើម្បីធានាដល់ការអនុវត្ត ការសម្រេចបាននូវយុទ្ធសាស្ត្រទាំង៣ និងកម្មវិធីទាំង១២ដែលបានកំណត់ក្នុងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់បីប្ញកមួយ។ ផែនការសកម្មភាពនេះមានសកម្មភាពជាអាទិភាពដែលមានភាពប្រទាក់ក្រឡាគ្នារវាងកំណែទម្រង់ទាំង៤ សរុបចំនួន៥៤សកម្មភាព ដែលក្នុងនោះសកម្មភាពជាអាទិភាពចំនួន០៩ត្រូវដឹកនាំសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋានគ.ជ.អ.ប.។

**៣. អំពីសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់បីប្ញកមួយ**

សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់បីប្ញកមួយត្រូវបានរៀបចំឡើងរួមមាន៤ជំពូក និង១៣មាត្រា ដោយបានកំណត់អំពីការបង្កើតឡើងនូវយន្តការសម្របសម្រួលកំណែទម្រង់៣ប្ញក១ កំណត់អំពីមុខងារ ភារកិច្ច ការទទួលខុសត្រូវ និងកិច្ចដំណើរការការងាររបស់យន្តការកំណែទម្រង់៣ប្ញក១។

ជារួម សេចក្តីព្រាងឯកសារទាំង៣ខាងលើនេះមានការពិភាក្សា ការពិគ្រោះយោបល់ និងការឯកភាពគ្នាក្នុងចំណោមលេខាធិការដ្ឋាននៃកំណែទម្រង់ទាំង៤ និងមានខ្លឹមសារស្របតាមចក្ខុវិស័យ គោលបំណង និងគោលដៅនៃកម្មវិធីជាតិនៃកំណែទម្រង់នីមួយៗ។

អាស្រ័យហេតុនេះ លេខាធិការដ្ឋានគ.ជ.អ.ប សូមគោរពស្នើសុំ **សម្តេចក្រឡាហោម** មេត្តាពិនិត្យ និងផ្តល់ការឯកភាពលើឯកសារទាំង៣នេះដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់។

សូមគោរពជូនភ្ជាប់មកជាមួយនូវ៖

- សេចក្តីព្រាងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់បីប្ញកមួយ
- សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការកែទម្រង់បីប្ញកមួយ
- សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលកំណែទម្រង់បីប្ញកមួយ។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

ទាន់ សុថា



ឧបសម្ព័ន្ធទី១៦

# ឧបសម្ព័ន្ធទី១៧

# ឧបសម្ព័ន្ធទី១៧. របាយការណ៍ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ស្តីពី លទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មកែទម្រង់ ៣ ប្លុក ១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ.........................

*ថ្ងៃចន្ទ ៧ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២*

សូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ÷** សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ស្តីពីចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយក-រដ្ឋមន្ត្រី** និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ នៅសណ្ឋាគារសុខាភ្នំពេញ **សិក្ខាសាលាពិគ្រោះយោបល់ស្តីពីចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១** ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាមួយនឹងលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀតដែលរួមមានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**), លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.ស.**) និងលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (**គ.ច.ប្រ.**)។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពបើកដោយឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន **គ.ច.ប្រ.** និងក្រោមអធិបតីភាពបិទដោយឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មា-ធិការកែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងមានការចូលរួមជាសិក្ខាកាមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ទាំង ៤, ក្រសួង-ស្ថាប័ន មន្ទីរ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សរុបប្រមាណ ២៥០ រូប។

សិក្ខាសាលារយៈពេលមួយថ្ងៃពេញនេះ ត្រូវបានរៀបចំដោយមានកិច្ចពិភាក្សាពេញអង្គនិងកិច្ចពិភាក្សាលម្អិតតាមក្រុម ដោយទទួលបានលទ្ធផល ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យនិងសម្រេចដូចតទៅ ÷

**ក. សាវតារនិងគោលបំណង**

សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានរៀបចំឡើងផ្អែកតាមស្មារតីនៃការឯកភាពក្នុងកិច្ចប្រជុំនិងវិបស្សនាជាបន្តបន្ទាប់នៃយន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ ក្នុងពេលកន្លងមក ដែលធ្លាប់ត្រូវបានរៀបចំចំនួន ៤ លើករួចមកហើយ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

ជាក់ស្តែង នៅមុនសិក្ខាសាលាពិគ្រោះយោបល់នេះ **អ.គ.ម.** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងអគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចប្រជុំនៃយន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ ប្លុក ១ សរុបចំនួន ២ លើកបន្ថែមទៀត។ កិច្ចប្រជុំទាំង ២ លើកនេះ បានទទួលលទ្ធផលជាសារវន្តនិងបានទទួលនូវមតិយោបល់កែលម្អបន្ថែមពីអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត ទាំងផ្ទាល់មាត់និងជាលាយលក្ខណ៍អក្សរផងដែរ ដែលធ្វើឱ្យឯកសារទាំងអស់នេះ កាន់តែមានភាពគ្រប់ជ្រុងជ្រោយ។

សិក្ខាសាលាពិគ្រោះយោបល់ ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបានមតិយោបល់និងធាតុចូលគន្លឹះពីគ្រប់តួអង្គពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបន្ថែមទៀត ទៅលើឯកសារគន្លឹះចំនួន ៣ ដែលរួមមាន÷

- *សេចក្តីព្រាងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ បី ប្លុក មួយ*
- *សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ បី ប្លុក មួយ*
- *សេចក្តីព្រាងផែនការសកម្មភាពស្តីពីសុខដុមនីយកម្មការកែទម្រង់ បី ប្លុក ១។*

**ខ. កិច្ចដំណើរការនិងការបូកសរុបលទ្ធផលគន្លឹះ**

បន្ទាប់ពីបានស្តាប់បទបង្ហាញ ពិភាក្សាតាមក្រុម និងការបង្ហាញលទ្ធផលតាមក្រុមនីមួយៗរួចមក អង្គសិក្ខាសាលាបានពិភាក្សារួមនិងមានការបូកសរុបគន្លឹះជាលទ្ធផលដូចតទៅ÷

- ឯកភាពលើសំណើកែសម្រួលលើសេចក្តីព្រាងឯកសារចក្ខុវិស័យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងផែនការសកម្មភាព ដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាតាមក្រុមនិងកិច្ចពិភាក្សារួមនៅក្នុងសិក្ខាសាលា
- ឯកភាពលើការពិនិត្យលទ្ធភាពសិក្សាយកស្តង់ដារប្រតិបត្តិរបស់ **អ.គ.ម.** ជាលំនាំនៃការរៀបចំនិងអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការងារកែទម្រង់ ៣ ប្លុក ១
- ឯកភាពលើសំណើឱ្យអគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវមានផែនការសកម្មភាពផ្ទាល់របស់ខ្លួនរៀងៗខ្លួន ដើម្បីគាំទ្រផែនការសកម្មភាពរួម
- ស្មារតីនៃយន្តការសម្របសម្រួលការងារកែទម្រង់ ៣ ប្លុក ១ គឺ "រក្សាភាពជាម្ចាស់ បង្កើនកិច្ចសហការ"។

**គ. សំណើសុំការសម្រេច**

ជាជំហានបន្ទាប់ ដោយអនុវត្តតាមការសម្រេចរបស់កិច្ចប្រជុំជាបន្តបន្ទាប់ និងការឯកភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** អ.គ.ម. នឹងត្រូវរៀបចំបូកសរុបឯកសារគន្លឹះទាំង ៣ ខាងលើ ឱ្យរួចរាល់នៅក្នុងអំឡុងនៃវិច្ឆិកានេះ។ ឯកសារនេះនឹងត្រូវដាក់ឱ្យអនុវត្តដោយបុព្វកថាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងត្រូវផ្សព្វផ្សាយក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តដែលគ្រោងនឹងរៀបចំនៅក្នុងខែធ្នូខាងមុខនេះ។

ក្នុងន័យនេះ ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការរៀបចំការងារនេះ, **អ.គ.ម.** សូមគោរពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាពិនិត្យនិងសម្រេចលើចំណុចដូចតទៅ ÷

- *សូមគោរពអញ្ជើញ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ជាអធិបតីបើកពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១ ដោយស្នើសុំកំណត់យកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ឬនៅកាលបរិច្ឆេទផ្សេងទៀតនៅក្រោយកាលបរិច្ឆេទស្នើខាងលើ តាមការកំណត់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ***
- *សូមគោរពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ចុះហត្ថលេខាលើលិខិតគោរពអញ្ជើញ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីបិទនៃពិធីប្រកាសខាងលើ។*

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

២

សូម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការកិច្ចដ៏ខ្ពង់ខ្ពស់ពិនិត្យ

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

និងជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**បណ្ឌិត ហ៊ើល ចំរើន**

បានពិនិត្យនិងសូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពិនិត្យនិងសម្រេច

ថ្ងៃ ពុធ ៩ កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២២

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី 6 ខែ 11 ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៥

ឧបសម្ព័ន្ធទី១៧

# ឧបសម្ព័ន្ធទី១៨

# ឧបសម្ព័ន្ធទី១៨. របាយការណ៍ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃវិបស្សនាលើកទី២ នៃកម្មវិធីកែទម្រង់ ៣ បូក ១



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:........................................

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ២០២២

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ** ÷ សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃវិបស្សនាលើកទី២ នៃកម្មវិធីកែទម្រង់ ៣ បូក ១។
**យោង** ÷ ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ លើរបាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថាកាលពីថ្ងៃទី១៣ និងទី១៤ ខែកញ្ញា ឆ្នាំ២០២២ ខ្ញុំបានរៀបចំនិងដឹកនាំវិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១ នៅខេត្តសៀមរាបជាមួយនឹង **ឯកឧត្តម ចាន់ សុផា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) **ឯកឧត្តម ហួត ស៊ីនាដ** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.រ.) និង **ឯកឧត្តម ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ ព្រមទាំងអង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងយុត្តិធម៌ផងដែរ។

វិបស្សនានេះ ត្រូវបានរៀបចំក្នុងគោលបំណងពិនិត្យនិងពិភាក្សាលើរបៀបវារៈដូចតទៅ÷

១. សេចក្តីព្រាងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
២. សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១
៣. ផ្សេងៗ។

វិបស្សនា បានរៀបចំប្រព្រឹត្តទៅ ស្របតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ÷

**ក. មតិពិភាក្សាគន្លឹះរបស់អង្គវិបស្សនា**

សម្រាប់ព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ជាការបើកអង្គវិបស្សនា និងមានការធ្វើបទបង្ហាញដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃ អ.គ.ហ. លើប្រធានបទចំនួន២ (ទី១). សេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រសុខដុមនីយកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ការកែទម្រង់ ៣ ប្លុក ១ និងទី២). សេចក្តីព្រាងអនុក្រឹត្យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១។ ធាតុចូលនេះ អង្គវិបស្សនា ត្រូវបានពិភាក្សានិងលើកជាមតិ ដូចតទៅ÷

- **អ.គ.ម.** បានស្នើពិនិត្យលើវេទយិតភាពនៃការប្រើប្រាស់ពាក្យពេចន៍ "គោលការណ៍វិមជ្ឈការកែទម្រង់" ដោយគួរប្រើប្រាស់ពាក្យ "**ពង្រឹងភាពជាម្ចាស់នៃការទម្រង់**"។ លើសពីនេះទៅទៀត ឯកសារពុំគួរផ្តោតលើឯកសារឆ្នាំ២០១៨ របស់ធនាគារពិភពលោក ក្នុងន័យរក្សាភាពជាម្ចាស់នៃឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រនេះ និងម្យ៉ាងវិញទៀតក្នុងឆ្នាំ២០១៨ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ខ្ពង់ខ្ពស់ផងដែរនូវសារៈសំខាន់នៃភាពត្រទាក់ក្រឡានៃកម្មវិធីកែទម្រង់ទាំង ៣ និងផ្តល់អនុសាសន៍បញ្ចូលកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ទៅជាកម្មវិធីកែទម្រង់ ៣ ប្លុក ១។
- **ឯកឧត្តម ចាន់ សុធា** អនុរដ្ឋលេខាធិការនិងជាអនុប្រធានលេខាធិការដ្ឋាន **គ.ជ.អ.ម.** បានស្នើក្រុមការងារ **អ.គ.ម.** ទទួលបន្ទុករៀបចំសេចក្តីព្រាងបុព្វកថារបស់ **សម្តេចតេជោ** សម្រាប់ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងបានស្នើការរៀបចំលំដាប់មាតិកានុក្រមជាថ្មីក្នុងចំណុច I។ ឯកឧត្តមក៏បានមានមតិលើសេចក្តីព្រាងអនុក្រឹត្យផងដែរលើទម្រង់ និងខ្លឹមសារមួយចំនួនផងដែរ។
- **ឯកឧត្តម ហ្វូត ស៊ីនាដ** រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន **គ.ក.រ.** បានមានមតិលើកឡើងអំពីភាពចាំបាច់បញ្ជាក់ឱ្យកាន់តែច្បាស់លើការរៀបចំឱ្យមាននិងការតែងតាំងមន្ត្រីបង្គោលបច្ចេកទេស ពោលគឺតម្រូវជាមន្ត្រីក្រៅពីលេខាធិការដ្ឋានកែទម្រង់ឬយ៉ាងណា។
- **ឯកឧត្តម ជិន ម៉ាលីន** រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារ **អ.គ.ម.** ដែលបានសម្រេចចេញជាឯកសារសម្រាប់វិបស្សនានេះឡើង និងបានលើកឡើងអំពីសកម្មភាពប្រទាក់ក្រឡាមួយចំនួនមានលក្ខណៈទ្វេកម្មវិធី ជាអាទិ៍រវាងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។
- **ឯកឧត្តម ឃៀត ទីរីណាល** អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការរងនៃ **អ.គ.ម.** បានលើកឡើងអំពីភាពចាំបាច់ក្នុងការរៀបចំជាផែនការសកម្មភាពដែលមានភាពប្រទាក់ក្រឡារវាងកម្មវិធីកែទម្រង់នីមួយៗ ដូចជាការបង្កើតនូវអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ការគ្រប់គ្រងចំណាយបន្ទុកបុគ្គលិក ការគ្រប់គ្រងប្រាក់រង្វាន់ជាដើម។
- **ឯកឧត្តម គីម ភែចមុនីវត្ត** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា មានមតិគាំទ្រប្រសាសន៍របស់អង្គវិបស្សនា និងមតិរបស់ **ឯកឧត្តម ឃៀត ទីរីណាល** លើចំណុចជាសកម្មភាពប្រទាក់ក្រឡា ដូចជាការគ្រប់គ្រងចំណាយបន្ទុកបុគ្គលិក និងការបង្កើតអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងបានលើកឡើងអំពីការចរចាថវិកាជាទូទៅ ត្រូវអនុលោមតាមសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងទាមទារនូវរបាយការណ៍សមិទ្ធកម្មសម្រាប់ជាមូលដ្ឋានជាការចរចាថវិកា។
- **ឯកឧត្តម ស៊ាង ដល្លា** អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម បានមានមតិទៅលើសេចក្តីព្រាងអនុក្រឹត្យ ក្នុងខ្លឹមសារស្តីពីតួនាទីនិងការផ្ទេរសិទ្ធិរបស់ប្រធានប្លុកវេន និងសង្គតិភាពនៃការប្រើប្រាស់នៃពាក្យ "ប្រធានប្លុកវេន" នេះ និងលើទម្រង់ដូចជាផ្នែកមូលបទ និងការយោង និងកន្លែងទទួល។

នៅរសៀលថ្ងៃទី១៣ ខែកញ្ញា មានរៀបចំកិច្ចពិភាក្សាតាមក្រុមចំនួន ៣ ដែលក្រុមនីមួយៗផ្តោតលើយុទ្ធសាស្ត្រនីមួយៗ នៃយុទ្ធសាស្ត្រទាំង ៣ នៃឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រសម្រាប់អនុវត្តក្នុងផែនការ ៣ឆ្នាំ ដូចខាងក្រោម÷

២

១. ក្រុមទី១÷ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី១ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់ ៣ ប្លុក ១" សម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

២. ក្រុមទី២÷ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី២ សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម" សម្របសម្រួលដោយលេខាធិការដ្ឋាន គ.ក.វ.

៣. ក្រុមទី៣÷ ប្រធានបទស្តីពី "យុទ្ធសាស្ត្រទី៣ សុខដុមនីយកម្មការងារគាំទ្រកម្មវិធីកែទម្រង់ ៣ ប្លុក ១" សម្របសម្រួលដោយ អ.គ.ម.។

**២. លទ្ធផលនៃអង្គពិបសស្សនា និងសំណើសុំការសម្រេច**

បន្ទាប់ពីបានពិនិត្យពិភាក្សាលម្អិតទាំងក្នុងអង្គធំ និងក្រុមពិភាក្សារយៈពេល ១ថ្ងៃពេញមក អង្គពិបស្សនាបានជជែកពិភាក្សា ឬកសរុប និងឯកភាពលើសំណើជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ពិនិត្យនិងសម្រេចដូចតទៅ÷

**២.១. ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១**

១. បន្ថែមសារលោកអនុសាសន៍របស់ធនាគារពិភពលោក ដោយបញ្ចូលឯកសាររបស់ធនាគារពិភពលោកស្តីពី "កម្មវិធីកែទម្រង់ក្រទាក់ក្រឡារបស់កម្ពុជា" ជាឧបសម្ព័ន្ធវិញ ,

២. ឯកភាពជូនក្រុមការងារ អ.គ.ម. ទទួលបន្ទុកព្រាងបុព្វកថារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

៣. កែសម្រួលរចនាសម្ព័ន្ធ និងលំដាប់លំដោយនៃមាតិកានុក្រមឯកសារ ដូចជាការកែសម្រួលចំណុចរុំម៉ាំងមកជា ជំពូក

៤. ពិនិត្យបន្ថែមលើសង្គតិភាពនៃការប្រើប្រាស់ពាក្យពេចន៍ក្នុងឯកសារ

៥. កំណត់ជាក់លាក់អំពីយន្តការមន្ត្រីបង្គោលបច្ចេកទេសជាថ្មី ដោយតម្រូវឱ្យជាមន្ត្រីបង្គោលបច្ចេកទេសជាអ្នកសម្របសម្រួលទាំងផ្ទៃក្នុង (អគ្គ/លេខាធិការដ្ឋានកែទម្រង់ អង្គភាពជំនាញក្រោមឱវាទក្រសួងសាមី) និងផ្ទៃក្រៅ (រវាងអគ្គ/លេខាធិការដ្ឋានកែទម្រង់ដទៃទៀត ឬក្រសួង-ស្ថាប័នដទៃទៀត) ដើម្បីធានាយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ ប្រព្រឹត្តទៅបានប្រសើរ ដោយហេតុថាសកម្មភាពកែទម្រង់គួរអនុលោមតាមអង្គភាពជំនាញ

៦. កែសម្រួលលើកម្មវិធីមួយចំនួន និងតម្រូវឱ្យលេខាធិការដ្ឋាននីមួយៗសម្របសម្រួលជាមួយអង្គភាពជំនាញនៅតាមក្រសួង-ស្ថាប័នសាមីរបស់ខ្លួនតាមរយៈមន្ត្រីបង្គោលបច្ចេកទេសក្នុងការស្នើជាសកម្មភាពដែលមានលក្ខណៈប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់ទាំង ៤។

**២.២. សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១**

១. ឯកភាពពិនិត្យមើលលើទម្រង់និងរចនាសម្ព័ន្ធនៃឯកសារសេចក្តីព្រាង ជាអាទិ៍ក្នុងផ្នែកមូលបទ ផ្នែកបញ្ចប់នៃសេចក្តីព្រាង និងសង្គតិភាពនៃការប្រើប្រាស់ពាក្យពេចន៍

២. ឯកភាពដកខ្លឹមសារនៃមន្ត្រីបង្គោលបច្ចេកទេស និងការកែសម្រួលអំពីការផ្ទេរសិទ្ធិរបស់ប្រធានប្តូរវេន។

**២.៣. ចំណុចសុំការសម្រេចលើជំហានបន្ត**

១. កំណត់កាលបរិច្ឆេទផ្តល់ធាតុចូលត្រឡប់មកវិញពីលេខាធិការដ្ឋានទាំង៣ ត្រឹមថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០២២

២. ឯកភាពរៀបចំកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន ក្រោមឱវាទ គសហវ. នៅសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២២

៣. ឯកភាពរៀបចំកិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ ប្លុក ១ នៅសប្តាហ៍ទី៣ ឬទី៤ ខែតុលា ឆ្នាំ២០២២

៣

៤. ឯកភាពរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាមួយក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ដោយមានការចូលរួមជាអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅថ្ងៃទី២៧ ឬទី២៨ ខែតុលា ឆ្នាំ២០២២

៥. ការរៀបចំកម្មវិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅត្រីមាសទី៤ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ បើកដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងអធិបតីដ៏ខ្ពង់ខ្ពស់បិទដោយ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី**។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត វ៉ោល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២២
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សិលម៉ា**

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី 5 ខែ 10 ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៤

# ឧបសម្ព័ន្ធទី១៩

# ឧបសម្ព័ន្ធទី១៩. របាយការណ៍ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ..............................

*ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២*

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ÷** សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

**យោង ÷** - លិខិតលេខ ៣៤៦ សហវ/អគហ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- លិខិតលេខ ៣៥២ សហវ/អគហ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នារសៀលថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ចត្វាស័ក ឆ្នាំខាល ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត រ៉ូហ៊ែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** តំណាង **ឯកឧត្តម វង្ស វិសុទ្ធ** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃអ.គ.ហ បានសម្របសម្រួលនិងរៀបចំកិច្ចប្រជុំយន្តការសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ដោយមានការចូលរួមពី **ឯកឧត្តម ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ **ឯកឧត្តម ខាន់ សុផា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង **ឯកឧត្តម ឃួត ស៊ីនាដ** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

កិច្ចប្រជុំនេះ មានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងអង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ និងបណ្ឌិត្យសភាជាតិរដ្ឋបាលកម្ពុជា ដែលមានសមាសភាពចូលរួមប្រមាណ ៥៣ រូប។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើង ដើម្បីពិភាក្សាលើរបៀបវារៈ ចំនួន ៤ រួមមាន÷

**១. សេចក្តីព្រាងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**

**២. សេចក្តីព្រាងអនុក្រឹត្យសម្របសម្រួលការកែទម្រង់ ៣ បូក ១**

៣. គម្រោងវិបស្សនា នាត្រីមាសទី៣ ឆ្នាំ២០២២

៤. ផ្សេងៗ។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅរយៈពេល ២ ម៉ោងនិង ៣០នាទី ដោយបានពិនិត្យ ពិភាក្សា និងទទួលបានលទ្ធផលសំខាន់ៗតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យនិងសម្រេចដូចតទៅ÷

**ក. មតិពិភាក្សាគន្លឹះក្នុងកិច្ចប្រជុំ**

**ឯកឧត្តមបណ្ឌិត វ៉ើល ចំរើន** មានមតិស្វាគមន៍និងរៀបរាប់អំពីសាវតារនិងស្មារតីដែលនាំឱ្យមានការរៀបចំឯកសារនេះ ដែលបានប្រែក្លាយពីឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បួក ១ មកជាឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បួក ១ ដែលជាការកំណត់នូវចក្ខុវិស័យនិងរបៀបវារៈការងារកែទម្រង់ប្រធានក្របខ័ណ្ឌរបស់កម្មវិធីទាំងបួន។ ឯកឧត្តម បានលើកឡើងថា ឯកសារគោលនេះនឹងត្រូវគោរពស្នើសូមពុទ្ធផលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ឯកឧត្តម ក៏បានបញ្ជាក់ថាឯកសារនេះតម្រូវមានការធ្វើវិបស្សនាពិភាក្សាលម្អិតម្តងទៀត ដើម្បីបញ្ចប់ និងប្រកាសដាក់ឱ្យអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ ២០២២ ក្នុងកម្មវិធីប្រកាសដាក់ឱ្យអនុវត្ត ក្រោមអធិបតីភាពបើកដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងអធិបតីភាពបិទដោយ **សម្តេចក្រឡាហោម ស ខេង**។

**ឯកឧត្តម ជិន ម៉ាលីន** រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (គ.ច្ប.ធ.) បានលើកឡើងថាកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ នៅមិនទាន់ច្បាស់លាស់នៅឡើយ ដោយហេតុថាក្រសួងយុត្តិធម៌មានការងារអាទិភាពក្នុងការកែសម្រួលរចនាសម្ព័ន្ធថ្មី និងការអភិវឌ្ឍធនធានមនុស្សជាមុន។ ឯកឧត្តម ក៏បានបញ្ចេញមតិយោបល់លើខ្លឹមសារនៃឯកសារចំពោះចំណុចស្តីពីប្រធានប្តូរវេនប្រចាំត្រីមាស ថាគួរពិចារណាបន្ថែមខ្លឹមសារឱ្យមានសហប្រធានប្តូរវេនប្រចាំត្រីមាស ក្នុងករណីចាំបាច់។

**ឯកឧត្តម ចាន់ សុផា** អនុរដ្ឋលេខាធិការ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការ-អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានមានមតិដូចតទៅ÷

- ស្នើពិចារណាឱ្យមាននូវសិក្ខាសាលាពិគ្រោះយោបល់មួយជាមួយនឹងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- គាំទ្រលើចំណងជើងរបស់ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បួក ១
- ស្នើពិចារណាបំពេញខ្លឹមសារពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្ន (ចំណុច ខ. នៃ I) និងក្របខ័ណ្ឌស្ថាប័ន (ចំណុច គ. នៃ I) ដើម្បីធានាសង្គតិភាពនៃមាតិកាទម្រង់ឯកសារពាក់ព័ន្ធកម្មវិធីកែទម្រង់នីមួយៗ
- ស្នើទុករយៈពេលជូនលេខាធិការដ្ឋាន គ.ជ.អ.ប. កែសម្រួលនិងផ្តល់ជូនមកក្រុមការងារ អ.គ.ហ. នូវខ្លឹមសារមួយចំនួនពាក់ព័ន្ធនឹង គ.ជ.អ.ប.
- ស្នើពិចារណាការពន្យល់លម្អិតអំពីកម្មវិធីនីមួយៗក្នុងឯកសារលើចំណុចចក្ខុវិស័យនិងបេសកកម្មសម្រាប់កម្មវិធីកែទម្រង់ ៣ បួក ១ (ចំណុច ក. នៃ II)
- ស្នើកែសម្រួលចំណងជើងសេចក្តីព្រាងអនុក្រឹត្យពី "អនុក្រឹត្យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បួក ១" មកជា "អនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បួក ១"
- ស្នើពិចារណាលើរបៀបវារៈកិច្ចប្រជុំប្រចាំត្រីមាស គួរមានលក្ខណៈទន់ភ្លន់ដោយស្នើឡើងដោយប្រធានប្តូរវេន
- ស្នើពិចារណាពិភាក្សាបន្ថែមលើចំណុចចក្ខុវិស័យនៃឯកសារ ក្នុងវិបស្សនា ដើម្បីធានាផលប៉ះការអភិវឌ្ឍ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋជាអាទិ៍
- ស្នើយកចំណុច ក.៥. នៃ II យន្តការដោះស្រាយបញ្ហាប្រឈមដែលមានចរិតលក្ខណៈអន្តរកែទម្រង់។

២

**ឯកឧត្តម ហ៊ុត ស៊ីនាង** អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.រ.) បានស្វាគមន៍សម្រាប់ការរៀបចំឱ្យមានឯកសារនេះឡើង និងបានលើកឡើងអំពីវឌ្ឍនភាពនៃការរៀបចំកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈដំណាក់កាលទី២ ដែលត្រូវបានពិគ្រោះយោបល់រួចនិងព្រាងអនុម័តក្នុងឆ្នាំ២០២២នេះ។ ឯកឧត្តម បានមានមតិមួយចំនួន ដូចតទៅ÷

- ស្នើពិចារណាបន្ថែមជាមាតិកានុក្រមតូចៗបន្ថែមក្នុងចំណុចស្តីពីស្ថានភាពបច្ចុប្បន្ន និងក្របខ័ណ្ឌស្ថាប័ន
- ពោធជាសំណួរអំពីប្រធានបួរវេន តម្រូវកំណត់នូវរបៀបវារៈកិច្ចប្រជុំយ៉ាងដូចម្តេច
- ស្នើពិចារណាឱ្យមាននូវសិក្ខាសាលាពិគ្រោះយោបល់មួយជាមួយនឹងដៃគូអភិវឌ្ឍន៍
- ស្នើពិចារណាអំពីយន្តការគាំទ្របន្ថែម។

**លោកជំទាវ ខូន សុម៉ាលី** អគ្គនាយិកាវិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិត្យសភាឌីជីថលកម្ពុជា បានស្វាគមន៍ការរៀបចំឯកសារទាំងនេះឡើង និងមានមតិលើការរៀបចំជាក្របខ័ណ្ឌចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងបានលើកជាយោបល់ក្នុងការពិចារណាកំណត់ដាក់ជាយុទ្ធសាស្ត្រច្បាស់លាស់តាមវិស័យ ដោយបានលើកឡើងអំពីចំណុចនៃការអភិវឌ្ឍធនធានមនុស្សដែលបណ្ឌិត្យសភាឌីជីថលកម្ពុជា បាននិងកំពុងសហការជាមួយនឹងសាលាភូមិន្ទរដ្ឋបាល បណ្តុះបណ្តាលលើមុខជំនាញឌីជីថលចាំបាច់។

### ខ. លទ្ធផលនៃកិច្ចប្រជុំ និងសំណើសុំការសម្រេច

បន្ទាប់ពីបានពិនិត្យពិភាក្សាលម្អិតលើរបៀបវារៈខាងលើ អង្គប្រជុំបានសំយោគ ប្ញកសរុប និងឯកភាពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ពិនិត្យនិងសម្រេចលើសំណើ ដូចតទៅ÷

១. ឯកភាពបន្ថែមខ្លឹមសារស្តីពី "សហប្រធានប្តូរវេនប្រចាំត្រីមាស ក្នុងករណីចាំបាច់" ក្នុងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងសេចក្តីព្រាងអនុក្រឹត្យលើចំណុច "ប្រធានប្តូរវេននៃយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្ញក ១"

២. ឯកភាពនិងគោរពស្នើសុំការឯកភាពជាគោលការណ៍លើការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ នៅក្នុងខែតុលា ឆ្នាំ២០២២

៣. ឯកភាពផ្តល់លទ្ធភាពជូនលេខាធិការដ្ឋាននីមួយៗ នូវពេលវេលាពិនិត្យនិងកែសម្រួលខ្លឹមសារពាក់ព័ន្ធ និងផ្តល់ការឆ្លើយតបមកក្រុមការងារប្ញកសរុបឱ្យបានមុនដំណាច់ខែសីហា ឆ្នាំ២០២២

៤. ឯកភាពបន្ថែមការពន្យល់ជាខ្លឹមសារលម្អិតបន្ថែមលើក្របខ័ណ្ឌចក្ខុវិស័យ បេសកកម្ម និងកម្មវិធី

៥. ឯកភាពលើសំណើកែសម្រួលក្របខ័ណ្ឌចក្ខុវិស័យនិងបេសកកម្ម និងពិភាក្សាក្នុងវិបស្សនា

៦. ឯកភាពដកខ្លឹមសារ "យន្តការដោះស្រាយបញ្ហាប្រឈមដែលមានចរិតលក្ខណៈអន្តរកែទម្រង់" ក្នុងស្មារតីមិនបង្កើតយន្តការផ្សេងក្រៅពីយន្តការលេខាធិការដ្ឋាន ៣ ប្ញក ១

៧. ឯកភាពកែសម្រួលចំណងជើងសេចក្តីព្រាងអនុក្រឹត្យពី "អនុក្រឹត្យស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្ញក ១" មកជា "អនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្ញក ១"

៨. ឯកភាពលើគម្រោងវិបស្សនាសុខដុមនីយកម្មការកែទម្រង់ ៣ ប្ញក ១ ដូចខាងក្រោម÷

- កំណត់យកទីតាំងនៅខេត្តសៀមរាប
- កំណត់យកកាលបរិច្ឆេទចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២
- សមាសភាពចូលរួមសម្រាប់ភាគីពាក់ព័ន្ធពីការដ្ឋានកែទម្រង់នីមួយៗ÷ មិនលើសពី ១០រូប ដែលមានសមាសភាពពីក្រុមការងារកែទម្រង់ និងអគ្គនាយកដ្ឋានជំនាញ។

៣

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត រ៉េហ៊ីល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃចន្ទ ១១កើត ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២២
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

[illegible]
ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ [illegible] ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៩

# ឧបសម្ព័ន្ធទី២០

# ឧបសម្ព័ន្ធទី២០. របាយការណ៍ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ស្ដីពីលទ្ធផលនៃវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:........................................................

ថ្ងៃព្រហស្បតិ៍ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២

សូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ**÷ សំណើសុំវិធិតប្រនិងសម្រេចលើលទ្ធផលនៃវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ។

**យោង** ÷- លិខិតលេខ ៣០៨៨សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ២០៧សហវ/អគហ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- លិខិតលេខ ២២៤សហវ/អគហ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នាថ្ងៃព្រហស្បតិ៍ ១២ កើត និងថ្ងៃសុក្រ ១៣ កើត ខែពិសាខ ចត្វាស័ក ឆ្នាំខាល ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១២ និងទី១៣ ខែឧសភា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត វ៉េហ៊ិល ម៉ះវ៉ែន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ អ.គ.ហ. កំណាង **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃ **អ.គ.ហ.** បានដឹកនាំរៀបចំវិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១ នៅខេត្តកំពត ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងអង្គភាពក្រោមឱវាទ **កសហវ.** ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងយុត្តិធម៌។

វិបស្សនានេះ ត្រូវបានរៀបចំឡើង ដើម្បីពិភាក្សាលើរបៀបវារៈ ចំនួនពីរ រួមមាន÷

**១. សេចក្ដីព្រាងឯកសារទស្សនាទានស្ដីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ បី បូក មួយ**

**២. សំណើផែនការប្រតិបត្តិកម្មវិធីកែទម្រង់ បី បូក មួយ។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
១
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

វិបស្សនា បានរៀបចំប្រព្រឹត្តទៅ ស្របតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ៖

**ក. សាវតារ និងមូលដ្ឋានគតិ**

ឯកសារទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់នូវជំនាញការក្នុងស្រុក ចាប់តាំងពីខែតុលា ឆ្នាំ២០២០។ ជាលទ្ធផល ជំនាញការបានរៀបចំនិងផលិតជារបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន វឌ្ឍនភាព និងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់ ៣ បូក ១ និងបានផលិតជាឯកសារទស្សនាទានចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១ ដោយត្រូវបានដាក់ពិគ្រោះយោបល់ក្នុងយន្តការអន្តរកម្មវិធីកែទម្រង់ ៣ បូក ១ ដោយមានការចូលរួមពីបណ្តាអង្គភាពក្រោមឱវាទ **គសមាធ.** ដែលពាក់ព័ន្ធ ចំនួន ៤លើក។ ផ្អែកលើសាវតារនិងមូលដ្ឋាននេះ វិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំឡើងដើម្បីពិភាក្សានិងសម្រេចលើឯកសារស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១។

**ខ. មតិពិភាក្សារបស់អង្គវិបស្សនា**

សម្រាប់ព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ជាការបើកអង្គវិបស្សនា និងមានការធ្វើបទបង្ហាញដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃ លើប្រធានបទចំនួន២ គឺទី១).“សាវតារនិងលទ្ធផលនៃគម្រោងទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ បី បូក មួយ ” និងទី២).“បទបង្ហាញស្តីពីសំណើផែនការប្រតិបត្តិនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ បី បូក មួយ”។ ពន្លឺមនឹងនេះ អង្គវិបស្សនា ត្រូវបានពិភាក្សានិងលើកជាមតិ ដូចខាងក្រោម៖

- **ឯកឧត្តមបណ្ឌិត រ៉ហ៊ុល ចំរើន** បានមានមតិរៀបរាប់អំពីសាវតារនៃយន្តការសម្របសម្រួលកម្មវិធីកែទម្រង់ទាំង៣ កន្លងមក និងការរៀបចំឯកសារនេះឡើង ដែលជាការប្រមូលផ្តុំនូវការងារគន្លឹះ ដែលមានការប្រទាក់ក្រឡាគ្នា ដើម្បីធានាយន្តការការងាររួម។ ឯកឧត្តម ក៏បានលើកឡើងថា នេះជាជំហានមួយធំ ដែលជាការកសាងទស្សនាទាន ៣ បូក ១ រយៈពេល ១០ ឆ្នាំ អមដោយផែនការប្រតិបត្តិ ដែលសកម្មភាពជាក់ស្តែងត្រូវសាកល្បងអនុវត្ត លើគម្រោងតូចណាមួយ ដោយឈរលើគោលការណ៍បញ្ហាប្រឈមមួយ លទ្ធភាពឬឱកាសមួយ (One Problem, One Possibility/Opportunity)។
- **ឯកឧត្តម ចាន់ សុផា** អនុរដ្ឋលេខាធិការ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានមានមតិស្វាគមន៍ និងលើកឡើងអំពីសារៈសំខាន់នៃការរៀបចំនូវវិបស្សនា និងបានលើកឡើងអំពីកម្មវិធីកែទម្រង់ទាំង៤ មានភាពប្រទាក់ក្រឡាគ្នា ដោយបានលើកឡើងអំពីករណីជាឧទាហរណ៍នូវការផ្ទេរមុខងារនានា គឺត្រូវភ្ជាប់គ្នាទៅនឹងការផ្ទេរធនធានមនុស្ស និងហិរញ្ញវត្ថុស្របគ្នា។
- **ឯកឧត្តម សយ រាសី** អគ្គនាយករង និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានឯកភាពនិងគាំទ្រនូវការបង្កើតនូវវិបស្សនានេះ និងគាំទ្រក្នុងការកសាងនូវឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិនេះឡើង ដែលជាឯកសារតម្រង់ទិសឬត្រីវិស័យរួមនៃកម្មវិធីកែទម្រង់ ៣ បូក ១។
- **ឯកឧត្តម ជិន ម៉ាលីន** រដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានលើកឡើងថាវិបស្សនានេះជាកម្មវិធីពិភាក្សាបានជាចាំបាច់ សម្រាប់ឯកសារនិងកំណត់បាននូវផែនការដែលអាចអនុវត្តបានសម្រាប់កម្មវិធីកែទម្រង់ទាំង៤។ លើសពីនេះ

២

ទៅទៀត ឯកឧត្តមបានលើកឡើងអំពីលក្ខណៈពិសេសដោយឡែករបស់កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

- **ឯកឧត្តម ឱ សុវណ្ណ** តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមឱវាទ **គសធភ.** បានមានមតិលើការរៀបចំនូវឯកសារទស្សនាទាននិងផែនការប្រតិបត្តិជាការចូលរួម ដើម្បីដំណោះស្រាយរួមគ្នារវាងកម្មវិធីកែទម្រង់ទាំង៤។ ឯកឧត្តមក៏បានលើកអំពីចំណុចដែលតម្រូវឱ្យឯកសារកំណត់នូវបញ្ហាជាច្រើនទៀត និងបញ្ជាក់ថាឯកសារនេះគួរតែមានការចុះមើលផ្ទាល់ ជាពិសេសជាឧទាហរណ៍អំពីបញ្ហានៃការផ្ទេរមុខងារ ២០ វិស័យ ៥៥មុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានភាពប្រទាក់ក្រឡារវាងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ។
- **ឯកឧត្តម គីម រ័តនមុនីរ័ត្ន** តំណាងអគ្គនាយកដ្ឋានថវិកា ក្រោមឱវាទ **គសធភ.** បានមានមតិលើកឡើងអំពីការផ្ទេរមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺបានអនុវត្តបានដោយមានការទម្លាក់ថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ ជាក់ស្តែងជាឧទាហរណ៍កញ្ចប់ថវិការបស់ប៉ុស្តិ៍នគរបាលនៅកម្រិតស្រុក (សម្រាប់វិស័យសន្តិសុខ ការពារជាតិ)។
- **ឯកឧត្តម សៀក សុផាត** តំណាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ក្រោមឱវាទ **គសធភ.** បានមានមតិថាវិបស្សនាជាការគាំទ្រកម្មវិធី ៣ បូក ១ ដែលអាចឃើញទិដ្ឋភាពធំនិងរួមគ្នា។ ឯកឧត្តម ក៏បានលើកឡើងអំពីករណីការផ្ទេរការកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានអនុវត្តរួចរាល់ ប៉ុន្តែនៅមានការមិនទាន់បានផ្ទេរនូវបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាអាទិ៍។
- **ឯកឧត្តម យ៉េត ចរិណាល** អនុរដ្ឋលេខាធិការ **គសធភ.** ជាអគ្គលេខាធិការរងនៃ **អ.គ.ភ.** បានមានមតិដូចខាងក្រោម÷
  - ចំពោះករណីការផ្ទេរមុខងារទាំង៥៥ក្នុង២០វិស័យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ÷ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកតាមដាន ដោយមានយន្តការប្រចាំត្រីមាស។ ម្យ៉ាងវិញទៀត ករណីនេះគួរត្រូវបានដាក់ក្នុងផែនការប្រតិបត្តិកម្មវិធីកែទម្រង់ ៣ បូក ១ ដើម្បីដោះស្រាយ
  - ផែនការប្រតិបត្តិនេះ តម្រូវឱ្យមានយន្តការដាក់អនុវត្តជាក់លាក់ និងដោះស្រាយក្នុងឆ្នាំ២០២២នេះ
  - គួរមានយន្តការលើកទឹកចិត្ត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ជាសំណូមពរ÷ កិច្ចប្រជុំផ្លាស់វេនរបស់យន្តការសម្របសម្រួលកម្មវិធីកែទម្រង់ គួរលើកប្រធានបទជាក់លាក់ណាមួយ សម្រាប់ពិភាក្សាប្រចាំត្រីមាស
  - គួរមានការជំរុញការផ្ទេរសិទ្ធិ ជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រោះរដ្ឋបាលរាជធានី-ខេត្ត ជាអាណាប័កផ្ទេរសិទ្ធិ (មិនត្រឹមទីចាត់ការហិរញ្ញវត្ថុទេ)។

សម្រាប់របៀបវារៈរសៀលថ្ងៃទី១២ គឺជាការពិភាក្សាតាមក្រុមចំនួន ៣ ដោយផ្តោតលើប្រធានបទចំនួន៣ ដែលអាចជាការកំណោត់ចេញបានជាយុទ្ធសាស្ត្រ៣ សម្រាប់ផែនការប្រតិបត្តិ ដូចខាងក្រោម÷

១. ក្រុមទី១÷ ប្រធានបទស្តីពី "សុខដុមនីយកម្មមុខងារ បរដ្ឋានគតិយុត្ត និងធនធាន" សម្របសម្រួលដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

២. ក្រុមទី២÷ ប្រធានបទស្ដីពី "សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម" សម្របសម្រួលដោយ លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

៣. ក្រុមទី៣÷ ប្រធានបទស្ដីពី "ការលើកកម្ពស់ស្មារតី ឆន្ទៈ ភាពជាម្ចាស់នៃកម្មវិធីកែទម្រង់ ៣ បូក ១" សម្របសម្រួលដោយ **អ.គ.ហ.**។

សម្រាប់របៀបវារៈនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ គឺជាការធ្វើបទបង្ហាញរបស់ក្រុមទាំង ៣ ដោយមានការពិភាក្សាលម្អិតទៅលើប្រធានបទទាំង៣ សំណើមាតិកាគ្រោងនៃផែនការប្រតិបត្តិ និងផែនការប្រតិបត្តិចំនួន៩។

**គ. លទ្ធផលនៃអង្គវិបស្សនា និងសំណើសុំការសម្រេច**

បន្ទាប់ពីបានពិនិត្យពិភាក្សាលម្អិតរយៈពេល ២ថ្ងៃរួចមក អង្គវិបស្សនា បានសំយោគ ឬកសរុប និងឯកភាព ស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ពិនិត្យនិងសម្រេចលើសំណើ ដូចតទៅ÷

១. ប្រែក្លាយឯកសារទស្សនាទានស្ដីពីចក្ខុវិស័យនិងបេសកកម្ម មកជាឯកសារចក្ខុវិស័យនិងបេសកកម្ម ដែលមានផែនការប្រតិបត្តិនិងផែនការថវិកា ដែលយន្តការអនុវត្តត្រូវបានផ្លាស់ប្ដូរពីការសម្របសម្រួលធម្មតាគ្មានសកម្មភាពជាក់លាក់ មកជាមានសកម្មភាពសុខដុមនីយកម្ម ខណៈដែលកម្មវិធីកំណែទម្រង់ទាំង ៤ មានរចនាសម្ព័ន្ធ ថវិកា ការដឹកនាំ និងការអនុវត្ត មិនដូចគ្នា

២. ចក្ខុវិស័យរួមនេះ នឹងមិនសំដៅដល់ស្ថាប័នូបនីយកម្មនៃការកែទម្រង់ទេ ដោយនៅនឹងត្រូវអនុលោមតាមការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងពេលកន្លងមក គឺការផ្លាស់ប្ដូរពីមជ្ឈការកែទម្រង់ (ក្រុមប្រឹក្សាកែទម្រង់រដ្ឋ) មកជាវិមជ្ឈការកែទម្រង់

៣. គោរពស្នើសុំចំណងជើងឯកសារ÷ "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**"

៤. លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់នីមួយៗ ត្រូវបំពេញមុខងារជាតួអង្គគាំទ្រនៃការអនុវត្តចក្ខុវិស័យ និងយុទ្ធសាស្ត្រ ៣ បូក ១

៥. ស្នើសុំកែសម្រួលសេចក្ដីសម្រេចរួមស្ដីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ មកជាអនុក្រឹត្យ និងមានបទដ្ឋានគាំទ្រផ្សេងទៀតតាមការចាំបាច់

៦. ស្នើសុំបុព្វកថារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ** ដើម្បីដាក់ឱ្យអនុវត្ត "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**"

៧. ស្នើសុំរៀបចំវិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១ ម្ដងទៀត នៅត្រីមាសទី៣ ឆ្នាំ២០២២ ដើម្បីបញ្ចប់រួចរាល់នូវឯកសារសេចក្ដីព្រាងចុងក្រោយ

៨. ស្នើសុំរៀបចំកម្មវិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១**" នៅត្រីមាសទី៤ ឆ្នាំ២០២២ ដោយគោរពសុំវត្តមានជាអធិបតីភាពបើកកម្មវិធីរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងបិទដោយ **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី**។

៤

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហៃល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៥

# ឧបសម្ព័ន្ធទី២១

# ឧបសម្ព័ន្ធទី២១. របាយការណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់ បី បួក មួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:.................................................

*ថ្ងៃអង្គារ ៦ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២*

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ**÷ សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បួក មួយ។

**យោង** ÷- លិខិតលេខ ០៥៨ សហវ/អគហ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- លិខិតលេខ ០៧៧ សហវ/អគហ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាខ្ពង់ខ្ពស់ថា នារសៀលថ្ងៃពុធ ១៥ កើត ខែមាឃ ឆ្នាំឆ្លូវ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត រ៉ោស ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** តំណាង **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញនៃ **អ.គ.ហ** និងជំនាញការក្នុងស្រុក បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់បី បួក មួយ តាមរយៈប្រព័ន្ធចម្រុះ ដោយប្រជុំផ្ទាល់នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមរយៈប្រព័ន្ធវីឌីអូអនឡាញ Zoom ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងតំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពចូលរួមចំនួន ២៥ រូប។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើង ដើម្បីពិភាក្សាលើរបៀបវារៈ ចំនួនបី រួមមាន÷

**១. សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ បី បួក មួយ**

**២. គម្រោងវិបស្សនាកម្មវិធីកែទម្រង់ បី បួក មួយ**

**៣. ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

កិច្ចប្រជុំ បានប្រព្រឹត្តទៅរយៈពេល ៣ ម៉ោង ដោយបានពិនិត្យ ពិភាក្សា និងទទួលបានលទ្ធផលសំខាន់ៗតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ÷

**ក. ការពិភាក្សាលើសេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ បី បូក មួយ**

- **ឯកឧត្តម ចាន់ សុផា** តំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) បានមានមតិ÷
  - អំពីភាពសមស្របនៃចក្ខុវិស័យនិងបេសកកម្មរបស់សេចក្តីព្រាងឯកសារទស្សនាទាន
  - ស្នើកំណត់ឱ្យកាន់តែជាក់ច្បាស់អំពីលទ្ធផលរំពឹងទុកទៅជាលទ្ធផល ឬសមិទ្ធផល ជាជាងសកម្មភាព
  - ស្នើការរៀបចំសកម្មភាព សម្រេចតាមយុទ្ធសាស្ត្រ
  - លើកអំពីបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងសកម្មភាពនានាដែលបាំងស្ទះដោយក្របខណ្ឌពេលវេលាមិនស្របគ្នានៃកម្មវិធីកែទម្រង់នីមួយៗ, យន្តការកែទម្រង់ទាំងពានៅតាមក្រសួង-ស្ថាប័នមិនមានទំនាក់ទំនងគ្នា ឬមិនមែនជាក្រុមការងារតែមួយ, និងយន្តការសវនកម្មនិងអធិការកិច្ចដែលនៅជាកត្តាបញ្ហារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - ស្នើលើកអំពីលទ្ធភាពក្នុងកំណត់អំពីសុខដុមនីយកម្មយន្តការសវនកម្មនិងអធិការកិច្ច។
- **ឯកឧត្តម សយ រាសី** តំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.ស.**) មានមតិ÷
  - គាំទ្រនូវឯកសារទស្សនាទាន ជាពិសេសលើចំណុចការកំណត់ដាក់ឱ្យសាកល្បងការអនុវត្តកម្មវិធីកែទម្រង់ បី បូក មួយ នៅតាមអង្គភាព ឬស្ថាប័នណាមួយ
  - លើកអំពីការរំលេចសកម្មភាពជាក់លាក់ ដែលឆ្លុះបញ្ចាំងតាមយុទ្ធសាស្ត្រ
  - ស្នើសុំពេលវេលាពិនិត្យខ្លឹមសារដែលពាក់ព័ន្ធនឹង **គ.ក.ស.**។
- **ឯកឧត្តម ឃ្លោក ដារ៉ា** តំណាងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានមានមតិ÷ លើកឡើងអំពីវិសេសភាពនៃការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងគាំទ្រលើការរៀបចំឯកសារទស្សនាទាននេះ ជាពិសេសលើការបង្កើតយន្តការរួមមួយ ឬក្រុមការងាររួមមួយ ក្នុងក្របខណ្ឌក្រសួង-ស្ថាប័នសម្រាប់ការងារកែទម្រង់បី បូក មួយ និង គាំទ្រលើចំណុចការស្នើឱ្យមានការចាត់ក្រុមការងារកែទម្រង់ ទៅជាអង្គភាពថវិកានៅតាមក្រសួង-ស្ថាប័ន។

**ខ. ការពិភាក្សាលើគម្រោងទិវាទស្សនាកម្មវិធីកែទម្រង់ បី បូក មួយ**

តំណាងលេខាធិដ្ឋានកែទម្រង់ទាំងបី បានលើកឡើងអំពីមតិលើគម្រោង និងសេចក្តីព្រាងរបៀបវារៈនៃអង្គវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ÷

- សមាសភាពចូលរួមអង្គវិបស្សនា គួរមានសមាសភាពពីគ្រប់ភាគី ពោលពីក្រុមការងារកែទម្រង់ និងតំណាងអគ្គនាយកដ្ឋានជំនាញ
- ស្នើកំណត់នូវកាលបរិច្ឆេទណាមួយសមស្របតាមការវិវត្តជាក់ស្តែងនៃការរីករាលដាលកូវីដ ១៩
- ស្នើកំណត់ទីតាំងសម្រាប់ការធ្វើវិបស្សនា និងដំណើរទស្សនកិច្ច ក្នុងខេត្តណាមួយ ដែលអាចអនុញ្ញាតក្រុមការងារធ្វើការស្ទង់ស្ទាបី និងកម្មវិធីប្រព្រឹត្តទៅប្រកបដោយសមិទ្ធផល។

២

**គ. ការពិភាក្សាលើឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- **ឯកឧត្តម សយ វាសី** តំណាង **គ.ភ.រ.** មានមតិ÷
  - ឯកសារទស្សនាទាននេះ ពិតជាមានសារៈសំខាន់ និងស្របទិសដៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ
  - ឯកភាពថាឯកសារនេះ នឹងត្រូវធ្វើក្នុងកម្រិតប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ
  - បានចាត់សំណួរថាតើមូលដ្ឋានអ្វីសម្រាប់ការកំណត់ នៅពេលបេក្ខភាពទទួលការបណ្តុះបណ្តាលកម្រិត ៣ ដោយជោគជ័យនេះ នឹងត្រូវតំឡើង ១ថ្នាក់នៃឋានន្តរស័ក្តិមន្ត្រីនេះ។
- **ឯកឧត្តម ចាន់ សុផា** តំណាង **គ.ជ.អ.ប.** បានមានមតិ÷
  - គាំទ្រក្នុងការកសាងឯកសារទស្សនាទាននេះ
  - លើកអំពីការទាក់ទងគ្នានឹងការពិពណ៌នាមុខតំណែង និងបានលើកឡើងអំពីឯកសារនេះ បានឆ្លុះបញ្ចាំងអំពីការបណ្តុះបណ្តាលសម្រាប់មន្ត្រីថ្មី និងមន្ត្រីចាស់ដែលមានមុខតំណែងរួចហើយ
  - លើកអំពីបញ្ហាប្រឈមអំពីមន្ត្រីហិរញ្ញវត្ថុសាធារណៈកម្រិតឃុំ ដែលជាទូទៅជាស្មៀនឃុំ និងថ្មីៗកន្លងទៅមានការជ្រើសរើសនូវជំនួយការហិរញ្ញវត្ថុនៅរដ្ឋបាលឃុំសង្កាត់ជាដើម
  - លើកអំពីការបណ្តុះបណ្តាលកម្រិត ៥ ដែលកំណត់យកនាយករដ្ឋបាល អភិបាល/អភិបាលរងនៃរដ្ឋបាលរាជធានីខេត្ត មកទទួលការបណ្តុះបណ្តាលនេះ គឺមិនសមស្រប ពោលគួរកំណត់ថាជានាយកទីចាត់ការហិរញ្ញវត្ថុជាជាង
  - លើកអំពីវិសាលភាពនៃឯកសារទស្សនាទាននេះគឺធំធេង ដែលពាក់ព័ន្ធនឹងគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទាមទារឱ្យមានធ្វើការពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ។
- **ឯកឧត្តម ឃ្លោក ដារ៉ា** តំណាងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានមានមតិ÷ គាំទ្រការរៀបចំឱ្យមានឯកសារនេះ និងបានលើកឡើងអំពីបញ្ហាសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មន្ត្រីរដ្ឋបាលនៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

**ឃ. ការសម្រេចរបស់អង្គប្រជុំ**

អង្គប្រជុំ បានបូកសរុប និងសម្រេចនូវលទ្ធផលដូចខាងក្រោម÷

- ឯកភាពតាមមតិរបស់អង្គប្រជុំ និងកំណត់ផ្តល់លទ្ធភាពសម្រាប់ជំនាញការក្នុងការកែសម្រួល និងបញ្ចប់ជាសេចក្តីព្រាង សម្រាប់ដាក់ជូនការដ្ឋានកែទម្រង់នានាដើម្បីពិនិត្យ មុននឹងកាលបរិច្ឆេទនៃវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ
- ឯកភាពផ្តល់ជូនក្រុមការងារ **អ.គ.ហ.** ក្នុងការបន្តនីតិវិធីកសាងឯកសារទស្សនាទាននេះ ភ្ជាប់ជាមួយនឹងតារាងម៉ាទ្រីស
- ឯកភាពផ្តល់លទ្ធភាពដល់ **គ.ភ.រ.** ក្នុងការពិនិត្យ និងកែសម្រួលខ្លឹមសារពាក់ព័ន្ធនឹងមុខងាររបស់ខ្លួន និងផ្តល់ការឆ្លើយតបឱ្យបានមុនកាលបរិច្ឆេទនៃវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ
- ឯកភាពលើគម្រោងវិបស្សនាកម្មវិធីកែទម្រង់ បី បូក មួយ ដូចខាងក្រោម÷
  - កំណត់យកទីតាំងនៅ ខេត្តកំពត ឬ ខេត្តកែប
  - កំណត់យកកាលបរិច្ឆេទចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

៣

ឧបសម្ព័ន្ធទី២១

- សមាសភាពធ្វើបេឡូមសម្រាប់ភាគីពាក់ព័ន្ធពីការដ្ឋានកែទម្រង់នីមួយៗ÷ មិនលើសពី ១០រូប ដែលមានសមាសភាពពីក្រុមការងារកែទម្រង់ និងអគ្គនាយកដ្ឋានជំនាញ។
- ឯកភាពផ្តល់ពេលវេលារយៈពេល ១ ខែក្រោយពីកិច្ចប្រជុំថ្ងៃទី១៦ នៃកុម្ភៈ ឆ្នាំ២០២២នេះ សម្រាប់ការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត ក្នុងផ្តល់មតិយោបល់មក **អ.គ.ហ.** លើឯកសារទស្សនាទានស្តីពីកុណាវឌ្ឍមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត វ៉ោល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២២
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៤

# ឧបសម្ព័ន្ធទី២២

# ឧបសម្ព័ន្ធទី២២. របាយការណ៍ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពី លទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បូក មួយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:..................................................

*ថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១*

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ៖** សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បូក មួយ។

**យោង ៖** លិខិតលេខ ៤២១ សហវ/អគហ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាព័ត៌មានថា នារសៀលថ្ងៃព្រហស្បតិ៍ ៧ រោច ខែអស្សុជ ឆ្នាំឆ្លូវ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ែល ម៉ីរ៉េន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** តំណាង **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញនៃ **អ.គ.ហ** និងជំនាញការក្នុងស្រុក បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់បី បូក មួយ តាមរយៈប្រព័ន្ធវីឌីអូអនឡាញ Zoom ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងតំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលមានសមាសភាពចូលរួមចំនួន ២៤ រូប។

កិច្ចប្រជុំនេះ ជាលទ្ធផលនៃការសម្រេចរបស់អង្គប្រជុំកាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ដោយកំណត់យកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ជាកិច្ចប្រជុំអន្តរការដ្ឋានកែទម្រង់ បី បូក មួយ លើកទី២ ដើម្បីពិភាក្សាលើរបៀបវារៈ ចំនួនពីរ រួមមាន៖

**១. សេចក្ដីព្រាងឯកសារទស្សនទានស្ដីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ**

**២. ផ្សេងៗ។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥

St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

ឧបសម្ព័ន្ធទី២២

កិច្ចប្រជុំ បានប្រព្រឹត្តទៅរយៈពេល ១ ម៉ោង និង ៣០ នាទី ដោយបានពិនិត្យ ពិភាក្សា និងទទួលបានលទ្ធផលសំខាន់ៗតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ÷

**ក. ការពិភាក្សាលើសេចក្តីព្រាងឯកសារទស្សនទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ**

- **ឯកឧត្តម ង៉ាន់ ចំរើន** ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) បានមានមតិ និងធ្វើបទបង្ហាញអំពីសេចក្តីព្រាងមាតិកាដែលស្នើឡើងដោយ **គ.ជ.អ.ប.** ជូនអង្គប្រជុំ
- **ឯកឧត្តម ហ្គូត ស៊ីនាង** ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.រ.**) មានអតិតាំទ្រលើសេចក្តីព្រាងមាតិកាដែលស្នើឡើងដោយ **គ.ជ.អ.ប.** និងបានសង្កត់ធ្ងន់អំពីការកំណត់នូវក្របខ័ណ្ឌត្រួតពិនិត្យនិងតាមដាន (M&E Framework) ជាខ្លឹមសារសម្រាប់ឯកសារទស្សនទាន និងបានស្នើគោលគំនិតនូវការដ្ឋានកែទម្រង់និមួយៗបំពេញនូវខ្លឹមសារដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់របស់ខ្លួន
- **ឯកឧត្តម ខាន់ ចណ្ណា** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានមានអតិតាំទ្រលើសេចក្តីព្រាងមាតិកាដែលស្នើឡើងដោយ **គ.ជ.អ.ប.** ដែលឆ្លុះបញ្ចាំងអំពីកម្មវិធីកែទម្រង់នីមួយៗក្នុងរចនាសម្ព័ន្ធឯកសារដែលងាយស្រួលមើលនិងយល់។
- **ឯកឧត្តម ង៉ាន់ ចំរើន** ប្រធានលេខាធិការដ្ឋាននៃ **គ.ជ.អ.ប.** បានលើកសំណើអំពីការធ្វើបសុរនាសម្រាប់កិច្ចពិភាក្សាលម្អិតលើឯកសារទស្សនទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ នេះ។

**ខ. ការសម្រេចរបស់អង្គប្រជុំ**

អង្គប្រជុំ បានបូកសរុប និងសម្រេចនូវលទ្ធផលដូចខាងក្រោម÷

- ឯកភាពលើសេចក្តីព្រាងមាតិកាដែលស្នើឡើងដោយលេខាធិការដ្ឋាន **គ.ជ.អ.ប.** និងសម្រេចជូន **អ.គ.មា.** ក្នុងការផលិតជាសេចក្តីព្រាងឯកសារទស្សនទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ ថ្មី ដោយយកមូលដ្ឋានលើសំណើមាតិកាដែលស្នើឡើង
- ឯកភាពសម្រេចកំណត់រយៈពេល ១ ខែ សម្រាប់ការដ្ឋានកែទម្រង់នីមួយៗ ក្នុងការបំពេញនូវខ្លឹមសារដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់របស់ខ្លួន ក្នុងចំណុចទី២ នៃសេចក្តីព្រាងមាតិកា
- ឯកភាពសម្រេចជូន **អ.គ.មា.** ក្នុងបំពេញនិងពាក់តែងលើចំណុចផ្សេងទៀត ក្រៅពីចំណុចទី២ នៃសំណើមាតិកា
- ឯកភាពក្នុងការរៀបចំវិបស្សនាចង្អៀតរវាងលេខាធិការដ្ឋានកែទម្រង់បីបូកមួយ នៅខេត្តណាមួយ ដើម្បីពិភាក្សាលើគម្រោងរបៀបវារៈចំនួនពីរ រួមមាន ទី១). សេចក្តីព្រាងឯកសារទស្សនទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ និងទី២). ទស្សនៈកិច្ចសិក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ លើមុខងារណាមួយ ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការងារកែទម្រង់ បី បូក មួយ ដើម្បីយកពិសោធន៍និងប្រមូលធាតុចូលបន្ថែមសម្រាប់កសាងឯកសារ
- ចំពោះគម្រោងវិបស្សនានៃការដ្ឋានកែទម្រង់ បី បូក មួយនេះ អង្គប្រជុំសម្រេចឱ្យ លេខាធិការដ្ឋាន **គ.ជ.អ.ប.** កំណត់នូវខេត្តជាទិសដៅសម្រាប់ការធ្វើវិបស្សនា និងការកំណត់នូវមុខងារណាមួយសម្រាប់កិច្ចពិភាក្សាក្នុងគម្រោងរបៀបវារៈទី២។

២

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាបោយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើទាំងឡាយខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ែល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃអង្គារ ១២ រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០២១
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ .... ខែ .... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី 5 ខែ 11 ឆ្នាំ២០២១
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធទី២៣

# ឧបសម្ព័ន្ធទី២៣. របាយការណ៍ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បូក មួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:..................................................

*ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១*

**សូមគោរពជូន**
**ឯកឧត្តម សេ សីលហ៊ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ÷** សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បូក មួយ។

**យោង ÷** លិខិតលេខ ៤០៣ សហវ/អគក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គលេខាធិការ** មេត្តាជ្រាបជាព័ត៌មានថា នារសៀលថ្ងៃព្រហស្បតិ៍ ៨ កើត ខែអស្សុជ ឆ្នាំឆ្លូវ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** តំណាង **ឯកឧត្តម សេ សីលហ៊ា** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញនៃ **អ.គ.ហ** និងជំនាញការក្នុងស្រុក បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់បី បូក មួយ តាមរយៈប្រព័ន្ធវីឌីអូអនឡាញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងតំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងតំណាងអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពចូលរួមចំនួន ៥៣ រូប។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយមានរបៀបវារៈ ចំនួនពីរ រួមមាន÷

**១. សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ**

**២. ផ្សេងៗ។**

កិច្ចប្រជុំ បានប្រព្រឹត្តទៅរយៈពេល ២ ម៉ោង និង ៣០ នាទី ដោយបានពិនិត្យ ពិភាក្សា និងទទួលបានលទ្ធផលសំខាន់ៗតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គលេខាធិការ** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

ឧបសម្ព័ន្ធទី២៣

ខ. សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ បី បូក មួយ

- **ឯកឧត្តម ឌី សុវណ្ណា** តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានមតិលើការប្រើប្រាស់ពាក្យពេចន៍ក្នុងឯកសារទស្សនាទាន និងបានលើកឡើងថាឯកសារទស្សនាទាននេះ គួរលើកអំពីក្របខណ្ឌគោលគំនិត (Conceptual Framework) ឬអង្គសំខាន់ៗក្នុងការងារកែទម្រង់ បី បូក មួយ ផែនការសកម្មភាពផ្សារភ្ជាប់ជាមួយនឹងសូចនាករ និងក្របខណ្ឌពេលវេលាជាក់លាក់ណាមួយ ស្របតាមទិសដៅកែទម្រង់ ពោលឯកសារទស្សនាទាននេះគួរផ្តល់ និងឆ្លុះបញ្ចាំងនូវភាពប្រទាក់ក្រឡាគ្នានៃកំណែទម្រង់ បី បូក មួយ។
- **ឯកឧត្តម ឈុន សុជាតិ** អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានមានមតិលើឯកសារទស្សនាទាននេះ ជាសំណើចក្ខុវិស័យ យុទ្ធសាស្ត្រ និងសកម្មភាព មិនទាន់ស៊ីចង្វាក់គ្នានៅឡើយ និងស្នើឱ្យមាននូវការពិនិត្យពិភាក្សាកម្រិតបច្ចេកទេសជាមុនសិន ដើម្បីឱ្យឯកសារទស្សនាទាននេះ អាចផលិតចេញបាននិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។
- **ឯកឧត្តម ខាន់ ចណ្ណៈ** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានមានមតិលើឯកសារទស្សនាទានអំពីកង្វះភាពប្រទាក់ក្រឡាគ្នា និងចំណុចប្រសព្វនៃការងារកែទម្រង់ទាំងបួន និងស្នើឱ្យមានការពិភាក្សាកម្រិតជំនាញនៃលេខាធិការដ្ឋានជាមុនសិន មុននឹងដាក់ជូនកម្រិតអន្តរក្រសួងស្ថាប័ន។
- **ឯកឧត្តម ង៉ាន់ ចំរើន** ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) បានមានមតិលើឯកសារទស្សនាទានមិនគួរផ្តោតលើសកម្មភាពបច្ចេកទេសពេកនោះទេ ពោលគឺគួរកំណត់អំពីចក្ខុវិស័យរបស់ការងារកែទម្រង់ទាំងបួន និងលើកអំពីបញ្ហាប្រឈមជាក់លាក់ដែលឆ្លុះបញ្ចាំងអំពីចំណុចខ្វះខាតដោយឡែក និងចំណុចប្រទាក់ក្រឡានៃកម្មវិធីកែទម្រង់ បី បូក មួយ ដែលបញ្ហាអន្តរវិស័យ។
- ទន្ទឹមនេះ អង្គប្រជុំបានបូកសរុប និងទទួលយកនូវមតិយោបល់អំពីខ្លឹមសារសំខាន់ៗទាំងនេះ ដោយឯកភាពសម្រេចថាឯកសារទស្សនាទាននេះនឹងត្រូវយកទៅកែសម្រួលដោយផ្តោតទៅលើខ្លឹមសារគន្លឹះ និងផ្តោតលើគុណតម្លៃស្នូលពីក្របខណ្ឌសមាហរណកម្ម និងសុខដុមនីយកម្មនៃកម្មវិធីកែទម្រង់ បី បូក មួយ និងស្មារតីអនុវត្តយន្តការសម្របសម្រួលអន្តរការងារកែទម្រង់ បី បូក មួយ។

គ. ផ្សេងៗ

- **ឯកឧត្តមបណ្ឌិត រ៉ហ៊ើល ចំរើន** ប្រធានអង្គប្រជុំ ស្នើឱ្យតំណាងនៃអង្គភាពដែលពាក់ព័ន្ធ ជាពិសេសលេខាធិការដ្ឋានទាំងបួន ផ្តល់ធាតុចូលកែលម្អនានាលើឯកសារទស្សនាទានក្នុងអំឡុងពេល មួយខែ គិតចាប់ពីកិច្ចប្រជុំ។
- អង្គប្រជុំបានឯកភាព លើសំណើឱ្យមានកិច្ចប្រជុំនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៤÷៣០ នាទី ដើម្បីសម្រេចលើក្របខណ្ឌពេលវេលា និងខ្លឹមសារនិងរចនាសម្ព័ន្ធនៃឯកសារទស្សនាទាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គលេខាធិការ** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គលេខាធិការ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**មន្ត្រីជំនាញ**

**ទុទ្ធី សុភ្រា** **ស៊ិន គីមហេង**

បានឃើញ ពិនិត្យ កែសម្រួល និងសូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការរង ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

**មន្ត្រីជំនាញជាន់ខ្ពស់**

**លី ឌុច**

បានឃើញ និងសូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការ ពិនិត្យនិងជ្រាបជារបាយការណ៍
ថ្ងៃ សុក្រ ០១រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ តុលា ឆ្នាំ២០២១

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ើល ចំរើន**

[illegible]
..........................................................................
ថ្ងៃ ចន្ទ ០៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០២១

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

៣

# ឧបសម្ព័ន្ធទី២៤

# ឧបសម្ព័ន្ធទី២៤. របាយការណ៍ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ ស្តីពីលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ ប៊ី ប្លូក មួយ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខៈ..............................................

*ថ្ងៃព្រហស្បតិ៍ ១០រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១*

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ៖** សំណើសុំពិនិត្យនិងសម្រេចលើលទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ ប៊ី ប្លូក មួយ។

**យោង ៖** លិខិតលេខ ១៤២ សហវ/អគហ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នារសៀលថ្ងៃអង្គារ ៨ រោច ខែពិសាខ ឆ្នាំឆ្លូវ ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ៅ ធនីន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) និងជាអគ្គលេខាធិការរងនៃ **អ.គ.ហ.** តំណាង **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ នៃ **កសហវ.** និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញនៃ **អ.គ.ហ** និងជំនាញការក្នុងស្រុក បានរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ប៊ី ប្លូក មួយ តាមរយៈប្រព័ន្ធវីដេអូអនឡាញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងតំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយមានរបៀបវារៈ ចំនួនបី រួមមាន៖

**១. សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកែសម្រួលយន្តការសម្របសម្រួលកែទម្រង់ប៊ី ប្លូក មួយ**

**២. បទបង្ហាញស្តីពីការរៀបចំទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ប៊ី ប្លូក មួយ**

**៣. ផ្សេងៗ។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទៈ ៨៥៥-២៣-៤៣០ ៧៩១ ទូរសារៈ ៨៥៥-២៣-៤៣០ ៧៤៥

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

កិច្ចប្រជុំ បានប្រព្រឹត្តទៅរយៈពេល ២ ម៉ោង ដោយបានពិនិត្យ ពិភាក្សា និងទទួលបានលទ្ធផលសំខាន់ៗតាមរបៀបវារៈនីមួយៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដូចតទៅ÷

**ក. សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកែសម្រួលយន្តការសម្របសម្រួលកែទម្រង់បី បូក មួយ**

- អង្គប្រជុំបានពិនិត្យនិងពិភាក្សាលើការបញ្ចូលលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ នៅក្នុងសេចក្តីសម្រេចផ្លូវការនៃយន្តការកែទម្រង់ បី បូក មួយ តែម្តង ដែល **អ.គ.ហ.** បានលើកឡើងនូវជម្រើសចំនួន២ គឺ ទី១ រៀបចំជាសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងទី២ រៀបចំជាសេចក្តីសម្រេចរួមរបស់ប្រធានគណៈកម្មាធិការកែទម្រង់ទាំង ៤ ។
- លេខាធិការដ្ឋានកែទម្រង់នីមួយៗ បានឯកភាពជ្រើសរើសយកជម្រើសទី១ ដោយត្រូវរៀបចំជាសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងបានឯកភាពស្នើសុំរយៈពេល ១ ខែ ដើម្បីស្នើសុំគោលការណ៍និងការណែនាំពីប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ។
- ទន្ទឹមនេះ អង្គប្រជុំបានសម្រេចជាគោលការណ៍ថា សេចក្តីសម្រេចនេះនឹងត្រូវរៀបចំអនុលោមតាមតាមរចនាសម្ព័ន្ធថ្មីនៃលេខាធិការដ្ឋានកែទម្រង់ដែលមានតម្រូវការចាំបាច់ក្នុងការកែសម្រួលរចនាសម្ព័ន្ធ និងបន្ទាប់ពីរចនាសម្ព័ន្ធថ្មីនេះ ត្រូវបានអនុម័ត។

**ខ. ការរៀបចំទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់បី បូក មួយ**

- តាមការឯកភាពរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ និងការឯកភាពមូលមតិរវាងលេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ **អ.គ.ហ.** បានជ្រើសរើសជំនាញការក្នុងស្រុក ១ រូប ដើម្បីរៀបចំនូវទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១។
- អង្គប្រជុំបានស្តាប់ការធ្វើបទបង្ហាញនិងពិភាក្សាផ្តល់យោបល់ ព្រមទាំងបានលើកឡើងនូវតម្រូវការក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ ដែលជំនាញការក្នុងស្រុកបានរៀបចំនេះ។
- ក្នុងន័យខាងលើនេះ អង្គប្រជុំបានសម្រេចស្នើឱ្យជំនាញការធ្វើការផ្ទាល់ជាមួយនឹងមន្ត្រីបង្គោលនៃលេខាធិការដ្ឋាននីមួយៗ ដោយមានការសម្របសម្រួលពី **អ.គ.ហ.** សំដៅកែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងនិងមានភាពគ្រប់ជ្រុងជ្រោយ។

**គ. ផ្សេងៗ**

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានឯកភាពតាមស្មារតីអង្គប្រជុំ និងធ្វើការរាយការណ៍ជូនថ្នាក់ដឹកនាំ **គ.ជ.អ.ប.** ដើម្បីរៀបចំកិច្ចប្រជុំឆ្លាស់វេនពេលបន្ទាប់។
- ប្រធានអង្គប្រជុំ ស្នើលេខាធិការដ្ឋាននីមួយៗ ដែលរៀបចំកិច្ចប្រជុំឬវិបស្សនាតាមលេខាធិការដ្ឋាននីមួយៗ សូមឱ្យមានការចូលរួមពីតំណាងការដ្ឋានកែទម្រង់ផងទៀត។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប ជាវបាយការណ៍ និងមេត្តាពិនិត្យសម្រេចតាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ើល ចំរើន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
ដើម្បីពិនិត្យនិងសម្រេច
ថ្ងៃ ៣រោច កើត ខែ ធ្នូ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២១
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី 21 ខែ [illegible] ឆ្នាំ២០២១
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធទី២៥

# ឧបសម្ព័ន្ធទី២៥. របាយការណ៍ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ស្តីពី លទ្ធផលនៃកិច្ចប្រជុំយន្តការសម្របសម្រួលការងារកែទម្រង់ បី បូក មួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:...៣០៥...សហវ/អគក...

ខុទ្ទកាល័យ ឧ.ន.រ.ម
ចូលថ្ងៃទី 11.8.20 ម៉ោង........
លេខ...A12020.31.49.......

ថ្ងៃ ៥ ខែ ៤ រោច ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២០

សូមគោរពជូន
ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជា ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំនៃយន្តការសម្របសម្រួលការងារកែទម្រង់ ៣ បូក ១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ កន្លងទៅនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានរៀបចំកិច្ចប្រជុំវិសាមញ្ញនៃយន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ បូក ១ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត **ទំហិល ចិរឹន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃ **អ.គ.ហ.** ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត គឺលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំនេះ មានរបៀបវារៈជាសំខាន់ផ្តោតទៅលើការពិភាក្សាលើការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ ដែលត្រូវបានបង្អង់ដោយសារវិបត្តិកូវីដ-១៩។

ដូចនេះ ខ្ញុំសូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃកិច្ចប្រជុំនេះ ដើម្បីពិនិត្យនិងសម្រេចដូចតទៅ៖

**ក. ចំណុចគន្លឹះនៃកិច្ចប្រជុំ**

កិច្ចប្រជុំបានប្រព្រឹត្តទៅរយៈពេល ៣ ម៉ោង ដោយបានពិនិត្យនិងពិភាក្សាលើរបៀបវារៈចំនួន ៥ និងទទួលបានលទ្ធផលសំខាន់ៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដូចតទៅ៖

- ក្រសួងយុត្តិធម៌កំពុងរៀបចំកែសម្រួលនូវគោលនយោបាយដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំពុងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ១ ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

- ក្រសួងមុខងារសាធារណៈ បានរៀបចំរួចរាល់នូវសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ១០ ឆ្នាំ (២០២០-២០៣០) និងកំពុងពិនិត្យដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ក្រសួងមហាផ្ទៃ បានបញ្ចប់នូវសេចក្តីព្រាងឯកសារទស្សនាទានស្តីពីកម្មវិធីកែទម្រង់ ១០ ឆ្នាំ (២០២១-២០៣០) ក្នុងកម្រិតបច្ចេកទេស និងកំពុងដាក់ឆ្លងការពិភាក្សាកម្រិតថ្នាក់ដឹកនាំ
- ត្រូវចាត់ទុក ចក្ខុវិស័យនិងបេសកកម្ម ជាពន្លឺសម្រាប់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់នីមួយៗ។

**ខ. លទ្ធផលនៃកិច្ចប្រជុំ**

បន្ទាប់ពីបានពិភាក្សានិងចែករំលែកមតិយោបល់អំពីការងារសំខាន់ៗ ដូចបានលើកឡើងខាងលើរួចមក អង្គប្រជុំបានឯកភាពនិងសម្រេច ដើម្បីគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច ដូចតទៅ÷

- ស្នើឱ្យលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវផ្ញើសេចក្តីព្រាងកម្មវិធីនិងយុទ្ធសាស្ត្រកែទម្រង់នីមួយៗ មកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងប្រមូលសរុប នៅក្នុងរយៈពេល ១ ខែ បន្ទាប់ពីកិច្ចប្រជុំ។
- ស្នើរកិលការរៀបចំវិបស្សនា នៅក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ២០២០ ឬ ត្រីមាសទី១ ឆ្នាំ២០២១។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេច តាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# ឧបសម្ព័ន្ធទី២៦

# ឧបសម្ព័ន្ធទី២៦. របាយការណ៍ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២០ នៃយន្តការសម្របសម្រួលការងារកែទម្រង់ ៣ បូក ១



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ: ១០៧ សហវ/អគហ

លេខ ... 2002354

ថ្ងៃ ចន្ទ ០១ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២០

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវត្ថុ ÷** សំណើសុំពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រចាំត្រីមាសទី ១ ឆ្នាំ២០២០ នៃយន្តការសម្របសម្រួលការងារកែទម្រង់ ៣ បូក ១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលត្រូវជាប្រធានផ្លាស់វេន បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២០ នៃយន្តការសម្របសម្រួលការងារកែទម្រង់ទាំង ៣ បូក ១ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត **វង្សឹម ចំរើន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃ **អ.គ.ហ.** ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត គឺលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ គួរបញ្ជាក់ថា មុននឹងរៀបចំកិច្ចប្រជុំនេះ **អ.គ.ហ.** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ផ្ទៃក្នុងដើម្បីប្រមូលធាតុចូលពីគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចប្រជុំក្រុមមន្ត្រីបង្គោលគម្រិតបច្ចេកទេសរបស់លេខាធិការដ្ឋានកែទម្រង់ផងដែរ។

ដូចនេះ ខ្ញុំសូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃកិច្ចប្រជុំនេះ ដើម្បីពិនិត្យនិងសម្រេចដូចតទៅ÷

**ក. លទ្ធផលគន្លឹះៗនៃកិច្ចប្រជុំ**

កិច្ចប្រជុំបានប្រព្រឹត្តទៅរយៈពេល ៣ ម៉ោង ដោយបានពិនិត្យនិងពិភាក្សាលើរបៀបវារៈចំនួន ៥ និងទទួលបានលទ្ធផលសំខាន់ៗ ដែលខ្ញុំសូមគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដូចតទៅ÷

St.92 Sangkat Wat Phnom Khan Daun Penh Phnom Penh CAMBODIA ១ ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
Phone 855-23-430 791 Fax 855-23-430 745

**១. ការវាយតម្លៃដំណាក់កាលបច្ចុប្បន្ន សម្រាប់ជំហានបន្ទាប់**

*បច្ចុប្បន្ន កម្មវិធីកែទម្រង់នីមួយៗ កំពុងស្ថិតនៅក្នុងចំណុចរបត់គន្លឹះប្រហាក់ប្រហែលគ្នា គឺការបញ្ចប់ដំណាក់កាលមួយ ឈានឆ្ពោះទៅកាន់ដំណាក់កាលថ្មីមួយទៀត* ដែលមានដូចតទៅ៖

- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖
  - កំពុងស្ថិតនៅក្នុងឆ្នាំចុងក្រោយនៃដំណាក់កាលទី៣ "ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ៖ បច្ចុប្បន្ន អ.គ.ហ. កំពុងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី៣ (CAP 3) ដើម្បីជាមូលដ្ឋានក្នុងការរៀបចំនូវផែនការសកម្មភាពនៃដំណាក់កាលទី៤ (CAP 4) សម្រាប់ដំណាក់កាលទី៤ "គណនេយ្យភាពចំពោះសមិទ្ធកម្ម" ដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។
  - ការដាក់ចេញនូវយុទ្ធសាស្ត្រកែទម្រង់គន្លឹះទាំង ៥៖ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតួអង្គនិម្មាបនករនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានដាក់ចេញនូវយុទ្ធសាស្ត្រកែទម្រង់ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ៥ ធំៗ រួមមាន ៖ ១) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥, ២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ២០១៩-២០២៥, ៣) យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, ៤) យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥ និង ៥) យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥។
- កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៖
  - កម្មវិធីជាតិ ១០ ឆ្នាំ ត្រូវបានបញ្ចប់ ៖ កម្មវិធីកែទម្រង់នេះ ត្រូវបានចាប់ផ្តើមអនុវត្តតាមរយៈកម្មវិធីជាតិ ១០ ឆ្នាំ (២០១០-២០១៩) របស់ខ្លួន។ បច្ចុប្បន្ន កម្មវិធីនេះ ត្រូវបានពន្យារពេលអនុវត្តមួយឆ្នាំ សម្រាប់ឆ្នាំ២០២០ ដោយពុំទាន់បានរៀបចំនូវកម្មវិធីជាតិថ្មី នៅឡើយទេ។
  - ការដាក់ឱ្យអនុវត្តនូវរដ្ឋបាលឯកភាពនៅថ្នាក់ក្រុង-ស្រុក ៖ នៅក្នុងឆ្នាំ២០១៩ កន្លងមកនេះ ការអនុវត្តកម្មវិធីកែទម្រង់នេះ បានសម្រេចនូវសមិទ្ធផលដ៏ធំមួយជាប្រវត្តិសាស្ត្ររបស់ខ្លួន នោះគឺ ការរៀបចំរដ្ឋបាលឯកភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការបញ្ចូលការិយាល័យជំនាញមួយចំនួនចំណូលទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តែម្តង ដែលប្រការនេះ ក៏មាននូវចំណុចពាក់ព័ន្ធដល់ការគ្រប់គ្រងមន្ត្រីរាជការ និងការងារថវិកាផងដែរ។
- កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ៖ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ត្រូវបានបញ្ចប់ រីឯកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈថ្មី ដែលកំពុងនៅជាសេចក្តីព្រាងនៅឡើយ ត្រូវបានរៀបចំជាកម្មវិធីជាតិ ១០ ឆ្នាំ (២០២០-២០៣០) ដោយមាន *ចក្ខុវិស័យ គឺ រដ្ឋបាលសាធារណៈ ផ្តោតលើប្រជាជនជាស្នូល ដែលមានលក្ខណៈ ខ្លាំង ស្អាតស្អំ និងឆ្លាតវៃ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌។*
- កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ៖ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវបានបញ្ចូលក្នុងយន្តការកែទម្រង់ទាំង ៣ កាលពីឆ្នាំ២០១៨ តាមអនុសាសន៍របស់ **សម្តេចក្រឡាហោម ស ខេង**។ កម្មវិធីកែទម្រង់នេះ ត្រូវដឹកនាំដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងមានលេខាធិការដ្ឋាន

២

អចិន្ត្រៃយ៍មួយជាលេខាធិការ។ បច្ចុប្បន្ន កម្មវិធីកែទម្រង់នេះ នៅមិនទាន់មានឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្ររបស់ខ្លួននៅឡើយទេ រីឯលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក៏មិនទាន់មានទូររចនាសម្ព័ន្ធច្បាស់លាស់នៅឡើយដែរ។

២. **សេចក្តីព្រាងផែនការសកម្មភាពរួម ប្រចាំឆ្នាំ២០២០ ៖** សម្រាប់ឆ្នាំ២០២០ អគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់នីមួយៗ បានរៀបចំសេចក្តីព្រាងផែនការសកម្មភាព ដែលមានសរុបចំនួន ១៥ ដែលត្រូវអនុវត្តរៀងៗខ្លួន។ ជាគោលការណ៍ អង្គប្រជុំបានឯកភាពគាំទ្រលើផែនការសកម្មភាពនេះ និងណែនាំឱ្យក្រុមមន្ត្រីបង្គោលនៃលេខាធិការដ្ឋានទាំងអស់យកទៅពិភាក្សាសម្រួលរួមគ្នា មុននឹងចុះហត្ថលេខាដាក់ឱ្យអនុវត្តជាផ្លូវការ។

៣. **ការរៀបចំវិបស្សនាស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១ ៖** អង្គប្រជុំបានពិនិត្យនិងពិភាក្សាលើការរៀបចំវិបស្សនាស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ ដែលបានទទួលការឯកភាពជាគោលការណ៍ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ក្នុងពេលកន្លងមក។ ដើម្បីធានាប្រសិទ្ធភាពនៃការងារនេះ លេខាធិការដ្ឋានកែទម្រង់ ៣ ផ្សេងទៀត បានសម្រេចផ្តល់ជូន អ.គ.ម. ក្នុងការដឹកនាំនិងសម្របសម្រួលការងារនេះ។ ដូចនេះ ដើម្បីប្រសិទ្ធភាពការងារ អ.គ.ម. នឹងដឹកនាំប្រជុំសម្របសម្រួលលេខាធិការដ្ឋានកែទម្រង់នីមួយៗ ដោយមិនរង់ចាំកិច្ចប្រជុំប្តូរវេនគ្នាតាមត្រីមាសនោះឡើយ។

**ខ. សំណើសុំពិនិត្យនិងសម្រេចលើការរៀបចំវិបស្សនាស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក១**

បន្ទាប់ពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់អំពីការងារសំខាន់ៗ ដូចបានលើកឡើងខាងលើរួចមក អង្គប្រជុំបានឯកភាពនិងសម្រេចជាពិសេសលើការរៀបចំវិបស្សនាស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ ដើម្បីគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច ដូចតទៅ៖

១. សូមគោរពស្នើសុំការពិនិត្យនិងសម្រេចលើលទ្ធផលរំពឹងទុក (expected output) របស់វិបស្សនា ដែលអាចមាន ២ ជម្រើស ៖

- <u>ជម្រើសទី១</u> ៖ លទ្ធផលនៃវិបស្សនា គឺផលិតបាននូវ ចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ តែម្តង។ ជម្រើសនេះ នឹងតម្រូវឱ្យមានការសិក្សានិងពិភាក្សាយ៉ាងស៊ីជម្រៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់នីមួយៗ ដើម្បីស្វែងរកចំណុចសង្គតិភាពរួម សំដៅផលិតបាននូវចក្ខុវិស័យរួមគ្នាមួយ។
- <u>ជម្រើសទី២</u> ៖ លទ្ធផលនៃវិបស្សនា គឺការជំរុញឱ្យយល់ច្បាស់ទស្សនាទានជាបឋមសិន ដើម្បីជាដើមទុនក្នុងការកំណត់បញ្ហាប្រឈមនិងដំណោះស្រាយលើចំណុចសង្គតិភាពនិងប្រទាក់ក្រឡាទាំងឡាយ ជាពិសេស នៅក្នុងបរិបទនៃចំណុចរបត់ដ៏សំខាន់នៃការងារកែទម្រង់ ទាំង ៣ បូក ១ ដូចបានគូសបញ្ជាក់នៅខាងលើ រីឯចក្ខុវិស័យនិងយុទ្ធសាស្ត្រ នឹងត្រូវកំណត់នៅពេលក្រោយក្នុងវេទិកាផ្សេង (ឬវិបស្សនាលើកទី២)។

២. សូមគោរពស្នើសុំការពិនិត្យនិងសម្រេចលើការរៀបចំចក្ខុវិស័យនេះ ក្នុងរយៈពេលវែងពី ៥ ទៅ ១០ ឆ្នាំ។

៣. សូមគោរពស្នើឡើងជាបឋម នូវប្រធានបទចំនួន ៥ ដែលត្រូវជជែកពិភាក្សាលម្អិតនៅក្នុងវិបស្សនា ៖

- **រចនាសម្ព័ន្ធរដ្ឋបាលថែនដី** ៖ ដឹកនាំនិងសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប.
- **ធនធានមនុស្ស** ៖ ដឹកនាំនិងសម្របសម្រួលដោយលេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ
- **ថវិកាកម្មវិធី** ៖ ដឹកនាំនិងសម្របសម្រួលដោយរដ្ឋលេខាធិការប្រចាំការនៃ កសហវ (ឯកឧត្តម វង្ស វិស្សុត)
- **ការផ្ទេរមុខងារ/ប្រតិភូកម្មមុខងារ** ៖ ដឹកនាំនិងសម្របសម្រួលដោយ លេខាធិការដ្ឋាន គ.ជ.អ.ប.

៣



ឧបសម្ព័ន្ធទី២៦

- អធិការកិច្ច/ សវនកម្មផ្ទៃក្នុង ÷ ដឹកនាំនិងសម្របសម្រួលដោយរដ្ឋលេខាធិការទទួលបន្ទុក នៃ គសហវ (ឯកឧត្តម ស្មើង សុខុម)។

៤. សូមគោរពស្នើសុំរៀបចំក្នុងរយៈពេល ១ ថ្ងៃពេញ នៅកាលបរិច្ឆេទណាមួយ ក្នុងអំឡុងត្រីមាសទី៣ ឬ ត្រីមាសទី៤ ឆ្នាំ២០២០ ដោយសូមគោរពស្នើសុំរៀបចំនៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ។

៥. សូមគោរពស្នើសុំវត្តមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជាប្រធានគណៈអធិបតីបើកកម្មវិធីពេលព្រឹក និងគោរពស្នើសុំវត្តមាន **សម្តេចក្រឡាហោម ស ខេង** ជាប្រធានគណៈអធិបតីបិទកម្មវិធី។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ និងមេត្តាពិនិត្យសម្រេច តាមសំណើនីមួយៗខាងលើ ឬមានការណែនាំបន្ថែមជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ ស៊ីលវ៉ា**

# ឧបសម្ព័ន្ធទី២៧

# ឧបសម្ព័ន្ធទី២៧. របាយការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី លទ្ធផលនៃកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកំណែទម្រង់ ទាំង ៣ បូក មួយ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
លេខាធិការដ្ឋាន

**របាយការណ៍**
**លទ្ធផលកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកំណែទម្រង់ទាំងបី បូក មួយ**
**ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩**

កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៩:០០នាទីព្រឹក នៅក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំកិច្ចប្រជុំប្តូរវេនប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ ក្នុងក្របខណ្ឌការដ្ឋានកំណែទម្រង់ទាំងបី បូក មួយ ដឹកនាំដោយ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានសមាសភាពចូលរួមពី **ឯកឧត្តម ថោ សេដ្ឋាណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ **ឯកឧត្តម ម៉ាន់ ចំរើន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) **ឯកឧត្តម ខាន់ វណ្ណៈ** អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងយុត្តិធម៌ និងជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ តំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) និងមន្ត្រីជំនាញពាក់ព័ន្ធសរុបចំនួន២៣រូប ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១. ពិភាក្សាអំពីបញ្ហាប្រឈម និងវិធានការដោះស្រាយនៃការអនុវត្តផែនការសកម្មភាពរួមរវាងកម្មវិធីកែទម្រង់ទាំងបី បូក មួយ និងទិសដៅបន្ទាប់
២. ពិនិត្យសំណើដាក់បញ្ចូលផែនការសកម្មភាពរួមថ្មីនៃកម្មវិធីកែទម្រង់ទាំងបី បូក មួយ សម្រាប់ឆ្នាំ២០២០
៣. ការរៀបចំសិក្ខាសាលាភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ជាមួយកំណែទម្រង់ដទៃទៀត និងគោលនយោបាយតាមវិស័យ (រៀបចំនៅត្រីមាសទី២ ឆ្នាំ២០២០)
៤. បញ្ហាផ្សេងៗ ដែលស្នើរបៀបវារៈដោយកម្មវិធីកែទម្រង់ទាំងបីផ្សេងទៀត។

អង្គប្រជុំបានពិភាក្សា និងសម្រេចដូចតទៅ៖

<u>របៀបវារៈទី១និងទី២</u>៖ ការអនុវត្តផែនការសកម្មភាពរួមកន្លងមក និងផែនការសកម្មភាពរួមថ្មីឆ្នាំ២០២០

- លេខាធិការដ្ឋានកំណែទម្រង់ទាំងបី បូក មួយ បានឯកភាពជាគោលការណ៍ក្នុងការរៀបចំផែនការសកម្មភាពរួមកំណែទម្រង់ទាំងបី បូក មួយ ឱ្យបានរួចរាល់នៅសប្តាហ៍ទី១ ខែមករា ឆ្នាំ២០២០ ដោយមានការឯកភាពពីប្រធានស្ថាប័ន។

<u>របៀបវារៈទី៣</u>៖ ការរៀបចំសិក្ខាសាលាភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈជាមួយកម្មវិធីកំណែទម្រង់ដទៃទៀត និងគោលនយោបាយតាមវិស័យ (រៀបចំនៅត្រីមាសទី២ ឆ្នាំ២០២០)

- ឯកភាពឱ្យអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ទទួលបន្ទុករៀបចំសិក្ខាសាលា ដើម្បីរៀបចំចក្ខុវិស័យរួមនៃកំណែទម្រង់ទាំងបី បូក មួយ។

-១-

ឧបសម្ព័ន្ធទី២៧

<u>របៀបវារៈទី៤៖</u> បញ្ហាផ្សេងៗ

- ឯកភាពឱ្យមានការចាត់តាំងក្រុមជនបង្គោលក្នុងលេខាធិការដ្ឋាននីមួយៗ ចំនួន០៣រូប ដែលសម្រេចដោយប្រធានលេខាធិការដ្ឋាននីមួយៗ និងកំណត់ពីតួនាទីនិងភារកិច្ចឱ្យបានច្បាស់លាស់ ដែលជាយន្តការក្នុងការសម្របសម្រួលការងាររវាងការដ្ឋានកំណែទម្រង់ទាំងបី បូក មួយ ដោយស្នើសុំឱ្យមានការសម្រេចឱ្យបាននៅសប្តាហ៍ទី១ ខែមករា ឆ្នាំ២០២០
- ស្នើសុំឱ្យអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិចារណាលើយន្តការអធិការកិច្ចនិងសវនកម្ម ដោយដាក់ជាប្រព័ន្ធរួមក្នុងការអនុវត្តនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ស្នើសុំឱ្យអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិនិត្យមើលលទ្ធភាពក្នុងការផ្ទេរធនធានហិរញ្ញវត្ថុឱ្យទៅរដ្ឋបាលឯកភាពថ្មីរបស់ ក្រុង ស្រុក ខណ្ឌ ឱ្យទាន់ពេលវេលាស្របទៅនឹងអនុក្រឹត្យដែលបានចេញក្នុងខែធ្នូ ឆ្នាំ២០១៩
- ស្នើសុំឱ្យអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ពិចារណាលើលទ្ធភាពក្នុងការលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់បីផ្សេងទៀត
- ស្នើសុំឱ្យក្រសួងមុខងារសាធារណៈ រៀបចំសេចក្តីជូនដំណឹងនិងផ្ញើជូនគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការផ្អាកការផ្ទេរមន្ត្រីពីការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ទៅមន្ទីរជំនាញរបស់ខ្លួន និងអង្គភាពផ្សេងៗទៀត នៅក្នុងដំណាក់កាលធ្វើសមាហរណកម្មមន្ត្រីនៅក្នុងរដ្ឋបាលរបស់ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តអនុក្រឹត្យដែលបានចេញក្នុងខែធ្នូ ឆ្នាំ២០១៩នេះឱ្យមានប្រសិទ្ធភាព
- ស្នើសុំឱ្យលេខាធិការដ្ឋាន គ.ក.រ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម និងថ្នាក់ដឹកនាំទទួលបន្ទុកនៃក្រសួងមុខងារសាធារណៈ រៀបចំអង្គរដ្ឋបាល
- លេខាធិការដ្ឋាន គ.ក.រ នឹងតាមដានទៅលើប្រាក់បំណាច់មុខងាររបស់ប្រធានការិយាល័យថ្មី និងអនុប្រធានការិយាល័យថ្មី នៃរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌ ដែលបានធ្វើសមាហរណកម្ម ដោយធ្វើយ៉ាងណាមិនឱ្យប្រាក់បំណាច់មុខងារបច្ចុប្បន្នទាបជាងប្រាក់បំណាច់មុខងារដែលធ្លាប់ទទួលបានពីមុន
- ក្រសួងមុខងារសាធារណៈ សហការជាមួយស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំសិក្ខាសាលាកម្រិតអន្តរជាតិ ដោយផ្តោតលើការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈដោយពិនិត្យមើលយន្តការវិសហមជ្ឈការ និងវិមជ្ឈការ នៅក្នុងឆ្នាំ២០២០ខាងមុខនេះ ដោយមានការចូលរួមពីគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសាលាភូមិន្ទរដ្ឋបាល។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១១:០០នាទីព្រឹក ថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ។

ថ្ងៃចន្ទ ១២ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩
**អ្នកធ្វើរបាយការណ៍**

**ខុច ចំណាន**

បានឃើញ និងឯកភាព
ថ្ងៃ សុក្រ ២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩
**ប្រធានអង្គប្រជុំ**

**យង់ ម៉ិនណា**

-៥-

# ឧបសម្ព័ន្ធទី២៨

# ឧបសម្ព័ន្ធទី២៨. របាយការណ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស្ដីពី លទ្ធផលនៃកិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌនៃការងារកែទម្រង់ទាំង៣ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:......................................................

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៨

**របាយការណ៍**
**ស្ដីពី**
**លទ្ធផលនៃកិច្ចប្រជុំពិភាក្សាក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ទាំង៣ និង**
**លេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**

កាលពីថ្ងៃអង្គារ ៦ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០១៨ នៅវេលាម៉ោង ៩ ព្រឹក នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំពិភាក្សាក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ទាំង៣ និងការពិភាក្សាជាមួយនឹងលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយឯកឧត្តមបណ្ឌិត **វ៉ោហ្វ ចំរើន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំបានប្រព្រឹត្តទៅរយៈពេល ៣ ម៉ោង ដោយមានរបៀបវារៈ ចំនួន ៧ ដូចតទៅ÷

១. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ២០១៧ និងសកម្មភាពឆ្នាំ ២០១៨
២. បច្ចុប្បន្នកម្មផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៨
៣. បុងធារនីតិកម្ម និងការកែទម្រង់
៤. ផែនការសកម្មភាពកែទម្រង់ទាំង ៤
៥. ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស
៦. កិច្ចដំណើរការនិងយន្តការសម្របសម្រួលរវាងការងារកែទម្រង់ទាំង៤
៧. ផ្សេងៗ

ជាកិច្ចចាប់ផ្ដើម, ឯកឧត្តមបណ្ឌិត **វ៉ោហ្វ ចំរើន** បានគូសបញ្ជាក់បន្ថែមជូនអង្គប្រជុំ អំពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "មូលហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា" កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ និងនិភាទានុសាសន៍របស់ឯកឧត្តម **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឱ្យពិចារណាលទ្ធភាពក្នុងការបញ្ចូលកម្មវិធីកែទម្រង់ច្បាប់និងវិស័យយុត្តិធម៌ ជាមួយនឹងយន្តការកែទម្រង់ទាំងបីដែលមានស្រាប់។

បន្ទាប់ពីបានពិភាក្សាយ៉ាងស្វាះស្វាយនិងស៊ីជម្រៅ លើគ្រប់ចំណុចភាពល្អមក អង្គប្រជុំបានសម្រេចគោរពរាយការណ៍ ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យនិងសម្រេច លើចំណុចដូចតទៅ÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ១ ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

**ក. កិច្ចការសម្រេចបានក្នុងឆ្នាំ ២០១៨**

១. ការរៀបចំ និងដាក់ឱ្យអនុវត្ត អនុក្រឹត្យស្តីពីការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ដែលផ្តោតលើវិស័យអប់រំ និងសុខាភិបាល ជាដំណាក់កាលដំបូង

២. ការចុះត្រួតពិនិត្យនិងជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល សម្រាប់ការិយាល័យច្រកចេញចូលតែមួយក្នុងស្រុក/ក្រុង គោលដៅខេត្តបាត់ដំបង

៣. ការចុះត្រួតពិនិត្យ និងវាយតម្លៃលើមូលនិធិក្រុងស្រុក ដែលត្រូវបានដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ការរៀបចំក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុ

៤. ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "**មូលហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល**" សម្រាប់យុវជន សរុបចំនួន ប្រមាណ ៦០០ រូប កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨។

**ខ. កិច្ចការដែលពុំទាន់សម្រេចបាន និងបន្តអនុវត្តក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០១៨**

១. ការរៀបចំក្របខ័ណ្ឌ និងយន្តការអនុវត្តទណ្ឌកម្មចំពោះការគ្រប់គ្រងធនធានសាធារណៈ

២. ការសិក្សាពាក់ព័ន្ធនឹងបញ្ហារចនាសម្ព័ន្ធស្ថាប័ន ដោយយក ក្រុងស្រុក ចំនួន១២ ពីឆ្នាំ ២០១៧ មកសិក្សា ដើម្បីកែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យមានសមានុពលភាពជាមួយនឹងប្រព័ន្ធដំណើរការការងារថ្មីដែលរួមមានផ្នែករដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ និងបច្ចេកទេស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៣. ការវិភាគមុខងារ និងការត្រួតពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង-ស្ថាប័ន ត្រូវបានអនុវត្តនឹងធ្វើវិចារណកម្ម

៤. ការបង្កើនគុណភាពលើការកសាងសមត្ថភាព និងការបណ្តុះបណ្តាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៥. ការរៀបចំនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុ (គោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម ការអនុវត្តការប្រមូល ចំណូលផ្ទាល់, ឧបករណ៍វិនិយោគ សម្រាប់រដ្ឋបាល ថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា, ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ, ថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា)

៦. ការរៀបចំនិងដាក់ឱ្យអនុវត្តយន្តការស្ថាប័នគាំទ្រភាពជាម្ចាស់, ភាពជាអ្នកដឹកនាំ និងការលើកទឹកចិត្តការងារកែទម្រង់

៧. ការសិក្សាស្រាវជ្រាវអំពីលិខិតបទដ្ឋាន សេចក្តីណែនាំ និងនីតិវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ, ភាពជាដៃគូ និងបញ្ហានានាដែលរាំងដល់ការកំណត់ និងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ក្រុង ស្រុក និងឃុំ សង្កាត់ និងការពិនិត្យនិងកែសម្រួលលិខិតបទដ្ឋាន សេចក្តីណែនាំ និងនីតិវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ភាពជាដៃគូ និងបញ្ហានានាដែលរាំងដល់ការកំណត់ និងការអនុវត្តមុខងារជាអាណត្តិទូទៅ

៨. ការរៀបចំផែនការសិក្ខាសាលាផ្សព្វផ្សាយ "**មូលហេតុ សមិទ្ធផល និងទស្សនវិស័យការងារកែទម្រង់របស់រាជរដ្ឋាភិបាល**" ក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

**គ. ទស្សនវិស័យសម្រាប់ការអនុវត្តការងារ**

ឆ្លងតាមការពិភាក្សាយ៉ាងស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយនៃលេខាធិការដ្ឋានកែទម្រង់ទាំងបួន, ទស្សនវិស័យ សម្រាប់ការអនុវត្តនូវយន្តការរួមនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ដែលត្រូវស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** មានដូចតទៅ៖

១. សិក្ខាសាលាកែទម្រង់ទាំងបួន ក្នុងក្របខ័ណ្ឌទូទាំងប្រទេស គួររៀបចំឱ្យមានការរំលេចឡើងនូវភាពផុសភ្ជាប់គ្នារវាងអ្នកកែ អ្នកកាន់ និងអ្នកទទួលផល ដោយកែប្រែការប្រព្រឹត្តទៅនៃអង្គសិក្ខាសាលាពី **សិក្ខាសាលាផ្សព្វផ្សាយជូនយុវជន** ទៅជា **សិក្ខាសាលាពិគ្រោះយោបល់** ជូនដល់មន្ត្រីរាជការ និងយុវជន

២. ការបញ្ចូលកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ទៅក្នុងយន្តការកែទម្រង់ទាំងបីដែលមានស្រាប់ តាមរយៈការសម្រេចចិត្តកម្រិតនយោបាយនៃថ្នាក់ដឹកនាំកម្មវិធីកែទម្រង់ទាំងបួន ដែលអាចជ្រើសរើសជម្រើសយន្តការកែទម្រង់បី

២

បួន មួយ ឬ យន្តការកែទម្រង់ទាំងបួន)។ ជម្រើសណាមួយនៅទីនេះ នឹងត្រូវយកមកបញ្ចូលជាសកម្មភាពអនុវត្តក្នុងផែនការសកម្មភាពប្រចាំឆ្នាំតែម្តង។

**ឃ. សំណើសុំការសម្រេច**

ទន្ទឹមនេះ កិច្ចប្រជុំបានពិភាក្សាលើបញ្ហានៃប្រសិទ្ធភាពការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន ដែលបាននិងកំពុងអនុវត្តក្រោមយន្តការមិនអចិន្ត្រៃយ៍ និងក្រោមយន្តការជាក្រុមការងារ។ នៅក្នុងទស្សនវិស័យនៃការជំរុញការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព អង្គប្រជុំបានឯកភាពគោរពស្នើសុំការពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក្នុងការអនុញ្ញាតឱ្យក្រុមការងារកែទម្រង់ទាំង ៣ សិក្សាលើការរៀបចំបញ្ចូលនូវក្រុមការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន ជារចនាសម្ព័ន្ធអចិន្ត្រៃយ៍ នៅក្នុងក្របខ័ណ្ឌរដ្ឋបាលនៅតាមក្រសួង-ស្ថាប័ន តែម្តង។

កិច្ចប្រជុំបានបិទបញ្ចប់នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ក្នុងស្មារតីសាមគ្គីភាព និងស្មារតីកែទម្រង់។

**អ្នកធ្វើរបាយការណ៍**

**ខុទ្ទី សង្គ្រា**

បានពិនិត្យ ឯកភាព និងគោរពជូន

ឯកឧត្តមអគ្គលេខាធិការ នៃ អ.ត.ហ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៨

**អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត ហ៊ើល ចំរើន**

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជា ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៨

**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

.................................................

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ឧបសម្ព័ន្ធទី២៩

# ឧបសម្ព័ន្ធទី២៩. របាយការណ៍ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីលទ្ធផលនៃសិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:.............................................

*ថ្ងៃ ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៨*

**របាយការណ៍**
**ស្តីពី**
**លទ្ធផលនៃ សិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល**

កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហការជាមួយ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំង សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) បានរៀបចំសិក្ខាសាលាស្តីពី "**បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា**" ជូនដល់ថ្នាក់ដឹកនាំយុវជន នៃ ស.ស.យ.ក. ទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការចូលរួមពី ឯកឧត្តមបណ្ឌិត **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធាន ស.ស.យ.ក តំណាងឯកឧត្តម **ហ៊ុន ម៉ានី** ប្រធាន ស.ស.យ.ក, ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនថិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, ថ្នាក់ដឹកនាំ ព្រមទាំងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន/លេខាធិការនៃកម្មវិធីកំណែទម្រង់ទាំងបួន និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សរុបសមាសភាពប្រមាណ ៦០០រូប។

សិក្ខាសាលានេះ ទទួលបានលទ្ធផលជារួម ដូចតទៅ÷

**ក. កម្មវិធីបើក**

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគូសបញ្ជាក់ជូនអង្គសិក្ខាសាលាថា ការងារកែទម្រង់បានចាក់ឫសគល់យ៉ាងជ្រៅ នៅក្នុងកិច្ចដំណើរការអភិវឌ្ឍប្រទេសកម្ពុជា ចាប់តាំងពីពេលក្រោយពីការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងបានឆ្លងកាត់កែទម្រង់របបសេដ្ឋកិច្ចជាតិ ពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារ ខណៈដែលស្ថាប័ននយោបាយកំពុងផ្លាស់ប្តូរជាបណ្តើរៗ និងបានបន្តរហូតការដាក់ឱ្យមានដំណើរការគ្រប់ជ្រុងជ្រោយនូវកម្មវិធីកែទម្រង់ ទៅតាមគ្រប់វិស័យឱ្យស្របទៅតាមឧត្តមានុវត្តន៍ជាអន្តរជាតិ រហូតដល់បច្ចុប្បន្ន។ នេះគឺជាការដឹកនាំនយោបាយសេដ្ឋកិច្ចទីផ្សារប្រជាជន ដែលគួរត្រូវបានប្រសិទ្ធនាមថា "**ហ៊ុនសែនណូមិកស៍** (Hunsenomics)" មានន័យថាជា ការដឹកនាំឆ្លងកាត់ដំណាក់កាលជាច្រើន នៅក្នុងរយៈពេលវែង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone 855-23-430 791 Fax: 855-23-430 745

សំដៅឆ្ពោះទៅកាន់ការកសាងខឿនសេដ្ឋកិច្ចទំនើបមួយរបស់កម្ពុជា ឈរលើគោលការណ៍ និងយន្តការសេដ្ឋកិច្ចទីផ្សារបើកចំហ ហើយប្រើការគ្រប់គ្រងយន្តការសេដ្ឋកិច្ចទីផ្សារនេះ ឱ្យបម្រើផលប្រយោជន៍ប្រជាជនគ្រប់ស្រទាប់ សំដៅធានាឱ្យប្រជាជាតិកម្ពុជាទាំងមូល អាចក្តាប់ជាប់ និងធ្វើជាម្ចាស់យ៉ាងពេញលេញ លើជោគវាសនារបស់ខ្លួន ក្នុងភាពថ្កុំថ្កើងរុងរឿង។ មហាសមិទ្ធផលនេះ មិនអាចកើតឡើងដោយឯកឯង ឬគ្មានការលះបង់កំលាំងកាយចិត្តបានឡើយ ពីសំណាក់យុវជនជំនាន់មុន ជាពិសេសគឺក្រោមអគ្គមគ្គុទ្ទេសក៍ឧត្តុង្គឧត្តមរបស់ អគ្គមហាបុរសនៃយើងទាំងអស់គ្នាគឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានលើកទឹកចិត្តឱ្យយុវជនទាំងអស់ក្នុងសិក្ខាសាលាយកចិត្តទុកដាក់លើខ្លឹមសារនៃបទបង្ហាញ និងចូលរួមក្នុងវគ្គពិភាក្សាឱ្យបានផុសផុល។

ឯកឧត្តម **សាយ សំអាល់** បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ការដ្ឋាននៃកំណែទម្រង់ទាំងបួនរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំកម្មវិធីដ៏មានខ្លឹមសារ និងសារៈសំខាន់នេះ។ ឯកឧត្តម ក៏បានគូសបញ្ជាក់ផងដែរថា គោលបំណងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា គឺប្រែក្លាយយុវជនទៅជាពលរដ្ឋល្អសម្រាប់ប្រទេសជាតិ តាមរយៈ÷

១. ការទទួលបានការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
២. ការលើកទឹកចិត្តឱ្យមាន នវានុវត្តន៍ ការច្នៃប្រឌិតផ្សេងៗ
៣. ការលើកកំពស់យេនឌ័រ
៤. ការអភិវឌ្ឍកាយសម្បទា ចំណេះដឹង និងសីលធម៌ និង
៥. ការបង្កឱ្យមានការចូលរួមបញ្ចេញមតិ។

ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានគូសបញ្ជាក់ថាការរៀបចំសិក្ខាសាលានេះ ជាទិកាសដ៏កម្រមួយ ដែលអគ្គលេខាធិការដ្ឋាន/លេខាធិការដ្ឋានកែទម្រង់ទាំងបួន បានប្រមូលផ្តុំបង្កើតជាសិក្ខាសាលាក្នុងក្របខ័ណ្ឌរួមដើម្បីចែករំលែកបទពិសោធន៍ដល់យុវជនដែលជាកំលាំងស្នូលនិងជាអ្នកបន្តវេនរបស់ប្រទេសជាតិ។

**១. ទស្សនបទបង្ហាញ**

វគ្គពេលព្រឹកនៃសិក្ខាសាលាបានប្រមូលផ្តុំដោយបទបង្ហាញអំពីការងារកែទម្រង់ស្នូលទាំង ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយវាគ្មិនដ៏មានគុណវុឌ្ឍិបរិបូរ ក្នុងឋានៈជាអ្នកកាន់ការដោយផ្ទាល់ លើការងារកែទម្រង់ជាគន្លឹះទាំង ៤ ដែលមានដូចជា÷

១. ឯកឧត្តម **គង់ សុគី** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានបង្ហាញយ៉ាងជាក់ច្បាស់ថា ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឱ្យមានគុណវុឌ្ឍិនិងស្តង់ដារវិជ្ជាជីវៈស្របតាមឧត្តមានុវត្តន៍អន្តរជាតិ, ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងការអភិវឌ្ឍយន្តការស្ថាប័ន ប្រកបដោយវិចារណញ្ញាណ ប្រសិទ្ធភាព និងកិច្ចដំណើរការជាប្រព័ន្ធ នៃស្ថាប័នសាធារណៈ, ការកែទម្រង់បានសម្រេចជាសារវន្ត នូវការកែលម្អប្រព័ន្ធបៀវត្សនិងប្រាក់បំណាច់នានា (មានការដំឡើងបៀវត្សមន្ត្រីរាជការដល់លើសពីមួយលានរៀល, ការបើកបៀវត្សទៀងទាត់និងដល់សាមីខ្លួន)ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការរៀបចំជាថ្មីនូវប្រព័ន្ធ

មុខងារសាធារណៈ អង្គវិជ្ជាជីវៈ ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីរាជការ ការគ្រប់គ្រងកិច្ចដំណើរការនៃវិចារណកម្ម/សនិទានកម្មស្ថាប័ន ជាដើម។

២. ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរំលេចច្បាស់ថា នៅក្នុងបុព្វហេតុនៃការលើកតម្កើងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការផ្តល់សេវាសាធារណៈរួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន, ការកែទម្រង់សម្រេចបានសមិទ្ធផលគួរជាទីកត់សម្គាល់ ជាអាទិ៍ ការរៀបចំក្របខ័ណ្ឌច្បាប់និងបទដ្ឋានអនុវត្តយន្តការស្ថាប័ននិងការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ កិច្ចដំណើរជាប្រក្រតីនៃការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការជាប្រក្រតីនៃការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការនៃការផ្ទេរនិងប្រតិភូកម្មមុខងារពីរដ្ឋបាលថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការបង្កើនសិទ្ធិអំណាចនិងការទទួលខុសត្រូវ ក្នុងវដ្តថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការហិរញ្ញវត្ថុ នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាដើម។

៣. ឯកឧត្តម **ម៉ី ចន្ទសុខា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចង្អុលបង្ហាញថា ដើម្បីសម្រេចបានប្រព័ន្ធថវិកាមួយ ដែលមានបូរណភាពពេញលេញនៃការគោរពវិន័យថវិកា ស័ក្តិសិទ្ធភាពនៃការវិភាជន៍ថវិកា ព្រមទាំងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ, ការកែទម្រង់សម្រេចបានពេញលេញនូវ ភាពជឿទុកចិត្តបាននៃថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ព្រមទាំងកំពុងផ្សារភ្ជាប់កាន់តែជិតស្និទ្ធរវាងថវិកានិងគោលនយោបាយ ពោលគឺកំណើនសេដ្ឋកិច្ចរក្សាបាន ជុំវិញ ៧% ក្នុងមួយឆ្នាំ អតិផរណាទាបអាចគ្រប់គ្រងបានជុំវិញ ៣.៥% ក្នុងមួយឆ្នាំ មូលដ្ឋានចំណូលកាន់តែទូលាយនិងគ្រប់គ្រាន់កាន់តែមានប្រសិទ្ធភាព រីឯចំណាយកាន់តែមានលទ្ធភាពទូលំទូលាយជាងមុនទ្វេដង ជាមួយនឹងការគោរពវិន័យនិងធានាប្រសិទ្ធភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ពិសេសជួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល កាន់តែចំគោលដៅអាទិភាព ឆ្លើយតបបានទាន់សភាព-ការណ៍ចំពោះមុខ និងទាន់តម្រូវការចាំបាច់ ដូចជាការគាំទ្រដល់ការកែទម្រង់តាមវិស័យអាទិភាពនានាជាដើម។

៤. ឯកឧត្តម **ជិន ម៉ាលីន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានគូសបញ្ជាក់ថា នៅក្នុងបុព្វហេតុនៃការពង្រឹងនីតិរដ្ឋ និងការធានាយុត្តិធម៌សង្គម, ការកែទម្រង់សម្រេចបានសមិទ្ធផលយ៉ាងច្រើន ជាអាទិ៍ ការធ្វើទំនើបកម្មប្រព័ន្ធខ្មែរសំខាន់ៗដែលជាសសរស្តម្ភនៃនីតិរដ្ឋ ការពង្រឹងរចនាសម្ព័ន្ធស្ថាប័ននៃវិស័យយុត្តិធម៌ ការលើកកម្ពស់ការយល់ដឹងនិងការគោរពច្បាប់ ទាំងក្នុងកម្រិតក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ព្រមទាំងការផ្តល់សេវាយុត្តិធម៌ ទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ ដល់ប្រជាពលរដ្ឋ ឱ្យកាន់តែកៀកកិត ជិតស្និទ្ធ និងកាន់តែមានប្រសិទ្ធភាព តម្លាភាព នៅនឹងមូលដ្ឋាន ពិសេស ពលរដ្ឋងាយរងគ្រោះ។

ក្នុងស្មារតីជារួម ការដ្ឋានកែទម្រង់ទាំងបួន បានរំលេចយ៉ាងច្បាស់និងព្រមគ្នានូវ ទស្សនវិស័យ តទៅអនាគត ប្រកបដោយគោលបំណងដ៏មហិច្ឆតា ដោយផ្សារភ្ជាប់ជាមួយនឹងលទ្ធភាពប្រាកដនិយមជាក់ស្តែង ឆន្ទៈនយោបាយមោះមុតឥតរាថយ សមត្ថភាពមនុស្សនិងស្ថាប័ន ស្មារតីនៃភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ សម្បជញ្ញៈនៃភាពបន្ទាន់និងស្មារតី

៣

ឧបសម្ព័ន្ធ២៩

តម្រង់ឱ្យចំគោលដៅអាទិភាពនៃការកែទម្រង់ ក្នុងបុព្វហេតុរួមនៃវឌ្ឍនភាពសង្គមនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

**គ. ទន្ទពិភាក្សា និង សួរ-ឆ្លើយ**

នៅក្នុងវេទិកាពិភាក្សា និង សួរ-ឆ្លើយ ត្រូវបានរៀបចំឡើងនាពេលរៀល ហើយសម្របសម្រួលដោយ ឯកឧត្តមបណ្ឌិត **វង្ស ចំរើន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.គ.ហ ក្នុងរយៈពេល ២ ម៉ោង និង៣០នាទី, យុវជនជាសិក្ខាកាមរបស់យើង បានចោទជាសំណួរយ៉ាងច្រើនពីគួរឱ្យចាប់អារម្មណ៍ មកកាន់វាគ្មិន ដែលបង្ហាញពីការយកចិត្តទុកដាក់របស់យុវជនយើងលើការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា *(ខ្លឹមសារសំណួរមានភារពជូនភ្ជាប់មកជាមួយ)*។

ជារួម អង្គសិក្ខាសាលាបានជជែក វែកញែក វិភាគ ពិភាក្សា ចោទសួរ ឆ្លើយស្រាយ ប្រកបដោយស្តង់ដារវិជ្ជាជីៈ វិន័យ និងក្រមសីលធម៌ខ្ពស់។ ជារួម តាមរយៈនៃវេទិកាសួរ-ឆ្លើយ ខ្លឹមសារសំខាន់ៗត្រូវបានផុសចេញឡើងជាទស្សនៈ ៣ ប្រភេទដូចខាងក្រោម÷

១. **ពិពិធភាពនៃតំណភ្ជាប់ការកែទម្រង់នានា÷** វេទិកាពិភាក្សា បានក្លាយទៅជាមូលដ្ឋាននៃការរៀនសូត្រ ដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមក ប្រកបដោយភាពសម្បូរបែបនិងខុសប្លែកៗពីគ្នា រវាងយុវជន និងអ្នកកែទម្រង់ ក៏ដូចជារវាងអ្នកកែទម្រង់ ក្នុងការដ្ឋានទាំងបួន ដោយបានទម្លុះនាំងគំនិត ទម្លាយរបាំងវិជ្ជា នៃការកែទម្រង់ នៅតាមការដ្ឋាននីមួយៗ ធ្វើឱ្យស្តែងចេញនូវលំហូរមេរៀននិងបទពិសោធន៍ជាច្រើន ទាំងជោគជ័យ ទាំងការប្រយេមនានា ដែលមិនទាន់ទទួលបានជោគជ័យ ដែលក្នុងនោះមានបញ្ហាជាមូលដ្ឋានជាច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា ជាអាទិ៍ ភាពជាអ្នកដឹកនាំ ឆន្ទៈដឹកនាំ ស្មារតីភាពជាម្ចាស់ សមត្ថភាពមនុស្ស និងរចនាសម្ព័ន្ធស្ថាប័ន កិច្ចសម្របសម្រួលស្ថាប័ន និងអន្តរស្ថាប័នជាដើម។

២. **អន្តរសកម្មនៃការពឹងផ្អែកគ្នាទៅវិញទៅមក រវាងការកែទម្រង់នានា÷** នៅក្នុងបរិការណ៍មួយចំនួន ការកែទម្រង់មួយអាចសម្រេចវឌ្ឍនភាពទៅមុខបាន លុះត្រាតែត្រូវពឹងផ្អែកលើសមិទ្ធផលនៃការកែទម្រង់មួយទៀត ដែលមានទំនាក់ទំនងផ្សារភ្ជាប់គ្នាទៅវិញទៅមកជាប់មិនដាច់ និងឆ្លើយឆ្លងគ្នាទៅវិញទៅមក។ ជាក់ស្តែង ការផ្ទេរមុខងារ ឬប្រតិភូកម្មមុខងារ ពីរដ្ឋបាលថ្នាក់ជាតិ ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការគិតគូររៀបចំនិងអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងធនធានមនុស្សនិងបញ្ចូលធនធានហិរញ្ញវត្ថុភ្ជាប់ទៅជាមួយ។ ឯការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ អាចចោទជាបញ្ហានៃការរៀបចំជំហាននៃការកែទម្រង់វិមជ្ឈការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចឈានទៅដល់ គណនេយ្យភាពសមិទ្ធកម្ម មុនរដ្ឋបាលថ្នាក់ជាតិ នៅក្នុងការកែទម្រង់ប្រព័ន្ធថវិកា។ ម្យ៉ាងទៀត សេវាយុត្តិធម៌ ក្នុងឬក្រៅប្រព័ន្ធតុលាការ អាចសម្រេចទៅបានដោយប្រសិទ្ធភាព លុះត្រាតែការគាំទ្រផ្នែកហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូនទន្ទឹមគ្នានឹងការបង្កើតមុខងារផ្តល់សេវាយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ ឬការពង្រឹងសមត្ថភាពរដ្ឋបាល តុលាការ ក្នុងការទទួលយកនូវសិទ្ធិអំណាចនិងការទទួលខុសត្រូវជាអង្គភាពថវិកា។

៣. **អន្តរសកម្មនៃការគាំទ្រឱ្យគ្នាទៅវិញទៅមករវាងការកែទម្រង់នានា÷** ក្នុងបរិការណ៍មួយចំនួនទៀត វឌ្ឍនភាពនៃការកែទម្រង់មួយ នឹងផ្តល់ជាកម្លាំងគាំទ្រ ដល់ការសម្រេចលទ្ធផលនៃការកែទម្រង់មួយទៀត ទោះដោយផ្ទាល់ឬប្រយោលក្តី។ ឧទាហរណ៍ កំណើនចំណូលថវិកាជាតិ ដែលបានមកពីការកែទម្រង់រដ្ឋបាលសារពើពន្ធ និងការពង្រឹងប្រព័ន្ធប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាទ្រព្យសម្បត្តិដែលតុលាការរឹប

អួសទុកជាទ្រព្យសម្បត្តិរដ្ឋ នឹងផ្តល់លទ្ធភាពដល់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌កាន់តែមានថវិកាគាំទ្រប្រសើរឡើង។ រីឯការផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវលើការរៀបចំនិងអនុវត្តថវិកាដល់រដ្ឋបាលតុលាការ ជាមួយនិងសាមញ្ញកម្មនីតិវិធីហិរញ្ញវត្ថុ នឹងអនុញ្ញាតឱ្យស្ថាប័នតុលាការមានលទ្ធភាពបម្រើសេវាយុត្តិធម៌ កាន់តែមានប្រសិទ្ធភាព ឆាប់រហ័សជាងមុន។ ម្យ៉ាងទៀត ការកែទម្រង់ប្រព័ន្ធបៀវត្សនិងប្រព័ន្ធមុខងារសាធារណៈ បានផ្តល់ជីវភាពថ្មីដល់មន្ត្រីរាជការ ក្នុងការចូលរួមចំណែកកាន់តែសកម្ម ក្នុងការងារកែទម្រង់ តាមវិស័យអាទិភាព ដូចជាវិស័យអប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ បរិស្ថានជាដើម។

អាស្រ័យហេតុនេះ ទំនាក់ទំនងជាអន្តរសកម្ម នៃការកែទម្រង់នេះ ហាក់ដូចជាបានបង្កើតទៅជាសង្សារវដ្តនៃគុណធម៌ ឬ គុណវដ្ត (Virtuous Circle) ដែលគុណបំណាច់នៃការកែទម្រង់មួយ នឹងផ្តល់ជាគុណប្រយោជន៍ដល់ការជំរុញល្បឿននៃការកែទម្រង់មួយទៀត នៅក្នុងរង្វង់នៃការគាំទ្រ និងពឹងផ្អែកគ្នាទៅវិញទៅមក ចន្លឹមចឹងនេះ ក៏ហាក់ដូចជាបានត្រួសត្រាយមាគ៌ាដោះស្រាយការប្រឈម ឆ្ពោះទៅរកនិន្នាការនៃការផ្សារភ្ជាប់ទំនាក់ទំនងនៃការកែទម្រង់ផ្សេងៗគ្នាឱ្យកាន់តែជិតស្និទ្ធ នៅលើមាគ៌ាដឹកនាំពីអន្តរការដ្ឋាននៃការកែទម្រង់ ទៅកាន់ការដ្ឋានអន្តរកែទម្រង់។

ដើម្បីវាយតម្លៃទៅលើការរៀបចំអង្គសិក្ខាសាលានាំងមូល កម្រងសំណួរស្ទាបស្ទង់លើមតិរបស់យុវជនលើសិក្ខាសាលានាំងមូល ត្រូវបានរៀបចំ សម្រាប់ប្រមូលជាធាតុចូលអភិវឌ្ឍការរៀបចំសិក្ខាសាលានេះឱ្យកាន់តែល្អប្រសើរ។ ជាលទ្ធផល អង្គសិក្ខាសាលា ទទួលបានការពេញចិត្តខ្ពស់ពីសំណាក់យុវជន ស.ស.យ.ក ដែលបានចូលរួម លើការរៀបចំ សម្របសម្រួល របៀបវារៈ ខ្លឹមសារនៃអង្គសិក្ខាសាលា ជាពិសេសគឺការផ្តួចផ្តើមឱ្យមានសិក្ខាសាលានេះផ្ទាល់តែម្តង។ ជាពិសេស យុវជនលើសពី ៨០% បានយល់ថាសិក្ខាសាលានេះពិតជាមានសារៈសំខាន់ដល់ពួកគេ និងស្ទើរតែ ១០០% នៃយុវជននឹងចែករំលែកចំនេះ និងបទពិសោធន៍ទាំងនេះ ហើយនិងចង់ឱ្យមានសិក្ខាសាលានេះបានទៅដល់សហគមន៍របស់ពួកគាត់។ ដោយឡែកអ្វីដែលជាចំណុចខ្វះខាតតម្រូវឱ្យការកែប្រែនោះគឺ តម្រូវបន្ថែមរយៈពេលនៃការរៀបចំកិច្ចពិភាក្សា និងបទបង្ហាញឱ្យបានច្រើនជាងនេះ។

**ឃ. កម្មវិធីបិទ**

ជាកិច្ចបញ្ចប់ បន្ទាប់ពីបានស្តាប់នូវរបាយការណ៍បូកសរុបលទ្ធផលនៃសិក្ខាសាលា រួចមក **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានសាទរនឹងលទ្ធផលនៃការរៀបចំសិក្ខាសាលានេះ ដែលជាទម្រង់នៃការបញ្ច្រាបពុទ្ធិ ក៏ដូចជាកិច្ចដឹកនាំរបស់រាជរដ្ឋាភិបាលទៅកាន់យុវជន ជាពិសេស គឺជាសារដល់យុវជនឱ្យខិតខំប្រឹងប្រែង, ចូលរួម, ជួយ, ជ្រោមជ្រែង, កម្មវិធីកំណែទម្រង់ដែលសម្តៅដល់ការអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនតទៅទៀត។ លើសពីនេះ សម្តេចក្រឡាហោម ក៏បានគូសបញ្ជាក់នូវបុរេលក្ខខណ្ឌ និងលក្ខខណ្ឌសំខាន់ៗសម្រាប់ទិសដៅរួមនៃកម្មវិធីកំណែទម្រង់ ដូចជា÷

១. ការបន្តរក្សាបាននូវសន្តិភាព ស្ថេរភាពនយោបាយ និងការពង្រឹងបាននូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស គឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់សម្រាប់ការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយភាពជោគជ័យ។

២. ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្តេជ្ញាលើកិច្ចការងារកំណែទម្រង់ ព្រោះថាវាមិនមែនជាកិច្ចការងារងាយស្រួលទេ គឺហាក់ដូចជាការរុះរើ និងជួសជុលផ្ទះ ដែលកំពុងមានមនុស្សស្នាក់នៅយ៉ាងដូច្នោះដែរ។

៥



ឧបសម្ព័ន្ធទី២៩

៣. ការរៀបចំ និងអនុវត្តយន្តការនៃការងារកំណែទម្រង់ទាំងបី ដែលមានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ-ការ, កំណែទម្រង់រដ្ឋបាលសាធារណៈ, និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវតែមានភាពស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា ហើយសម្តេចក៏បានស្នើ និងពង្រីកបន្ថែមនូវពីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងកំណែទម្រង់ផ្សេងៗទៀត នៅតាមវិស័យសាធារណៈសំខាន់ៗនៅក្នុងយន្តការនេះផងដែរ។

៤. ការចូលរួមនៃគ្រប់ភាគីពាក់ព័ន្ធ គឺជាកត្តាកំណត់ជោគជ័យតែមួយគត់របស់កិច្ចការការងារកំណែទម្រង់ ហើយសូមលើកទឹកចិត្តដល់យុវជន ដែលជាធនធានក៏មានសក្តានុពលរបស់ជាតិ ឱ្យចូលរួមក្នុងការងារកំណែទម្រង់ឱ្យកាន់តែសកម្ម និងស៊ីជម្រៅបន្ថែមទៀត។

*ទន្ទឹមនេះ សម្តេចក្រឡាហោម បានគូសបញ្ជាក់និងបានផ្តល់អនុសាសន៍ដល់លេខាធិការដ្ឋានកែទម្រង់ទាំង ៣ ពិចារណា អំពីលទ្ធភាពនៃបញ្ចូលលេខាធិការដ្ឋានកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ឬយន្តការការងារកែទម្រង់ផ្សេងទៀត នៅក្នុងយន្តការសម្របសម្រួលនៃលេខាធិការដ្ឋានកែទម្រង់ជាប្រព័ន្ធទាំង ៣ ដែលកំពុងមានស្រាប់ជាធរមាន។*

សិក្ខាសាលា ត្រូវបានបិទបញ្ចប់ជាផ្លូវការ នៅវេលាម៉ោង ៦ ល្ងាច ក្នុងថ្ងៃដដែល ប្រកបដោយលទ្ធផលត្រចះត្រចង់ និងស្មារតីសាមគ្គីភាព ភាតរភាព និងស្មារតីកែទម្រង់។

រាជធានីភ្នំពេញ ថ្ងៃទី 19 ខែមិថុនា ឆ្នាំ២០១៨
អ្នកធ្វើរបាយការណ៍

**ធុជិ សត្រា**

បានពិនិត្យ និង សូមគោរពជូន
**ឯកឧត្តមអគ្គលេខាធិការ អ.គ.ហ.**
រាជធានីភ្នំពេញ ថ្ងៃទី 20 ខែមិថុនា ឆ្នាំ២០១៨
**អនុរដ្ឋលេខាធិការ កសហវ និងជា អគ្គលេខាធិការរងនៃ អ.គ.ហ.**

**បណ្ឌិត វ៉េហិល ចិរវ៉ែន**

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់**
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
រាជធានីភ្នំពេញ ថ្ងៃទី 22 ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការ នៃ អ.គ.ហ.**

**រស់ សីលវ៉ា**

........................................................................
រាជធានីភ្នំពេញ ថ្ងៃទី 29 ខែ 6 ឆ្នាំ២០១៨
**ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការ**
**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

៦

# ឧបសម្ព័ន្ធទី៣០

# ឧបសម្ព័ន្ធទី៣០. សេចក្តីសម្រេចរួមលេខ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ (និរាករណ៍)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ

សេចក្តីសម្រេចរួម
ស្តីពី
ការបង្កើតយន្តការសម្របសម្រួលរវាង
កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**សម្រេច**

**ប្រការ១.-**

បង្កើតយន្តការសម្របសម្រួល រវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្ម នៃកិច្ចការងារកែទម្រង់ទាំងបីនេះ របស់រាជរដ្ឋាភិបាល។

**ប្រការ២.-**

យន្តការសម្របសម្រួល ត្រូវបានកំណត់ ដូចតទៅ៖

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវរៀបប្រជុំប្រចាំត្រីមាស និងតាមការចាំបាច់ ដែលដឹកនាំតាមវេនគណៈប្ដូរវេន
- កិច្ចប្រជុំត្រូវដឹកនាំដោយអគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋាន ដែលជាប្រធានតាមវេន
- របៀបវារៈនៃកិច្ចប្រជុំ ត្រូវបានកំណត់ទៅតាមប្រធានបទដែលស្នើឡើងដោយអគ្គលេខាធិការដ្ឋាន ឬ លេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី
- ប្រធានប្ដូរវេនត្រូវប្រមូលព័ត៌មានពាក់ព័ន្ធនឹងរបៀបវារៈនៃកិច្ចប្រជុំ ដើម្បីធ្វើការកិច្ចប្រជុំប្រកបដោយផលិតភាពនិងប្រសិទ្ធភាព
- ប្រធានប្ដូរវេន មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៣.-**

ប្រធានគណៈកម្មាធិការនីមួយៗ អាចកោះប្រជុំអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី តាមការចាំបាច់ក្រោមការដឹកនាំផ្ទាល់ ឬតំណាងប្រធានគណៈកម្មាធិការ។

**ប្រការ៤.-**

រាល់កិច្ចប្រជុំដូចមានចែងក្នុងប្រការ២ និងប្រការ៣ ត្រូវមានរបាយការណ៍ជម្រាបជូនប្រធានគណៈកម្មាធិការទាំងបី។

**ប្រការ៥.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងប្រធានអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃនិងជាប្រធាន
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**ស ខេង**

រដ្ឋមន្ត្រី
ក្រសួងមុខងារសាធារណៈ
និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**ពេជ្រ ប៊ុនធិន**

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

២

# ឧបសម្ព័ន្ធទី៣១

# ឧបសម្ព័ន្ធទី៣១. ផែនការសកម្មភាពឆ្នាំ២០២៥ នៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| **១** | **យុទ្ធសាស្ត្រទី១ ៖ សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ** | | | | | | | |
| **១.១** | **កំណត់និងរៀបចំមុខងារ និងរចនាសម្ព័ន្ធ** | **ល.គ.ជ.អ.ប.** | | | | | | |
| ១.១.១. | សិក្សាលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យសុខាភិបាលពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ (២០២៤-២០២៥) | ល.គ.ជ.អ.ប. | សេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | រៀបចំសេចក្តីសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ផែនការសកម្មភាព និងបញ្ជីសំណួរ សម្រាប់សិក្សាលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យសុខាភិបាលពីរដ្ឋបាល រាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ | ធ្វើការសិក្សា និងរៀបចំរបាយការណ៍ស្តីពីលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យសុខាភិបាលពីរដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ | ស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលស្តីពីការប្រតិភូកម្មមុខងារសុខាភិបាលទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធ នឹង ការប្រតិភូកម្មមុខងារសុខាភិបាលទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | លិខិតបទដ្ឋានគតិយុត្ត |



ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១.១.២. | សិក្សាលទ្ធភាពកែសម្រួលរដ្ឋបាលខេត្ត ឱ្យក្លាយជារដ្ឋបាលដែលមានចរិត-លក្ខណៈជារដ្ឋបាលតំបន់ និង រដ្ឋបាលរាជធានីឱ្យ ក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន | ល.គ.ជ.អ.ប. | របាយការណ៍ស្តីពីជម្រើសនានា ដើម្បីកំណត់អំពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់និងរដ្ឋបាលរាជធានី ឱ្យក្លាយជារដ្ឋបាល ដែលមានចរិត-លក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន | បន្តការសិក្សាស្វែងយល់ដកស្រង់បទពិសោធន៍ និង សិក្ខាសាលាចែករំលែកមេរៀនបទពិសោធន៍ អំពីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តនៅបណ្តាប្រទេសមួយចំនួន | បន្តការសិក្សាស្វែងយល់ដកស្រង់បទពិសោធន៍ និងសិក្ខាសាលាចែករំលែកមេរៀនបទពិសោធន៍អំពីរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តនៅបណ្តាប្រទេសមួយចំនួន និងការសិក្សានិងវាយតម្លៃលើរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តនៅក្នុងប្រទេស | | កំណត់ជម្រើសនានាសម្រាប់ការកែសម្រួលមុខងារ និងរចនា-សម្ព័ន្ធរបស់រដ្ឋបាលខេត្ត និងរដ្ឋបាររាជធានី | របាយការណ៍ |
| ១.១.៣. | រៀបចំវេទិការាជរដ្ឋា-ភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ | ល.គ.ជ.អ.ប. | របាយការណ៍ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ | រៀបចំកិច្ចប្រជុំ គ.ជ.អ.ប. ពិនិត្យពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ-ការ និងការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និង | | | | របាយការណ៍ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | | | រដ្ឋបាលថ្នាក់ក្រោមជាតិ ខ្ពង់ខ្ពស់របស់សម្តេចធិបតីនាយក-រដ្ឋមន្ត្រី អំពីកំណែ-ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | |
| ១.១.៤. | បង្កើតក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័ន | អ.គ.ក.ច. | របាយការណ៍បូកសរុបចំនួនសេចក្តីសម្រេចបង្កើតក្រុមការងារកែទម្រង់ច្បាប់ នៅក្នុងក្រសួងស្ថាប័ន | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារកែទម្រង់ច្បាប់ នៅក្នុងក្រសួងស្ថាប័ន | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារកែទម្រង់ច្បាប់ នៅក្នុងក្រសួងស្ថាប័ន | សេចក្តីសម្រេចបង្កើតក្រុមការងារកែទម្រង់ច្បាប់ នៅក្នុងក្រសួងស្ថាប័ន | សេចក្តីសម្រេចបង្កើតក្រុមការងារកែទម្រង់ច្បាប់ នៅក្នុងក្រសួងស្ថាប័ន | របាយការណ៍ |
| ១.១.៥. | បង្កើតគណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យ | អ.គ.ក.ច. | សេចក្តីសម្រេចបង្កើតគណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តីសម្រេច គ.ក.ច. ត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តីសម្រេច គ.ក.ច. ត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តីសម្រេច គ.ក.ច. ត្រូវបានរៀបចំ | សេចក្តីសម្រេច គ.ក.ច. |
| ១.១.៦. | បង្កើតគណៈកម្មការជាតិការពារនីត្យានុកូលភាព | អ.គ.ក.ច. | សេចក្តីសម្រេចរាជរដ្ឋា-ភិបាលបង្កើតគណៈកម្មការជាតិការពារនីត្យានុកូលភាពត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តី-សម្រេចរាជរដ្ឋាភិបាល |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១.១.៧. | បង្កើតគណៈកម្មការជាតិភាសាច្បាប់ | អ.គ.ក.ច. | សេចក្តីសម្រេចរាជរដ្ឋាភិបាលបង្កើតគណៈកម្មការជាតិភាសាច្បាប់ ត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តីព្រាងសេចក្តី-សម្រេចរាជរដ្ឋាភិបាលត្រូវបានរៀបចំ | សេចក្តី-សម្រេចរាជរដ្ឋាភិបាល |
| **១.២.** | **កំណត់ រៀបចំ និងសម្របសម្រួលការគ្រប់-គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ** | | | | | | | |
| ១.២.១. | សិក្សា និងកំណត់អំពីមុខងារអាទិភាព និងធនធានហិរញ្ញវត្ថុដែលបានផ្ទេរតាមរយៈយន្តការនៃការផ្ទេរមុខងារទាំង៥៥ នៃ១៩ វិស័យ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | កសហវ. ល.គ.ជ.អ.ប. | មុខងារអាទិភាព និងធនធានហិរញ្ញវត្ថុសមស្រប ត្រូវបានកំណត់សម្រាប់ផ្ទេរដល់ការិយា-ល័យមន្ទីរជំនាញ១៩ វិស័យ នៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ការសិក្សា វិភាគ និងកំណត់មុខងារអាទិភាព និងធនធានហិរញ្ញវត្ថុ | របាយការណ៍សិក្សា និងរបកគំហើញ ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំ | | ធនធានសមស្រប ត្រូវបានវិភាជតាមអាទិភាពមុខងារ | លិខិតបទ-ដ្ឋានគតិយុត្ត និងឬ របាយការណ៍ |
| ១.២.២. | រៀបចំផ្ទេរទ្រព្យសម្បត្តិរដ្ឋពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋ-បាលថ្នាក់ក្រោម ជាតិស្របតាមមុខងារ ដែលបានផ្ទេរ | ល.គ.ជ.អ.ប. | លិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរទ្រព្យសម្បត្តិត្រូវដាក់ចេញ | | ការរៀបចំលិខិតបទ-ដ្ឋានគតិយុត្ត សម្រាប់ផ្ទេរទ្រព្យសម្បត្តិ | | | លិខិតបទដ្ឋានគតិយុត្ត |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/ សកម្មភាព | អង្គភាព ដឹកនាំ | សូចនាករសមិទ្ធកម្ម គន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារ អំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| **១.៣.** | **កំណត់ រៀបចំ និង សម្របសម្រួលការ គ្រប់គ្រងធនធានមនុស្ស** | **អ.គ.ក.ស.** | **ក្របខ័ណ្ឌគតិយុត្ត និង នីតិវិធីពាក់ព័ន្ធនឹងធនធាន មនុស្ស ត្រូវបានរៀបចំ** | | | | | |
| ១.៣.១. | រៀបចំលិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធការ ជ្រើសរើសនិងគ្រប់គ្រង មន្ត្រីរាជការស៊ីវិល និងមន្ត្រីបច្ចេកទេស/ ជំនាញតាមកិច្ចសន្យា | អ.គ.ក.ស. | ព្រះរាជក្រឹត្យស្តីពីគោល-ការណ៍រួមនៃការជ្រើស-រើសនិងការគ្រប់គ្រង មន្ត្រីផ្អែកលើកិច្ចព្រម-ព្រៀង ការងារ ត្រូវបាន អនុម័ត និងផ្សព្វផ្សាយ ដាក់ឱ្យអនុវត្ត | -សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីគោលការណ៍ រួមនៃការជ្រើសរើស និង ការគ្រប់គ្រងមន្ត្រីផ្អែក លើកិច្ចព្រមព្រៀងការងារ ត្រូវបានរៀបចំ<br>-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ មុខតំណែង និងការ ពិពណ៌នាមុខតំណែង វិជ្ជាជីវៈសុខាភិបាល ត្រូវបានរៀបចំ | -ព្រះរាជក្រឹត្យស្តីពី គោលការណ៍រួមនៃការ ជ្រើសរើសនិងការគ្រប់-គ្រង មន្ត្រីផ្អែកលើកិច្ច-ព្រមព្រៀងការងារ ត្រូវ បានរៀបចំ អនុម័ត និង ដាក់ឱ្យអនុវត្ត<br>-អនុក្រឹត្យស្តីពី ការកំណត់ មុខតំណែង និងការពិពណ៌នា មុខតំណែងវិជ្ជាជីវៈ សុខាភិបាល ត្រូវបាន រៀបចំ អនុម័ត និង ដាក់ឱ្យអនុវត្ត | -អនុក្រឹត្យស្តីពីការ កំណត់មុខតំណែង និងការពិពណ៌នា មុខតំណែង វិជ្ជាជីវៈ អប់រំ ត្រូវបានរៀបចំ<br>-លិខិតបទដ្ឋានគតិយុត្ត សម្រាប់ អនុវត្តព្រះរាជ-ក្រឹត្យស្តីពីគោលការណ៍ រួមនៃការជ្រើសរើស និងការគ្រប់គ្រងមន្ត្រី ផ្អែកលើកិច្ចព្រមព្រៀង ការងារ ត្រូវបានរៀបចំ | -អនុក្រឹត្យស្តីពីការ កំណត់មុខតំណែង និងការពិពណ៌នា មុខតំណែង វិជ្ជាជីវៈ អប់រំ ត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្ត<br>-លិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តព្រះរាជ-ក្រឹត្យស្តីពីគោលការណ៍ រួមនៃការជ្រើសរើសនិង ការគ្រប់គ្រងមន្ត្រីផ្អែកលើ កិច្ចព្រមព្រៀងការងារ ត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្ត | ព្រះរាជក្រឹត្យ និង អនុក្រឹត្យ |
| ១.៣.២. | រៀបចំព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែក នៃ អង្គអប់រំ និងសុខាភិបាល | អ.គ.ក.ស. | ព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែក នៃអង្គគ្រូបង្រៀន និង សុខាភិបាល ត្រូវបាន អនុម័ត និងដាក់ឱ្យ អនុវត្ត | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីលក្ខន្តិកៈ ដោយឡែកនៃអង្គ គ្រូបង្រៀន និងសុខា-ភិបាល ត្រូវបានរៀបចំ ពិនិត្យផ្តល់យោបល់ | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីលក្ខន្តិកៈ ដោយឡែកនៃអង្គ គ្រូបង្រៀន និងសុខា-ភិបាល ត្រូវបានរៀបចំ ពិនិត្យផ្តល់យោបល់ | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីលក្ខន្តិកៈ ដោយឡែកនៃអង្គ គ្រូបង្រៀន និងសុខា-ភិបាល ត្រូវបានរៀបចំ ពិនិត្យផ្តល់យោបល់ | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីលក្ខន្តិកៈ ដោយឡែកនៃអង្គ គ្រូបង្រៀន និងសុខា-ភិបាល ត្រូវបានរៀបចំ ពិនិត្យផ្តល់យោបល់ | ព្រះរាជក្រឹត្យ |

ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/ សកម្មភាព | អង្គភាព ដឹកនាំ | សូចនាករសមិទ្ធកម្ម គន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារ អំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១.៣.៣. | ការដាក់ឱ្យដំណើរការ តុលាការជំនាញ | អ.គ.ក.ប.យ. | សេចក្តីព្រាងការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្ត-ទៅតុលាការពាណិជ្ជកម្ម បានបញ្ចប់ក្នុងកម្រិត ថ្នាក់ដឹកនាំ | កំពុងពិនិត្យ និងរៀបចំ សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ តុលាការពាណិជ្ជកម្ម ក្នុងកម្រិតបច្ចេកទេស | កំពុងពិនិត្យ និងរៀបចំ សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ តុលាការពាណិជ្ជកម្ម ក្នុងកម្រិតបច្ចេកទេស | កំពុងពិនិត្យ និងរៀបចំ សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ តុលាការពាណិជ្ជកម្ម ក្នុងកម្រិតបច្ចេកទេស | កំពុងពិនិត្យ និងរៀបចំ សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ តុលាការពាណិជ្ជកម្ម ក្នុងកម្រិតបច្ចេកទេស | ច្បាប់ ឬ លិខិតបទដ្ឋាន គតិយុត្ត |
| **១.៤.** | **កំណត់ រៀបចំ និង សម្របសម្រួល ការគ្រប់គ្រងប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មាន/ ប្រព័ន្ធឌីជីថល** | **អ.គ.ហ.<br>ល.គ.ជ.អ.ប.<br>អ.គ.ក.ឋ.<br>អ.គ.ក.ប.យ.<br>អ.គ.ក.ស.** | | | | | | |
| ១.៤.១. | ក្រសួង ស្ថាប័ន ប្រើប្រាស់ ប្រព័ន្ធ NRMIS សម្រាប់ ប្រមូលចំណូលមិនមែន សារពើពន្ធ តាមរយៈ ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) | អ.រតន.<br>អ.ទ.ច.<br>ក.ស.ដ. | ការធ្វើសន្ធានកម្មទិន្នន័យ រវាងប្រព័ន្ធទូទាត់អេឡិច-ត្រូនិករបស់ក្រសួងសាធា-រណការ និងដឹកជញ្ជូន (MPWT e-Payment) និងប្រព័ន្ធទូទាត់ | - រៀបចំកិច្ចប្រជុំពិភាក្សា បន្ថែមជាមួយក្រសួង សាធារណការ និង ដឹកជញ្ជូន អំពី ការធ្វើ សន្ធានកម្ម<br>- រៀបចំនីតិវិធីបើក គណនីប្រាក់វង្វាន់របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន | - រៀបចំកិច្ចប្រជុំពិភាក្សា បន្ថែមជាមួយក្រសួង សាធារណការ និង ដឹកជញ្ជូន អំពី ការធ្វើ សន្ធានកម្ម<br>- រៀបចំនីតិវិធីបើក គណនីប្រាក់វង្វាន់របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន | - រៀបចំ Pilot ជាមួយ ធនាគារដៃគូ<br>- ដាក់ឱ្យអនុវត្ត e-Payment | - រៀបចំ Pilot ជាមួយ ធនាគារដៃគូ<br>- ដាក់ឱ្យអនុវត្ត e-Payment | -លិខិតអញ្ជើញ<br>-របាយការណ៍ លទ្ធផល កិច្ចប្រជុំ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | អ.វតន.<br>អ.ទ.ប.<br>ក.ប.ទ. | ការធ្វើសន្ធានកម្មទិន្នន័យរវាង ប្រព័ន្ធនៃការទូទាត់សាច់ ប្រាក់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធទូទាត់ អេឡិចត្រូនិក (e-Payment) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានសិក្សា រៀបចំ និងដាក់ឱ្យអនុវត្ត | - រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែម ជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អំពីការធ្វើសន្ធានកម្ម<br>- រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | - រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែម ជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អំពីការធ្វើសន្ធានកម្ម<br>- រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | - រៀបចំ Pilot ជាមួយធនាគារដៃគូ<br>- ដាក់ឱ្យអនុវត្ត e-Payment | រៀបចំ Pilot ជាមួយធនាគារដៃគូ<br>- ដាក់ឱ្យអនុវត្ត e-Payment | -លិខិតអញ្ជើញ<br>-របាយការណ៍លទ្ធផលកិច្ចប្រជុំ |
| ១.៤.២. | ក្រសួង ស្ថាប័ន ប្រើប្រាស់ប្រព័ន្ធ NRMIS សម្រាប់ប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) | អ.វតន.<br>អ.ទ.ប.<br>ក.ម. | នីតិវិធីបើកគណនីប្រាក់វង្វាន់រួមសម្រាប់បង់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួងមហាផ្ទៃត្រូវបានរៀបចំ និងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ជំហានទី៣ ជាមួយ ក្រសួងមហាផ្ទៃត្រូវបានដាក់ឱ្យអនុវត្ត | -រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែមជាមួយក្រសួងមហាផ្ទៃ<br>-រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់រួមរបស់ក្រសួងមហាផ្ទៃ | -រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែមជាមួយក្រសួងមហាផ្ទៃ<br>-រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់រួមរបស់ក្រសួងមហាផ្ទៃ | -រៀបចំ Pilot ជាមួយធនាគារដៃគូ<br>-ដាក់ឱ្យអនុវត្ត e-Payment | -រៀបចំ Pilot ជាមួយធនាគារដៃគូ<br>-ដាក់ឱ្យអនុវត្ត e-Payment | -លិខិតអញ្ជើញ<br>-របាយការណ៍លទ្ធផលកិច្ចប្រជុំ |

ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | អ.រតន. អ.ទ.ប. ក.យ. | នីតិវិធីបើកគណនីប្រាក់វង្វាន់សម្រាប់បង់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួងយុត្តិធម៌ ត្រូវបានរៀបចំ និងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ជំហានទី៣ ជាមួយក្រសួងយុត្តិធម៌ ត្រូវបានដាក់ឱ្យអនុវត្ត | -រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែមជាមួយទីស្តីការក្រសួងយុត្តិធម៌<br>-រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់របស់ទីស្តីការក្រសួងយុត្តិធម៌ | -រៀបចំកិច្ចប្រជុំពិភាក្សាបន្ថែមជាមួយទីស្តីការក្រសួងយុត្តិធម៌<br>-រៀបចំនីតិវិធីបើកគណនីប្រាក់វង្វាន់របស់ទីស្តីការក្រសួងយុត្តិធម៌ | -រៀបចំ Pilot ជាមួយធនាគារដៃគូ<br>-ដាក់ឱ្យអនុវត្ត e-Payment | -រៀបចំ Pilot ជាមួយធនាគារដៃគូ<br>-ដាក់ឱ្យអនុវត្ត e-Payment | -លិខិតអញ្ជើញ<br>-របាយការណ៍លទ្ធផលកិច្ចប្រជុំ |
| ១.៤.៣. | ធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលនៅតាមអង្គភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពសុខាភិបាលមូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មី | អ.គ.ក.ស. | រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន អង្គភាពសុខាភិបាលមូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មីត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព | រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន អង្គភាពសុខាភិបាល មូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មីត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព | រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន អង្គភាពសុខាភិបាល មូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មីត្រូវបានរៀបចំធ្វើបច្ចុប្បន្នភា | រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន អង្គភាពសុខាភិបាល មូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មីត្រូវបានរៀបចំធ្វើបច្ចុប្បន្នភា | រចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន អង្គភាពសុខាភិបាល មូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យាថ្មីត្រូវបានរៀបចំធ្វើបច្ចុប្បន្នភា | -របាយការណ៍<br>-ប្រព័ន្ធទិន្នន័យ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១.៤.៤. | ការធ្វើឌីជីថលូបនីយកម្មនៃប្រព័ន្ធយុត្តិធម៌ | អ.គ.ក.ប.យ. | កំពុងសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងការងារនៅក្នុងក្រសួងយុត្តិធម៌ និងប្រព័ន្ធគ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី | កំពុងសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងការងារនៅក្នុងក្រសួង យុត្តិធម៌ និងប្រព័ន្ធ គ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី | កំពុងសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងការងារនៅក្នុងក្រសួង យុត្តិធម៌ និងប្រព័ន្ធ គ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី | កំពុងសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងការងារនៅក្នុងក្រសួង យុត្តិធម៌ និងប្រព័ន្ធ គ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី | កំពុងសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងការងារនៅក្នុងក្រសួង យុត្តិធម៌ និងប្រព័ន្ធ គ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី | អនុស្សរណៈនៃការយោគយល់ (MOU) |
| ១.៤.៥. | រៀបចំប្រព័ន្ធមូលទិន្នន័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (Legal Database) | អ.គ.ក.ច. | ទស្សនាទាននៃការរៀបចំប្រព័ន្ធមូលទិន្នន័យច្បាប់និងលិខិតបទដ្ឋានគតិយុត្ត (Legal Database) ត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុងប្រមូលធាតុចូល ត្រូវបានរៀបចំ | សេចក្តីព្រាង ទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុង | សេចក្តីព្រាង ទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ គ.ក.ច. | សេចក្តីព្រាង ចុងក្រោយត្រូវបានដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំ គ.ក.ច. | ទស្សនាទាន |
| ១.៤.៦. | រៀបចំគេហទំព័រស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តកម្ពុជា (Chbab.gov.kh) | អ.គ.ក.ច. | ទស្សនាទាននៃរៀបចំគេហទំព័រស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តកម្ពុជា (Chbab.gov.kh) ត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុងប្រមូលធាតុចូល ត្រូវបានរៀបចំ | សេចក្តីព្រាង ទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុង | សេចក្តីព្រាង ទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ គ.ក.ច. | សេចក្តីព្រាង ចុងក្រោយត្រូវបានដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំ គ.ក.ច. | ទស្សនាទាន |

ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្ម គន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១.៤.៧. | រៀបចំប្រព័ន្ធឌីជីថលនៃការគ្រប់គ្រងការងារនីតិកម្មរបស់ទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួង ស្ថាប័ន | អ.គ.ក.ច. | ទស្សនាទាននៃការរៀបចំប្រព័ន្ធឌីជីថលនៃការគ្រប់-គ្រងការងារនីតិកម្មរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុងប្រមូលធាតុចូល ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុង | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ គ.ក.ច. | សេចក្តីព្រាងចុងក្រោយត្រូវបានដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំ គ.ក.ច. | ទស្សនាទាន |
| **២. យុទ្ធសាស្ត្រទី២ ៖ សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** | | | | | | | | |
| **២.១.** | **រៀបចំនិងសម្របសម្រួលការគ្រប់គ្រងអង្គភាពថវិកា** | | | | | | | |
| ២.១.១. | សិក្សា និងពិនិត្យលទ្ធភាពក្នុងការរៀបចំអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងន័យគាំទ្រដល់យន្តការសម្របសម្រួលអន្តរកែទម្រង់ស្នូល ទាំង ៥ នៃរាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព | អ.គ.ហ.<br>ល.គ.ជ.អ.ប.<br>អ.គ.ក.ច.<br>អ.គ.ក.ប.យ.<br>អ.គ.ក.ស.<br>អ.ថ. | អ.គ.ក.ច. និង ល.គ.ជ.អ.ប. ត្រូវបានរៀបចំជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ | | | អ.គ.ក.ច. និង ល.គ.ជ.អ.ប. ត្រូវបានរៀបចំជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ | របាយការណ៍សិក្សាវាយតម្លៃ ត្រូវបានរៀបចំ | របាយការណ៍ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| **២.២.** | **រៀបចំនិង សម្របសម្រួលការងារ សវនកម្មនិងអធិការកិច្ច** | | | | | | | |
| ២.២.១. | សិក្សា និងកំណត់តួនាទី និងភារកិច្ចរវាងអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិសាមី ជាមួយនឹងស្ថាប័នពាក់ព័ន្ធ | ល.គ.ជ.អ.ប. អ.ហ.ក. | របាយការណ៍សិក្សាត្រូវបានរៀបចំ | - របាយការណ៍សិក្សាវាយតម្លៃការបង្កើតសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ប្រជុំផ្ទៃក្នុងកសហវ.<br>- រៀបចំសេចក្តីសម្រេចបង្កើតក្រុមការងារអន្តរក្រសួង និងធ្វើការសិក្សា និងកំណត់តួនាទី និងភារកិច្ចរវាងអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ជាមួយនឹងស្ថាប័នពាក់ព័ន្ធ | របាយការណ៍សិក្សាវាយតម្លៃការបង្កើតសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ប្រជុំអន្តរក្រសួង | | រៀបចំរបាយការណ៍ស្តីពីជម្រើសនានាក្នុងការកំណត់តួនាទី និងភារកិច្ចរវាងអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ជាមួយនឹងស្ថាប័នពាក់ព័ន្ធ | របាយការណ៍ |
| ២.២.២. | រៀបចំបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ល.គ.ជ.អ.ប. អ.ហ.ក. | អង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ | បន្តការសិក្សា និងរៀបចំបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | | - រដ្ឋបាលរាជធានី ខេត្ត ចំនួន ២៥ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង<br>- រៀបចំលិខិតបទដ្ឋាន | គាំទ្រ និងអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងនីតិវិធី | លិខិតគតិយុត្តបង្កើតអង្គភាព |



ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | | | | | គតិយុត្តសម្រាប់បង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | សវនកម្មផ្ទៃក្នុង | សវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត |
| ២.២.៣. | រៀបចំយន្តការនៃការធ្វើសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (2023៖ នីតិវិធីនៃការអនុវត្តសវនកម្មផ្ទៃក្នុង) | អ.ហ.ក.<br>អ.ស.ក.<br>ល.គ.ជ.អ.ប. | បែបបទ នីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្តត្រូវបានផ្សព្វផ្សាយ | អនុវត្តបន្ទាប់ពីអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត | | | | |
| **២.៣.** | **ពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារកែទម្រង់ទាំង ៥** | | | | | | | |
| ២.៣.១. | ជំរុញការរៀបចំ និងបណ្តុះបណ្តាលអំពីបែបបទ នីតិវិធី ស្តង់ដាបច្ចេកទេស ក្នុងការអនុវត្តមុខងារដែលបានផ្ទេរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | ល.គ.ជ.អ.ប. | វគ្គបណ្តុះបណ្តាលសេចក្តីណែនាំបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានរៀបចំ | សម្របសម្រួលរៀបចំសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានរៀបចំ | សម្របសម្រួលរៀបចំសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានរៀបចំ | វគ្គបណ្តុះបណ្តាលសេចក្តីណែនាំបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ | វគ្គបណ្តុះបណ្តាលសេចក្តីណែនាំបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ | សេចក្តីណែនាំបច្ចេកទេស និង វគ្គបណ្តុះ-បណ្តាល |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| **២.៤.** | **រៀបចំនិងសម្របសម្រួលវិធានការបង្កើនប្រសិទ្ធភាពស្ថាប័ន និង គុណភាពសេវាសាធារណៈ** | | | | | | | |
| ២.៤.១. | រៀបចំការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន | អ.គ.ក.ស. ល.គ.ជ.អ.ប គ្រប់ក្រសួង ស្ថាប័ន | លិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការពិនិត្យឡើងវិញនិងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ត្រូវបានដាក់ឱ្យអនុវត្ត | សេចក្តីព្រាងសារាចរស្តីពីការកំណត់និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ត្រូវបានរៀបចំ | សារាចរស្តីពីការកំណត់និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ | សារាចរស្តីពីការកំណត់និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ត្រូវបានផ្សព្វផ្សាយ | សារាចរស្តីពីការកំណត់និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ត្រូវបានផ្សព្វផ្សាយ | សារាចរ |
| ២.៤.២. | រៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្តអំពីការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | អ.គ.ក.ស. | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈមន្ត្រីរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ | សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈមន្ត្រីរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ | សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈមន្ត្រីរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ | អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈមន្ត្រីរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងអនុម័ត | អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈមន្ត្រីរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ | អនុក្រឹត្យ |

| លរ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ២.៤.៣. | រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនិងអង្គភាពសុខាភិបាលមូលដ្ឋាន | អ.គ.ក.ស. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការតែងតាំងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនិងអង្គភាពសុខាភិបាលមូលដ្ឋាន ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | អនុក្រឹត្យស្តីពីការតែងតាំងនាយកសាលាបឋមសិក្សានិងមធ្យមសិក្សា ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | - អនុក្រឹត្យស្តីពីការតែងតាំងនាយកបឋមសិក្សា និងមធ្យមសិក្សា ត្រូវបានផ្សព្វផ្សាយ<br>- សេចក្តីព្រាងអនុក្រឹត្យស្តីពីការតែងតាំងប្រធានមន្ទីរពេទ្យ និងមណ្ឌលសុខភាព ត្រូវបានរៀបចំ | -អនុក្រឹត្យស្តីពីការតែងតាំងនាយករងសាលាបឋមសិក្សានិងមធ្យមសិក្សាត្រូវបានរៀបចំ និងអនុម័ត<br>- សេចក្តីព្រាងអនុក្រឹត្យស្តីពីការតែងតាំងប្រធានមន្ទីរពេទ្យ និងមណ្ឌលសុខភាព ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | -អនុក្រឹត្យស្តីពីការតែងតាំងនាយករងសាលាបឋមសិក្សានិងមធ្យមសិក្សា ត្រូវបានផ្សព្វផ្សាយ<br>-អនុក្រឹត្យស្តីពីការតែងតាំងប្រធានមន្ទីរពេទ្យ និងមណ្ឌលសុខភាព ត្រូវបានផ្សព្វផ្សាយ | អនុក្រឹត្យ |
| ២.៤.៤. | រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីក្រមសីល-ធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល | អ.គ.ក.ស. | ព្រះរាជក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ និងផ្សព្វផ្សាយប្រកាសដាក់ឱ្យអនុវត្ត | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ | សេចក្តីព្រាងព្រះរាជ-ក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ | ព្រះរាជក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ អនុម័ត | ព្រះរាជក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ត្រូវបានដាក់ឱ្យអនុវត្ត | ព្រះរាជក្រឹត្យ |
| ២.៤.៥. | ធ្វើបច្ចុប្បន្នភាពកម្រងទិន្នន័យព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | អ.គ.ក.ស. | កម្រងទិន្នន័យព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព | សិក្សាប្រមូលចងក្រងបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងកម្រងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ | ទិន្នន័យសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន៣១ ត្រូវបានធ្វើបច្ចុប្បន្នភាពតាម | ទិន្នន័យសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន៣១ ត្រូវបានធ្វើបច្ចុប្បន្នភាពតាម | ទិន្នន័យសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន៣១ ត្រូវបានធ្វើបច្ចុប្បន្នភាពតាម | កម្រងសេវាសាធារណៈ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | | | និងថ្នាក់ក្រោមជាតិ | វិស័យៈ<br>- ត្រីមាសទី២ចំនួន ១០ | វិស័យៈ<br>-ត្រីមាសទី៣ចំនួន ១១ | វិស័យៈ<br>-ត្រីមាសទី៤ចំនួន ១០ | |
| ២.៤.៦. | បន្តអនុវត្តការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល | អ.គ.ក.ស. | ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ(អនុវិទ្យា-ល័យនិងបឋមសិក្សា) និងវិស័យសុខាភិបាល (មណ្ឌលសុខភាព) ត្រូវបានអនុវត្ត និងទស្សនកិច្ចចុះសិក្សាពាក់ព័ន្ធនឹងការវាយតម្លៃសេវា ត្រូវបានរៀបចំ | បទដ្ឋានស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៤ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត | - កម្មវិធីផ្សព្វផ្សាយស្តីពីនីតិវិធីនិង វិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវា សាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៥ និងទស្សន-កិច្ចសិក្សាស្តីពីឧត្តមានុវត្តន៍និងនវានុវត្តន៍នៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅប្រទេសចិនត្រូវបានរៀបចំ<br>- វគ្គបណ្តុះបណ្តាលស្តីពីនវានុវត្តន៍ សម្រាប់អ្នកគ្រប់គ្រងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ចំនួន២វគ្គ ត្រូវបានរៀបចំ | -ធាតុចូលសម្រាប់ការធ្វើបច្ចុប្បន្នកម្មតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃនិងការទទួលស្គាល់មន្ទីរពេទ្យបង្អែក វិទ្យាល័យ និងសាលាមត្តេយ្យសិក្សាគំរូ ត្រូវបានប្រមូល<br>-គណៈកម្មការវាយតម្លៃថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានីខេត្ត ដំណើរ ការការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូសម្រាប់ឆ្នាំ២០២៥<br>- សិក្ខាសាលាចែក-រំលែកបទពិសោធន៍នៃការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភី | ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ (អនុវិទ្យាល័យនិងបឋមសិក្សា)និងវិស័យសុខាភិបាល (មណ្ឌលសុខភាព) ត្រូវបានអនុវត្តសម្រាប់ដំណាក់កាលវាយតម្លៃនៅថ្នាក់ជាតិ | - អនុក្រឹត្យស្តីពីការទទួលស្គាល់អង្គភាពគំរូ<br>- ប្រកាស្តីពីការដាក់ឱ្យ អនុវត្តអង្គភាពគំរូឆ្នាំ២០២៥ របាយការណ៍លទ្ធផល<br>- ករណីសិក្សា |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| | | | | | -ករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៤ ត្រូវបានរៀបចំ | ឆ្នាំ២០២៤ ត្រូវបានរៀបចំ | | |
| **២.៤.៧.** | រៀបចំទស្សនាទាននៃក្រមពាណិជ្ជកម្ម | អ.គ.ក.ច. ល.ក.ន. | សេចក្តីព្រាងចុងក្រោយត្រូវបានរៀបចំ | កិច្ចប្រជុំ ត្រូវបានរៀបចំ | កិច្ចប្រជុំនិងផ្តល់យោបល់លើសេចក្តី-ព្រាង ត្រូវបានរៀបចំ | សេចក្តីព្រាងចុងក្រោយត្រូវបានដាក់ឆ្លងថ្នាក់ដឹកនាំពិនិត្យនិងសម្រេច | សេចក្តីព្រាងត្រូវបានអនុម័ត | សេចក្តីព្រាងទស្សនាទាន |
| ២.៤.៨. | រៀបចំទស្សនាទាននៃក្រមរដ្ឋបាល | អ.គ.ក.ច. ល.ក.ន. | សេចក្តីព្រាងចុងក្រោយត្រូវបានរៀបចំ | កិច្ចប្រជុំ ត្រូវបានរៀបចំ | កិច្ចប្រជុំនិងផ្តល់យោបល់លើសេចក្តី-ព្រាង ត្រូវបានរៀបចំ | សេចក្តីព្រាងចុងក្រោយត្រូវបានដាក់ឆ្លងថ្នាក់ដឹកនាំពិនិត្យនិងសម្រេច | សេចក្តីព្រាងត្រូវបានអនុម័ត | សេចក្តីព្រាងទស្សនាទាន |
| ២.៤.៩. | រៀបចំអនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | អ.គ.ក.ស. | អនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្តីព្រាងអនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាល សាធារណៈ ត្រូវបានរៀបចំ | អនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | អនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវបានផ្សព្វផ្សាយ | អនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវបានផ្សព្វផ្សាយ | អនុក្រឹត្យ |

ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ២.៤.១០. | រៀបចំប្រព័ន្ធ និងយន្តការនៃការពិនិត្យនិងវាយតម្លៃអំពីគុណភាពនៃការតាក់តែង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | អ.គ.ក.ច. | ទស្សនាទានត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុងប្រមូលធាតុចូល ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុង | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ គ.ក.ច. | សេចក្តីព្រាងចុងក្រោយត្រូវបានដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំ គ.ក.ច. | ទស្សនាទាន |
| ២.៤.១១. | រៀបចំទស្សនាទានស្តីពីវប្បធម៌នីតិរដ្ឋនិងប្រព័ន្ធច្បាប់កម្ពុជា | អ.គ.ក.ច. | ទស្សនាទានត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានចុងក្រោយត្រូវបានរៀបចំ | ទស្សនាទាន |
| ២.៤.១២. | រៀបចំទស្សនាទានស្តីពីសន្ទានុក្រមគតិយុត្តតាមវិស័យ | អ.គ.ក.ច. | ទស្សនាទានត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានចុងក្រោយ ត្រូវបានរៀបចំ | ទស្សនាទាន |
| ២.៤.១៣. | រៀបចំទស្សនាទានស្តីពីមគ្គុទេសក៍សិល្បៈសាស្ត្រនីតិកម្មក្រោមទម្រង់ច្បាប់ជាច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ | អ.គ.ក.ច. | ទស្សនាទានត្រូវបានរៀបចំ | កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទានចុងក្រោយ ត្រូវបានរៀបចំ | ទស្សនាទាន |
| ៣. | **យុទ្ធសាស្ត្រទី៣ ៖ សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ** | | | | | | | |
| ៣.១. | **រៀបចំនិងសម្របសម្រួលកិច្ចដំណើរការ និងការគាំទ្រកម្មវិធី កែទម្រង់ទាំង ៥** | | **កិច្ចប្រជុំផ្លាស់វេន ឬតាមដានវឌ្ឍនភាព ត្រូវបានរៀបចំទៀតទាត់ ឬ ៤ ដង/ឆ្នាំ** | | | | | |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.១.១. | រៀបចំបច្ចុប្បន្នកម្មឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល | អ.គ.ហ. | ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្ដីពីយន្តការ សម្រប-សម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលត្រូវបានធ្វើអនុម័តនិងអនុវត្ត | | ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្ដីពីយន្តការសម្រប-សម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលត្រូវបានរៀបចំរួចរាល់និងបោះពុម្ព | ពិធីប្រកាសដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយត្រូវបានរៀបចំ | | ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្របច្ចុប្បន្នកម្ម |
| ៣.១.២. | រៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ២០២៥-២០៣៥ | អ.គ.ក.ប.យ. | ផែនការយុទ្ធសាស្ត្រ ត្រូវបានអនុម័ត និងអនុវត្ត | កំពុងពិនិត្យ និងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ឆ្នាំ២០២៥-២០៣៥ត្រូវបានរៀបចំ | កំពុងពិនិត្យ និងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ឆ្នាំ២០២៥-២០៣៥ត្រូវបានរៀបចំ | កំពុងពិនិត្យ និងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ឆ្នាំ២០២៥-២០៣៥ត្រូវបានរៀបចំ | | ផែនការយុទ្ធសាស្ត្រ |
| ៣.១.៣. | រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់នៃរាជរដ្ឋាភិបាល | អ.គ.ក.ច. | - ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ត្រូវបានអនុម័តនិងប្រកាសឱ្យប្រើពីរាជរដ្ឋាភិបាល<br>- ផែនការសកម្មភាពសម្រាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ត្រូវបានអនុម័តនិងអនុវត្ត | រៀបចំសេចក្ដីព្រាងផែនការសកម្មភាព | ផែនការសកម្មភាពត្រូវបានដាក់អនុម័ត | គម្រោងសកម្មភាពត្រូវបានដាក់អនុវត្ត | គម្រោងសកម្មភាពត្រូវបានដាក់អនុវត្ត | គម្រោងសកម្មភាពត្រូវបានដាក់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.១.៤. | រៀបចំវិបស្សនាប្រចាំឆ្នាំ និងបូកសរុបផែនការសកម្មភាពឆ្នាំថ្មី | អ.គ.ហ. | របាយការណ៍និងសេចក្តីសម្រេចរបស់ អង្គវិបស្សនា និងផែនការសកម្មភាពឆ្នាំ២០២៥ ត្រូវបានរៀបចំ | របាយការណ៍និងសេចក្តីសម្រេចរបស់អង្គវិបស្សនា និងផែនការសកម្មភាពឆ្នាំ២០២៥ ត្រូវបានរៀបចំ បានរៀបចំ និងអនុម័ត | | | | របាយការណ៍និងសេចក្តី-សម្រេចរបស់អង្គវិបស្សនា និងផែនការសកម្មភាពឆ្នាំ២០២៥ |
| ៣.១.៥. | សម្របសម្រួលនិងដឹកនាំ យ.ស.ក. និងបូកសរុបរបាយការណ៍វឌ្ឍនភាពត្រីមាសទី១ | ល.គ.ជ.អ.ប. អ.គ.ហ. | - របាយការណ៍វឌ្ឍនភាពត្រីមាសទី១ត្រូវបានបូកសរុប<br>-កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | | - របាយការណ៍វឌ្ឍនភាពត្រីមាសទី១ ត្រូវបាន បូកសរុប<br>- កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | | | របាយការណ៍លទ្ធផលកិច្ចប្រជុំ |
| ៣.១.៦. | សម្របសម្រួលនិងដឹកនាំ យ.ស.ក. និងបូកសរុបរបាយការណ៍វឌ្ឍនភាពត្រីមាសទី២ | អ.គ.ក.ប.យ. អ.គ.ហ. | - របាយការណ៍វឌ្ឍនភាពត្រីមាសទី២ត្រូវបានបូកសរុប<br>- កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | | | -របាយការណ៍វឌ្ឍនភាពត្រីមាសទី២ ត្រូវបាន បូកសរុប<br>-កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | | របាយការណ៍លទ្ធផលកិច្ចប្រជុំ |
| ៣.១.៧. | សម្របសម្រួលនិងដឹកនាំ យ.ស.ក. និងបូកសរុបរបាយការណ៍វឌ្ឍនភាពត្រីមាសទី៣ | អ.គ.ក.ច. អ.គ.ហ. | - របាយការណ៍វឌ្ឍនភាពត្រីមាសទី៣ត្រូវបានបូកសរុប<br>- កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | | | | - របាយការណ៍វឌ្ឍនភាពត្រីមាសទី៣ ត្រូវបាន បូកសរុប<br>-កិច្ចប្រជុំ យ.ស.ក. ត្រូវបានរៀបចំ | របាយការណ៍លទ្ធផលកិច្ចប្រជុំ |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.១.៨. | រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង ៤ ដំណាក់កាល នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់នៃរាជរដ្ឋាភិបាល | អ.គ.ក.ច. | ទស្សនាទាននៃការរៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង ៤ ដំណាក់កាល នៃក្រប-ខ័ណ្ឌ យុទ្ធសាស្ត្រនៃ កម្ម-វិធីកែទម្រង់ច្បាប់នៃរាជ-រដ្ឋាភិបាល ត្រូវបានរៀបចំ | | កិច្ចប្រជុំផ្ទៃក្នុងប្រមូលធាតុចូល ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុង | សេចក្តីព្រាងទស្សនាទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ គ.ក.ច. | របាយការណ៍ |
| **៣.២.** | **រៀបចំនិងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងអំពីកម្មវិធីកែទម្រង់ទាំង ៥** | | **សមត្ថភាព ត្រូវបានពង្រឹងតាមរយៈយន្តការបណ្តុះបណ្តាលនិងសិក្ខាសាលា** | | | | | |
| ៣.២.១. | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ | អ.គ.ក.ស. | វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ត្រូវបានរៀបចំ | | វគ្គបណ្តុះបណ្តាលចំនួន១ | | | កម្មវិធីអភិវឌ្ឍសមត្ថភាព |
| ៣.២.២. | រៀបចំនូវកម្រងមេរៀន ឬ ម៉ូឌុលមេរៀន សម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីហិរញ្ញវត្ថុសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | វ.ស.ហ. | សេចក្តីព្រាងម៉ូឌុលមេរៀន ត្រូវបានរៀបចំ | | បញ្ហានិងតម្រូវការ ត្រូវបានកំណត់ | ប្រមូលនិងវិភាគទិន្នន័យរបាយការណ៍ | សេចក្តីព្រាងម៉ូឌុលមេរៀន ត្រូវបានរៀបចំ | ម៉ូដែលមេរៀន |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.២.៣. | រៀបចំមគ្គុទេសក៍នីតិហិរញ្ញវត្ថុសាធារណៈ | ល.ក.ន. | ខ្លឹមសារសេចក្ដីព្រាងមគ្គុទេសក៍នីតិហិរញ្ញវត្ថុសាធារណៈ ត្រូវបានពិនិត្យនិងកែសម្រួលដោយឯកឧត្តមអនុរដ្ឋ-លេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធត្រូវបានប្រមូល សិក្សា ស្រាវជ្រាវ វិភាគ និងមាតិកានុក្រមត្រូវបានរៀបចំ | សេចក្ដីព្រាងខ្លឹមសារមគ្គ-ទេសក៍ ត្រូវបានតាក់តែងរៀបចំកម្រិតមន្ត្រីជំនាញនៃ ល.ក.ន. | សេចក្ដីព្រាងខ្លឹមសារមគ្គុទេសក៍ត្រូវបានពិនិត្យសម្រេចកម្រិតប្រធានផ្នែកនិងអនុប្រធាន ល.ក.ន. | សេចក្ដីព្រាងខ្លឹមសារមគ្គ-ទេសក៍ត្រូវបានពិនិត្យ សម្រេចកម្រិតអនុរដ្ឋលេខាធិការ និងជាប្រធាន ល.ក.ន. | សេចក្ដីព្រាងសៀវភៅមគ្គុទេសក៍ |
| ៣.២.៤. | រៀបចំសិក្ខាធ្វើសមថាមភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស | ស.ភ.រ.<br>រ.ស.ហ.<br>ស.ជ.រ.ម. | ទស្សនាទាន ត្រូវបានដាក់ឆ្លង យ.ស.ក. និងប្រធានកម្មវិធីកែទម្រង់ទាំង ៥ | បង្អង់ | | | | ទស្សនាទាន |
| ៣.២.៥. | រៀបចំវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពលើការរៀបចំសូចនាករសមិទ្ធកម្មនិងការគ្រប់គ្រងសមិទ្ធកម្ម | អ.គ.ហ. | វគ្គបណ្ដុះបណ្ដាល ត្រូវបានរៀបចំ | អនុវត្តក្នុងឆ្នាំ២០២៦ | | | | របាយការណ៍ |
| ៣.២.៦. | រៀបចំវេទិកាច្បាប់ខ្មែរទំនើប | ល.ក.ន. | វេទិកាច្បាប់ខ្មែរទំនើបត្រូវបានរៀបចំ | | ឯកសារទស្សនាទាននិងកិច្ចប្រជុំត្រៀមរៀបចំវេទិកាត្រូវបានរៀបចំ | វេទិកាត្រូវបានរៀបចំ | កម្រងឯកសារត្រូវបានចង-ក្រងបោះពុម្ព | កម្រងឯកសារ |



ឧបសម្ព័ន្ធទី៣១

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.២.៧. | រៀបចំវេទិកាស្តីពី នីតិកម្ម និងការកែទម្រង់ | អ.គ.ក.ច.<br>ល.ក.ន. | វេទិកាស្តីពីនីតិកម្ម និង ការកែទម្រង់ ត្រូវបានរៀបចំ | អនុវត្តក្នុងឆ្នាំ២០២៦ | | | | កម្រងឯកសារ |
| ៣.២.៨. | រៀបចំវេទិកាស្តីពីការការពារនីត្យានុកូលភាព និងវិវាទគតិយុត្ត | អ.គ.ក.ច. | វេទិកាស្តីពីការការពារ នីត្យានុកូលភាព និង វិវាទគតិយុត្ត ត្រូវបាន រៀបចំ | អនុវត្តក្នុងឆ្នាំ២០២៦ | | | | កម្រងឯកសារ |
| ៣.២.៩. | រៀបចំវេទិកាស្តីពីការចែករំលែកឧត្តមានុវត្តន៍នៃការអនុវត្តកិច្ចការងារកែទម្រង់ | អ.គ.ហ.<br>ល.គ.ជ.អ.ប.<br>អ.គ.ក.ស.<br>អ.គ.ក.ច.<br>អ.គ.ក.ប.យ. | ទស្សនាទាន ត្រូវបាន ដាក់ឆ្លង យ.ស.ក. និង ប្រធានកម្មវិធីកែទម្រង់ ទាំង ៥" | | | កិច្ចប្រជុំប្រមូលធាតុ-ចូល ត្រូវបានរៀបចំ | សេចក្តីព្រាងទស្សនាទាន ត្រូវបានរៀបចំ | ទស្សនាទាន |
| **៣.៣.** | **រៀបចំនិងសម្របសម្រួលវិធានការណ៍ យន្តការលើកទឹកចិត្តនិងស្មារតីទទួលខុសត្រូវ** | | | | | | | |
| **៣.៤.** | **រៀបចំនិងសម្របសម្រួលទស្សនកិច្ចសិក្សានៅតាមការដ្ឋានកែទម្រង់ក្នុងនិងក្រៅប្រទេស** | | **ទស្សនកិច្ចសិក្សាក្នុងឬក្រៅប្រទេសដកស្រង់ពិសោធន៍កែទម្រង់ត្រូវបានរៀបចំយ៉ាងតិច ១ លើក/ឆ្នាំ** | | | | | |

| ល.រ. | យុទ្ធសាស្ត្រ/កម្មវិធី/សកម្មភាព | អង្គភាពដឹកនាំ | សូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២៥ | គោលដៅសូចនាករប្រចាំត្រីមាស ប្រចាំឆ្នាំ២០២៥ | | | | ឯកសារអំណះអំណាង |
|---|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ៣.៤.២. | រៀបចំទស្សនកិច្ចសិក្សាដកស្រង់ពិសោធន៍អន្តរជាតិលើការកែទម្រង់និងប្រសិទ្ធភាពអភិបាលកិច្ចសាធារណៈ | អ.គ.ហ.<br>ល.គ.ជ.អ.ប.<br>អ.គ.ក.ស.<br>អ.គ.ក.ច.<br>អ.គ.ក.ប.យ. | ទស្សនកិច្ចសិក្សាត្រូវបានរៀបចំ | -វគ្គបណ្ដុះបណ្ដាលនៅណូវែលហ្សេឡង់ត្រូវបានរៀបចំ<br>-របាយការណ៍លទ្ធផលត្រូវបានរៀបចំ | | | | របាយការណ៍លទ្ធផល |
| ៣.៤.៣. | ទស្សនកិច្ចសិក្សាស្ដីពី ការងារកែទម្រង់តាមវិស័យ ដកស្រង់បទពិសោធន៍ និងឧត្តមានុវត្តន៍ នៅវិស័យអប់រំ និងវិស័យសុខាភិបាល | អ.គ.ហ.<br>ល.គ.ជ.អ.ប.<br>អ.គ.ក.ស.<br>អ.គ.ក.ច.<br>អ.គ.ក.ប.យ. | ទស្សនកិច្ចសិក្សាត្រូវបានរៀបចំ | អនុវត្តក្នុងឆ្នាំ២០២៦ | | | | របាយការណ៍លទ្ធផល |

**ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** នេះ ត្រូវបានសម្រេចឡើងបន្ទាប់ពីបានពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាច្រើនលើក រួមមាន៖ កិច្ចប្រជុំផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ កិច្ចប្រជុំនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល វិបស្សនាប្រចាំឆ្នាំ នៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល និងការពិនិត្យនិងឯកភាពដោយប្រធានគណៈកម្មាធិការកែទម្រង់នីមួយៗ។ សមាសភាពចូលរួមដឹកនាំ រៀបចំ ផ្ដល់មតិយោបល់ និងសម្របសម្រួលមានដូចតទៅ៖

**ក.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

| | |
|---|---|
| ១-ឯកឧត្តម **វង្ស សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ២-ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៣-ឯកឧត្តមបណ្ឌិត **យ៉េត ទីណែល** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៤-ឯកឧត្តម **អ៊ុំ យុទ្ធី** | នាយកផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យ និងវាយតម្លៃ |

| | |
|---|---|
| ៥-លោក **លី វ៉ុង** | មន្ត្រីជំនាញជាន់ខ្ពស់ |
| ៦-លោក **ឌុទ្ធី សុត្រា** | មន្ត្រីជំនាញជាន់ខ្ពស់ |
| ៧-លោក **ស៊ុន គឹមហេង** | មន្ត្រីជំនាញជាន់ខ្ពស់ |
| ៨-លោក **អ៊ូច សោភ័ណ** | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យ និងវាយ-តម្លៃគម្រោង |
| ៩-លោកបណ្ឌិត **ឆាយ សម្បត្តិ** | មន្ត្រីជំនាញ |
| ១០-លោកស្រី **អ៊ិន សុវណ្ណគង់គា** | មន្ត្រីជំនាញ |
| ១១-លោកស្រី **សុន្ធរៈ សូរិយា** | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ |
| ១២-លោក **ហ៊ុយ សុវណ្ណារ៉ា** | មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកលទ្ធកម្ម |
| ១៣-លោកស្រី **ហ៊ាង ស៊ីនួន** | មន្ត្រីគណនេយ្យករជាន់ខ្ពស់ |
| ១៤-លោកស្រី **លឿង សុវណ្ណឌី** | មន្ត្រីជំនាញថវិកា |
| ១៥-លោក **ស៊ុន បូទី** | មន្ត្រីព័ត៌មានវិទ្យា |
| ១៦-កញ្ញា **កែវ មល្លិកា** | លេខាធិការ |
| ១៧-កញ្ញា **យិន ទេពនិកា** | មន្ត្រីជំនួយការលទ្ធកម្ម |
| ១៨-កញ្ញា **នូ រតនៈធិតា** | មន្ត្រីជំនួយការ |
| ១៩-កញ្ញា **ហ៊ិន ណាលីស** | មន្ត្រីជំនួយការ |
| ២០-លោក **ឡុង ស៊ីថា** | មន្ត្រីជំនួយការ |

**ខ.លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

| | |
|---|---|
| ១-ឯកឧត្តម **ចាន់ សុធា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជា-ធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ២-ឯកឧត្តម **តូច ពលពន្លក** | ទីប្រឹក្សាក្រសួងមហាផ្ទៃ |

| | |
|---|---|
| ៣-ឯកឧត្តម **ជ័យ សម្បត្តិផល្លា** | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍ គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៤-លោកស្រី **គង់ ប៊ុណ្ណា** | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍ គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៥-លោកស្រី **ហេង សុវិចា** | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍ គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៦-លោក **ប៊ុន ម៉ានិត** | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍ គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៧-លោក **ពិសិដ្ឋ សិលា** | ប្រធានក្រុមជំនួយការ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. |

**គ.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

| | |
|---|---|
| ១-ឯកឧត្តម **ឈុន សុជាតិ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| ២-ឯកឧត្តម **ប្រាក់ ប្រានីដ្ឋា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| ៣-ឯកឧត្តម **សិក ហេងឡុង** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| ៤-លោកជំទាវ **តឹក កុសុរ្យនា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| ៥-លោក **សុខ សំណាង** | ប្រធាននាយកដ្ឋាន |

| | |
|---|---|
| ៦-លោក **សុក សុវ៉ាត** | ប្រធាននាយកដ្ឋាន |
| ៧-លោក **ខុច ចំណាន** | អនុប្រធាននាយកដ្ឋាន |
| ៨-លោក **គ៉ុំ សារ៉ាក់** | ប្រធានការិយាល័យ |
| ៩-លោកស្រី **ស៊ឹម សុគន្ធ** | ប្រធានការិយាល័យ |
| ១០-កញ្ញា **ឱណា ស៊ីថាមុនីរ័ត្ន** | អនុប្រធានការិយាល័យ |
| ១១-លោក **សុឃន ម៉ិនហេង** | មន្ត្រីជំនាញ |
| ១២-លោក **ឃឹម ឡេចហេង** | មន្ត្រីជំនាញ |

**ឃ.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌**

| | |
|---|---|
| ១-ឯកឧត្តម **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការគណៈ-កម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| ២-លោកជំទាវ **សុខ ឆវ័ន្ត** | អគ្គលេខាធិការរងនៃអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| ៣-ឯកឧត្តម **ឃ្លោក ដារ៉ា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| ៤-លោកជំទាវ **ឌី ម៉ូឡានី** | អគ្គលេខាធិការរងនៃអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| ៥-លោក **អៀម សំណាង** | ប្រធាននាយកដ្ឋាន |
| ៦-លោក **ឃឹម តុងខួង** | ប្រធាននាយកដ្ឋាន |
| ៧-លោកស្រី **ហួន សុគន្ធារី** | ប្រធាននាយកដ្ឋាន |

## ខ.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

| | |
|---|---|
| ១-ឯកឧត្តម **លី ច័ន្ទតុលា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ |
| ២-ឯកឧត្តម **ប៉ែន ប៊ុនឈា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ |
| ៣-លោក **ឌិន ស៊ីដែន** | ជំនាញការច្បាប់ |
| ៤-លោកស្រី **ឡេង ចាន់តួង** | ជំនាញការច្បាប់ |

## ច.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| | |
|---|---|
| ១-ឯកឧត្តម **ស៊ាង ផល្លា** | អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ២-ឯកឧត្តមបណ្ឌិត **ឌី សុវណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣-ឯកឧត្តមបណ្ឌិត **គីម កែវមុនីរ័ត្ន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា |
| ៤-ឯកឧត្តម **សៀក សុភ័គ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ |
| ៥-លោក **រស់ សុខណារុណ** | អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ៦-លោក **ឈាន សាមឌី** | អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ៧-លោក **ដៀប ពិសិដ្ឋ** | ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |

| | |
|---|---|
| ៨-លោក **សុខ ច័ន្ទកិត្យា** | ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ៩-លោក **ហ៊ើល ប៊ុនថាន** | ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១០-លោក **ហួត វ៉េងហួ** | ប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១១-លោក **ឈិត សុចន្ត្រា** | អនុប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១២-លោក **ជុំ សុក្រសេរី** | អនុប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១៣-លោក **អ៊ុក មិថុនា** | មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១៤-លោក **យឹម សុបញ្ញា** | មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| ១៥-លោក **ស៊ុន ច័ន្ទកក្កដា** | ប្រធានអធិការកិច្ចរតនាគារនៃអគ្គនាយកដ្ឋានរតនាគារជាតិ |
| ១៦-លោក **ម៉ៅ បូរាណ** | នាយករងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១៧-លោក **ថុន ខុឡ្សី** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន |
| ១៨-លោក **សុត ខុធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |

## ចក្ខុវិស័យ

សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## បេសកកម្ម

ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃភាពប្រទាក់ប្រឡាគ្នាជាអន្តរកែទម្រង់ ស្របតាមអភិក្រមជរភាពនៃប្រព័ន្ធតួអង្គតែមួយ

## អភិក្រម

ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីសក្តិសិទ្ធិភាពនិងសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## យុទ្ធសាស្ត្រ

សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ

សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ

ISBN-13: 978-9924-554-28-8

## ចក្ខុវិស័យ

សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## បេសកកម្ម

ធានាសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃភាពប្រទាក់ប្រឡាគ្នាជាអន្តរកែទម្រង់ ស្របតាមអភិក្រមជវភាពនៃប្រព័ន្ធតួអង្គតែមួយ

## អភិក្រម

ពង្រឹងភាពជាម្ចាស់នៃការដ្ឋានកែទម្រង់នីមួយៗ និងពង្រីកកិច្ចសហការ ដើម្បីសក្តិសិទ្ធិភាពនិងសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## យុទ្ធសាស្ត្រ

សុខដុមនីយកម្មប្រព័ន្ធការងារកែទម្រង់គន្លឹះ

សុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

សុខដុមនីយកម្មប្រព័ន្ធគាំទ្រការកែទម្រង់គន្លឹះ

ISBN-13: 978-9924-554-28-8